ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ការសិក្សាស្រាវជ្រាវនិងការស្វែងរកខ្លឹម
- រឿងរ៉ាវដែលមិនចេះសាបសូន្យ

លេខ ៧០ ខែតុលា ឆ្នាំ២០០៥

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៧០ ខែតុលា ឆ្នាំ២០០៥

## មាតិកា

◆ សំបុត្រៈ ការស្រាវជ្រាវនិងការធូរស្បើយ ............................១

**ផ្នែកឯកសារ**

◆ តាន់ លៀកផេង និស្សិតមកពីប្រទេសបារាំង .......................៥

◆ ញត្តិគាំទ្រសេចក្ដីសម្រេចចិត្តរបស់រដ្ឋសភា..............................៩

◆ បញ្ជីឈ្មោះជនរងគ្រោះមន្ទីរស-២១ .................................១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រឿងរ៉ាវដែលមិនចេះសាបសូន្យ..................................១៤

◆ ហ៊ុន ញ៉ៈ អតីតអ្នកទោសគុកក្រាំងតាចាន់.....................២៥

◆ អតីតអ្នកបើកបរប្រចាំស្ថានទូតគុយបានិងស្ថានទូតឡាវ.......... ២៨

◆ នៅតែងឿងឆ្ងល់................................................. ៣១

**ផ្នែកច្បាប់**

◆ ប្រភេទនៃការការពារក្ដី............................................... ៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ការរាប់ចំនួនមនុស្សស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ .....៤៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ មិនចង់រំឭករឿងរ៉ាវពីរបបខ្មែរក្រហម..............................៥៦

◆ គ្រួសារខ្ញុំនៅឯណា? .................................................៥៨



អែម ផល ថតក្នុងឆ្នាំ១៩៧២



(រូបពីឆ្វេងទៅស្ដាំ) អែម ផល និងមិត្តភក្តិ ឆ្នាំ១៩៧២

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះៈ** យិន នាន, ប៉ាំង ពីរ៉ែន, ស៊ីរ៉ិ សាវីណា, ញាណ សុជាតិ, ឡុង ដានី, សាយ សួរគា, ឆាយ ណារឿន, ប្រ៊ីស ស្បាប **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូ ហ្វារីណា **អ្នកបកប្រែៈ** ជី ទេវិទ្ធិ, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយករងៈ** សាន់ កល្យាណ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ៊ិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** រ័ត្ន តារាពិដោរ

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ៖*

# ការសិក្សាស្រាវជ្រាវនិងការធូរស្បើយ

មនុស្សជាច្រើនតែងតែសួរខ្ញុំថា ហេតុអ្វីបន្ទាប់ពីបានរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យហើយ ខ្ញុំនៅតែចង់ត្រឡប់មកប្រទេសកម្ពុជាទៀត ហើយចងក្រងឯកសារអំពីរបបនោះ ។ តាមពិតពីដំបូងខ្ញុំធ្វើបែបនេះគឺដោយសារខ្ញុំចង់សងសឹកអ្នកដែលសម្លាប់សមាជិកគ្រួសាររបស់ខ្ញុំអស់ជាច្រើននាក់ ។

ប៉ុន្មានឆ្នាំបន្ទាប់ពីខ្ញុំចាប់ផ្តើមការសិក្សាស្រាវជ្រាវមក ខ្ញុំបានទៅជួបប្រធានភូមិម្នាក់ដែលរួមចំណែកក្នុងការធ្វើឲ្យបងស្រីរបស់ខ្ញុំស្លាប់ ។ គាត់ចំណាំខ្ញុំមិនបានទេ ដោយហេតុថា កាលណោះខ្ញុំគ្រាន់តែជាក្មេងប្រុសតូចម្នាក់ប៉ុណ្ណោះ ។ ក៏ប៉ុន្តែ ខ្ញុំចំណាំគាត់បានច្បាស់ ហើយខ្ញុំកត់សម្គាល់ឃើញថា គាត់នៅតែដូចមុន ។ គាត់មានគោស្គមៗពីរក្បាល ហើយរស់នៅក្នុងផ្ទះសសរខ្ពស់មួយក្នុងភូមិដដែល ។ ស្ថានភាពគាត់ឥឡូវនេះគ្មានអ្វីគ្រាន់បើជាងកាលពីមុនពេលដែលខ្មែរក្រហមធ្វើបដិវត្តន៍ដើម្បី“រំដោះ”កសិករឡើយ ។

បន្ទាប់ពីទៅជួបគាត់ប៉ុន្មានដងមក ខ្ញុំមានការភ្ញាក់ផ្អើលដោយសារខ្ញុំយល់ថាគាត់មិនមែនជាមនុស្សអាក្រក់នោះទេ ។ តាមពិតទៅ គាត់ជាមនុស្សម្នាក់ដែលប្រព្រឹត្តអំពើអាក្រក់ដោយសារតែគាត់គិតថាការធ្វើបដិវត្តន៍និងផ្តល់ឲ្យគាត់នូវជីវិតនិងសង្គមមួយដែលល្អប្រសើរជាងមុន ។ ខ្ញុំចាប់ផ្តើមយល់ឃើញថា គឺមនោគមវិជ្ជាដែលអូសទាញប្រធានភូមិនិងខ្មែរក្រហមជាច្រើនទៀតឲ្យប្រព្រឹត្តទង្វើបែបនោះ ។ ការណ៍នេះជួយឲ្យខ្ញុំយល់ឃើញថា ការសងសឹកមិនមែនជាដំណោះស្រាយល្អនោះទេ ហើយក៏មិនអាចធ្វើឲ្យខ្ញុំនិងជនរងគ្រោះទាំងអស់ទទួលអ្វីដែលបានបាត់បង់មកវិញដែរ ។

សព្វថ្ងៃនេះ ឧបសគ្គក្នុងការសិក្សាស្រាវជ្រាវនិងការស្វែងរកដំណោះស្រាយបានផ្តល់ឲ្យខ្ញុំនូវកម្លាំងចិត្ត និងការរីករាយផ្នែកស្មារតី ។ ការសិក្សាស្រាវជ្រាវបានធ្វើឲ្យខ្ញុំមានសេរីភាពដោយសារខ្ញុំបានរកឃើញការពិត ទោះបីជាការពិតនោះមិនពេញលេញយ៉ាងណាក៏ដោយ ។ សម្រាប់មនុស្សខ្លះ មានតែពេលវេលានិងសេចក្តីស្រលាញ់ប៉ុណ្ណោះដែលអាចជួយឲ្យពួកគេធូរស្បើយ ប៉ុន្តែសម្រាប់ខ្ញុំការសិក្សាស្រាវជ្រាវនិងការចងក្រងឯកសារបានធ្វើឲ្យកំហឹងរបស់ខ្ញុំធូរស្បើយ និងបានជួយឲ្យខ្ញុំយល់ពីរបៀបដែលអាចធ្វើឲ្យប្រជាជនកម្ពុជាប្រព្រឹត្តអំពើឃោរឃៅបែបនោះបាន ។



*ម៉ៃឃើល អូលីវីត រដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងសង្គមកិច្ចរបស់សហរដ្ឋអាមេរិកទស្សនកិច្ចសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង*

យើងចាំបាច់ត្រូវតែស្វែងយល់ពីវប្បធម៌របស់ប្រជាជនកម្ពុជា ដើម្បីឲ្យដឹងពីមូលហេតុដែលអាចធ្វើឲ្យមនុស្សប្រព្រឹត្តអំពើឃោរឃៅដូចនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនកម្ពុជាមិនធ្វើអ្វីមួយដើម្បីបុព្វហេតុផ្ទាល់ខ្លួនទេ ព្រោះតាមទស្សនៈអ្នកដទៃ ការធ្វើដូច្នេះគឺជាកាយវិការក្រអឺតក្រទម ។ ប្រជាជនកម្ពុជាភាគច្រើនធ្វើអ្វីៗ គឺដើម្បីបុព្វហេតុជាតិ ។ ជាលទ្ធផលគឺថាបុគ្គលម្នាក់ៗមិនយល់ពីសារសំខាន់និងតម្លៃរបស់ខ្លួនឡើយ ។ ប្រជាជនកម្ពុជាបែរជាគិតថាប្រសិនបើរដ្ឋអំណាចរំលោភសិទ្ធិប្រជាជន ប្រជាជនអាចទទួលយកបាន ព្រោះសកម្មភាពនេះគឺដើម្បីផលប្រយោជន៍ជាតិ ។ ប៉ុន្តែការពិតជាតិកើតឡើងពីការប្រមូលផ្តុំរបស់បុគ្គលម្នាក់ៗ ។

ការសិក្សាស្រាវជ្រាវបានធ្វើឲ្យខ្ញុំមានបំណងចង់ចែករំលែកនូវអ្វីដែលខ្ញុំទទួលបានតាមរយៈការបង្រៀនទៅឲ្យអ្នកដទៃទៀត ។ ដូច្នេះទើបខ្ញុំចង់ឲ្យប្រជាជនទាំងអស់ដឹងថា យើងគ្រប់គ្នាសុទ្ធតែ

មានតម្លៃដូចៗគ្នា បើទោះបីជាយើងជានរណាក៏ដោយ ។ គ្រប់គ្នាជាមែកធាងផ្សេងៗរបស់សង្គម ហើយសិទ្ធិរបស់យើងត្រូវតែទទួលបាននូវការការពារ ។ ខ្ញុំចង់ឲ្យប្រជាជនទាំងអស់ដឹងថា គ្មាននរណាម្នាក់មានសិទ្ធិដកហូតសិទ្ធិមានជីវិតរបស់យើងបានឡើយ ។ ខ្ញុំចង់ឲ្យប្រទេសកម្ពុជាការពារសិទ្ធិជាមូលដ្ឋានឲ្យបានខ្ជាប់ខ្ជួនសម្រាប់ប្រជាជនទាំងអស់ ។

ដូច្នេះ ខ្ញុំបានបំពេញការងាររបស់ខ្ញុំជាមួយនឹងឥរិយាបថដែលខុសប្លែកទៅនឹងអ្វីដែលខ្ញុំធ្លាប់បានប្រកាន់យកកាលពីដំបូង ។ ឥរិយាបថនៅពេលនេះគឺ ខ្ញុំចង់ធ្វើការសិក្សាស្រាវជ្រាវមួយដើម្បីជួយឲ្យយើងទាំងអស់គ្នារកឃើញការពិត និងជួយប្រជាជនកម្ពុជាឲ្យចាប់ផ្តើមមើលឃើញខ្លួនឯងថាជាបុគ្គលដែលបានឆ្លងកាត់នូវហេតុការណ៍នោះដូចគ្នា ។ យើងត្រូវប្រមូលផ្តុំគ្នាជាគ្រួសារសិន មុនពេលបង្កើតបានជាជាតិមួយ ឬនិយាយម្យ៉ាងទៀត ការប្រមូលផ្តុំគ្រួសារមួយត្រូវតែចាប់ផ្តើមពីបុគ្គលម្នាក់ៗ ។


រដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងសង្គមកិច្ចរបស់សហរដ្ឋអាមេរិកនិងនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ការប្រមូលយកសក្ខីភាពរបស់អ្នកដែលរួចជីវិតពីរបបកម្ពុជាប្រជាធិប-តេយ្យ គឺជាកិច្ចការមួយក្នុងចំណោមកិច្ចការសំខាន់ៗបំផុតនៃការសិក្សាស្រាវជ្រាវរបស់ខ្ញុំ ។ កិច្ចការនេះបម្រើឲ្យគោលបំណងសំខាន់បីគឺ ទីមួយ ជំរុញឲ្យមានការយល់យោគនិងធូរស្បើយនៅក្នុងបុគ្គលគ្រប់រូប ទីពីរ រួមចំណែកដល់ការស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា និងទីបី ថែរក្សាប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជា ។

ពេលវេលាអាចធ្វើឲ្យការចងចាំរបស់បុគ្គលម្នាក់ផ្លាស់ប្តូរ ។ ខ្ញុំមិនចាំរឿងរ៉ាវគ្រប់យ៉ាងដែលបានកើតឡើងកាលពី២៥ឆ្នាំមុន ។ ប្រជាជនកម្ពុជាភាគច្រើនមិនចង់ចងចាំរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ។ ដូច្នេះទន្ទឹមនឹងពេលដែលការចងចាំអាចផ្តល់អត្ថប្រយោជន៍ វាក៏អាចបង្កជាគ្រោះថ្នាក់ដែរ ។ នៅពេលដែលប្រជាជនអាចរំឭកការចងចាំរបស់ខ្លួនឲ្យបានច្បាស់ឡើងវិញនោះ គាត់អាចយកវាធ្វើជាមូលដ្ឋានសម្រាប់ការពិចារណា ។

ការជួយឲ្យប្រជាជនចងចាំបានច្បាស់ជាងមុន អាចជួយឲ្យគាត់ដោះស្រាយបញ្ហាទុក្ខព្រួយនិងការប៉ះទង្គិចផ្លូវចិត្តបាន ព្រមទាំងជួយឲ្យប្រជាជនទាំងអស់ទទួលស្គាល់ថា អ្វីដែលគាត់បានជួបប្រទះ អ្នកដទៃទៀតក៏ជួបប្រទះដូចគ្នាដែរ ។ តាមរយៈនេះ ប្រជាជនប្រហែលជាអាចចាប់ផ្តើមយល់ថា អ្វីដែលគាត់ជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាអ្វីដែលកំណត់ថាគាត់ជាបុគ្គលដែលជាមែកធាងផ្សេងៗរបស់សង្គម ។

ខ្ញុំបានជួបសម្ភាសជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើននាក់ដែលសុទ្ធតែធ្លាប់បានឆ្លងកាត់ព្រឹត្តិការណ៍ដ៏សែនវេទនានោះ ។ ខ្ញុំគិតថាគ្មាននរណាម្នាក់អាចយល់បានពេញលេញអំពីអារម្មណ៍ដែលរស់នៅក្រោមរបបខ្មែរក្រហមទេ ។ យើងមិនអាចរៀបរាប់អំពើប្រល័យពូជសាសន៍តាមរយៈពាក្យសម្តីបានឡើយ ហេតុនេះហើយបានជាជនរងគ្រោះភាគច្រើនមានអារម្មណ៍ខឹងសម្បានៅពេលគាត់ព្យាយាមរៀបរាប់ពីសោកនាដកម្មនោះ ។ អ្នក អ្នកស្រាវជ្រាវជាន់ខ្ពស់បរទេសខ្លះមើលឃើញសក្ខីភាពរបស់ជនរងគ្រោះថាជាការបំផ្លើស នៅពេលជនរងគ្រោះរៀបរាប់អំពីរបៀបដែលមនុស្សត្រូវបំបែកជាបំណែកៗ របៀបដែលកុមារតូចៗត្រូវយោធាខ្មែរក្រហមដុត និងរបៀបដែលហេតុការណ៍នោះកើតឡើងចំពោះមុខមនុស្សរាប់ពាន់រាប់លាននាក់ ។ ខ្ញុំគិតថាពេលខ្លះសក្ខីភាពទាំងនេះស្ទើរតែក្លាយទៅជារឿងមិនពិតទាំងស្រុង ហើយការណ៍នេះមិនត្រឹមតែមិនអាចជួយឲ្យមានការចងចាំច្បាស់ឡើងវិញទេ ថែមទាំងធ្វើឲ្យមានការសង្ស័យលើសមាសភាពរបស់អ្នកផ្តល់សក្ខីភាពនោះទៀតផង ។

ដូច្នេះ ទាក់ទងនឹងការស្វែងរកយុត្តិធម៌ ខ្ញុំយល់ថា បើចង់ឲ្យ

សក្ខីភាពរបស់សាក្សីមានប្រយោជន៍ ជនរងគ្រោះចាំបាច់ត្រូវតែធ្វើខ្លួនឲ្យរឹងប៉ឹង ។ ប្រសិនបើយើងបង្ហាញភាពទន់ជ្រាយ ជនដៃដល់មុខជាមានកម្លាំងចិត្តកាន់តែខ្លាំងឡើងមិនខាន ។ ប្រសិនបើជនរងគ្រោះយំសោកក្នុងស្ថានភាពបែបនោះ វាជាសញ្ញាបង្ហាញថា ជនរងគ្រោះនោះកំពុងតែរស់នៅក្នុងអតីតភាពនៅឡើយ ។ ក៏ប៉ុន្តែ នៅពេលដែលជនរងគ្រោះម្នាក់រកឃើញមធ្យោបាយដើម្បីរំដោះខ្លួនឲ្យផុតពីអតីតភាពនោះ ជនរងគ្រោះអាចរួមចំណែកបានយ៉ាងច្រើននៅពេលផ្តល់សក្ខីភាពនៅក្នុងតុលាការ ។ ប្រសិនបើខ្ញុំមានការចងចាំតិចតួច ខ្ញុំមិនអាចប្រាប់បទពិសោធន៍នោះទៅកូនចៅអ្នកដទៃទៀត ឬមនុស្សជំនាន់ក្រោយបានឡើយ ហើយបើខ្ញុំមិនបន្តប្រាប់រឿងរ៉ាវនេះទេ តើអ្នកទាំងនោះធ្វើម៉េចនឹងជឿថាមានហេតុការណ៍បែបនេះកើតឡើងពិតមែន? ដូច្នេះវាមានសារសំខាន់ក្នុងការថែរក្សារឿងរ៉ាវរបស់អ្នករួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យសម្រាប់អ្នកជំនាន់ក្រោយ ។ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា យើងបានបញ្ចូលបទសម្ភាសន៍របស់អ្នករួចជីវិតពីសោកនាដកម្មនោះទៅក្នុងឯកសារក្រដាសនិងបញ្ចូលទៅក្នុងទិន្នន័យគន្ថនិទ្ទេសនៅក្នុងកម្មវិធីផ្ទុកទិន្នន័យរបស់ «គម្រោងជំរុញឲ្យមានការទទួលខុសត្រូវ» ។ យើងកំពុងតែបង្ហឹកប្រជាជនកម្ពុជាឲ្យសរសេរប្រវត្តិសាស្ត្រដោយខ្លួនឯង និងបង្ហឹកមនុស្សជំនាន់ក្រោយឲ្យក្លាយទៅជាអ្នកថែរក្សាប្រវត្តិសាស្ត្រនោះ ។

សព្វថ្ងៃ ខ្ញុំរីករាយចិត្តជាខ្លាំងដែលបានដឹងថាយុត្តិធម៌និងការផ្សះផ្សាបានក្លាយជាប្រធានបទសំខាន់សម្រាប់មនុស្សជាច្រើន ។ អ្នកខ្លះប្រហែលជាអាចសួរថា ហេតុអ្វីបានជាយើងនៅតែផ្តោតអារម្មណ៍មកលើអំពើប្រល័យពូជសាសន៍នៅកម្ពុជាទៀត បើរឿងនេះបានកើតឡើងជាង២៥ឆ្នាំមកហើយនោះ ។ តើយើងគួរតែបំភ្លេចអំពើឃោរឃៅនោះ ហើយគិតតែរឿងអនាគតឬយ៉ាងណា? ប៉ុន្តែកម្ពុជានិងប្រទេសជាច្រើនទៀត យើងមានមនុស្សជាច្រើនដែលនៅតែស្ម័គ្រចិត្តប្រឈមមុខជាមួយបញ្ហាដែលជាតថភាពនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃ ។ រឿងខ្មែរក្រហមគឺនៅតែជាបច្ចុប្បន្ននៅឡើយ ។ មេដឹកនាំខ្មែរក្រហមជាច្រើនកំពុងតែរស់នៅក្រៅច្បាប់យ៉ាងមានសេរីភាពនៅក្នុងប្រទេសកម្ពុជា ។ នៅពេលតុលាការជំនុំជម្រះទោសអ្នកទាំងនេះរួចហើយ សង្គមរបស់យើងនឹងរួចផុតពីស្រមោលអតីតកាលរបស់របបមួយដែលទទួលខុសត្រូវចំពោះការបាត់បង់ជីវិតរបស់ប្រជាជនអស់ជិតពីរលាននាក់ ។

ដោយសារតែរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានឆ្ពោះទៅកាន់តែជិតដល់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យហើយនោះ កម្ពុជាគួរតែផ្តល់មេរៀនមានតម្លៃខ្លះសម្រាប់ប្រជាជាតិដទៃទៀត ក៏ដូចជាសម្រាប់សហគមន៍អន្តរជាតិទាំងមូលដែរ ។ ដូចដែលយើងឃើញនៅក្នុងប្រវត្តិសាស្ត្រ អំពើប្រល័យពូជសាសន៍អាចកើតឡើងនៅគ្រប់ទីកន្លែងទាំងអស់ ។ បើយើងក្រឡេកមើលទៅប្រទេសរ៉្វាន់ដា ទីម័រខាងកើត បូស្នៀ ស៊ូដង់ និងប្រទេសផ្សេងៗទៀត យើងនឹងឃើញថា អំពើឃោរឃៅនេះនៅតែកើតឡើងជានិច្ច ។ ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែងនិងការគាំទ្រពីសហគមន៍អន្តរជាតិទេនោះ យើងក៏មិនអាចការពារអំពើប្រល័យពូជសាសន៍បានដែរ ។ ប្រសិនបើគ្មានទស្សនវិស័យសកលទេ ការយល់ឃើញរបស់យើងអាចនៅចង្អៀតចង្អល់ ដែលអាចធ្វើឲ្យយើងមានទស្សនៈជ្រុលនិយម ហើយភាពជ្រុលនិយមនេះអាចនាំទៅដល់ការប្រព្រឹត្តអំពើហិង្សាម្តងទៀត ។

ជួនកាល ខ្ញុំមានការភ្ញាក់ផ្អើលដោយសារអ្វីដែលយើងរៀនសូត្រពីបទពិសោធន៍អ្នកដទៃ គឺតិចតួចពេក ។ ជាក់ស្តែងប្រជាជនកម្ពុជាភាគច្រើនដឹងតិចតួចឬមិនដឹងទាល់តែសោះអំពីអំពើប្រល័យពូជសាសន៍ជនជាតិជ្វីហ្វនិងជនជាតិផ្សេងទៀត នៅអឺរ៉ុបដោយក្រុមណាហ្ស៊ី នៅអំឡុងសង្គ្រាមលោកលើកទីពីរ ។ វាជារឿងធម្មតាទេ សម្រាប់អ្នករួចជីវិតពីរបបប្រល័យពូជសាសន៍ភ្ញាក់ផ្អើលនៅពេលដឹងថា អ្នកផ្សេងទៀតក៏ជួបប្រទះអំពើឃោរឃៅនោះដែរ ។ ដូច្នេះការដឹងថាប្រទេសរបស់ខ្លួនមិនមែនជាប្រទេសតែមួយគត់ដែលមានអំពើសោកនាដកម្មកើតឡើង ជួនកាលអាចជួយលួងចិត្តយើងបានខ្លះដែរ ។ តាមរយៈការសិក្សាស្រាវជ្រាវនិងការចងក្រងឯកសារស្តីពីអំពើឃោរឃៅនេះ អាចជួយឲ្យយើងចែករំលែករឿងរ៉ាវនេះទៅអ្នកផ្សេងទៀត ជួយលើកទឹកចិត្តជនរងគ្រោះថាខ្លួនមិននៅឯកាទេ និងផ្តល់ការគាំទ្រដល់សហគមន៍អន្តរជាតិ


ម៉ៃឃើល អូលីវីត និង ឆាំង យុ

ដែលធ្វើការដើម្បីការពារកុំឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មី ។ ជំហានបន្ទាប់គឺប្រមូលផ្តុំការពិតដើម្បីស្វែងរកមូលហេតុដែលបង្កជាអំពើប្រល័យពូជសាសន៍និងដើម្បីការពារកុំឲ្យមានទង្វើបែបនេះកើតឡើងម្តងទៀត ។

មេរៀនទាំងនេះក៏ជួយដល់អ្នកដែលធ្វើការស្រាវជ្រាវនិងចងក្រងឯកសារអំពីរំលោភសិទ្ធិមនុស្ស និងអំពើប្រល័យពូជសាសន៍ដែរ ។ កិច្ចការនេះក៏អាចធ្វើឲ្យប្រជាជនមានអារម្មណ៍នឿយណាយ ហើយជួនកាលមានអារម្មណ៍ថាឯកាទៀតផង ប៉ុន្តែ ការដឹងថានៅក្នុងប្រទេសផ្សេងទៀតក៏មានការសិក្សាស្រាវជ្រាវនិងចងក្រងឯកសារបែបនោះដែរ អាចផ្តល់ឲ្យអ្នកទាំងនោះនូវការលើកទឹកចិត្តថ្មីបន្ថែមទៀត ។ ដោយសារហេតុផលនេះនិងដោយមានកិច្ចសហការជាមួយ “មជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌អន្តរកាល” យើងបានផ្តើមគំនិតបង្កើតអឹហ្វីនីធីគ្រុប (ក្រុមដែលធ្វើការប្រមូលឯកសារដែលមានប្រតិបត្តិការនិងរចនាសម្ព័ន្ធប្រហាក់ប្រហែលនិងមជ្ឈមណ្ឌលឯកសារកម្ពុជា) ដើម្បីផ្លាស់ប្តូរគំនិត ចំណេះដឹង និងបច្ចេកទេសរវាងគ្នាទៅវិញទៅមក ។ យើងមានសមាជិកជាមជ្ឈមណ្ឌលឯកសារមកពីប្រទេសអតីតយូហ្គោស្លាវី ហ្គាតេម៉ាឡា ភូមា អ៊ីរ៉ាក់ អាហ្វហ្គានីស្ថាន និងអាហ្វ្រិកខាងត្បូង ដើម្បីផ្សព្វផ្សាយពត៌មានបច្ចេកទេសនានា និងដើម្បីសហការដោះស្រាយបញ្ហាដែលសមាជិកជួបប្រទះ ។ យើងម្នាក់ៗមានអ្វីប្លែកៗទាំងខាងវិស័យវប្បធម៌និងនយោបាយរបស់ប្រទេសរៀងៗខ្លួនដើម្បីចែករំលែកគ្នា ។

អ្នកដែលធ្លាប់ឆ្លងកាត់អំពើប្រល័យពូជសាសន៍ដឹងថាគ្មានអ្នកណាម្នាក់ ឬអ្វីមួយអាចប៉ះប៉ូវសងវិញបានឡើយចំពោះអ្វីដែលបានកើតឡើង ហើយយើងដឹងថា អំពើប្រល័យពូជសាសន៍បានបំផ្លាញប្រទេសមួយតាមមធ្យោបាយជាច្រើន ។ ដូចដែលអ្នកបានដឹង វិថីឆ្ពោះទៅរកការធូរស្បើយគឺជាផ្លូវមួយដ៏វែងឆ្ងាយសម្រាប់កម្ពុជា ។ ២៥ឆ្នាំបន្ទាប់ពីអំពើសោកនាដកម្ម កម្ពុជានៅតែជាប្រទេសក្រីក្រមួយក្នុងចំណោមប្រទេសក្រីក្របំផុតនៅក្នុងពិភពលោក ហើយសុខុមាលភាពប្រជាជនរបស់ប្រទេសនេះកំពុងតែដើរថយក្រោយទៀតផង ។ យើងត្រូវតែសះស្បើយនៅក្នុងផ្លូវចិត្ត ទើបយើងអាចបន្តដំណើរឆ្ពោះទៅមុខទៀត ហើយការចងក្រងឯកសារនិងការយល់ដឹងអំពីបទពិសោធន៍ដូចៗគ្នានេះគឺជាជំហានតូចមួយឆ្ពោះទៅរកទិសដៅនេះ ។ **ឆាំង យុ**

# សេចក្តីជូនដំណឹង

យើងខ្ញុំកំពុងស្វែងរកភាពយន្តឯកសារ រូបថត កាសែតចម្រៀង (ឬសំឡេង) និងពត៌មានសម្រាប់ទំនាក់ទំនងជាមួយអ្នកចម្រៀងនិងតន្ត្រីករកម្ពុជាពីទសវត្សរ៍១៩៦០និង១៩៧០ ដើម្បីផលិតភាពយន្តឯកសារមួយអំពី “តន្ត្រីរបស់កម្ពុជា” ដែលកំពុងដំណើរការថតនៅក្នុងផលិតកម្មហូលីវូដ ។ យើងខ្ញុំចង់សម្ភាសជាមួយលោកអ្នកដែលដឹងរឿងរ៉ាវរបស់អ្នកចម្រៀងនិងតន្ត្រីករពីសម័យនោះ ។

ឯកសារទាំងអស់នឹងត្រូវប្រគល់ជូនឬតម្កល់ទុកនៅក្នុងបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់បម្រើឲ្យគោលបំណងស្រាវជ្រាវនៅពេលអនាគត ។ លោកអ្នកទាំងឡាយដែលបានរួមចំណែកនៅក្នុងកិច្ចការនេះ នឹងមានឈ្មោះនៅក្នុងភាពយន្តឯកសារនោះថាជាអ្នកដែលបានជួយថែរក្សាប្រវត្តិសាស្ត្រកម្ពុជា ។

ប្រសិនបើលោកអ្នកមានពត៌មានដែលលោកអ្នកគិតថាមានប្រយោជន៍ សូមទំនាក់ទំនងមកៈ ដាត រចនា តាមរយៈលេខទូរស័ព្ទ ០១២ ៨០២ ៧៨០ ឬតាមរយៈអ៊ីមែល *truthrachana@dccam.org* ឬ សូ ហ្វារីណា តាមរយៈលេខទូរស័ព្ទ ០១២ ៩៦៧ ៥៦៥ ឬតាមរយៈអ៊ីមែល *truthfarina@dccam.org* ឬតាមរយៈអ៊ីមែលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា dccam@online.com.kh ។ សូមអរគុណ ។

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# តាន់ លៀកផេង និស្សិតមកពីប្រទេសបារាំង

តាន់ លៀកផេង ជាអតីតនិស្សិតខ្មែរដែលទទួលបានអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំងផ្នែកកសិកម្មនៅខែកញ្ញា ឆ្នាំ១៩៧២ ។ បន្ទាប់ពីបញ្ចប់ការសិក្សានៅប្រទេសបារាំងនៅឆ្នាំ១៩៧៦ លៀកផេង ក៏ដូចជានិស្សិតខ្មែរនៅឯបរទេសផ្សេងទៀតដែរ បានត្រឡប់ចូលមកប្រទេសកម្ពុជាដើម្បីកសាងប្រទេស តាមមុខជំនាញរបស់ខ្លួន។ ប៉ុន្តែ លៀកផេង ត្រូវអង្គការចោទថាក្បត់បដិវត្ត ហើយត្រូវចាប់ខ្លួននៅថ្ងៃទី១២ ខែ ១១ ឆ្នាំ១៩៧៧និងបញ្ជូនមកមន្ទីរស-២១ ដើម្បីសួរចម្លើយ ។

តាន់ លៀកផេង មានអាយុ៣២ឆ្នាំ កើតនៅភូមិផ្សារចាស់ ឃុំស្អុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ ឆ្នាំ១៩៦៩ លៀកផេង រៀននៅមហាវិទ្យាល័យវិទ្យាសាស្ត្រផ្នែកកសិកម្ម ។ ពិន សំខុន ដែលជាប្រធាននិស្សិតនៃសមាគមជនភៀសខ្លួននៅប្រទេសបារាំង បានពន្យល់ណែនាំ លៀកផេង អំពីលទ្ធិលោកសេរី ហើយស្នើឲ្យ លៀកផេង ចូលធ្វើការជាមួយខ្លួន។ លៀកផេង ក៏យល់ព្រមធ្វើការតាមការអូសទាញរបស់ សំខុន។ លៀកផេង បានស្គាល់សាស្ត្រាចារ្យ៤នាក់នៅមហាវិទ្យាល័យវិទ្យាសាស្ត្រភ្នំពេញ មានដូចជា ខៀវ កុមារ, ផាន់ ប៊ួយហាក់, អ្នកស្រី ឌី ផុន និង លី សូភារិទ្ធ តាមរយៈការណែនាំរបស់ សំខុន។ នៅក្នុងឱកាសនោះ ខៀវ កុមារ បានបញ្ចូល លៀកផេង ជាសមាជិកសេ.អ៊ី.អា និងណែនាំឲ្យគាត់អនុវត្តនូវលក្ខន្តិកៈមួយចំនួន ព្រមទាំងកសាងកម្លាំងក្នុងចំណោមនិស្សិតមហាវិទ្យាល័យវិទ្យាសាស្ត្រផង ។

ឆ្នាំ១៩៦៩ លៀកផេង បានបញ្ចុះបញ្ចូលនិស្សិតមហាវិទ្យាល័យវិទ្យាសាស្ត្របាន២នាក់ឈ្មោះ ឈុន បូរាណ និង អាវ ឈុនហាន ព្រមទាំងអប់រំអ្នកទាំងពីរឲ្យកសាងកម្លាំងបន្តទៀត ។

លៀកផេង និងមិត្តភក្តិបានចុះទៅចែកទស្សនាវដ្តីនិងឯកសារផ្សេងៗរបស់លោកសេរីនៅវិទ្យាល័យទួលស្វាយព្រៃ វិទ្យាល័យស៊ីសុវត្ថិ វិទ្យាល័យយុគន្ធរ និងវិទ្យាល័យទួលគោក ក្នុងគោលបំណងឲ្យសិស្សវិទ្យាល័យទាំងនេះយល់អំពីវប្បធម៌លោកសេរី ។

នៅដើមឆ្នាំ១៩៧០ ស សុង បានហៅ លៀកផេង និងនិស្សិតនៅសាលាកសិកម្មទៅប្រជុំនៅមហាវិទ្យាល័យវិទ្យាសាស្ត្រភ្នំពេញក្នុងបន្ទប់មួយដែលជាកន្លែងធ្វើការរបស់ ផាន់ ប៊ួយហាក់ ។ នៅក្នុងបន្ទប់នោះមានមនុស្ស១៣នាក់ផ្សេងទៀត ។ ស សុង បានប្រកាសថា នៅពេលខាងមុខនេះ ប្រជាជន សិស្ស និស្សិតនឹងរៀបចំធ្វើបាតុកម្មប្រឆាំងនឹងទូតយៀកណាម យៀកកុង ដែលឈ្លានពានប្រទេសកម្ពុជា ។ ស សុង ស្នើសុំឲ្យនិស្សិតនៅសាលាកសិកម្មប្រុងប្រៀបបំផុសឲ្យនិស្សិតដទៃទៀតគាំទ្របាតុកម្មនេះឲ្យបានផុសផុល ។

ស សុង បន្ថែមថា ប្រសិនបើមានការផ្លាស់ប្តូររដ្ឋាភិបាល សុំឲ្យនិស្សិតគាំទ្ររដ្ឋាភិបាលថ្មី ហើយត្រូវធ្វើសកម្មភាពរារាំងកុំឲ្យនិស្សិតមានការជ្រួលច្របល់ និងត្រូវកសាងកម្លាំងនិស្សិតឲ្យបានច្រើន ។

នៅក្នុងឆ្នាំ១៩៧០ ក្រោយពេលរដ្ឋប្រហាររយៈពេលមួយខែ ស សុង បានហៅ លៀកផេង និងនិស្សិតមួយចំនួនទៀតទៅប្រជុំនៅបន្ទប់របស់ ផាន់ ប៊ួយហាក់ដដែលដោយមានគ្នា១២នាក់ចូលរួមដើម្បីឃោសនាប្រឆាំងនឹងយួនកុម្មុយនិស្តនិងខ្មែរក្រហមឲ្យកាន់តែខ្លាំងឡើង ។

ឆ្នាំដដែល លៀកផេង និងមិត្តភក្តិកសាងកម្លាំងបាន៣នាក់ទៀតដោយអប់រំអ្នកទាំងបីឲ្យចូលរួមក្នុងសកម្មភាពប្រឆាំងនឹងខ្មែរក្រហម ។

លៀកផេង បានបំផុសឲ្យនិស្សិតធ្វើបាតុកម្មប្រឆាំងនឹងទូតវៀតណាមខាងជើងនិង យៀកកុង និងបានបំផុសឲ្យបាតុកររកម្ទេចផ្ទះលក់សៀវភៅ ហុង យូ ដែលសង្ស័យថាមានជាប់ពាក់ព័ន្ធជាមួយយៀកកុង ។

លៀកផេង បានទៅឃោសនាសិស្សនៅសាលាមុនីវង្ស

ខេត្តបាត់ដំបងបំផុសឲ្យគាំទ្ររដ្ឋាភិបាលលន់នល់ថែមទៀត ។

នៅឆ្នាំ១៩៧១ ស សុផ បានហៅនិស្សិត១៣នាក់ទៅប្រជុំនៅទីស្នាក់ការរដ្ឋមន្ត្រីកសិកម្ម ជាកន្លែងធ្វើការរបស់ខ្លួន ។ ស សុផ បានណែនាំនិស្សិតឲ្យប្រុងប្រយ័ត្នកាន់តែខ្លាំងឡើងចំពោះខ្មាំងដោយសារខ្មាំងលួចបង្កប់គ្រាប់បែកនៅសាលមហោស្រពនិងនៅទីប្រជុំជននានា កុំឲ្យនិស្សិតភ្លើតភ្លើននឹងការសប្បាយនៅពេលប្រទេសជាតិកំពុងប្រឈមមុខទល់នឹងខ្មាំង និងបែងចែកកម្លាំងទៅចែកអំណោយដល់ជនភៀសខ្លួននៅជុំវិញភ្នំពេញនិងនៅតាមខេត្តនានា ដែលជាយុទ្ធវិធីមួយក្នុងការប្រមូលកម្លាំងប្រជារាស្ត្រឲ្យជួយគាំទ្រកាន់តែច្រើន ។

នៅដើមឆ្នាំ១៩៧២ ស សុផ បានប្រកាសឈ្មោះនិស្សិតដែលបានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំងដែលមាន ឈិន ធន់, ភិត កុត, ហេង ហំខេង, ហែម សូរិន និង ផេង ម៉េងឡុង ចំណែក លៀកផេង ត្រូវរង់ចាំឱកាសក្រោយ ។ នៅឆ្នាំដដែល លៀកផេង កសាងបានកម្លាំងម្នាក់ទៀតគឺ ឡាវ ប៊ុនហាក់ អតីតនិស្សិតកសិកម្មបច្ចេកទេស ។ ក្រោយព្រឹត្តិការណ៍បាញ់ទៅលើក្រុមបាតុករសិស្សប្រឆាំង លៀកផេង និងនិស្សិតទាំងអស់នៅសាលាកសិកម្មបានពន្យល់និស្សិតនៅសាលាចម្ការដូងនិងនៅវិទ្យាល័យនានាកុំឲ្យធ្វើបាតុកម្មប្រឆាំងនឹងរដ្ឋាភិបាល ។

ខែកញ្ញា ឆ្នាំ១៩៧២ លៀកផេង បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង ។ មុនពេលចេញដំណើរ ស សុផ បានហៅ លៀកផេង ទៅជួបនៅទីស្តីការរដ្ឋមន្ត្រីកសិកម្ម ដោយប្រាប់ឲ្យគាត់ទាក់ទងជាមួយ ផាន់ ប៊ួយហាក់ ដែលជាអ្នកទទួលខុសត្រូវនិស្សិតខ្មែរដែលរៀននៅប្រទេសបារាំង ។

នៅចុងឆ្នាំ១៩៧២ ផាន់ ប៊ួយហាក់ បានហៅ លៀកផេង ទៅប្រជុំនៅស្ថានទូតខ្មែរប្រចាំប្រទេសបារាំងដើម្បីជួបជុំជាមួយនិស្សិតខ្មែរដទៃទៀត ហើយណែនាំភារកិច្ចមួយចំនួនដូចជា ចែកខិត្តប័ណ្ណដល់ជនបរទេសឲ្យស្គាល់ពីប្រទេសកម្ពុជា ទទួលស្គាល់ពីការឈ្លានពានរបស់យួនក្រហមមកលើប្រទេសកម្ពុជា និងចូលធ្វើជាសមាជិករណសិរ្សរួបរួមជាតិនៅប្រទេសបារាំង ។ ហេង ហំខេង ដែលជាសមាជិករណសិរ្សបានណែនាំឲ្យ លៀកផេង សុំអាហារូបករណ៍ទៅសិក្សានៅប្រទេសចិនដើម្បីឆ្លៀតយកការណ៍សម្ងាត់ពីរណសិរ្សរួបរួមជាតិនៅប្រទេសចិន ។

នៅឆ្នាំ១៩៧៣ លៀកផេង បានឃោសនានិងចែកខិត្តប័ណ្ណស្តីពីការឈ្លានពានរបស់ខ្មែរក្រហមនិងការបាញ់ផ្លោងចូលទីក្រុងភ្នំពេញដែលបណ្តាលឲ្យមហាជនស្លាប់មួយចំនួន ។ ការឃោសនានេះធ្វើឡើងនៅតាមសាលានិងទីប្រជុំជននានា ។

លៀកផេង បានពង្រឹកសាមគ្គីភាពជាមួយសមាជិករណសិរ្សមួយចំនួនដើម្បីងាយស្រួលដល់ការឃោសនា ។ ដោយមានការជួយជ្រោមជ្រែងពី ផាន់ ប៊ួយហាក់, លៀកផេង និងនិស្សិតខ្មែរនៅទីក្រុងប៉ារីសបានរៀបចំពិធីបុណ្យចូលឆ្នាំខ្មែរយ៉ាងអធិកអធមជាមួយនឹងការថ្លែងសុន្ទរកថារបស់ ពិន សំខុន នៅចំពោះមហាជនខ្មែរអំពីការបំបាត់ប្រពៃណី វប្បធម៌ អារ្យធម៌ជាតិ និងសិទ្ធិសេរីភាពរបស់ប្រជាជនកម្ពុជាពីសំណាក់ខ្មែរក្រហម ។ សំខុន សំណូមពរឲ្យប្រជាជនខ្មែរទាំងអស់ប្រឆាំងនឹងរបបកុម្មុយនិស្តដោយដាច់ខាត ។

ដើមឆ្នាំ១៩៧៤ លៀកផេង និងនិស្សិត៨នាក់ទៀតបានជួបប្រជុំជាមួយ ផាន់ ប៊ួយហាក់ នៅស្ថានទូតខ្មែរប្រចាំទីក្រុងប៉ារីសដើម្បីទទួលផែនការថ្មីក្នុងការតាមដាននិស្សិតដែលទទួលអាហារូបករណ៍ពីរដ្ឋាភិបាលលន់នល់ ប៉ុន្តែទៅគាំទ្ររណសិរ្សរួបរួមជាតិកម្ពុជា ។ ពេលទទួលបានព័ត៌មានត្រូវឆាប់រាយការណ៍ដល់ស្ថានទូតខ្មែរ និងឃោសនាកុំឲ្យនិស្សិតឬមហាជនខ្មែរនៅទីក្រុងប៉ារីសចុះហត្ថលេខាគាំទ្រដល់រណសិរ្ស ។ នៅចុងបញ្ចប់នៃការប្រជុំ ផាន់ ប៊ួយហាក់ បានប្រកាសថា ហេង ហំខេង បានទទួលអាហារូបករណ៍ទៅបំពេញវិជ្ជានៅប្រទេសចិន ។

ឆ្នាំដដែល លៀកផេង និងនិស្សិត៨នាក់ទៀត បានចូលរួមក្នុងអង្គមិទ្ទីងមួយដែលរៀបចំឡើងដោយនិស្សិតបារាំងប្រឆាំងនឹងការឈ្លានពានរបស់យួនក្រហមមកលើប្រទេសខ្មែរនិងប្រទេសឡាវ ។

ឆ្នាំ១៩៧៥ រដ្ឋាភិបាលលន់នល់បានហៅ ផាន់ ប៊ួយហាក់ ត្រឡប់មកប្រទេសកម្ពុជាវិញ ។ តាវ សេងហួរ បានមកជំនួសតំណែងរបស់ ផាន់ ប៊ួយហាក់ ដើម្បីដាក់ផែនការឲ្យនិស្សិតធ្វើការបន្តទៀត ។ ពេលដែលរដ្ឋាភិបាលលន់លន់ត្រូវខ្មែរក្រហមផ្តួល

វិលំ ហើយប្រទេសកម្ពុជាត្រូវកាន់កាប់ដោយរបបកុម្មុយនិស្ត សេងហួរ បានសុំឲ្យនិស្សិតទាំងអស់រក្សាភាពស្ងប់ស្ងៀម ហើយបន្តការឃោសនាថែមទៀត ។ មួយខែក្រោយមក បន្ទាប់ពីរណសិរ្សរំដោះប្រទេសកម្ពុជាទាំងមូលនៅខែមេសា ឆ្នាំ១៩៧៥ លៀកដេង និងសមាជិក១១នាក់ទៀត បានជួបប្រជុំជាមួយ សេងហួរ នៅសណ្ឋាគារមួយ (ប្រទេសបារាំង) ដើម្បីទទួលផែនការថ្មីគឺឃោសនាប្រឆាំងនឹងរបបខ្មែរក្រហមដោយចាត់តាំងនិស្សិតដែលបន្តប់ខ្លួនក្នុងជួររណសិរ្សរួបរួមជាតិត្រឡប់ចូលប្រទេសកម្ពុជានិងរៀបចំបង្កើតសមាគមមនុស្សធម៌មួយដើម្បីជួយជនភៀសខ្លួន ។

ខែ៨ សេងហួរ បានណែនាំឲ្យ លៀកដេង ចូលជាសមាជិករណសិរ្សនៅទីក្រុងប៉ារីស ដើម្បីងាយស្រួលសុំការអនុញ្ញាតត្រឡប់ចូលប្រទេសកម្ពុជាក្នុងពេលខាងមុខ ។ រហូតដល់ខែ៩ លៀកដេង ត្រូវបានអនុញ្ញាតឲ្យចូលជាសមាជិករណសិរ្សនៅទីក្រុងប៉ារីស ។

ដើមឆ្នាំ១៩៧៦ លៀកដេង បានស្គាល់និស្សិត ជា ប៊ុនចេង សមាជិករណសិរ្សក្រុងប៉ារីស តាមការណែនាំរបស់ សេងហួរ ។ នៅក្នុងឱកាសនោះ សេងហួរ បានប្រកាសឈ្មោះនិស្សិត៦នាក់ដែលនឹងត្រឡប់ចូលមកប្រទេសកម្ពុជានៅដើមឆ្នាំ១៩៧៦ ។

លៀកដេង ត្រូវបានតែងតាំងជាអនុលេខានៃគណៈជាយក្រុងប៉ារីសនិងជាអ្នកទទួលខុសត្រូវក្នុងការបោះពុម្ពផ្សាយបន្តនូវទស្ស-នាវដ្តីកម្ពុជា ដោយសមាគមអាណិកជនកម្ពុជាប្រជាធិបតេយ្យ ។ លៀកដេង តែងទទួលបានការបណ្តុះបណ្តាលនិងអានឯកសារទិតៀន ស៊ុយទិតៀន ស្តីលដឹកនាំ ការបែងចែកវណ្ណៈនៅប្រទេសកម្ពុជា ការបង្កើតសហករណ៍ លោកទស្សនៈ ។ល។ លៀក ដេង តែងបញ្ជូនឯកសារទាំងនេះទៅឲ្យ សេងហួរ ជាបន្តបន្ទាប់ ។

សមាគមអាណិកជនកម្ពុជាប្រជាធិបតេយ្យមាននាទីសំខាន់ក្នុងការឃោសនាបញ្ចុះបញ្ចូលអាណិកជនខ្មែរឲ្យត្រឡប់ចូលប្រទេសកម្ពុជាវិញ ។ នៅខែ៦ ឆ្នាំដដែល សេងហួរ បានស្នើសុំឲ្យ លៀកដេង ដាក់ពាក្យសុំត្រឡប់ចូលប្រទេសកម្ពុជាវិញ ។ គាត់ត្រូវបានអនុញ្ញាតឲ្យត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៦ ។ សេងហួរ បានប្រគល់ភារកិច្ចមួយចំនួនឲ្យ លៀកដេង យកមកអនុវត្តនៅប្រទេសកម្ពុជាបន្តទៀត ដូចជា ទាក់ទងនិស្សិតដែលបញ្ជូនទៅមុននិងធ្វើឲ្យបក្សកុម្មុយនិស្តនិងមហាជនទុកចិត្តមកលើខ្លួន ។ បន្ទាប់មក សេងហួរ ណែនាំមនុស្សបីនាក់ឲ្យ លៀកដេង ស្គាល់ ដូចជា សារិន ហៅ កើត (សាស្ត្រាចារ្យ), សុង ហៅ ឆុន (និស្សិត) និង សិរិវុធ (និស្សិត) ជាដើម ។

នៅចុងខែធ្នូ លៀកដេង បានមកដល់ប្រទេសកម្ពុជា ហើយចូលធ្វើការនៅមន្ទីរក-១៥ (សាលាបចេកទេសមិត្តភាពខ្មែរសូវៀត) ដែលមានប្រធានមន្ទីរស្តីទីឈ្មោះ ទ្រី ម៉េងហួត ។ បន្ទាប់មក ទ្រី ម៉េងហួត បានចាត់គាត់ឲ្យធ្វើការនៅក្នុងក្រុមចល័ត ដែលមាន ជា ប៊ុនចេង ជាប្រធានក្រុម ។

នៅមន្ទីរនេះ លៀកដេង បានជួបជាមួយមិត្តភក្តិ៣នាក់ដែលបានមកដល់ប្រទេសកម្ពុជាមុនគាត់ ។ តាមរយៈអ្នកទាំងនេះបានឲ្យគាត់ដឹងថា និស្សិតមួយចំនួនទៀតដែលចូលមកប្រទេសកម្ពុជា ត្រូវបានអង្គការចាត់ឲ្យទៅបង្កបង្កើនផលនៅដីក្រហមខេត្តកំពង់ចាម ។

នៅចុងខែមករា ឆ្នាំ១៩៧៧ លៀកដេង បានជួបជាមួយ សារិន ហៅ កើត ជាប្រធានមន្ទីរក-១៥ និងជាបងចិញ្ចឹមរបស់ ជា ប៊ុនចេង ។ លៀកដេង បានប្រាប់ កើត អំពីគោលបំណងនិងផែនការរបស់ សេងហួរ ដែលដាក់ឲ្យគាត់អនុវត្ត ។

ដើមខែមីនា កើត បានជួបប្រជុំជាមួយ លៀកដេង និងសមាជិក៣នាក់ទៀតនៅក្នុងបន្ទប់របស់គាត់ ។ កើត ក៏ស្នើឲ្យជ្រើសរើសសមាជិកគណៈនិងអនុប្រធានមន្ទីរដែលមានទិន្នាការដូចគ្នា និងរកវិធីកម្ចាត់ ទ្រី ម៉េងហួត ដែលជាឧបសគ្គមិនឲ្យគាត់ធ្វើសកម្មភាពបានងាយស្រួល ។ កើត សុំឲ្យសមាជិកខិតខំកសាងកម្លាំងឲ្យបានច្រើន និងធ្វើឲ្យមហាជនទុកចិត្តនិងស្រលាញ់មកលើខ្លួនថែមទៀត ។ នៅចុងបញ្ចប់ កើត ណែនាំសមាជិកថ្មីចំនួន១៦នាក់ឲ្យស្គាល់គ្នាជាមួយសមាជិកចាស់ដើម្បីបង្កការងាយស្រួលក្នុងការបំពេញការងារ ។

ខែកុម្ភៈ ទ្រី ម៉េងហួត ចាត់តាំងឲ្យ លៀកដេង មើលថែទាំដំណាំផ្សេងៗ ។ លៀកដេង បានលាយថ្នាំហួសច្រើន សម្រាប់សម្លាប់សត្វល្អិតហួសកម្រិត បណ្តាលឲ្យដើមត្រឡាចឃ្លោកទាំង

នោះងាប់អស់ ។

ខែ៦ នៅពេលរុះរើផ្ទះ លៀកផេង និងក្រុមចល័តមិនប្រយ័ត្នបណ្តាលឲ្យធ្លាក់តុទូកញ្ចក់បាក់បែកខ្ទេចខ្ទីប្រើប្រាស់លែងកើត ហើយសំណង់ឈើមួយចំនួនធំមានឃ្លាបសសរផ្ទះក៏ត្រូវខូចខាតអស់មួយចំនួនដែរ ។

ដើមខែ៧ កើត ត្រូវអង្គការដកចេញពីមន្ទីរក-១៥ រាល់ភារកិច្ចទាំងអស់ត្រូវធ្លាក់មកលើ ទ្រី ម៉េងហួត ។ គាត់មើលការខុសត្រូវពាក់ព័ន្ធៈ ១) ការដ្ឋានសំណង់ទ្រុងមាន់ ទ្រុងទា ២) ការដ្ឋានបារកក់ធ្វើជី និង៣) ការដ្ឋានធ្វើបន្លីនិងកណ្តៀវ ។

ដើមខែ៨ ក្រោយពេលចប់ការងារប្រចាំថ្ងៃ លៀកផេង បានប្រជុំជាមួយ ឆុន និងសមាជិកមន្ទីរក-១៥ចំនួន៥នាក់ទៀតនៅក្នុងផ្ទះពេទ្យមួយ ។ ឆុន បានលើកឡើងអំពីសកម្មភាពការងារដែលកំពុងជាប់គាំងដោយសារមានការតាមដានពី ទ្រី ម៉េងហួត និងរិះរកវិធីដើម្បីកម្ចាត់ ម៉េងហួត ចេញពីមន្ទីរដោយលើកឡើងអំពីចំណុចខ្សោយរបស់ ម៉េងហួត ថាគាត់ជាមនុស្សមានធាតុអាជ្ញាធ្វើឲ្យប៉ះពាល់ខ្លាំងដល់មហាជន ។

ខែ៨ ម៉េងហួត បានបើកអង្គប្រជុំមួយដោយមាន សាវ៉ន ជាគណៈអង្គភាពចូលរួមដើម្បីសរុបគុណសម្បត្តិនិងការខ្វះខាតរបស់សមាជិកមន្ទីរ ។ ម៉េងហួត និយាយសរុបយ៉ាងខ្លីពីគុណសម្បត្តិនិងការខ្វះខាតរួមរបស់សមូហភាពក្នុងមន្ទីររយៈពេលកន្លះខែដែលគាត់គ្រប់គ្រងជំនួស កើត ។ បន្ទាប់មក គាត់អនុញ្ញាតឲ្យសមូហភាពឡើងធ្វើការចាប់អារម្មណ៍ ។ មហាជននៅមន្ទីរឡើងចាប់អារម្មណ៍ហើយពេញចិត្តនឹង លៀកផេង ព្រមទាំងសមាជិកមន្ទីរ២នាក់ទៀត ។ មហាជនបានបំផុសបំផុលឲ្យធ្វើការកសាង ម៉េងហួត ចំពោះការខ្វះខាតរបស់គាត់ ។ ដោយឃើញសភាពការណ៍តានតឹង សាវ៉ន បានឡើងការពារ ម៉េងហួត ដោយលើកហេតុផលថា ដោយសារការបំផុសពីខ្មាំងបង្កប់នៅក្នុងមន្ទីរនេះទើបរឿងទៅជាដូច្នេះ ។ ម៉េងហួត ក៏សម្រេចបិទអង្គប្រជុំភ្លាម ។

នៅឆ្នាំដដែល ឆុន បានជួបប្រជុំជាមួយ លៀកផេង និងសមាជិកជាច្រើនទៀតដើម្បីរកវិធីកម្ចាត់ ម៉េងហួត ។ គាត់ផ្តល់អនុសាសន៍ថាបើចង់កម្ចាត់ ម៉េងហួត ត្រូវកម្ចាត់ សាវ៉ន ដែរ ព្រោះ សាវ៉ន តែងការពារ ម៉េងហួត មិនឲ្យធ្លាក់ពីតំណែងជានិច្ច ។

ឆុន បានណែនាំឲ្យសមាជិករបស់គាត់បំផុសមហាជននៅការដ្ឋាននីមួយៗ ។ នៅខែ៩ ស៊ីន តំណាងរបស់អង្គការបានរៀបចំការប្រជុំមួយដើម្បីឲ្យសមាជិកមន្ទីរបញ្ចេញមតិអត្តនោម័តរៀងៗខ្លួនចំពោះទំនាស់កន្លងមក ។ លៀកផេង បានលើកឡើងនូវអត្តចរិតមិនចេះដោះស្រាយបញ្ហារបស់ សាវ៉ន ហើយអ្នកផ្សេងទៀតក៏លើកឡើងពីកង្វះខាតរបស់ ម៉េងហួត ដែរ ។ ស៊ីន សរុបមកវិញថា រឿងរ៉ាវទំនាស់ទាំងអស់ទំនងជាឧបាយកលរបស់ខ្មាំងដែលធ្វើឲ្យសមូហភាពបែកបាក់ផ្ទៃក្នុង ហើយស្នើឲ្យសមាជិកទាំងអស់រួបរួមគ្នាឡើងវិញ ។ នៅក្នុងឱកាសនោះដែរ ស៊ីន សម្រេចតែងតាំង ហ៊ីង អ៊ុន ជាប្រធាន, ទ្រី ម៉េងហួត ជាអនុប្រធាន និងមិត្តនារី ផល្លា ជាសមាជិកគណៈកម្មការ ។ ក្រោយពីការតែងតាំងនេះ ក្រុមរបស់ លៀកផេង កាន់តែពិបាកក្នុងការបំផុសបំផុស ហើយសកម្មភាពទាំងអស់ត្រូវជាប់គាំង ។

សាវ៉ន បានរៀបចំបើកវគ្គរៀនសូត្រដើម្បីការវែកមុខអ្នកដែលបំផុសបំផុលឲ្យមានទំនាស់នៅក្នុងមន្ទីរនិងការថ្នាំងថ្នាក់របស់មហាជនចំពោះអ្នកដឹកនាំមន្ទីរ ។ សាវ៉ន បានឲ្យសមាជិកនិងមហាជនម្នាក់ៗឡើងបង្ហាញមុខអ្នកដែលបង្កឲ្យមានទំនាស់នេះ ចាប់តាំងពីពេលនោះមក មហាជនក៏ចង្អុលមុខអ្នកដែលបង្កទំនាស់ម្តងម្នាក់ៗរហូតដល់ លៀកផេង ។ ថ្ងៃទី១២ ខែ១១ ឆ្នាំ១៩៧៧ លៀកផេង ត្រូវអង្គការចាប់ខ្លួន ហើយបញ្ជូនមកមន្ទីរឃុំឃាំង ស-២១ ។ លៀកផេង ត្រូវបានឈ្មោះ ភៀង បង្ខំឲ្យសរសេរចម្លើយសារភាពរបស់ខ្លួនចាប់ពីថ្ងៃទី៩ ខែ១២ ឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី១ ខែ១ ឆ្នាំ១៩៧៨ ។

នៅក្នុងចម្លើយសារភាពរបស់ គាត់ លៀកផេង ចំនួន៣៧ ទំព័រ បានឆ្លើយលាតត្រដាងនូវសកម្មភាពទំនាក់ទំនងជាមួយនិស្សិតខ្មែរតាំងពីនៅក្នុងប្រទេសកម្ពុជារហូតដល់ប្រទេសបារាំង និងនៅពេលត្រឡប់មកធ្វើការនៅមន្ទីរក-១៥ ។ ប៉ុន្តែគាត់បញ្ជាក់មិនបានច្បាស់អំពីសកម្មភាពបំផ្លាញបដិវត្តន៍ឡើយ ។

**សូ ហ្វារីណា**

# ញត្តិគាំទ្រសេចក្តីសម្រេចចិត្តរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា សម័យប្រជុំលើកទី៥ នីតិកាលទី១ និងលិខិតចំហរបស់បញ្ញាជននិងបព្វជិតកម្ពុជា ស្តីអំពីឧក្រិដ្ឋកម្មរបស់បន ប៉ុល ពត, អៀង សារី និង ខៀវ សំផន

យើងខ្ញុំជាប្រជាជនក្នុងភូមិស្វាយធំ សង្កាត់ទី២ ទីរួមខេត្តកំពត ទាំងអស់ បន្ទាប់ពីបានចូលរៀនសូត្រសេចក្តីសម្រេចចិត្តរបស់រដ្ឋសភាក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី១ និងលិខិតចំហរបស់បញ្ញាជននិងបព្វជិតកម្ពុជាមក យើងខ្ញុំជាប្រជាជនបានអនុម័តលើកំណត់ហេតុស្តីពីទោសឧក្រិដ្ឋរបស់ ប៉ុល ពត, អៀង សារី, ខៀវ សំផន មកលើប្រជាជនកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៨ ។ តាមរយៈការរៀនសូត្រនេះ យើងខ្ញុំជាប្រជាជនបានដឹងច្បាស់ថា របបនេះបានកាប់សម្លាប់ប្រជាជនស្លូតត្រង់អស់ ៣លាន៣សែន១ម៉ឺន៤ពាន់៧រយ៦៨នាក់ បន្សល់ទុកនូវជនពិការបាក់កម្លាំង១សែន៤ម៉ឺន១ពាន់៨រយ៤៨នាក់ កុមារកំព្រាជាង២សែននាក់ នារីរាប់សែននាក់បានក្លាយជាស្ត្រីមេម៉ាយ ។ ក្រៅពីបំផ្លាញជីវិតជនស្លូតត្រង់ របបនេះបានកម្ទេចសាលារៀន ចំនួន៥៨៥៧ មន្ទីរពេទ្យចំនួន៧៩៦ វត្តអារាម១៩៦៨ ។ ជាងនេះទៅទៀត រាល់សកម្មភាពអប់រំ សាសនា វប្បធម៌ សិល្បៈ សង្គមកិច្ច ការផ្ញើជំនួញដូរផ្សេងៗ ប្រាក់កាស ផ្សារផ្សា ក៏ត្រូវពួកវាកម្ទេចចោលអស់គ្មានសល់ ។ ឯបញ្ញាជន បព្វជិត ក៏មិនអាចជៀសផុតពីការធ្វើទារុណកម្មយ៉ាងខ្លោចផ្សា ។ ព្រះសង្ឃចំនួន២៥.១៦៨អង្គ វេជ្ជបណ្ឌិត និងទន្តពេទ្យ៥៩៤នាក់ អ្នកច្បាប់ សាស្ត្រាចារ្យ៩៧៥នាក់ គ្រូបង្រៀន១ម៉ឺន៨ពាន់នាក់ និស្សិត ១០.៥៥០នាក់ អ្នកកាសែត១៩១នាក់ សិល្បករ១.១២០នាក់ ត្រូវបានកាប់សម្លាប់យ៉ាងឃោរឃៅព្រៃផ្សៃបំផុត ។

មិនតែប៉ុណ្ណោះ បនក្បត់បានឃោសនាបោកបញ្ឆោតបញ្ញាជនដែលរៀននៅបរទេសឲ្យវិលមកកាន់មាតុភូមិកម្ពុជាវិញ និងសន្យាប្រគល់តំណែងនេះតំណែងនោះឲ្យ បញ្ញវន្តស្នេហាជាតិចំនួន១ពាន់នាក់ ត្រូវពួកវាកាប់សម្លាប់ និងធ្វើទារុណកម្មយ៉ាងវេទនាបំផុតនៅគុកទួលស្លែង ហើយមានតែ៨៤នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិតមកទល់សព្វថ្ងៃនេះ ។ បនក្បត់ជាតិប្រល័យពូជសាសន៍ ប៉ុល ពត, អៀង សារី, ខៀវ សំផន មិនគ្រាន់តែបានកម្ទេចរូបរាងកាយរបស់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ថែមទាំងបានកម្ទេចទាំងស្រុងនូវស្មារតីមនោសញ្ចេតនាមនសិការ និងទំនាក់ទំនងរបស់មនុស្សទៀតផង ដូចជាទំនាក់ទំនងក្នុងគ្រួសារ ប្តីនិងប្រពន្ធ ម្តាយនិងកូន បងនិងប្អូន មិត្តភក្តិ សាច់សាលោហិតនៅជិតឆ្ងាយ សំដៅប្រែក្លាយមនុស្សឲ្យទៅជាសត្តិរច្ឆាន ។

បនក្បត់នៅតែមិនស្កប់ស្កល់ ថែមទាំងកម្ទេចឫសគល់រចនាសម្ព័ន្ធសង្គម ដូចជាខឿនសេដ្ឋកិច្ច វប្បធម៌ជាតិ ប្រពៃណីដ៏ល្អរបស់ប្រជាជនដែលធ្លាប់មានស្នាដៃដ៏ល្បីល្បាញ ក្នុងការកសាងប្រាសាទអង្គរដ៏បវរនៃយើង ។ បនក្បត់បានបំផ្លាញមូលដ្ឋានសម្ភារ បរិក្ខារបច្ចេកទេស និងភោគទ្រព្យ ធនធានដ៏សម្បូរនៅលើទឹកដីកម្ពុជា ។ ពួកវាមិនគ្រាន់តែកម្ទេចអ្វីៗដែលមាននៅក្នុងពេលនោះទេ ថែមទាំងកម្ទេចនូវអ្វីៗសម្រាប់អនាគតកាល ពោលគឺលទ្ធភាពបន្តពូជពង្សរបស់ប្រជាជនកម្ពុជាអស់ជាងបីលាននាក់ដូចមានភ័ស្តុតាងបញ្ជាក់ស្រាប់ ។

យើងខ្ញុំប្រជាជនទាំងអស់មិនដែលជួបប្រទះព្រឹត្តិការណ៍ក្នុងអំឡុងឆ្នាំ១៩៧៥-៧៨ ក្នុងរបប ប៉ុល ពត, អៀង សារី, ខៀវ សំផន ឡើយ ។ រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានកត់ត្រាទុកនូវឧក្រិដ្ឋកម្មនេះថាពិតជាត្រឹមត្រូវមិនអាចប្រែក្រឡាស់បាន ។ រដ្ឋសភាបានយល់ព្រមជាឯកច្ឆន្ទឲ្យប្រជាជនកត់ត្រាទុកជាប្រវត្តិសាស្ត្រដ៏ជូរចត់បំផុតសម្រាប់កូនចៅជំនាន់ក្រោយ ។ ប្រជាជនកម្ពុជា ព្រមទាំងសភាទាំងមូលបានកំណត់យកថ្ងៃទី២០

ខសភា ជារៀងរាល់ឆ្នាំជាទិវាចងកំហឹងចំពោះរបបប្រល័យពូជសាសន៍ប៉ុលពត ។

រដ្ឋសភាជាតិបានសម្រេចឲ្យប្រជាជនកម្ពុជាសាងសង់សិលាចារឹកនិងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះរបបប៉ុលពតដោយរៀបចំឲ្យបានល្អ ចាប់តាំងពីខេត្ត ក្រុង ស្រុក រហូតដល់មូលដ្ឋានឃុំ ។

យោងតាមសេចក្តីរៀបចំដូចពោលខាងលើព្រឹត្តិការណ៍អំឡុងឆ្នាំ១៩៧៥-៧៨ យើងខ្ញុំជាប្រជាជនក្នុងភូមិស្វាយធំសង្កាត់ទី២ទាំងមូល សូមឯកភាពទាំងស្រុងលើសេចក្តីសម្រេចចិត្តរបស់រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ សូមគោរពផ្ញើជូនការឯកភាពនេះចំពោះ ÷

- ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- ក្រុមប្រឹក្សាទូទាំងប្រទេស រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា

ពេលណាក៏ដូចជាពេលណាទាំងអស់ យើងខ្ញុំប្រជាជនតែងតែនឹកឃើញពីឧក្រិដ្ឋកម្មនៃរបបប៉ុលពតនេះមិនភ្លេច យើងខ្ញុំជាប្រជាជនចងកំហឹងឈឺចាប់ក្តៅឆេះ ពុះកញ្ជ្រោលឥតឈប់ឈរ ហើយសូមសច្ចាជាឱឡារិកថា ÷

ប្តេជ្ញាអនុវត្តចលនាបដិវត្តទាំងបីឲ្យបានដាច់ខាតគឺ ÷

១) វាយខ្ទាំងគ្រប់រូបភាពឲ្យអស់ពីទឹកដីកម្ពុជា ។

២) បង្កបង្កើនផលឲ្យបានខ្លាំងក្លានិងសម្រេចតាមផែនការដែលបក្សដាក់ចុះ ។

៣) ប្តេជ្ញាកសាងកម្លាំងពិតរបស់បដិវត្តឲ្យបានរឹងមាំ ។

ជាអវសានយើងខ្ញុំជាប្រជាជនភូមិស្វាយធំ សង្កាត់ទី២ទីរួមខេត្តកំពត សូមចូលរួមចំណែកក្នុងសកម្មភាពនេះ ហើយសូមអំពាវនាវដល់ប្រជាជននិងប្រទេសជាច្រើនលើសកលលោកដែលស្នេហាសន្តិភាពនិងយុត្តិធម៌ព្រមទាំងអង្គការអន្តរជាតិនានាដែលមានសុភវិនិច្ឆ័យមើលឃើញនូវរឿងពិតជាក់ស្តែងរបស់ប្រជាជនកម្ពុជា សូមជួយធ្វើអន្តរាគមន៍ប្រកបដោយកាយវិការសាមគ្គីភាពមិត្តភាព ជួយគ្នាទៅវិញទៅមកជាភាគរបដិវត្ត ធ្វើយ៉ាងណាបណ្តេញពួកក្បត់ជាតិ ប៉ុល ពត, អៀង សារី, ខៀវ សំផន ចេញពីអាសនៈអង្គការសហប្រជាជាតិ ហើយប្រគល់អាសនៈនោះមកឲ្យប្រជាជនកម្ពុជាវិញ ដើម្បីបង្ការនិងចៀសវាងអសន្តិសុខលើសកលលោក ។

ធ្វើនៅភូមិស្វាយធំ, ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៨៣

ហត្ថលេខាអ្នកតំណាងប្រជាជន

ញាន ស៊ាន

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ÷

- វិទ្យុ FM១០២MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ល្ងាច ។
- វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើងនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ផាត រចនា**

# ស្វែងរករូបថតជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្តាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ *FM102MHz* ទីក្រុងភ្នំពេញ វិទ្យុ *FM93.25MHz* ខេត្តកំពត វិទ្យុ *FM99MHz* ខេត្តព្រះវិហារ និងវិទ្យុ*FM* ១០៣.២៥*MHz* ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះយើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួនតែប៉ុណ្ណោះ ។ រូបថតទាំងនោះចាំបាច់ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នក បន្ទាប់មកនឹងប្រគល់រូបថតដើមជូនទៅលោកអ្នកវិញ ។


ក្រុមគ្រួសាររបស់ ខៀន នឿន

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញឬទាក់ទងតាមអ៊ីមែល truthpivoine@dccam.org ។

សូមអរគុណ ។

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៣១១ | ធីម ហេង ហៅ កើត | ប្រធានកងធំ | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ |
| ២៣១២ | កែ យឿន ហៅ យ៉េង | សមាជិកក្រុម | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ |
| ២៣១៣ | វ៉ា យុត | មេក្រុម | កងពល៤៥០ | ៥-៥-៧៧ | ៧-៥-៧៧ |
| ២៣១៤ | ដា ឈឿន ហៅ ឈាន | អនុក្រុម | កងពល៣១០ | ៥-៥-៧៧ | ៧-៥-៧៧ |
| ២៣១៥ | កន ដួង ហៅ ដឿន | សមាជិកក្រុម | កងពល៣១០ | ៥-៥-៧៧ | ៧-៥-៧៧ |
| ២៣១៦ | ស្រី ខុន ហៅ វែន | សមាជិកកងធំ | កងពល៣១០ | ៥-៥-៧៧ | ៧-៥-៧៧ |
| ២៣១៧ | វ៉ា កេន ហៅ គាម | យុទ្ធជន | កងពល៣១០ | ៥-៥-៧៧ | ៧-៥-៧៧ |
| ២៣១៨ | អ៊ី សុក | យុទ្ធជន | ស-២១យ | ៦-៥-៧៧ | ៧-៥-៧៧ |
| ២៣១៩ | ឡុង មេរិក (ស្រី) | យុទ្ធនារី | ស-២១យ | ៦-៥-៧៧ | ៧-៥-៧៧ |
| ២៣២០ | ចៅ វៀ (ស្រី) | យួន | ស-២១យ | ៦-៥-៧៧ | ៧-៥-៧៧ |
| ២៣២១ | សោម រី ហៅ រីន | យុទ្ធជន | កងពល៤៥០ | ៤-៥-៧៧ | ៧-៥-៧៧ |
| ២៣២២ | សូ រុំ ហៅ វ៉ាត | អនុនយោបាយ | កងពល៤៥០ | ៤-៥-៧៧ | ៧-៥-៧៧ |
| ២៣២៣ | យិន យូត ហៅ យឿន | ភ័ស្តុភារកងធំ | កងពល៤៥០ | ៤-៥-៧៧ | ៧-៥-៧៧ |
| ២៣២៤ | សែ សួ | យុទ្ធជន | កងពល៤៥០ | ២៨-៤-៧៧ | ៧-៥-៧៧ |
| ២៣២៥ | ម៉ៅ រ៉ឹម ហៅ ជុន | លេខាកងធំ | កងពល៤៥០ | ៣០-៤-៧៧ | ៧-៥-៧៧ |
| ២៣២៦ | ម៉ាន គង់ ហៅ អុល | អនុនយោបាយ | កងពល៤៥០ | ៣០-៤-៧៧ | ៧-៥-៧៧ |
| ២៣២៧ | ចាន់ នី ហៅ ហ៊ាង | លេខាកងធំ | កងពល៤៥០ | ៣០-៤-៧៧ | ៧-៥-៧៧ |
| ២៣២៨ | កែវ មុត ហៅ ឌឹម | អនុនយោបាយ | កងពល៤៥០ | ២-៥-៧៧ | ៧-៥-៧៧ |
| ២៣២៩ | ឡុង អឿន ហៅ អែម | សមាជិកមន្ទីរ | កងពល៤៥០ | ១-៤-៧៧ | ៧-៥-៧៧ |
| ២៣៣០ | ឡឹង ឌី ហៅ ថេន | យុទ្ធជន | ស-២១យ | ២-៥-៧៧ | ៧-៥-៧៧ |
| ២៣៣១ | ដួន តៃអ៊ី ហៅ ណូ | យុទ្ធជន១៣ | ស-២១យ | ២-៥-៧៧ | ៧-៥-៧៧ |
| ២៣៣២ | អ៊ុន លើង ហៅ ភឿន | យុទ្ធជន | ស-២១យ | ២-៥-៧៧ | ៧-៥-៧៧ |
| ២៣៣៣ | សួង ទឹម | អនុក្រុម | កងពល៣១០ | ២-៥-៧៧ | ៧-៥-៧៧ |
| ២៣៣៤ | ឡុង លឿន ហៅ ឡេន | អនុនយោបាយ | កងពល៣១០ | ២-៥-៧៧ | ៧-៥-៧៧ |
| ២៣៣៥ | ខ្ចុត សយ ហៅ ហាន | យុទ្ធជន | កងពល៣១០ | ២៨-៤-៧៧ | ៧-៥-៧៧ |
| ២៣៣៦ | ញឹម វ៉ាត ហៅ ឆៃ | យោធាកងធំ | កងពល៣១០ | ៣០-៤-៧៧ | ៧-៥-៧៧ |
| ២៣៣៧ | រី រុន ហៅ ភឿន | មេក្រុម | កងពល៣១០ | ៣០-៤-៧៧ | ៧-៥-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៣៣៨ | សន ម៉េង ហៅ កើត | យុទ្ធជនពេទ្យ | កងពល៣១០ | ២៨-៤-៧៧ | ៧-៥-៧៧ |
| ២៣៣៩ | ណែម សួន ហៅ ដាន | មេក្រុម | កងពល៣១០ | ២៨-៤-៧៧ | ៧-៥-៧៧ |
| ២៣៤០ | ទៀង មន ហៅ មឿន (ស្រី) | អនុប្រធានពេទ្យ | កងពល៣១០ | ២៨-៤-៧៧ | ៧-៥-៧៧ |
| ២៣៤១ | ឱត ឈឿន ហៅ ឈាន | លេខាកងធំ | កងពល៣១០ | ៣០-៤-៧៧ | ៧-៥-៧៧ |
| ២៣៤២ | សេក នឿន ហៅ ថា | យោធាកងតូច | កងពល៣១០ | ៣០-៤-៧៧ | ៧-៥-៧៧ |
| ២៣៤៣ | អោម គឿន ហៅ ហឿន | យុទ្ធជន | ស-២១ | ២២-៤-៧៧ | ៧-៥-៧៧ |
| ២៣៤៤ | រស់ ផាត ហៅ ហាន | សមាជិកមន្ទីរ | កងពល៣១០ | ២៥-១-៧៧ | ៧-៥-៧៧ |
| ២៣៤៥ | ឈឹម ស៊ីម ហៅ ពីន | សមាជិកមន្ទីរ | កងពល៣១០ | ២២-១-៧៧ | ៧-៥-៧៧ |
| ២៣៤៦ | សឹម ម៉ន ហៅ ហៃ (ស្រី) | មេក្រុមពេទ្យ | កងពល៣១០ | ២១-៤-៧៧ | ៧-៥-៧៧ |
| ២៣៤៧ | ទឹម យ៉ា ហៅ សឿន (ស្រី) | មេក្រុមពេទ្យ | កងពល៣១០ | ២១-៤-៧៧ | ៧-៥-៧៧ |
| ២៣៤៨ | កែវ អឿន (ស្រី) | មេក្រុមពេទ្យ | កងពល៣១០ | ២១-៤-៧៧ | ៧-៥-៧៧ |
| ២៣៤៩ | ប៊ុ រ៉ន ហៅ រ៉ុន (ស្រី) | មេក្រុមពេទ្យ | កងពល៣១០ | ២១-៤-៧៧ | ៧-៥-៧៧ |
| ២៣៥០ | ឆេង យ៉ន ហៅ រ៉ន (ស្រី) | កងហា | កងពល៣១០ | ២១-៤-៧៧ | ៧-៥-៧៧ |
| ២៣៥១ | ឆម លះ ហៅ ឡៃ (ស្រី) | ភ័ស្តុភារ | កងពល៣១០ | ៧-៥-៧៧ | ៧-៥-៧៧ |
| ២៣៥២ | លឹក ថៃ ហៅ ផាត | យោធាកងតូច | កងពល៤៥០ | ៧-៥-៧៧ | ៧-៥-៧៧ |
| ២៣៥៣ | យិត យ៉ុត ហៅ ផល | យុទ្ធជន | កងពល៤៥០ | ៧-៥-៧៧ | ៧-៥-៧៧ |
| ២៣៥៤ | វ៉ា ហៃ ហៅ វ៉ា | សមាជិកកងធំ | កងពល៤៥០ | ៧-៥-៧៧ | ៧-៥-៧៧ |
| ២៣៥៥ | យក់ មឿន ហៅ រី | សមាជិកកងធំ | កងពល៤៥០ | ៧-៥-៧៧ | ៧-៥-៧៧ |
| ២៣៥៦ | ឡាយ ឡេងហួ ហៅ ជួប | ស្លថ្នាំ | កសិកម្មរដ្ឋ | ១៧-១០-៧៦ | ១២-៥-៧៧ |
| ២៣៥៧ | ឈុន សុកផួន ហៅ សោម | គណៈដៃ | ដៃកំពង់សោម | ១៩-១០-៧៦ | ១២-៥-៧៧ |
| ២៣៥៨ | ម៉េន សាខន ហៅ ម៉ុល | សមាជិក | ពាណិជ្ជកម្ម | ២៣-១១-៧៦ | ១២-៥-៧៧ |
| ២៣៥៩ | ចេវ ឆុន ហៅ ម៉ុន | សមាជិក | កងពល៣១០ | ៩-៩-៧៦ | ១២-៥-៧៧ |
| ២៣៦០ | សោ ប៉េង ហៅ ហំ | លេខាវរសេនាធំ | តំបន់១០៦ | ២៧-១០-៧៦ | ១២-៥-៧៧ |
| ២៣៦១ | ឈឹម មាស ហៅ ហោះ | លេខាវរសេនាធំ | ភូមិភាគឧត្តរ | ១៤-១០-៧៦ | ១២-៥-៧៧ |
| ២៣៦២ | កើត វ៉ែម ហៅ ម៉ុម | ប្រធានពាណិជ្ជកម្មរដ្ឋ | ភូមិភាគឧត្តរ | ១១-៥-?? | ១២-៥-៧៧ |
| ២៣៦៣ | មាស សាមី | ជំនួយការ | កងពល៣១០ | ១១-១២-៧៦ | ១២-៥-៧៧ |
| ២៣៦៤ | ស៊ឹម ម៉េងលី ហៅ ឈី | គណៈសាលា | កងពល៣១០ | ១១-១២-៧៦ | ១២-៥-៧៧ |
| ២៣៦៥ | អ៊ុម អ៊ាន | អនុប្រធាន | រោងចក្រកែវ | ១៥-១១-៧៦ | ១២-៥-៧៧ |
| ២៣៦៦ | ណុប ឃុន ហៅ ភាព | បញ្ជាការ | ភូមិភាគឧត្តរ | ៨-១១-៧៦ | ១២-៥-៧៧ |
| ២៣៦៧ | អាន សេងហ៊ាង ហៅ ជុន | សមាជិក | កងពល៣១០ | ១២-១២-៧៦ | ១២-៥-៧៧ |
| ២៣៦៨ | ផាច់ តូណែត ហៅ យុទ្ធ | ជំនួយតំបន់ | តំបន់៥០៥ | ៣០-១០-៧៦ | ១២-៥-៧៧ |

**(នៅមានត)**

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

## ជ័យ ផុន


ជ័យ ផុន ឆ្នាំ១៩៦២

ជ័យ ផុន មានស្រុកកំណើតនៅឃុំព្រៃកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ ផុន អតីតជាគ្រូបង្រៀន ។ ផុន បានរក្សាទុករូបថត៥សន្លឹកដែលថតមុនឆ្នាំ១៩៧៥ ។ រូបថតទាំងនេះគឺជារូបថតសាច់ញាតិរបស់គាត់ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ ផុន បានផ្ញើរូបថតទាំង៥សន្លឹកមកមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីកត់ត្រារឿងរ៉ាវរបស់គាត់ទុកជាឯកសារប្រវត្តិសាស្ត្រ ។ ខាងក្រោមនេះគឺជាការរៀបរាប់របស់ ជ័យ ផុន ។

«បងប្រុសរបស់ខ្ញុំ២នាក់បួសរៀននៅវត្ត ហើយខ្ញុំក៏ទៅសំណាក់នៅវត្តជាមួយបងទាំងពីរតាំងពីអាយុ៩ឆ្នាំម្ល៉េះ ។ ក្រុមគ្រួសាររបស់ខ្ញុំក្រណាស់ ។ ឪពុកខ្ញុំស្លាប់នៅសម័យសង្គមរាស្ត្រនិយម ដោយសារជំងឺចាស់ជរា ដូច្នេះបន្ទុកគ្រួសារធ្លាក់ទៅលើម្តាយខ្ញុំតែម្នាក់គត់ ។ ម្តាយប្រកបមុខរបរលក់កន្ទេល ដូច្នេះគាត់គ្មានលទ្ធភាពគ្រប់គ្រាន់សម្រាប់ឲ្យ ពួកខ្ញុំបានរៀនសូត្រទេ ។

ខ្ញុំជាសិស្សពូកែ ។ ខ្ញុំតែងតែរៀនបានចំណាត់ថ្នាក់លេខ១ ឬលេខ២ជានិច្ច ។ ខ្ញុំរៀនពូកែផ្នែកគណិតវិទ្យានិងផ្នែកភាសាបារាំង ។ ដោយសារខ្ញុំរៀនពូកែ ដូច្នេះមានមិត្តភក្តិជាច្រើនមកនិយាយលេងជាមួយខ្ញុំ ។

ខ្ញុំរៀននៅសាលាបឋមសិក្សាព្រៃកតាមាក់ ក្រោយមកខ្ញុំផ្លាស់ទៅរៀននៅសាលាព្រែកឯង ។ ខ្ញុំក៏ប្រឡងជាប់ ហើយខ្ញុំមករៀនបន្តនៅសាលាគរុកោសល្យជាន់ខ្ពស់នៅទីក្រុងភ្នំពេញ ដែលមានលោក កេង វ៉ាន់សាក់ ជានាយកគ្រប់គ្រងទូទៅ និង លោក សុន សេន ជានាយកគ្រប់គ្រងផ្នែកសិក្សា ។ សុន សេន ស្អាតដូចកូនចៅចិន ។ គាត់ជាមនុស្សស្លូតបូត ។ ក្រោយពីរៀនចប់ ខ្ញុំបានទៅធ្វើជានាយកសាលានៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ នៅទីនោះ មានគ្រូបង្រៀនតិចណាស់ ។ ដូច្នេះខ្ញុំទទួលខុសត្រូវបង្រៀនសិស្សជាច្រើនថ្នាក់ ។

ខ្ញុំរៀបការនៅឆ្នាំ១៩៦២ ។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ប៉ុល យ៉ែម ត្រូវជាប្អូនជីដូនមួយរបស់ខ្ញុំ ។ ស្រុកកំណើតរបស់នាងនៅខាងឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ។ ក្រោយឆ្នាំ១៩៧៩ ប្រពន្ធរបស់ខ្ញុំស្លាប់បាត់បង់ជីវិតក្នុងអាយុ៥០ឆ្នាំ ដោយសារជំងឺប្រចាំកាយ ។


ប៉ុល យ៉ែម ឆ្នាំ១៩៦០

នៅឆ្នាំ១៩៦៧ ខ្ញុំបានផ្លាស់មកបង្រៀននៅសាលាបឋមសិក្សាព្រៃកតាមាក់វិញ ។ នៅអំឡុងពេលនោះ មានរឿងជ្រួលច្របល់តាមចាប់គ្រូបង្រៀនដែលឃោសនាពីរឿងខ្មែរក្រហម ។ គ្រូរបស់ខ្ញុំឈ្មោះ ឆេង វុន តែងឃោសនាពីរឿងខ្មែរក្រហមជារឿយៗ ប៉ុន្តែខ្ញុំមិនបានចូលរួមក្នុងចលនានេះទេ ។ ដោយសភាពការណ៍កាន់តឹងតែងឡើងៗនិងដោយមានការទម្លាក់គ្រាប់បែកផង ខ្ញុំនិងប្រពន្ធកូនបានសម្រេចចិត្តមករស់នៅទីក្រុងភ្នំពេញ ។ ខ្ញុំធ្វើជាអ្នកយាមនៅសាលាខេត្តកណ្តាល ។ នៅឆ្នាំ១៩៧៤ ខ្ញុំបានសុំផ្លាស់មកធ្វើជាគ្រូបង្រៀនកុមារនៅម្តុំជ្រោយចង្វារ ។ ខ្ញុំបានទិញផ្ទះមួយខ្នងនៅទីនោះ ហើយបានទិញកីតម្បាញមួយនិងឧបករណ៍ផ្សេងៗ ដើម្បីឲ្យប្រពន្ធខ្ញុំត្បាញមុងនិងកន្ទេលលក់ ។

នៅឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះលើរបបលន់នល់ មានការស្រែកប្រកាសតាមមីក្រូថា «យើងឈ្នះហើយ យើងបានសុខសប្បាយហើយ លែងមានសង្គ្រាមអីទៀតហើយ» ។ ពេលនោះខ្ញុំមានបំណងវិលមកស្រុកកំណើតវិញ ។ នៅតាមផ្លូវ កងទ័ពខ្មែរក្រហមបានឲ្យអង្ករមួយតៅ

ដល់ក្រុមគ្រួសាររបស់ខ្ញុំ ។ ខ្ញុំបានស្នាក់នៅម៉ុំបាក់ខែង ។ នៅទីនោះខ្ញុំបានទៅរកត្រីខ្លះដើម្បីមកផ្គត់ផ្គង់ក្រុមគ្រួសាររបស់ខ្ញុំ ។ ក្រោយមកទើបអង្គការជម្លៀសខ្ញុំបន្តទៅស្រុកកំណើតរបស់ខ្ញុំនៅស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

ពេលខ្ញុំធ្វើដំណើរមកដល់ភូមិកំណើត ប្រជាជនទាំងអស់គ្នានៅទីនោះបានដឹងថាខ្ញុំធ្លាប់ធ្វើគ្រូពីមុនមក ហើយប្រធានសហករណ៍ក៏បានសួរនាំខ្ញុំអំពីការងាររបស់ខ្ញុំពីមុនមកដែរ ។ ខ្ញុំឆ្លើយប្រាប់តាមត្រង់ថា ខ្ញុំធ្លាប់ធ្វើគ្រូបង្រៀននិងចេះនេសាទត្រី ។ ប្រធានសហករណ៍រូបនោះ ចាត់តាំងឲ្យខ្ញុំធ្វើការក្នុងក្រុមនេសាទត្រីដែលមានសមាជិក៣នាក់ ។ ប្រសិនបើខ្ញុំប្រាប់គេថាខ្ញុំធ្លាប់កាន់កាំភ្លើងយាមកាមនៅតាខ្មៅ ខ្ញុំប្រហែលត្រូវអង្គការសម្លាប់ហើយ ។ ខ្ញុំរស់នៅជាមួយប្រជាជនចាស់ ប៉ុន្តែប្រជាជនចាស់មិនពេញចិត្តចំពោះខ្ញុំឡើយ ។ អ្នកទាំងនោះមើលងាយខ្ញុំថាជាប្រជាជន១៧មេសា ។ អង្គការជ្រើសរើសអ្នកមិនចេះអក្សរឲ្យមកធ្វើជាអ្នកដឹកនាំអ្នកមានចំណេះវិជ្ជា ។ ក្រោយមកដោយសារខ្ញុំចេះធ្វើការងារជាច្រើនមុខដូចជា ស្ទូងស្រូវ ដកសំណាប នេសាទត្រី ជួសជុលមង ចាក់ថ្នាំ និងចេះកូតទ្រ អ្នកទាំងនោះក៏ស្រឡាញ់រាប់អានខ្ញុំវិញ ។

ជារៀងរាល់យប់ គណៈសហករណ៍ហៅខ្ញុំទៅកូតទ្រ និងលេងកម្សាន្តជាមួយក្រុមភ្លេងផងទៃទៀត ។ បទចម្រៀងដែលខ្ញុំតែងតែយកមកកូតមានចំណងជើងថា "យុទ្ធជនយុទ្ធនារីជួសជុលផ្លូវដែក" ។ បទនេះខ្ញុំតែងតែច្រៀងតាមមីក្រូនៅពេលហូបបាយល្ងាច ។ ខ្ញុំបានយកចម្រៀងទាំងនោះមកហាត់កូតជាបទភ្លេង ។ ពេលលេងភ្លេងម្តងៗ ឈ្លបឲ្យថ្នាំជក់ខ្ញុំ ។ ប្រពន្ធរបស់ខ្ញុំត្រូវអង្គការចាត់តាំងឲ្យធ្វើការខាងក្រុមស្ទូងស្រូវ ដកសំណាបនៅក្នុងសហករណ៍ ។ ប្រពន្ធខ្ញុំលំបាកណាស់ ទាំងការងារនិងការហូបចុក ។ ពេលខ្លះខ្ញុំលួចយកត្រីដែលនេសាទបានមកដុត ហើយខ្ចប់លាក់ទុកនៅក្នុងហោប៉ៅយកមកផ្ញើប្រពន្ធខ្ញុំនៅឯផ្ទះ ។ ខ្ញុំមិនអាចយកត្រីដែលខ្ញុំនេសាទបានមកហូបទេ ពីព្រោះប្រសិនបើអង្គការដឹង ខ្ញុំពិតជាស្លាប់ ។

ខ្ញុំចែវទូកកាត់រលកដងខ្យល់ផងទៅនេសាទត្រី ។ ទោះបីជាចង់ឬមិនចង់ក៏ខ្ញុំត្រូវតែទៅដែរ ។ ខ្ញុំឮសូរមនុស្សធ្លាក់ទឹកដោយការប្រានទម្លាក់ពីលើច្រាំង ។ នៅមុនពេលប្រានទម្លាក់ ខ្ញុំឮសំឡេងមនុស្សស្រែកទ្រហោយំ ។ គាលនំ អ្នកនេសាទត្រីជាមួយខ្ញុំបានប្រាប់ខ្ញុំថា ពេលខ្លះគាត់លើកឈ្នាងត្រីមកឃើញជាប់សាកសពមនុស្ស ។ ជួនកាលពេលខ្ញុំកំពុងតែហូបបាយនៅមាត់ច្រាំង ក៏ឃើញសាកសពអណ្តែតមកក្បែរ ។

ជារៀងរាល់យប់ ឈ្លបយកមនុស្សទៅបាត់ៗ ។ ខ្ញុំមិនដែលបានដេកលក់ស្រួលទេ ។ ខ្ញុំចេះតែភិតភ័យ មិនដឹងជាដល់វេនអ្នកណាឡើយ ។ អង្គការចង់យកខ្ញុំទៅរៀនសូត្រជាច្រើនដង ប៉ុន្តែអ្នកភូមិបានសុំអង្គការកុំឲ្យយកខ្ញុំទៅអី ព្រោះខ្ញុំមិនដែលមានទំនាស់ជាមួយអ្នកណាឡើយ ខ្ញុំដឹងថា បើខ្ញុំទៅរៀនសូត្រ ខ្ញុំពិតជាស្លាប់ ។

នៅឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយរំដោះ កងទ័ពខ្មែរក្រហមបានឲ្យខ្ញុំចែវទូកចម្លងទៅត្រើយម្ខាងទៀតទាំងយប់ដើម្បីគេចខ្លួន ។ ខ្ញុំមិនហ៊ានប្រកែកតវ៉ាឡើយ ពីព្រោះអ្នកទាំងនោះមានកាន់កាំភ្លើងគ្រប់ដៃ ។ ខ្ញុំបានត្រៀមពូថៅមួយដាក់ជាប់នឹងខ្លួនដើម្បីការពារខ្លួនពេលមានអាសន្ន ។ ប៉ុន្តែអ្នកទាំងនោះមិនបានធ្វើបាបខ្ញុំទេ ។

ខ្ញុំមានកូន៨នាក់ សព្វថ្ងៃនៅរស់៥នាក់ ។ កូនស្រី៣នាក់បានស្លាប់ ក្នុងនោះកូនម្នាក់អាយុ៥ឆ្នាំស្លាប់ដោយសាររលាកភ្លើង ។ កាលណោះប្រពន្ធរបស់ខ្ញុំធ្វើឲ្យឆាបភ្លើងចង្កៀងបណ្តាលឲ្យឆេះផ្ទះ ប៉ុន្តែពន្លត់បានវិញ ។



(រូបពីឆ្វេងទៅស្តាំ៖ ជ័យផន, ជ័យស្បាន, ជ័យ ដាន់ និងជ័យ ផុន ក្នុងឆ្នាំ១៩៥៧

រូបថតមួយសន្លឹកនេះ បងប្អូនខ្ញុំថតជុំគ្នាទុកជាអនុស្សាវរីយ៍ ។ រូបទី១ខាងឆ្វេងដៃ គឺជាបងប្រុសទី២របស់ខ្ញុំឈ្មោះ ជ័យ ផន ក៏ជាអ្នករៀនចេះដឹងបានជ្រៅជ្រះម្នាក់ ។ បន្ទាប់ពីបញ្ចប់ការសិក្សានៅស្រុកមុខកំពូល គាត់ចូលបម្រើការជាប៉ូលិសនៅដីឥដ្ឋ ។ មួយឆ្នាំក្រោយមក គាត់ប្រឡងចូលរៀនផ្នែកពេទ្យ ហើយមកធ្វើការនៅមន្ទីរពេទ្យព្រះកេតុមាលានៅទីក្រុងភ្នំពេញ ។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារគាត់មកស្រុកកំណើត ប៉ុន្តែគាត់រស់នៅទីនោះបានតែរយៈពេល១ឆ្នាំ អង្គការក៏ជម្លៀសក្រុមគ្រួសារគាត់ទៅរស់នៅខេត្តបាត់ដំបងទៀត ។ ក្រុមគ្រួសាររបស់គាត់បានស្លាប់ជាបន្តបន្ទាប់ ដោយសារគ្មានអាហារបរិភោគគ្រប់គ្រាន់ ។ ចំណែករូបទី២គឺបង ជ័យ ស្បោង អតីតធ្វើអាចារ្យនៅវត្តសុវត្ថិ ។ គាត់ស្លាប់នៅឆ្នាំ១៩៩៧ ដោយបាក់កម្លាំង ។ រូបទី៣គឺបង ជ័យ ផាន ហៅ ស យន ពីមុនធ្វើការនៅក្រសួងកសិកម្ម ។ គាត់ស្លាប់នៅក្នុងរបបខ្មែរក្រហម ។ រូបទី៤ គឺរូបខ្ញុំ ។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំលាក់រូបថតទុកនៅក្នុងបាវ ។ ឈ្លបខ្មែរក្រហមបានមកឆែកឆេររកដែរ ប៉ុន្តែរកមិនឃើញ ។ ឈ្លបឆែកយកបានតែសៀវភៅប៉ុណ្ណោះ ។ ខ្ញុំក៏បានលាក់ទុកសៀវភៅធម៌បានខ្លះដែរ ។ រូបថតមួយសន្លឹកទៀតដែលខ្ញុំថតម្នាក់ឯង គឺខ្ញុំថតក្រោយពេលខ្ញុំរៀបការហើយ ខ្ញុំថតនៅម្តុំតាខ្មៅ ។ រូបថតប្រពន្ធខ្ញុំមួយនេះ នាងថតកាលនៅជាសិស្ស ។»

◆◆◆

## ឈុន យឿន
## អតីតអ្នកលក់ដូរ

ឈុន យឿន ជាកូនកសិករក្រនៅភូមិអន្លង់គង ឃុំព្រៃស សង្កាត់ដង្កោរាជធានីភ្នំពេញ ។ សព្វថ្ងៃ យឿន រស់នៅជាមួយកូនស្រី២នាក់និងចៅ៧ ។ ប្តីនិងសាច់ញាតិដទៃទៀតរបស់គាត់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ខាងក្រោមនេះជារឿងរ៉ាវរបស់ យឿន ៖

«ខ្ញុំមានប្តីពីរ ប្តីទី១ ខ្ញុំបានលែងលះគ្នា ដោយសារតែគាត់និងខ្ញុំមានគំនិតមិនចុះសម្រុងគ្នា ។ ខ្ញុំបានរស់នៅជាមួយប្តីទីពីរ


ឈុន យឿន
ទសវត្សរ៍ឆ្នាំ១៩៦០

ខ្ញុំរហូតដល់ខ្មែរក្រហមចាប់គាត់យកទៅសម្លាប់ចោល ។

ប្តីខ្ញុំទាំងពីរសុទ្ធសឹងតែជាសាច់ញាតិរបស់ខ្ញុំ ។ ពួកខ្ញុំរៀបការតាមការផ្សំផ្គុំរបស់ចាស់ទុំ ។ ប្តីទី១រស់នៅក្នុងភូមិជាមួយខ្ញុំដែរ ។ គាត់ធ្វើស្រែនិងចម្ការ ។ ក្រោយពេលរៀបការហើយគាត់ទៅជួយលក់នំចិននៅហាងមួយម្តុំផ្សារអូរឫស្សី ដោយទទួលបានប្រាក់កម្រៃ១ខែ១.៣០០រៀល ។ ចំណែកខ្ញុំនៅធ្វើស្រែនិងចម្ការ ។ រយៈពេល៩ខែដែលខ្ញុំរស់នៅជាមួយគាត់ គាត់មិនដែលប្រគល់ប្រាក់ខែរបស់គាត់ឲ្យខ្ញុំរក្សាទុកទេ ។ ក្រោយមក ខ្ញុំក៏សម្រេចចិត្តលែងលះគាត់ ។

មួយឆ្នាំក្រោយខ្ញុំបានរៀបការម្តងទៀត ជាមួយបុរសម្នាក់ឈ្មោះម៉ាក ទុន ដែលជាសាច់ញាតិរបស់ខ្ញុំដែរ ។ ដំបូងឡើយគាត់ជាអ្នកបួសរៀននៅវត្តកាកខ្សាច់ ។ ក្រោយមក គាត់ក៏សឹកពីនេនមកប្រកបរបរធ្វើស្រែ ហើយចូលស្តីដណ្តឹងខ្ញុំរៀបការ ។ គាត់គឺជាបុរសសង្ហាហើយចិត្តល្អ ប៉ុន្តែមិនបានរៀនសូត្រជ្រៅជ្រះទេ ។ មុនពេលរៀបការយើងទាំងពីរនាក់ក៏ធ្លាប់ស្គាល់គ្នាដែរ ។ ចាស់ទុំទាំងសងខាងបានផ្សំផ្គុំយើង ប៉ុន្តែពេលនោះខ្ញុំក៏មានសិទ្ធិសម្រេចចិត្តថាតើត្រូវជ្រើសរើសយកគាត់ឬក៏អត់ មិនដូចកាលពីលើកមុនឡើយ ។


ម៉ាក់ ទុន
ទសវត្សរ៍ឆ្នាំ១៩៦០

ខ្ញុំមិនបានរៀនសូត្រអ្វីជ្រៅជ្រះទេ ដោយសារតែជីវភាពក្រុមគ្រួសារខ្ញុំមានការខ្វះខាត ។ ឪពុកម្តាយខ្ញុំគ្មានលទ្ធភាពគ្រប់គ្រាន់សម្រាប់ឲ្យបងប្អូនខ្ញុំទាំងបីនាក់បានចូលសាលារៀនឡើយ ។ ម្យ៉ាងទៀត ម្តាយរបស់ខ្ញុំបានស្លាប់ចោលតាំងពីខ្ញុំនៅតូចៗ ចំណែកឪពុករបស់ខ្ញុំក៏បានរៀបការប្រពន្ធមួយទៀត ។ ពេលអាយុ១៥ឆ្នាំ ខ្ញុំបានចូលរៀនវគ្គអក្ខរកម្មនៅក្នុងភូមិរបស់ខ្ញុំ ។ ក្នុងចំណោមសិស្សប្រមាណ២០នាក់ ខ្ញុំរៀនពូកែជាងគេ ។ ខ្ញុំរៀនវគ្គនេះបានតែមួយឆ្នាំ ក៏ឈប់រៀនហើយរៀបការ ។

បន្ទាប់ពីរៀបការជាមួយប្តីទី២ ខ្ញុំបានធ្វើនំយកទៅលក់នៅទីក្រុងភ្នំពេញ មានដូចជា នំត្នោតនិងត្រប៉ែជាដើម ។ ចំណែកប្តីរបស់ខ្ញុំរត់កង់ឌុបនិងធាក់ស៊ីក្លូនៅភ្នំពេញ ។ ពេលខ្លះគាត់ត្រឡប់មកផ្ទះវិញនៅពេលល្ងាច ពេលខ្លះទៀត១អាទិត្យទើបគាត់មកផ្ទះម្តង ។

នៅក្នុងរបបលន់នល់ ភូមិរបស់ខ្ញុំត្រូវកងទ័ពខ្មែរក្រហមកាន់កាប់ ។ ភូមិរបស់ខ្ញុំរងការទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ធ្ងរដោយសារចម្បាំងរវាងទាហានលន់នល់និងកងទ័ពខ្មែរក្រហម ដែលធ្វើឲ្យប្រជាជនមិនអាចរស់នៅបាន ។ ក្រុមគ្រួសាររបស់ខ្ញុំនិងប្រជាជននៅក្នុងភូមិបានភៀសខ្លួនទៅរស់នៅថ្នល់បត់ម្តុំចម្ការដូង នៅទីនោះប្តីខ្ញុំធ្វើកូនខ្ទមមួយ ដែលអាចដាក់បានតែគ្រែដេកមួយប៉ុណ្ណោះ ។ ខ្ញុំរស់នៅទីនោះអស់រយៈពេល៣ឆ្នាំ ។ ប្តីរបស់ខ្ញុំឈប់រត់កង់ឌុបនិងធាក់ស៊ីក្លូ ហើយគាត់មកជួយលក់ទឹកត្នោតនៅផ្ទះនិងធ្វើស្រែនៅក្បែរផ្ទះវិញ ។ យើងមានកូន១នាក់ ។

ពេលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ កូនទី២របស់ខ្ញុំទើបតែកើតបាន១ខែប៉ុណ្ណោះ ។ ភ្នែករបស់ខ្ញុំខ្វាក់មាន់ទៀត ខ្ញុំបីកូនដើរទាំងភ្នែកមើលមិនសូវច្បាស់ ។ ប្តីរបស់ខ្ញុំរៀបចំស្រូវអង្ករនិងរបស់របរបន្តិចបន្តួចដាក់លើរទេះគោ ។ ពេលនោះមានកងទ័ពស្លៀកពាក់ខ្មៅមានស្ពាយកាំភ្លើងមកដេញប្រជាជនឲ្យចេញ ។ ក្រុមគ្រួសារខ្ញុំត្រូវបានជម្លៀសទៅដល់ទីរួមស្រុកកណ្តាលស្ទឹង ប៉ុន្តែឈ្លបបានដេញពួកខ្ញុំឲ្យទៅរស់នៅឃុំសៀមរាបវិញ ។ ពេលទៅដល់ប្តីរបស់ខ្ញុំបានរៀបចំប្រក់ក្រណាត់កៅស៊ូជាកូនខ្ទមមួយស្នាក់នៅបណ្តោះអាសន្ន ។ ៤-៥ខែក្រោយមកទើបប្តីខ្ញុំរកបានស្លឹកត្នោតមកប្រក់ធ្វើផ្ទះ ។ រយៈពេលមួយឆ្នាំទើបក្រុមគ្រួសារខ្ញុំបានផ្ទះនៅស្រួលបួល ។ អង្គការបានដកហូតអង្ករដែលខ្ញុំយកទៅតាមខ្លួនមកដាក់ជារបស់រួម ហើយបែងចែកឲ្យវិញម្នាក់បានអង្ករ១ខាំក្នុង១ថ្ងៃ ចំណែកម្ហូបអាហារត្រូវរកដោយខ្លួនឯង ។ យើងហូបមិនឆ្អែតទេ ។ ពេលខ្លះខ្ញុំដើររកត្រកួនដើមចេក ព្រលិត និងគល់ល្ហុង ដើម្បីយកមកហូប ។ កន្លះឆ្នាំក្រោយមក អង្គការចាត់តាំងឲ្យហូបបបររួមក្នុងសហករណ៍ ។ ខ្ញុំទទួលបានបបរតែ១វែកប៉ុណ្ណោះក្នុងមួយពេល ។ អង្គការបានបែងចែកក្រុមគ្រួសារខ្ញុំឲ្យកាប់ឆ្ការព្រៃដើម្បីធ្វើស្រែ ។ ប្តីរបស់ខ្ញុំធ្វើការនៅខាងកងភ្ជួរ ។ ចំណែកខ្ញុំដាំបបរឲ្យជ្រូកនិងដកស្ទូង ។ ពេលខ្លះខ្ញុំស្ទូងទាំងថ្ងៃទាំងយប់ ស្ទើរតែគ្មានពេលសម្រាក ។ អង្គការហៅប្រជាជនទៅប្រជុំជីវភាពនៅរៀងរាល់ថ្ងៃទី១០ ទី២០ និងទី៣០ ដើម្បីនិយាយពីរឿងធ្វើការមានភាពស្មើគ្នា សម្រុកធ្វើស្រែនិងចម្ការឲ្យបានហូបគ្រប់គ្រាន់និងទាន់ពេលវេលា ។ ពេលប្រជុំម្តងៗត្រូវចំណាយអស់ពេលវេលាពេញមួយថ្ងៃ ។ ខ្ញុំសម្រាកបានតែពេលបាយថ្ងៃត្រង់ទេ ។ ខ្ញុំចេះតែឆ្ងល់ក្នុងចិត្តថា ស្រូវដែលធ្វើបានយកទៅដាក់ពេញៗជង្រុក ហេតុអ្វីប្រជាជននៅតែហូបមិនឆ្អែតទៀត តើស្រូវនោះដឹកយកទៅណា?

នៅទីនោះក្រុមគ្រួសារខ្ញុំរស់នៅលាយឡំជាមួយប្រជាជនមូលដ្ឋាន ។ ប្រជាជនថ្មីគ្មានសិទ្ធិនិយាយរកគ្នាទេ ។ សូម្បីតែខ្ញុំដើរទៅធ្វើស្រែជួបប្តីរបស់ខ្ញុំនៅតាមផ្លូវក៏ខ្ញុំមិនហ៊ានមើលមុខគ្នាដែរ ។ មានពេលមួយខ្ញុំឈឺគ្រុនញាក់ ហើយដេកព្យាបាលនៅមន្ទីរពេទ្យឃុំសៀមរាប ។ អង្គការមិនអនុញ្ញាតឲ្យប្តីខ្ញុំមកមើលថែរក្សាខ្ញុំទេ ។ ពេទ្យឲ្យតែថ្នាំអាចម៍ទន្សាយនិងឫសឈើបន្តិចបន្តួចសម្រាប់ដាំទឹកផឹក ។ ចំណែកអាហារគឺមានតែសម្លព្រលិតនិងត្រកួនដែលមានទឹកខ្មៅកខ្វក់មិនគួរឲ្យចង់ហូប ។

ប្រសិនបើនរណាម្នាក់ខ្ជិលធ្វើការងារ ប្រធានក្រុមនឹងរាយ-ការណ៍ទៅអង្គការលើ ហើយអង្គការនឹងយកអ្នកនោះទៅសម្លាប់ចោលនៅពេលយប់ ។ ខ្ញុំមិនដែលធ្វេសប្រហែសនឹងការងារទេ ។ បើមិនដូច្នេះទេ ខ្ញុំពិតជាត្រូវស្លាប់ ។ មានគ្រួសារមួយនៅក្បែរផ្ទះខ្ញុំនិងធ្លាប់ស្ទូងជាមួយខ្ញុំ ត្រូវឈ្លបហៅយកទៅបាត់នៅពេលយប់ ។ មុនពេលគាត់បាត់ខ្លួន គាត់បានតវ៉ាអំពីការហូបមិនគ្រប់គ្រាន់និងសួរថាស្រូវដែលធ្វើបានមិនដឹងជាយកទៅកន្លែងណាខ្លះ ។ អង្គការចាប់គាត់និងប្តីយកទៅជាបន្តបន្ទាប់ ចំណែកកូនត្រូវអង្គការយកទៅដាក់នៅក្នុងកងកុមារ ។ ថ្ងៃមួយ ដោយខ្ញុំឃ្លានខ្លាំងពេក ខ្ញុំបានទៅលួចកាស់ទំពាំងយកមកហូប អង្គការតាមទាន់ចាប់ខ្ញុំយកទៅកសាង ហើយព្រមានថា ថ្ងៃក្រោយកុំលួចទំពាំងដែលជារបស់សមូហភាពទៀត អង្គការមានឲ្យហូបគ្រប់គ្រាន់ហើយ ។

ប្តីទី២របស់ខ្ញុំត្រូវអង្គការហៅឲ្យទៅកាប់ព្រៃនៅឆ្នាំ១៩៧៧ ហើយក៏បាត់ខ្លួនរហូត ។ ក្រោយមក ខ្ញុំបានទទួលដំណឹងថា គាត់

ត្រូវបញ្ជូនទៅដាក់ក្នុងគុកសង់នៅខេត្តកណ្ដាល ។ មុនពេលអង្គការហៅគាត់ទៅ ខ្ញុំមិនបាននៅជាមួយគាត់ទេ ព្រោះខ្ញុំធ្វើការនៅការដ្ឋានផ្សេងពីគាត់ ប៉ុន្តែពេលដែលខ្ញុំត្រឡប់មកផ្ទះវិញ អ្នកជិតខាងខ្សឹបប្រាប់ខ្ញុំថា ប្ដីខ្ញុំត្រូវអង្គការហៅទៅបាត់ហើយ ។

មុនពេលមានរឿងនេះកើតឡើង ប្រធានក្រុមខាងធ្វើស្រែឈ្មោះ ជឿន បានមកសុំដូរគោគ្នាជាមួយប្ដីរបស់ខ្ញុំ ប៉ុន្តែគាត់មិនព្រម ។ ប្ដីខ្ញុំនិយាយថា ដូរធ្វើអីគោដូចតែគ្នាហ្នឹង ។ តាមការពិតគោនោះគឺជារបស់ពួកខ្ញុំដែលយកមកពីផ្ទះនៅពេលជម្លៀសចេញពីភ្នំពេញ ។ អង្គការចោទប្រកាន់ប្ដីខ្ញុំថាជាទាហានពាក់ស័ក្តិ៥ ។ មួយខែបន្ទាប់មក អង្គការបានហៅគាត់និងយុវជនដែលនៅក្នុងភូមិក្បែរគ្នា ប្រមាណ៨០នាក់ ទៅកាប់ឈើ ។ ម៉ោង៧ព្រឹក ឈ្លបពីរនាក់បណ្ដើរគាត់និងយុវជនទាំងនោះចេញពីភូមិ ។ ខ្ញុំចេះតែរង់ចាំមើលផ្លូវគាត់ត្រឡប់មកវិញ ប៉ុន្តែប្រធានក្រុមប្រាប់ខ្ញុំថា កុំបារម្ភអី រយៈពេលតែ៩ខែ១០ថ្ងៃទេ ប្ដីខ្ញុំនឹងវិលត្រឡប់មកវិញហើយ ។ ខ្ញុំបន់ឲ្យតែដល់ថ្ងៃនោះ ដើម្បីបានជួបមុខគាត់ ។ ប៉ុន្តែខ្ញុំនៅតែមិនឃើញគាត់ត្រឡប់មកវិញសោះ ។ អ្នកធ្វើការនៅទីនោះលួចខ្សឹបប្រាប់ខ្ញុំថា៩ខែ១០ថ្ងៃ គឺមានន័យថាប្ដីខ្ញុំស្លាប់ ហើយកើតសាជាថ្មីម្ដងទៀត ។ មានស្រីម្នាក់ដែលប្ដីរបស់គាត់ត្រូវខ្មែរក្រហមហៅទៅដែរ ប្រាប់ខ្ញុំថា ឃើញឈ្លបបណ្ដើរប្ដីខ្ញុំទៅគុកសង់ អ្នកដែលបញ្ជូនទៅគុកសង់កម្រនឹងបានរស់រានមានជីវិតណាស់ ។ ខ្ញុំបាត់ដំណឹងប្ដីខ្ញុំតាំងពីពេលនោះមក ។ ស្ត្រីដែលធ្វើការជាមួយខ្ញុំ ភាគច្រើនជាស្ត្រីមេម៉ាយដោយសារអង្គការហៅប្ដីរបស់គាត់ទៅកាប់ព្រៃកាប់ឬស្សីនិងកាប់ស្លឹក ។

អង្គការបានសួរពួកខ្ញុំថា តើមានអ្នកណាចង់ត្រឡប់ទៅស្រុកភូមិកំណើតវិញទេ ។ ខ្ញុំនិយាយថា ខ្ញុំចង់ទៅ ។ អ្នកនៅទីនោះបានប្រាប់ខ្ញុំថា កុំទៅអី រស់នៅទីណាក៏ដូចជាទីណាដែរ គឺមានអង្គការដូចតែគ្នា ។

រូបថតរបស់ខ្ញុំនិងប្ដីខ្ញុំមានច្រើនសន្លឹក ប៉ុន្តែសាច់ញាតិរបស់ខ្ញុំចេះតែមកសុំម្នាក់មួយសន្លឹកពីរសន្លឹកយកទៅ ។ សព្វថ្ងៃខ្ញុំនៅសល់តែរូបថតពីរសន្លឹកទេ ។ ប្ដីខ្ញុំថតពេលដែលគាត់ទើបតែសឹកពីនេន ចំណែករូបថតរបស់ខ្ញុំគឺថតនៅពេលដែលខ្ញុំរៀនអក្សរកម្ម ហើយទទួលបានចំណាត់ថ្នាក់លេខ១ ។ ខ្ញុំថតរូបនេះដើម្បីយកទៅបិទកាត ។ ពេលជម្លៀសចេញពីទីក្រុងភ្នំពេញខ្ញុំបានយករូបថតទាំងនេះទៅជាមួយ ហើយលាក់ទុកនៅក្នុងបង្កេចខោអាវ ។ ពេលខ្ញុំចេញទៅធ្វើការនៅការដ្ឋាន ឈ្លបតែងតែមកឆែកឆេរផ្ទះរបស់ខ្ញុំ ពីព្រោះពេលខ្ញុំត្រឡប់មកពីធ្វើការវិញ ឃើញរបស់របរនៅរាយប៉ាយពេញផ្ទះ ប៉ុន្តែខ្ញុំអត់មានបាត់រូបថតទេ ។ ក្រោយពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានយករូបថតនេះត្រឡប់មកផ្ទះនៅឯភូមិវិញ ប៉ុន្តែផ្ទះខ្ញុំត្រូវរងនូវខូចខាតយ៉ាងធ្ងន់ធ្ងរ ។ រហូតមកដល់សព្វថ្ងៃនេះ ខ្ញុំនៅតែនឹកឃើញប្ដីខ្ញុំជានិច្ច ។ ខ្ញុំគិតថាគាត់ស្លាប់បាត់ហើយ ។ នៅពេលមានពិធីបុណ្យទានម្ដងៗ ខ្ញុំតែងតែធ្វើម្ហូបអាហារយកទៅវត្តដើម្បីឧទ្ទិសកុសលផលបុណ្យឲ្យគាត់ជានិច្ច ។ ខ្ញុំសោកស្ដាយដែលមិនបានជួបមុខគាត់ជាលើកចុងក្រោយ ។ ខ្ញុំសង្ឃឹមថានឹងមានតុលាការយុត្តិធម៌មួយដើម្បីស្វែងរកខុសរកត្រូវឲ្យប្ដីរបស់ខ្ញុំ ។» ◆◆◆

# អែម ផល

អែម ផល និង សា សុន គឺជាប្ដីប្រពន្ធ ហើយត្រូវខ្មែរក្រហមចាប់ខ្លួន និងសម្លាប់នៅគុកទួលស្លែង ។ អ្នកទាំងពីរបានបន្សល់ទុកនូវប្រវត្តិរូបនិងចម្លើយសារភាព ។ សុន មានស្រុកកំណើតនៅស្រុកស្វាយរៀង តំបន់២៤ ។ មុនពេលរំដោះ សុន ជាវិស្វករអស្សាណូ កម្មសិទ្ធិករខ្សែភាពយន្តនៅក្រសួងឃោសនាការ ។ សុន ត្រូវបានឃាត់ខ្លួននៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៥ នៅភូមិសំរោងទី ហៅភូមិថ្មី និងបញ្ជូនទៅផ្ទះក-០៥ បន្ទប់លេខ៩ និងគុកទួលស្លែងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៦ ។ ចម្លើយសារភាពរបស់ សា សុន បានកត់ត្រាថា សុន ត្រឡប់ពីប្រទេសបារាំងចូលមកប្រទេសកម្ពុជាវិញនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧២ និងចាប់មកពីតំបន់២២ ។ សុន បានសារភាពថា គាត់បានចូលបម្រើសេ.អ៊ី.អា នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៤ ។ ចម្លើយសារភាពរបស់គាត់បានបញ្ចប់នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៧៥ ។

អែម ផល មុនរំដោះធ្វើទាហាន និងក្រោយរំដោះធ្វើស្រែ ។ ផល មានកូនប្រុសម្នាក់ ។ ផល ត្រូវបានចាប់ខ្លួននៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៥ នៅរកាកោង (តំបន់២២) ហើយ

យកមកឃុំខ្លួននៅផ្ទះក-០៦ បន្ទប់ធំលេខ៨ ។ នៅលើប្រវត្តិរូបរបស់ អែម ផល មានចំណារ ឌុច ចារថា «ស្នើជួយបញ្ជាក់ភិនភាគនិងអាសយដ្ឋានបច្ចុប្បន្នដើម្បីចាប់ និងជួយបំពេញលិខិតរាយការណ៍អំពីករណីឯកជនម្នាក់ដែលគិញឆ្លើយដាក់» ។ អែម ផាន ដែលត្រូវជាប្អូនរបស់ អែម ផល បានរំឭកឡើងវិញថា÷

«ខ្ញុំមានបងប្អូនទាំងអស់៦នាក់ គឺស្រី៤នាក់និងប្រុស២នាក់ ។ បងផល ស្អាតណាស់ រូបរាងខ្ពស់ក្នុងចំណោមបងប្អូនស្រី៤នាក់ ។ គាត់ជាកូនស្រីទី២និងជាកូនដែលម៉ែស្រលាញ់ជាទីបំផុត ។ ក្នុងចំណោមបងប្អូនទាំងអស់ មានតែខ្ញុំម្នាក់គត់ដែលរួចផុតពីសេចក្តីស្លាប់ពីរបបខ្មែរក្រហម ។



(រូបពីឆ្វេងទៅស្តាំ) អែម ផល និងមិត្តភក្តិ ឆ្នាំ១៩៧២

ពេលដែល បងផល នៅក្មេងគាត់រៀននៅសាលាបឋមសិក្សារការកោង ។ ពេលនោះគាត់ជាកីឡាការិនីបាល់ទះផង បងផល ចូលរៀននៅអនុវិទ្យាល័យវត្តដីរស ។ គាត់បានប្រឡងធ្លាក់សញ្ញាប័ត្រឌីប្លូម ហើយក៏ឈប់រៀន ។ នៅឆ្នាំ១៩៧០ បងផល ផ្លាស់ទៅរស់នៅទីក្រុងភ្នំពេញ ដោយស្នាក់នៅជាមួយបងទី១ ឈ្មោះ ភួង ហើយ បងភួង បានជួយឧបត្ថម្ភលុយកាក់និងជួយរកការងារឲ្យគាត់ធ្វើ ។ បងផល បានចូលធ្វើការខាងវាយអង្គុលីលេខជាភាសាបារាំងនៅបន្ទាយទាហានដេអិន (DN) ។ ដោយសារតែមានការជួយជ្រោមជ្រែងពីបងភួង, បងផល ធ្វើការតែនៅក្នុងការិយាល័យទេ ។

នៅពេលដែល បងផល កំពុងរៀននៅវត្តដីរស គាត់បានស្គាល់បុរសម្នាក់ឈ្មោះ សា សុន ។ ពេលនោះ បងសុន ចាប់ចិត្តស្រលាញ់ បងផល ។ អ្នកទាំងពីរបានយល់ចិត្តថ្លើមគ្នា ។ បងសុន បានទៅបន្តការសិក្សានៅប្រទេសបារាំងផ្នែកបច្ចេកទេសថតខ្សែភាពយន្តរយៈពេល២ឆ្នាំ ។ នៅអំឡុងពេលនោះ បងសុន តែងតែសរសេរសំបុត្រនិងផ្ញើរបស់របរមកឲ្យ បងផល ជានិច្ច ។

នៅឆ្នាំ១៩៧២ បងសុន បានបញ្ចប់ការសិក្សា ហើយត្រឡប់មកប្រទេសកម្ពុជាវិញ ។ ពេលនោះ ពុកនិងម៉ែ បានផ្សំផ្គុំអ្នកទាំងពីរជាប្តីប្រពន្ធតាមគន្លងប្រពៃណីខ្មែរនៅស្រុករកាកោង ។ ក្រោយពេលរៀបការហើយ បងទាំងពីរបានត្រឡប់ទៅធ្វើការនៅទីក្រុងភ្នំពេញវិញ ។ បងផល នៅតែធ្វើការងារដូចមុន ។ ចំណែក បងសុន ចូលធ្វើការនៅក្រសួងឃោសនាការ មានតួនាទីអ្នកថតពត៌មានសម្រាប់ចាក់ផ្សាយតាមទូរទស្សន៍ ។

នៅចុងឆ្នាំ១៩៧៤ បងសុន បានលួចទាក់ទងជាសម្ងាត់ជាមួយខ្មែរក្រហម ។ បងសុន ឧស្សាហ៍ទៅជួបបក្សពួកគាត់នៅម្តុំគៀនស្វាយ ។ ក្រោយមកគាត់ត្រូវចាប់ខ្លួនដាក់គុកនយោបាយ (គុកតេ-៣) ដោយសារគាត់ប្រឆាំងជាមួយ កែវ សង់គីម និង ថាច់ ជា ។ រឿងរ៉ាវរបស់គាត់ត្រូវបានចុះផ្សាយនៅក្នុងទំព័រកាសែតទៀតផង ។ ពេល បងសុន ចាប់ផ្តើមទាក់ទងជាមួយពួកកុម្មុយនិស្ត បងផល ក៏បានដឹងពីរឿងនេះដែរ ។ ខ្ញុំ និង បងផល តែងតែទៅសួរសុខទុក្ខគាត់ជាញឹកញាប់ ។ នៅក្នុងគុក បងសុន មានអាហារហូបចុកគ្រប់គ្រាន់និងមានកន្លែងដេកត្រឹមត្រូវ ។ គាត់ធ្វើជាជាងកាត់សក់នៅក្នុងគុក ។

ពេលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បងសុន បានរួចចេញពីគុក ហើយសំដៅមករកប្រពន្ធនិងកូនប្រុសគាត់ និងមកជួបជុំបងប្អូននៅម្តុំទឹកល្អក់ដើម្បីធ្វើដំណើរទៅជាមួយគ្នា ។ ក្រុមគ្រួសារខ្ញុំមានទិសដៅមួយ គឺត្រឡប់មកស្រុកកំណើតវិញ ។ នៅតាមផ្លូវពីភ្នំពេញមកព្រែកពោធិ ខ្មែរក្រហមបានសាកសួរប្រវត្តិរូបបងប្អូនខ្ញុំជាហូរហែ ។ បងប្អូនខ្ញុំ៥នាក់បានឆ្លើយប្រាប់ការពិតទាំងអស់ ។ ចំណែកខ្ញុំនិងប្តីខ្ញុំមានគំនិតមួយថា បើនៅជុំគ្នាជាមួយបងប្អូន ហើយនិយាយប្រាប់ការពិតមុខជា

ត្រូវស្លាប់ហើយ ។ ដូច្នេះប្តីខ្ញុំបានកុហកគេថា គាត់ពីមុនធ្លាប់រត់រ៉ឺម៉ក ហើយខ្ញុំអត់មានធ្វើការងារអ្វីទាំងអស់ ។ ជារៀងរាល់យប់ ខ្ញុំត្រូវឈ្លបមកឈ្លបសួរអំពីប្រវត្តិរូប ។ ខ្ញុំនៅតែរក្សាការលាក់ប្រវត្តិរូបជានិច្ច ។

រយៈពេល៣-៤ខែក្រោយ បងសុន ត្រូវអង្គការចាប់ខ្លួន ។ នៅមុនពេលចាប់ខ្លួន ខ្មែរក្រហមបានកុហកគាត់ថា អង្គការចង់ឲ្យគាត់ត្រឡប់ទៅធ្វើការតាមមុខតំណែងចាស់នៅទីក្រុងភ្នំពេញវិញ ។ បងសុន ប្រាប់ឲ្យ បងផល មកចាំគាត់នៅផ្ទះឯរការកោងសិន ។ ចាប់តាំងពីពេលនោះមក បងសុន ក៏បាត់ខ្លួនរហូត ។ មួយរយៈក្រោយមក បងផល និងកូនត្រូវអង្គការហៅទៅភ្នំពេញដែរ ។ កងទ័ពម្នាក់បានជិះកង់មកប្រាប់ បងផល ថានាំគាត់ទៅជួបប្តី ហើយក៏ឌុបយកគាត់ទៅបាត់រហូត ។ ចំណែកបងប្អូនខ្ញុំ៤នាក់ត្រូវអង្គការតាមចាប់ទាំងប្តីប្រពន្ធនិងកូន ដោយចោទប្រកាន់ថាជាខ្សែរយៈរបស់ បងផល ។


សា សុន ឆ្នាំ១៩៧២

បងទី១ឈ្មោះ អែម ភួង ប្តីធ្វើប៉ូលិសត្រូវអង្គការយកទៅសម្លាប់ទាំងក្រុមគ្រួសារនៅពេលជម្លៀសទៅដល់ស្រុកពារាំងខេត្តព្រៃវែង ។ បងទី២គឺបងផល ។ ទី៣គឺខ្ញុំ ។ ប្អូនទី៤ឈ្មោះ ផល្លា និងក្រុមគ្រួសារស្លាប់នៅខេត្តពោធិសាត់ ដោយសារអត់អាហារ ។ ប្អូនប្រុសខ្ញុំឈ្មោះ សាមុត ត្រូវអង្គការចាប់យកទៅសម្លាប់លើកោះរកានៅក្នុងឆ្នាំ១៩៧៥ ដោយសារវាធ្លាប់ធ្វើជាកងទ័ពខ្មែរក្រហម ហើយរត់មករកបងប្អូននៅទីក្រុងភ្នំពេញ ។ ប្អូន សាមុត ចូលបម្រើកងទ័ពតាំងពីឆ្នាំ១៩៧៣ ក្រោមបង្ខិតបង្ខំពីសំណាក់ប្រធានភូមិ ។ ប្អូនពៅឈ្មោះ សាម៉ុន ជាអតីតទាហានលន់ណល់ ។ វាត្រូវអង្គការយកទៅសម្លាប់ដែរ ។

ពេលនៅព្រែកពោធិ ប្អូនខ្ញុំម្នាក់បានប្រាប់ខ្ញុំថា កុំនៅទីនោះធ្វើអី ពីព្រោះកន្លែងនោះមានគ្រោះថ្នាក់ ហើយវាជាគុកឥតជញ្ជាំង ។ ក្រោយមកអង្គការជម្លៀសប្រជាជន២០គ្រួសារចេញពីសហករណ៍ នៅក្នុងនោះក៏មានឈ្មោះក្រុមគ្រួសារខ្ញុំដែរ ។ ខ្ញុំបដិសេធថា ខ្ញុំមិនព្រមទៅទេ ប្រសិនបើបញ្ជូនខ្ញុំទៅកន្លែងផ្សេងមែន សូមសម្លាប់ខ្ញុំចោលនៅទីនេះចុះ ។ ប៉ុន្តែទីបំផុតខ្ញុំនៅតែផ្លាស់ទៅទីកន្លែងផ្សេងដដែល ។ ពេលនោះអង្គការស៊ើបដឹងការពិត ហើយបញ្ជូនក្រុមគ្រួសារខ្ញុំទៅស្រុកស្ទោងខេត្តកំពង់ធំ ។

ក្រុមគ្រួសារខ្ញុំបានទៅរស់នៅសហករណ៍ព្រះនគ្គ័លស្ថិតនៅក្នុងស្រុកស្ទោង ។ នៅទីនោះប្តីខ្ញុំ ភ្ជួរស្រែ បរទេះគោនិងនេសាទត្រី ។ ប្រជាជននៅទីនោះឆ្ងល់ថាប្តីខ្ញុំជាប្រជាជនថ្មីសោះ ហេតុអ្វីបានជាចេះការងារស្រែចម្ការបែបនេះ ។ ប្តីរបស់ខ្ញុំត្រូវចាត់តាំងឲ្យធ្វើជាអ្នកនេសាទត្រីដើម្បីយកមកផ្គត់ផ្គង់ប្រជាជននៅក្នុងសហករណ៍ ។ ចំណែកខ្ញុំដកស្ទូងនិងរែកដីនៅការដ្ឋាន ។ កាលណោះ បើប្តីខ្ញុំធ្វើការនៅការដ្ឋានវិញ គាត់ប្រាកដជាត្រូវស្លាប់ហើយ ព្រោះមនុស្សភាគច្រើនស្គាល់គាត់ថា ធ្លាប់ធ្វើទាហាននិងធ្វើជាអ្នកត្រួតពិនិត្យទំនិញនៅបន្ទាយដេអិនពីមុនមក ហើយ ខ្ញុំក៏ធ្លាប់ធ្វើជាជាងកាត់ដេរខោអាវទាហាននៅទីនោះដែរ ។ ខ្ញុំនិងកូនរស់នៅជុំគ្នាគឺបែកតែប្តីម្នាក់គត់ ។ ថ្ងៃមួយ ពេលប្តីខ្ញុំដឹកក្របីទៅកន្លែងផ្សេង ខ្ញុំបានឮសំឡេងស្រែកអូយៗនៅពេលយប់ ហើយខ្ញុំបានឃើញស្រមោលមនុស្សស្លុងៗ ។ ខ្ញុំសន្និដ្ឋានថា អ្នកទាំងនោះត្រូវស្លាប់ដោយវាយនឹងដំបង ។ អ្នកភូមិនៅទីនោះខ្សឹបប្រាប់ខ្ញុំថា ប្រសិនអង្គការហៅទៅធ្វើការនៅកន្លែងផ្សេងកុំទៅឲ្យសោះ ពីព្រោះជាលេសដែលអង្គការយកទៅសម្លាប់ទេ ។ នៅកន្លែងដែលខ្ញុំរស់នៅអង្គការបានយកមនុស្សទៅសម្លាប់ច្រើន ជាពិសេសនៅចុងឆ្នាំ១៩៧៨ ។ ខ្ញុំស្ទើរតែអង្គការយកទៅសម្លាប់ដែរ ប៉ុន្តែដោយសារពេលនោះមានសារាចរមួយប្រកាសឲ្យផ្អាកសម្លាប់មនុស្សសិន ។ ខ្ញុំមិនបានឃើញសារាចរនោះដោយផ្ទាល់ទេ ប៉ុន្តែខ្ញុំបានឮអ្នកស្រុកនិយាយពីមាត់មួយទៅមាត់មួយ ។

ពេលបែករបបខ្មែរក្រហម ខ្ញុំមិននឹកស្មានថាខ្លួនមានជីវិតរស់ឡើយ ។ ខ្ញុំបានត្រឡប់មកផ្ទះវិញ ។ អ្នកភូមិបានទៅប្រាប់ម្ដាយខ្ញុំថា ខ្ញុំមកវិញហើយ ប៉ុន្តែគាត់នៅតែមិនជឿ ព្រោះគាត់យល់ថា កូនរបស់គាត់ទាំងអស់ត្រូវស្លាប់នៅក្នុងរបបខ្មែរក្រហមអស់ហើយ ។

ក្រោយឆ្នាំ១៩៧៩ ខ្ញុំបានទៅមើលគុកទួលស្លែង ព្រោះអាជ្ញាធរភូមិឃុំបានប្រាប់ខ្ញុំថា ឃើញមានឈ្មោះ បងផល នៅទីនោះដែរ ។ ខ្ញុំបានទៅមើលនៅទីនោះ ក៏ឃើញឈ្មោះ បងផល មែន ប៉ុន្តែមិនបានឃើញឈ្មោះបងថ្លៃខ្ញុំឈ្មោះ សា សុន ឡើយ ។ ម៉ែខ្ញុំក៏បានទៅនៅទីនោះដែរដើម្បីឲ្យដឹងការពិត ។ ពេលត្រឡប់មកមកផ្ទះវិញ គាត់ចាប់ផ្ដើមគេងមិនលក់ ហើយធ្លាក់ខ្លួនឈឺតាំងពីពេលនោះមក ។ ម៉ែខ្ញុំស្លាប់នៅក្នុងឆ្នាំ១៩៨៣ ដោយសារតែគាត់នឹក បងផល ខ្លាំងពេក ។

រូបថតរបស់ខ្ញុំមានច្រើនសន្លឹកណាស់ ។ នៅក្នុងរបបខ្មែរក្រហម មានឈ្លបមកឆែកឆេរដែរ ប៉ុន្តែរកមិនឃើញដោយសារម្ដាយខ្ញុំលាក់វានៅក្នុងគ្រែប្រអប់ ហើយក្រាលកន្ទេលសម្រាន្តពីលើ ។ ចំណែករូបថតផ្សេងទៀត ខ្ញុំថតកាលពីពួកខ្ញុំនៅធ្វើទាហាន ។ ខ្ញុំមានរូបថតទាំងនេះមួយអាល់ប៊ុម ។ ពេលឈ្លបមកឆែកឆេររករូបថត ខ្ញុំបានរុំវានឹងក្រមាហើយឲ្យកូនខ្ញុំយកក្រមានោះទៅបង់កដើម្បីកុំឲ្យគេរកឃើញ ។ ប្រសិនបើឈ្លបខ្មែរក្រហមរកឃើញ ខ្ញុំមុខជាស្លាប់ទាំងគ្រួសារហើយ ។ រូបថតនោះបានបាត់រតាត់រតាយអស់ នៅសល់តែ២-៣សន្លឹកប៉ុណ្ណោះ ។» ◆◆◆

## នៅ គីមអាន់

រូបថតបីសន្លឹកដែលថតក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ បានបង្កប់រឿងរ៉ាវជាច្រើនទាក់ទងនឹងប្រវត្តិផ្ទាល់ខ្លួនប្រវត្តិគ្រួសារ និងបទពិសោធន៍ដែលម្ចាស់រូបថតបានឆ្លងកាត់នៅក្នុងរយៈកាលដែលខ្លួនរស់នៅ ។ រូបថតទាំងបីសន្លឹកនេះបានមកតាមរយៈការចូលរួមប្រកួតប្រជែងស្នាដៃតែងនិពន្ធរបស់ នៅ គីមអាន់ ក្នុងវេទិកាថែរក្សាប្រវត្តិសាស្ត្រខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅ គីមអាន់ ជាអ្នកប្រមូលនិងថែរក្សារូបថតទាំងបីនេះ ដែលមនុស្សនៅក្នុងរូបថតនេះគឺមានពាក់ព័ន្ធនឹងក្រុមគ្រួសាររបស់ គីមអាន់ ។ គីមអាន់ បានចំណាយពេលវេលានិងធនធានជាច្រើនក្នុងការសុើបសួរនិងស្វែងរករូបថតទាំងអស់នេះនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ។ ក្នុងចំណោមរូបថតទាំងបី មានរូបថតមួយសន្លឹកជារូបថតរបស់សាច់ញាតិ គីមអាន់ រូបថតមួយសន្លឹកទៀតជារូបរបស់ព្រះតេជគុណមួយអង្គដែលធ្លាប់មានទំនាក់ទំនងជាមួយជីដូនរបស់គីមអាន់និងខ្លួនគាត់ផ្ទាល់ និងរូបថតមួយសន្លឹកចុងក្រោយជារូបថតព្រះសង្ឃកំពុងឆាន់ចង្ហាន់ ។ ការចងចាំចំពោះក្រុមគ្រួសារ ជាពិសេស ជីដូនជីតារបស់ គីមអាន់ ធ្វើឲ្យគាត់នឹកឃើញទៅដល់ការប្រមូលរូបថតត្រឡប់មកវិញ ។ រូបថតទាំង៣សន្លឹកនេះនឹងស្ដែងចេញតាមរយៈការរៀបរាប់របស់ គីមអាន់ ។


ព្រះតេជគុណ ចាំង ចើម
ទសវត្សរ៍ឆ្នាំ១៩៦០

វត្តមានរបស់ព្រះសង្ឃមួយអង្គដែលមានព្រះភ័ក្ត្រស្រដៀងនឹងព្រះតេជគុណ ចាំង ចើម នៅអំឡុងឆ្នាំ១៩៨៦-១៩៨៧ និងការចងចាំរបស់ខ្ញុំចំពោះគាត់ធ្វើឲ្យខ្ញុំចង់ស្វែងរករូបថតរបស់ព្រះតេជគុណ ចាំង ចើម ។ ខ្ញុំបានពឹងបងជីដូនមួយខ្ញុំម្នាក់ឈ្មោះ ប៉េន អាន ឲ្យទៅជួយរក ។ ប៉េន អាន ក៏បានរូបថតនេះមកបន្តពីយាយទាំងពីរដែលជាពុទ្ធបរិស័ទគោរពប្រតិបត្តិព្រះតេជគុណ ចើម តាំងពីលោកមិនទាន់សុគតម៉្លេះ ។ រូបថតរបស់ព្រះតេជគុណ ចាំង ចើម ថតតែមួយអង្គឯង គ្រងស្បង់ចីពរថតក្នុងលក្ខណៈមួយកំណាត់ខ្លួន ។

ខ្ញុំបានស្រាវជ្រាវរករូបថតមួយសន្លឹកទៀតដែលបានមកពីបងប្អូនជីដូនមួយខ្ញុំម្នាក់ឈ្មោះ ចែ សៀង ថតក្នុងឆ្នាំ១៩៦៨-៦៩ ដែលមានរូបម្ដាយធំខ្ញុំឈ្មោះ អ៊ិត (រូបទីមួយរាប់ពីស្ដាំ) យាយជីវ៉ូ ជាជីដូនធំខ្ញុំនិងត្រូវជាម្ដាយរបស់អ៊ីអ៊ិត (រូបទីពីរអង្គុយ) និងជីដូនខ្ញុំបង្កើតឈ្មោះ យាយរ៊ុក (រូបទីបីអង្គុយ) ។ ខ្ញុំមិនដឹងថាគាត់រក្សាទុករូបថតនេះយ៉ាងដូចម្ដេច ឬក៏គាត់បានមកតាមវិធីណាដែរទេ ។ ខ្ញុំបានស្រាវជ្រាវរករូបថតនេះតាំងពីឆ្នាំ១៩៨៦ ដល់១៩៨៧ ។ ពេលរកឃើញរូបថតនេះ ខ្ញុំនឹកឃើញចង់ស្វែងរករូបថតរបស់ឪពុកខ្ញុំទៀត ប៉ុន្តែមិនបានលទ្ធផលអ្វីឡើយ ។ ខ្ញុំគិតថា រូបថតឪពុករបស់ខ្ញុំមិននៅសេសសល់ទេ ដោយសារគាត់



(រូបពីស្តាំមកឆ្វេង) អ៊ំអ៊ុត, យាយរ៉ូ, និង យាយរ៉ុក ក្នុងទសវត្សរ៍ឆ្នាំ១៩៦០

ថតក្នុងសម្លៀកបំពាក់ជាកងអាសាស្ម័គ្រជំនាន់សង្គមរាស្ត្រនិយម ។

ព្រះតេជគុណ ចាំង ចើម ជាព្រះចៅអធិការវត្តភ្នំទែតក្នុងនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ ព្រះតេជគុណធ្លាប់មានឈ្មោះល្បីរន្ទឺខាងមន្តអាគមគាថា ។ កេរ្តិ៍ឈ្មោះលោកនៅជំនាន់នោះធ្វើឲ្យពុទ្ធបរិស័ទជាច្រើនមានជំនឿនិងចងចាំរឿងរបស់លោកជានិច្ច ។ ជីដូនខ្ញុំឈ្មោះ រ៉ុក ជាពុទ្ធបរិស័ទដែលគោរពនិងមានជំនឿទៅលើព្រះអង្គដែរ ។ ខ្ញុំនៅចាំបានថាកាលខ្ញុំអាយុ៩ឆ្នាំ ជីដូនខ្ញុំបាននាំខ្ញុំទៅថ្វាយបង្គំព្រះតេជគុណនៅវត្តដើម្បីសុំឲ្យប្តូរឈ្មោះ នៅ គឹមសៀង របស់ខ្ញុំ ។ ខ្ញុំនៅចាំបានទៀតថា នៅពេលដែលលោកយាយដឹកដៃខ្ញុំ ទើបតែដល់ចម្ងាយប្រហែលជា៦-៧ម៉ែត្រពីព្រះតេជគុណ លោកក៏មានសង្ឃដីកាថា “ហៅវាថា គឹមអាន់ ទៅ វាឈប់ឈឺហើយ” ។ លោកតាយល់ពីបំណងរបស់លោកយាយដែលនាំខ្ញុំមកថ្វាយបង្គំលោក ។ មានម្តងនោះនៅរដូវចូលវស្សា មានភាពអស្ចារ្យមួយដែលធ្វើឲ្យខ្ញុំជឿថាព្រះតេជគុណ មានបារមីខ្ពស់ គឺនៅពេលដែលខ្ញុំកំពុងជួយជីដូនខ្ញុំរៀបចង្ហាន់ព្រះសង្ឃនៅវត្ត លោកតាបានចង្អុលពីសាលាឆាន់ ស្រែកហៅដូនជីនៅវាលស្រែថា “យាយៗនៅព្រាតធ្វើអី ម៉េចមិនឡើងទាំងអស់មក” ។ ខ្ញុំបានក្រឡេកមើលទៅតាមចង្អុលដៃលោកតា ខ្ញុំឃើញសុទ្ធតែដូនជីនៅពាសវាលស្រែកំពុងតែដើរមក ។ ភ្លាមនោះពេលខ្ញុំក្រឡេកមើលម្តងទៀតខ្ញុំឃើញតែវាលស្រែទទេ គ្មានឃើញដូនជីម្នាក់សោះ ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ បានរយៈពេលមួយឆ្នាំ ព្រះតេជគុណ ចើម បានភៀសខ្លួនចេញពីភូមិ ។ ខ្ញុំមិនដឹងពីមូលហេតុពិតប្រាកដនៃការចាកចេញនេះទេ ខ្ញុំគ្រាន់តែដឹងថាព្រះតេជគុណ មានជាប់សាច់សាលោហិតជាមួយរាជវង្សនិងជាអ្នកគាំទ្រព្រះមហាក្សត្រ ។ ព្រះតេជគុណក៏បាត់ខ្លួន ។ ក្រោយពេលខ្មែរក្រហមទទួលជ័យជម្នះ ខ្ញុំបានឃើញព្រះតេជគុណក្នុងសម្លៀកបំពាក់ស្បង់ចីពរនិមន្តមកភូមិបុសខ្នុរវិញ ។ មកដល់ភូមិមិនបានប៉ុន្មានថ្ងៃផង មេភូមិបុសខ្នុរបានបញ្ជូនព្រះតេជគុណទៅកាន់មន្ទីរសន្តិសុខទីទួលប្រាក់ស៊ីសាហា ដែលជាអតីតទីទួលរបស់តំណាងរាស្ត្រ ។ មន្ទីរសន្តិសុខនោះមានចម្ងាយប្រហែលជាមួយគីឡូម៉ែត្រពីផ្ទះរបស់ខ្ញុំ ។ ប្រជាជននៅក្នុងភូមិមានសេចក្តីរីករាយចំពោះវត្តមានរបស់ព្រះតេជគុណ ព្រមទាំងនាំគ្នាបះបោរ សុំជួបព្រះតេជគុណទៀតផង ។ ពេលលោកគង់នៅក្នុងមន្ទីរសន្តិសុខឃុំ ខ្ញុំបានធ្វើចង្ហាន់ទៅប្រគេនព្រះតេជគុណដែរ ប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាតឲ្យខ្ញុំចូលទេ ។ លោកតាគង់នៅក្នុងមន្ទីរសន្តិសុខបានប្រហែល២សប្តាហ៍ក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ ។ មុននឹងសម្លាប់ លោកតាត្រូវខ្មែរក្រហមផ្ចាញ់អំណាចបារមីដោយដោះខ្សែគាថាចេញអស់ នៅសល់តែសំពត់ស្ងួត រួចទើបយកទៅសម្លាប់នៅម៉ោង៦កន្លះល្ងាច ។ ពុទ្ធបរិស័ទខ្លះមិនជឿថា លោកស្លាប់ដោយសារការសម្លាប់ទេ ។ នៅឆ្នាំ១៩៨៦-៨៧ ខ្ញុំបានឮអ្នកស្រុកនិយាយថាមានព្រះសង្ឃមួយអង្គមានព្រះភ័ក្ត្រស្រដៀងនឹងព្រះតេជគុណ ដំណឹងនេះធ្វើឲ្យពុទ្ធបរិស័ទដែលធ្លាប់មានជំនឿលើព្រះតេជគុណ ភ្ញាក់ផ្អើលហើយនាំគ្នាទៅមើល ។ អ្នកស្រុកនាំគ្នាសន្និដ្ឋានថា ព្រះតេជគុណមិនទាន់សុគតនៅឡើយទេ ហើយលោកបានមកបួសវិញ ប៉ុន្តែមិនហ៊ានចូលស្រុក ។ ពេលណាខ្ញុំនឹកឃើញជីដូនជីតាខ្ញុំ ខ្ញុំក៏នឹកឃើញដល់រឿងព្រះតេជគុណដែរ ។

## ជីដូននិងជីដូនធំខ្ញុំ

ជីដូនបង្កើតរបស់ខ្ញុំឈ្មោះ យាយរ៉ុក ។ យាយរ៉ុក មានកូនប្រុសពីរនាក់ គឺឪពុកធំខ្ញុំឈ្មោះ នៅ កៅ និងឪពុកខ្ញុំ ។ យាយរស់នៅជាមួយគ្រួសារខ្ញុំរហូតដល់ពេលខ្មែរក្រហមទទួលជ័យជម្នះឆ្នាំ១៩៧៥ ។ យាយចូលសមាទានសីលតាំងពីពេលដែលលោកតាខ្ញុំស្លាប់ម្ល៉េះ ដែលនៅពេលនោះឪពុកខ្ញុំមានអាយុ៨ឆ្នាំនៅឡើយ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ យាយរស់នៅជាមួយប៉ាក្នុងភូមិសាមគ្គី ឃុំបុសខ្នុរ ខេត្តកំពង់ចាម ។ ខ្មែរ

ក្រហមបានឲ្យយាយមើលក្មេងតូចៗ ត្បាញកន្ទេល និងវែងអង្ករ ។ ក្រោយមក យាយបានធ្លាក់ខ្លួនឈឺនិងស្លាប់បាត់បង់ជីវិតដោយសារតែទទួលទានមិនគ្រប់គ្រាន់ ។

ជីដូនធំខ្ញុំឈ្មោះ យាយជីវ៉ូ គាត់ក៏ជាស្ត្រីមេម៉ាយដូចជីដូនខ្ញុំដែរ ។ អ៊ឹមអ៊ិត ជាកូនរបស់យាយវ៉ូ ។ នៅមុនឆ្នាំ១៩៧៥ អ៊ឹមអ៊ិតប្រកបមុខរបរដាំបន្លែនិងលក់ដូរ ។ នៅឆ្នាំ១៩៧៥ អ៊ឹមអ៊ិត និងគ្រួសារត្រូវបានជម្លៀសចេញពីខេត្តកំពង់ចាមទៅនៅឃុំកំពង់ថ្មខេត្តកំពង់ធំ ។ កាលនោះ អ៊ឹមអ៊ិត បានផ្ញើសំបុត្រមួយច្បាប់ដោយសុំឪពុកខ្ញុំ ទៅទទួលគាត់យកមកស្រុកវិញផង ។ ប៉ុន្តែឪពុកខ្ញុំពុំបានទៅទទួលគាត់មកស្រុកកំណើតទេ ពីព្រោះក្រុមគ្រួសារខ្ញុំក៏ជាមុខសញ្ញាមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ ក្រោយមកទើបខ្ញុំដឹងថា គ្រួសាររបស់ យាយវ៉ូ ដែលជម្លៀសទៅនៅឃុំកំពង់ថ្ម ខេត្តកំពង់ធំ ហើយបានស្លាប់នៅទីនោះទាំងអស់ ។

## គ្រួសារខ្ញុំនិងការជម្លៀស

មុនឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំរស់នៅក្នុងភូមិសាមគ្គី ឃុំបុសខ្នុរ ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ ឪពុកខ្ញុំឈ្មោះ នៅ ទ្រី ម្តាយខ្ញុំឈ្មោះ សៀក គឹមហ៊ាន់ ។ កាលនោះខ្ញុំមានអាយុ១៦ឆ្នាំហើយ ។ ឪពុកខ្ញុំធ្លាប់ចូលបម្រើការនៅក្នុងកងអាសាស្ម័គ្រនៅក្នុងសម័យសង្គមរាស្ត្រនិយម ។ កងអាសាស្ម័គ្រគឺជាក្រុមកងទ័ពដែលទទួលការហ្វឹកហាត់ត្រៀមដើម្បីការពារក្នុងស្រុកភូមិ ។ ឪពុកខ្ញុំធ្លាប់ទៅធ្វើការនៅផ្ទះម្តាយធំខ្ញុំឈ្មោះ ណៃ ហួយ ដែលជាអ្នកមានម្នាក់នៅក្នុងឃុំបុសខ្នុរនេះ ។ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ដោយសភាពការណ៍ក្នុងភូមិអស្ថិរភាព ម្តាយធំខ្ញុំនិងឪពុកធំខ្ញុំម្នាក់ទៀតដែលជាជាងផ្ទោរដើរប្រមូលទិញកសិផលប្រចាំខេត្តកំពង់ចាមបានផ្លាស់ទៅរស់នៅទីក្រុងភ្នំពេញដែរ ។

នៅក្នុងឆ្នាំដដែលនោះ ឪពុករបស់ខ្ញុំបានដឹកនាំក្រុមបាតុករមួយក្រុមធ្វើបាតុកម្មប្រឆាំងនឹងរដ្ឋប្រហារទម្លាក់ព្រះមហាក្សត្រ ។ ឪពុកខ្ញុំជាអ្នកស្រឡាញ់ព្រះមហាក្សត្រ ។ ខ្ញុំនៅចាំបានថា គាត់បានចូលរួមធ្វើបាតុកម្មរហូតទៅដល់ព្រែកក្តាម ហើយគាត់ត្រូវខាងទាហានលន់នល់បាញ់ដាច់ស្លឹកត្រចៀកម្ខាង ។ តាំងពីពេលនោះមកកងទ័ពលន់នល់តែងតែស្វែងរកនិងតាមចាប់ខ្លួនរហូត ។ ឪពុកខ្ញុំក៏បានគេចទៅលាក់ខ្លួននៅក្នុងព្រៃនិងបានចូលបម្រើក្នុងកងទ័ពរំដោះបានមួយរយៈខ្លី ។ នៅពេលនោះ ខ្ញុំក៏បានយកថ្នាំនិងអង្ករឲ្យគាត់នៅក្នុងព្រៃ ។ បន្ទាប់ពីនោះមក គាត់ក៏ត្រឡប់មកនៅស្រុកភូមិវិញ ។

នៅឆ្នាំ១៩៧១ គ្រួសាររបស់ខ្ញុំត្រូវកងទ័ពខ្មែរក្រហមជម្លៀសទៅភូមិកៀនឃ្លាំងដែលជាតំបន់រំដោះរបស់ខ្មែរក្រហមស្ថិតនៅខាងកើតភូមិបុសខ្នុរចម្ងាយប្រហែល៤០គីឡូម៉ែត្រ ។ ពេលគ្រួសារខ្ញុំត្រឡប់មកភូមិវិញ(ភូមិបុសខ្នុរ)ផ្ទះបានឆេះអស់ ។ នៅឆ្នាំ១៩៧២ គ្រួសារខ្ញុំត្រូវជម្លៀសចេញពីបុសខ្នុរម្តងទៀតទៅរស់នៅភូមិស្ពឺ ស្រុកចម្ការលើ អស់រយៈពេល២ឆ្នាំ ។ នៅឆ្នាំ១៩៧៤ គ្រួសារខ្ញុំបានត្រឡប់មកស្រុកកំណើតវិញ ។ ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំចេញពីស្រុកកំណើតមកនៅភូមិសាមគ្គី ឃុំបុសខ្នុរ ស្រុកចម្ការលើ ហើយរស់នៅរហូតដល់ឆ្នាំ១៩៧៩ ។ នៅឆ្នាំ១៩៧៦ពេលខ្ញុំមានអាយុ១៦ឆ្នាំ អង្គការឲ្យខ្ញុំចូលក្នុងកងចល័តកុមារនៅល្វាលើ ។ ឪពុកខ្ញុំធ្វើជាអ្នកចិញ្ចឹមជ្រូក ។ ជាអកុសលនៅឆ្នាំ១៩៧៧ ភ្នែកគាត់ចាប់ផ្តើមងងឹត ហើយគាត់ត្រូវធ្វើការរហូតដល់យប់ទៀត ។ ឪពុកខ្ញុំបានធ្លាក់ចូលក្នុងអណ្តូងខែប្រាំង(អណ្តូងគ្មានទឹក)មួយដែលមានជម្រៅប្រមាណ៣ទៅ៤ម៉ែត្រ ។ តាំងពីនោះមកគាត់ធ្លាក់ខ្លួនឈឺរហូតដល់ស្លាប់ ។

ឆ្នាំ១៩៧៧ នៅរដូវប្រាំងរាំងស្ងួតមានគោជាច្រើនឈឺស្លាប់ អង្គការអនុញ្ញាតឲ្យបងប្អូននៅតាមការដ្ឋានយកទៅចម្អិនហូប ។ ប្អូនស្រីខ្ញុំមិនចេះហូបសាច់គោទេ នាងហូបបាយតែជាមួយអំបិលប៉ុណ្ណោះ ។ ខ្ញុំអាណិតប្អូនពេកក៏ទៅកាប់ដើមល្ហុងមួយដើមដែលគ្មានផ្លែដើម្បីយកមកធ្វើនែបវ៉ូទុកឲ្យប្អូនខ្ញុំ ប៉ុន្តែអង្គការបានចោទប្រកាន់ខ្ញុំថាបានកាប់បំផ្លាញដើមល្ហុងរបស់អង្គការ ។ ប្រធានកងខ្ញុំឈ្មោះ ប៉ន បានបញ្ឆោតឲ្យខ្ញុំទៅទីស្នាក់ការភូមិសាមគ្គីដោយប្រាប់ថា ប្រធានភូមិឈ្មោះ គៀន បានហៅខ្ញុំឲ្យត្រឡប់ទៅដឹកស្បៀងនៅការដ្ឋានវិញ ។ និយាយបណ្តើរ ប៉ន គ្រៀកដៃខ្ញុំបណ្តើរ ហើយប្រាប់ឲ្យខ្ញុំប្រញាប់ ពីព្រោះប្រធានភូមិកំពុងរង់ចាំ ។ នៅពេលខ្ញុំទៅដល់ទីស្នាក់ការភូមិ ប្រធានភូមិបានទះខ្ញុំមួយកំផ្លៀង និងបោចសក់ខ្ញុំគ្រវីចុះឡើង រួចហើយស្រែកហៅមេ

ឈ្លបភូមិឈ្មោះ ចន ឲ្យចងស្លាបសេកខ្ញុំ ព្រមទាំងបញ្ជាឲ្យយកខ្ញុំទៅព្រៃឫស្សីខាងកើតភូមិ ។ ខ្ញុំតក់ស្លុតយ៉ាងខ្លាំង ពេលឮឈ្មោះព្រៃឫស្សី ។ ឈ្លបវាយទាត់ធាក់ខ្ញុំយ៉ាងណាក៏ខ្ញុំមិនដឹងឈឺដែរ ខ្ញុំរវល់តែភ័យអំពីរឿងព្រៃឫស្សី ព្រោះខ្ញុំដឹងថាព្រៃឫស្សីដែលនៅក្រោយមន្ទីរសន្តិសុខភូមិនោះគឺជាកន្លែងសម្លាប់មនុស្ស ។ ឈ្លបបានអូសខ្ញុំចេញពីមន្ទីរសេដ្ឋកិច្ចទាំងទីណាត់ទីណែង ប៉ុន្តែខ្ញុំក្រាញនៀលមិនព្រមទៅ ខ្ញុំបាននិយាយអង្វរថា "មិត្តបងខ្ញុំកាប់ល្ហុងហ្នឹងដោយសារវាអត់ផ្លែពីរឆ្នាំហើយវាស្អុយទេ បើមិនជឿមិត្តបងអញ្ជើញទៅពិនិត្យមើលម្តងទៀតចុះ..." ។ ពាក្យសម្តីខ្ញុំបញ្ចាក់ចុងក្រោយ ប្រធានភូមិបានហៅឈ្លបនោះមកខ្សឹបប្រាប់ ប៉ុន្តែខ្ញុំមិនដឹងថាគាត់ខ្សឹបគ្នាពីរឿងអ្វីទេ ។ នៅពេលឈ្លបត្រឡប់មកវិញ គាត់បានបន្ធូរដៃខ្ញុំ មិនអូសខ្ញុំដូចមុនទេ គាត់បណ្តើរខ្ញុំធម្មតាទៅមន្ទីរសន្តិសុខភូមិ ។ អ្នកយាមគុកម្នាក់បានចេញមកយកខ្ញុំទៅដាក់ច្រវាក់ទុកក្នុងមន្ទីរឃុំ ។ ឈ្លបបានផ្តែផ្តាំអ្នកយាមគុកនោះឲ្យមើលខ្ញុំកុំឲ្យលួចរត់ ។ នៅពេលខ្ញុំឃើញមុខរបស់អ្នកយាមគុកនោះខ្ញុំស្គាល់ភ្លាមថាជាអ្នកធ្លាប់ស្គាល់គ្នាជិតដិតឈ្មោះចក់ ។ ចក់ បានសួរនាំខ្ញុំពីហេតុផល ខ្ញុំក៏បានរៀបរាប់តាមដំណើររឿង ។ បន្ទាប់មក សន្តិសុខគុកបានដោះច្រវាក់ចេញពីជើងខ្ញុំ ហើយបានយកខ្ញុំទៅដាក់នៅកន្លែងលត់ដំថ្មី ។ ខ្ញុំធ្វើជាអ្នកប្រមូលលាមកធ្វើជីប្រភេទលេខមួយ ។ អង្គការដាក់បញ្ជាឲ្យខ្ញុំរកលាមកឲ្យបាន ១២ធុងសាំងក្នុងមួយថ្ងៃ ។ ខ្ញុំខំប្រឹងកសាងខ្លួនខំធ្វើការដើម្បីឲ្យអង្គការទុកចិត្ត ។ ខ្ញុំធ្វើការនៅទីនោះបានរយៈពេលមួយខែ អង្គការបានសម្រាលទោសខ្ញុំ និងបញ្ជូនខ្ញុំទៅធ្វើការនៅមន្ទីរឃុំក្នុងកងកម្លាំងពិសេសសម្រាប់ឃុំបុសខ្នុរទាំងមូល ។

នៅក្នុងកងពិសេស ខ្ញុំធ្វើការងារជាច្រើនដូចជាបោកស្រូវ កាប់ព្រៃឫស្សី បំបែកដីដំបូក... ។ល ។ នៅតាមទីកន្លែងខុសៗគ្នា ។ ទីតាំងនីមួយៗ ខ្ញុំធ្វើការបានប្រហែល៥ថ្ងៃឬមួយអាទិត្យប៉ុណ្ណោះ ។ យប់មួយនោះពេលខ្ញុំកំពុងបោកស្រូវ ខ្ញុំឃើញរថយន្តឡានរ៉ូវែមួយគ្រឿងបើកចេញតាមផ្លូវចម្ការកៅស៊ូឆ្ពោះទៅភូមិចាស់ ដែលនៅចម្ងាយប្រមាណជា៧០០ម៉ែត្រពីកន្លែងខ្ញុំបោកស្រូវ នៅទីនោះមានអណ្តូងចាស់មួយមានជម្រៅជ្រៅណាស់ ។ ដោយការសង្ស័យ ស្អែកឡើងក្រោយពេលបាយថ្ងៃត្រង់រួច ខ្ញុំបានលបដើរតាមស្នាមកង់រថយន្តជាមួយ លោកម៉ូវ (សព្វថ្ងៃគាត់ជានាយកសាលាស្រះចក) ដែលជាអ្នកធ្វើការនៅតាមកងចល័តជាមួយខ្ញុំទៅដល់អណ្តូងនោះ ។ ខ្ញុំមានអារម្មណ៍ថា ដូចជាមានអ្វីមួយនៅជាប់នឹងស្បែកជើងខ្ញុំ ។ ខ្ញុំឱនមើលបាតស្បែកជើងរបស់ខ្ញុំ ឃើញសុទ្ធតែឈាមកកជាប់នឹងស្លឹកឈើងាប់ ។ ភ្លាមនោះ ខ្ញុំបានអើតមើលទៅក្នុងអណ្តូង ឃើញសាកសពមនុស្សជាច្រើនស្លាប់គរលើគ្នា ។ ខ្ញុំភ័យខ្លាចខ្លាំងណាស់ ។ តាំងពីពេលនោះមក អារម្មណ៍របស់ខ្ញុំមិននៅនឹងខ្លួនទេ ពេលធ្វើការខ្ញុំមានអារម្មណ៍ភ្ញាក់ៗខ្លាចក្រែងអង្គការកេះខ្លួនហៅយកទៅ ។ ដូច្នេះខ្ញុំខិតខំកសាងខ្លួនសកម្មនឹងការងារណាស់ ខ្ញុំយកចិត្តអង្គការមិនហ៊ានធ្វើអ្វីឲ្យទាស់ចិត្តអង្គការទេ ។ ដោយមើលឃើញខ្ញុំថាជាក្មេងវាងវៃឆ្លាត ធ្វើការសកម្ម អង្គការបានផ្លាស់ខ្ញុំឲ្យទៅធ្វើការងារមួយទៀត ។ អង្គការបម្រុងឲ្យខ្ញុំធ្វើការនៅក្នុងកងកម្លាំងពិសេសនៅក្នុងក្របខ័ណ្ឌក្រសួងដែរ ប៉ុន្តែ បន្ទាប់ពីអង្គការស្រាវជ្រាវប្រវត្តិរូប ហើយចោទថាឈ្មោះ នៅ គឹមអាន់ ជាឈ្មោះវៀតណាម ក៏មិនអនុញ្ញាតឲ្យខ្ញុំធ្វើការនៅក្នុងកងពិសេស ។ ខ្ញុំកាន់តែភ័យខ្លាចថែមទៀត ។ គាប់ជួនជាពេលនោះមានការបង្រៀនបច្ចេកទេសកសិកម្មពូជស្រូវនៅទំនប់ស្ទឹងក្តីជាសាខានៃមន្ទីរពិសោធន៍កសិកម្ម អង្គការបានឲ្យខ្ញុំទៅរៀនសូត្រនៅទីនោះ ។ ខ្ញុំនៅទីនោះរហូតដល់កងទ័ពវៀតណាមវាយសម្រុកចូលប្រទេសកម្ពុជានៅចុងឆ្នាំ១៩៧៨ ។

កងទ័ពវៀតណាមមិនទាន់រំដោះបានមូលដ្ឋានរបស់ខ្ញុំទាំងស្រុងទេ ។ ខ្ញុំព្យាយាមលាក់ខ្លួនដើម្បីគេចឲ្យផុតពីការឆក់សម្លាប់របស់ពួកខ្មែរក្រហម ។ លុះដល់កងទ័ពវៀតណាមរំដោះប្រទេសជាតិបានជាស្ថាពរហើយ ទើបខ្ញុំត្រឡប់មកភូមិរស់នៅជាមួយគ្រួសារខ្ញុំវិញ ។ ◆◆◆

**ប៉ាង ពីច័ន និង ស៊ឺរ សាវីណា**

## ពាក្យស្លោកខ្មែរក្រហម

◆ **កិច្ចការអ្វីដែលសត្រូវប្រឆាំង យើងត្រូវតែគាំទ្រ កិច្ចការអ្វីដែលសត្រូវគាំទ្រ យើងត្រូវតែប្រឆាំង។**

*(ដកស្រង់ពីសៀវភៅញ៉ុក)*

# ហ៊ុន ញ៉ី៖ អតីតអ្នកទោសគុកក្រាំងតាចាន់

ហ៊ុន ញ៉ី ជាអតីតអ្នកទោសគុកក្រាំងតាចាន់ ។ សព្វថ្ងៃ ញ៉ី មានអាយុ៧៣ឆ្នាំ រស់នៅភូមិស្រែគ្រូ ស្រុកត្រាំកក់ ខេត្តតាកែវ ។ កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៥ ហ៊ុន ញ៉ី មានឱកាសបានទៅទស្សនាមន្ទីរនេះម្តងទៀត ។ វត្តមានរបស់ ញ៉ី នៅពេលនេះគឺខុសគ្នាពីពេលដែលឈ្លបខ្មែរក្រហមចាប់គាត់និងក្រុមគ្រួសារកាលពីខែមិថុនា ឆ្នាំ១៩៧៦ ។ លើកនេះ ញ៉ី គ្មានការបង្ខិតបង្ខំ និងគ្មានការមន្ទិលសង្ស័យដូចកាលពីពេលមុនឡើយ ។

ក្រាំងតាចាន់គឺជាមន្ទីរសន្តិសុខសម្ងាត់មួយរបស់ខ្មែរក្រហម នៅក្នុងភូមិភាគនិរតីដែលមានទីតាំងនៅលើទួលមួយក្នុងភូមិក្រាំងតាចាន់ ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។ តាមការស្រាវជ្រាវបានឲ្យដឹងថា អ្នកទោសជាងមួយម៉ឺននាក់បានស្លាប់នៅក្នុងមន្ទីរនេះដោយសារការធ្វើទារុណកម្ម ការសម្លាប់ ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការហួសកម្លាំង និងជំងឺខ្វះថ្នាំព្យាបាល ។

តាមផ្លូវទៅកាន់មន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងចម្ងាយផ្លូវប្រហែលជា១៥០ម៉ែត្រ ញ៉ី បានចង្អុលទៅដើមអម្ពិលមួយដើម ដែល ញ៉ី នៅចាំបានថាប្រធានគុកក្រាំងតាចាន់ធ្លាប់បានឲ្យកូនរបស់គាត់ឈ្មោះ សុខា ឡើងបេះអម្ពិល ហើយបានធ្លាក់ពីលើដើម របួសដៃជើងនិងហើមភ្លៅ ហើយទម្រាំតែព្យាបាលបានជាសះស្បើយត្រូវចំណាយអស់ពេលយ៉ាងយូរ ។

គ្រាន់តែចូលដល់បរិវេណមន្ទីរសន្តិសុខនេះភ្លាម អ្វីដែល ញ៉ី ត្រូវធ្វើមុនគេបង្អស់គឺរកធូបមកអុជដើម្បីរំឭកនិងគោរពវិញ្ញាណក្ខន្ធ ប្តី កូន និងចៅរបស់គាត់ដែលបានស្លាប់នៅក្នុងមន្ទីរនេះកាលពីសម័យខ្មែរក្រហម ។ នៅមន្ទីរនេះ ញ៉ី បាត់បង់សមាជិក ៥នាក់ បីនាក់ស្លាប់ដោយសារការអត់ឃ្លាន និងពីរនាក់ទៀត (ប្តីនិងកូនប្រសា) ស្លាប់ដោយការសម្លាប់ ។ ក្រោយពេលត្រឡប់មកពីអុជធូបវិញ ញ៉ី បានមកអង្គុយក្រោមដើមចន្ទគិរីធំមួយ ភ្នែកសម្លឹងមើលស្តូបដែលមានតម្កល់អដ្ឋិធាតុជនរងគ្រោះ ហើយបាននិយាយមករកខ្ញុំថា “កូនអើយ! អារម្មណ៍ទៅវិញដេកនឹកអត់ភ្លេចទេ នឹកឃើញដល់រូបគេ រូបឯង គេនៅតាមភូមិស្រួល ឯងនៅទីនេះបើគិតតាមកម្មផល គឺកម្មផលឯងវាអាក្រក់ណាស់ វេទនាណាស់កូនអើយ ទម្រាំតែបានរស់» ។

កាលពីមុនរបបខ្មែរក្រហមកាន់អំណាច ញ៉ី រស់នៅជាមួយប្តីឈ្មោះ មាស គុន ប្រកបមុខរបរធ្វើស្រែចម្ការនិងជួញដូរបន្តិចបន្តួច ។ ញ៉ី ខិតខំសន្សំលុយកាក់រហូតមានលទ្ធភាពអាចសង់ផ្ទះមួយដែលមាន៣ខ្នង ។ នៅក្នុងភូមិគ្រួសាររបស់ ញ៉ី មានជីវភាពរស់នៅធូរធារជាងគេ ។

នៅជំនាន់នោះមានអ្នកភូមិម្នាក់ឈ្មោះណុប (ណុប ជាមេកន្ទុយលេខនិងអ្នកលេងល្បែងស៊ីសង ហើយបានលក់ទ្រព្យសម្បត្តិយកទៅលេងល្បែងរហូតអស់ពីខ្លួន) បានមកសុំខ្ចីលុយ ញ៉ី ជាច្រើនលើកច្រើនសា ប៉ុន្តែគាត់បដិសេធ ព្រោះគាត់ទុកលុយនោះសម្រាប់ទិញឈើធ្វើផ្ទះនិងទុកសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ។ តាំងពីពេលនោះមក ណុប គុំកួននឹងគ្រួសាររបស់ ញ៉ី រហូត ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ពេលដែលភូមិស្រែគ្រូត្រូវកងទ័ពរំដោះគ្រប់គ្រង ណុប ត្រូវបានតែងតាំងជាប្រធានភូមិ ព្រោះគាត់ត្រូវបានចាត់ទុកថាជាវណ្ណៈស្អាតស្អំរបស់អង្គការ ។ នៅដើមឆ្នាំ១៩៧៥ ណុប បានស្នើសុំផ្ទះរបស់ ញ៉ី ធ្វើជាទីស្នាក់ការសម្រាប់ដាក់បាយស្ទុកបញ្ជូនទៅសមរភូមិដែលកងទ័ពរំដោះកំពុងប្រយុទ្ធដណ្តើមយកទីរួមខេត្តតាកែវទាំងមូល និងធ្វើជាកន្លែងដាក់កងទ័ពរបួសមុននឹងដឹកទៅព្យាបាលនៅមន្ទីរពេទ្យ២២ (នៅតាមបណ្តោយស្ទឹងស្លាគូ ជិតព្រំប្រទល់ខេត្តតាកែវនិងខេត្តកំពង់ស្ពឺ) ។

ក្រោយថ្ងៃ១៧មេសាឆ្នាំ១៩៧៥ គ្រួសាររបស់ ញ៉ី ត្រូវបានជម្លៀសចេញពីភូមិទៅរស់នៅភូមិតាប៉ាត់ ដែលមានចម្ងាយប្រមាណ៨គីឡូម៉ែត្រពីភូមិស្រែគ្រូ ។ នៅទីនោះបានមួយ រយៈ ប្រធានភូមិបានឲ្យគ្រួសាររបស់ ញ៉ី ត្រឡប់មកភូមិវិញ ហើយធ្វើស្រែតាមសហករណ៍ដូចប្រជាជនដទៃទៀតតាមការចាត់តាំងរបស់អង្គការ ។

ពេលនោះថ្នាក់ដឹកនាំឃុំបានមកបញ្ចុះបញ្ចូល ញ៉ី និងប្តីឲ្យធ្វើជាប្រធានភូមិ ។ ញ៉ី នៅចាំបានពីការរៀបរាប់របស់កម្មាភិបាលនោះ

ថា «អង្គការគឺធ្វើយ៉ាងណាឲ្យប្រទេសជាតិបានសម្បូរសប្បាយ ។ ប្រជាជនត្រូវលើកទំនប់ដើម្បីយកផ្លូវសម្រាប់ធ្វើដំណើរ ហើយនិងផ្លូវទឹកសម្រាប់បើកនាវាទូកដើម្បីដឹកទំនិញពីទន្លេមកដាក់តាមសហករណ៍ តែប្រជាជនត្រូវធ្វើស្រែរួមនិងហូបរួម» ។ ញ៉ៀ និង ប្តី បានបដិសេធ ពីព្រោះគាត់យល់ច្បាស់ថា ច្បាប់កុម្មុយនិស្តមិនអាចចៀសផុតពីការសម្លាប់មនុស្សទេ ។ ក្រោយពីបញ្ចុះបញ្ចូលមិនបាន ញ៉ៀ និង ប្តី ត្រូវបញ្ជូនទៅធ្វើការតាមសហករណ៍វិញ ។ ពេលធ្វើការលំបាកនិងទទួលរបបអាហារមិនគ្រប់គ្រាន់ តាគុន តែងតែនិយាយត្អូញត្អែរពីការហូបមិនឆ្អែត ។ មានពេលមួយប្រធានភូមិបានយកជ្រូករបស់គាត់ទៅកាប់ដើម្បីធ្វើម្ហូបសម្រាប់សហករណ៍ទាំងមូល ។ តាគុន ទទួលបានបបរតែមួយចាននិងមានខ្លាញ់ពីរបីដុំក្នុងនោះប៉ុណ្ណោះ ។ គាត់ក៏ត្អោយមាត់ថា «ជ្រូកអញធំម្ល៉េះ គេយកមកធ្វើ ឥឡូវអត់មានសាច់ស៊ីមួយដុំសោះ» ។ គាប់ជួនពេលនោះ ប្រធានក្រុមដាំស្លព្រក៏តបវិញថា «សាច់ពេញៗចានម៉េចមិនហូបទៅ និយាយធ្វើអី» ។ មិនយូរប៉ុន្មាននៅខែមិថុនា ឆ្នាំ១៩៧៦ តាគុន និងកូនប្រសាឈ្មោះ មុំ បឿន ត្រូវអង្គការហៅទៅរៀនសូត្រ ។ តាំងពីពេលនោះអ្នកទាំងពីរមិនដែលឃើញត្រឡប់មកវិញទេ ។


(រូបឆ្វេងទៅស្តាំ)
អៀប ឌុច, យាយ ហ៊ិន ញ៉ៀ និង បេ ពេលទៅទស្សនាមន្ទីរសន្តិសុខក្រាំងតាចាន់

មួយសប្តាហ៍ក្រោយមក ប្រធានឈ្លបឈ្មោះ អេម និងអ្នកបើករថយន្តម្នាក់បានមកដឹកគ្រួសាររបស់ ញ៉ៀ និងចៅៗមានសមាជិកទាំងអស់ចំនួន១១នាក់ដោយប្រាប់ថាយកទៅរស់នៅសហករណ៍ផ្សេង ។ តាមពិតឈ្លបរូបនោះបានដឹកគាត់ទៅដាក់មន្ទីរសន្តិសុខក្រាំងតាចាន់ ។ ពេលនោះ ញ៉ៀ ទើបតែសម្រាលកូនបានពីរខែ ហើយកូនស្រីរបស់គាត់សម្រាលកូនបានមួយខែប៉ុណ្ណោះ ។ ពេលទៅដល់ដំបូង ញ៉ៀ បានជួបប្អូនថ្លៃជីដូនមួយ គាត់ម្នាក់ឈ្មោះ ស៊ិន ជាប់នៅទីនោះ ។ ស៊ិន បានប្រាប់ថា ប្តីនិងកូនប្រសារបស់ ញ៉ៀ ក៏ជាប់នៅទីនេះដែរ ប៉ុន្តែត្រូវអង្គការបញ្ជូនចេញពីទីនេះបាត់ទៅហើយ ។ ញ៉ៀ ដឹងច្បាស់ថាប្តីនិងកូនប្រសារបស់គាត់ពិតជាត្រូវយកកងឈ្លបទៅសម្លាប់មិនខាន ។

ក្នុងរយៈពេល២០ថ្ងៃដំបូង ញ៉ៀ និងកូនស្រីឈ្មោះ មាស រតនា ត្រូវឆ្មាំគុកដាក់ខ្នោះជើងជាប់មិនឲ្យចេញក្រៅឡើយ ។ ចំណែកកូននិងចៅៗដែលអាចធ្វើការបានត្រូវប្រធានគុកចាត់តាំងឲ្យដើររើសអាចម៍គោ កាប់ដើមទន្ទ្រានខែត្រ និងមើលគោ ។

ក្រោយមក ប្រធានគុកអនុញ្ញាតឲ្យ ញ៉ៀ និងកូនចេញទៅធ្វើការនៅពេលថ្ងៃ ហើយពេលល្ងាចត្រូវត្រឡប់ចូលគុកវិញ ប៉ុន្តែពេលយប់ ញ៉ៀ ត្រូវដាក់ខ្នោះជើងដដែល ។ ញ៉ៀ បានរំឭកពីការលំបាករបស់គាត់ថា «២០ថ្ងៃ ខ្ញុំត្រូវដាក់ខ្នោះឲ្យនៅស្ងៀមជាប់ខ្នោះជើងទាំងម៉ែទាំងកូន ។ ពេលគេ [ប្រធានគុកក្រាំងតាចាន់] ឲ្យចេញមក ខ្ញុំបីកូនដៃម្ខាង ដៃម្ខាងច្រត់ដើរលូនចេញមក ។ ខ្ញុំស្គមណាស់ ដើរលែងរួចហើយ ។ បានប្រធានមន្ទីរ [អាន់] គាត់ឲ្យដំឡូងមួយចាន បាយកកមួយដុំយកមកហូប ទើបមានកម្លាំងបន្តិច ក្រោយមកទើបគេ [អាន់] ប្រើខ្ញុំដេរស្លឹកនិងមើលកូន» ។

ញ៉ៀ នៅដេរស្លឹកនិងមើលកូននិងចៅរបស់គាត់ដែលនៅតូចៗនៅឡើយ ។ ចំណែករតនា (កូនស្រី) ទៅធ្វើការនៅឯស្រែ ។ កូនទី៤របស់យាយឈ្មោះ សុខា ត្រូវអង្គការចាត់តាំងឲ្យមើលគោ ។ ចំណែកចៅរបស់ ញ៉ៀ ឈ្មោះ បេ (អាយុប្រហែល៦ឆ្នាំ) ត្រូវបានចាត់តាំងឲ្យរើសអាចម៍គោនិងកាប់ទន្ទ្រានខែត្រសម្រាប់ធ្វើជី ។ អាន់ បានបញ្ជាឲ្យ បេ ដើរដោះខ្នោះអ្នកទោសនៅពេលព្រឹកនិងដាក់ខ្នោះអ្នកទោសនៅពេលល្ងាច ។ បេ ក៏ត្រូវអង្គការបញ្ជាឲ្យដាក់ខ្នោះម្តាយនិងយាយរបស់ខ្លួនដែរ ។ ពីមួយថ្ងៃទៅ

មួយថ្ងៃ សុខភាពរបស់ ញ៉ កាន់តែទ្រុឌទ្រោមទៅៗ ។ ញ៉ គ្មានទឹកដោះបំបៅកូនទេ ទីបំផុតកូនរបស់ ញ៉ បានស្លាប់ដោយខ្វះជីវជាតិចិញ្ចឹមរាងកាយ ។ ប្រមាណ៤ខែក្រោយមក ចៅម្នាក់ទៀតរបស់ ញ៉ ក៏ស្លាប់បាត់បង់ជីវិតដែរ ។

នៅក្នុងគុក អ្នកទោសត្រូវឆ្មាំគុកឲ្យដេកនៅលើគ្រែដែលសង់ផុតពីដី ដោយទុកប្រឡោះកណ្តាលសម្រាប់ឲ្យឆ្មាំគុកដើរពិនិត្យមើលអ្នកទោស ។ នៅក្នុងនោះមានធុងទឹកនោមមួយនិងធុងលាមកមួយ ។ អ្នកទោសត្រូវបន្ទោរបង់ដាក់ក្នុងត្រឡោក បន្ទាប់មកហុចត្រឡោកនោះទៅឲ្យអ្នកទោសផ្សេងទៀតដើម្បីយកទៅចាក់ក្នុងធុងរួម ។ អ្នកទោសម្នាក់ៗមិនអាចហុចរំលងគ្នាបានទេ ហើយក៏មិនត្រូវឲ្យកំពប់ដែរ ។

ក្រោយមក អាន់ ប្រធានគុកបានឲ្យយាយធ្វើចុងភៅដាំស្លឲ្យអ្នកទោស ប៉ុន្តែ ញ៉ នៅតែឋិតនៅក្រោមការឃ្លាំមើលពីឆ្មាំគុកស្ទើរគ្រប់ពេលវេលាដដែល ។ ទោះជាយ៉ាងណាក៏ដោយ ក៏ ញ៉ អាចកឹបកេងបបរខ្លះ សម្រាប់កូនចៅរបស់គាត់ដែរ ។ ថ្ងៃមួយ បេ បានមកសុំបបរ ញ៉ យកទៅហូប ដោយឃ្លានខ្លាំងពេក បេ បានលើកបបរនោះហុតទាំងក្តៅបណ្តាលឲ្យរលាកមាត់ ហើយត្រូវប្រធានគុកចោទថាបានលួចបបរអ្នកទោសហូប ។ បេ ត្រូវប្រធានគុកធ្វើទារុណកម្មវាយនឹងក្បាលបដូងរបួសពេញខ្លួននិងឲ្យឈរជើងម្ខាងស្ទើរពេញមួយថ្ងៃ ។

នៅក្នុងគុករយៈពេលពីរឆ្នាំ ញ៉ មិនដែលត្រូវឆ្មាំគុកធ្វើទារុណកម្មរាងកាយទេ ហើយក៏មិនដែលឃើញការសម្លាប់អ្នកទោសដោយផ្ទាល់ភ្នែកដែរ ។ ញ៉ បាននិយាយថា “ពេលវៃ[សម្លាប់] អត់ឲ្យយើងឃើញទេ ហើយពេលគេវៃមិនសូវឮសំឡេង[អ្នកទោស]ស្រែកទេ ព្រោះគេចាក់មីក្រូបំពង់សំឡេងខ្លាំងៗកុំឲ្យយើងនៅខាងក្នុងឮ តែខ្ញុំផ្ទៀងត្រចៀកស្តាប់ ឮស្រែកយ៉ូយៗ ដូចគេទម្លាក់ដូងទុំអ៊ីចឹង ឮសូរតែអ៊ីចឹង រឿងឃើញផ្ទាល់ភ្នែកអត់ទេ នរណាឲ្យឃើញ បើគេបិទជិតអស់ហើយ ដល់ពេលគេវៃហើយបានគេបញ្ចេញយើងមកវាល” ។ ញ៉ បន្ថែមទៀតថា “មុនយក[អ្នកទោស]វៃ(សម្លាប់) គេថា ឥឡូវគេឲ្យមិត្តយើងទៅជួបជុំគ្រួសារ បងប្អូនម៉ែឪ នៅផ្ទះឯសហករណ៍វិញ ។ ពេលមិត្តទៅវិញមិត្តកុំប្រាប់គេថា កន្លែងនេះពិបាកហូប ពិបាកបត់ដៃបត់ជើង ពិបាកសម្រាន្ត ។ ប្រពន្ធកូនយើងផ្ទាល់ក៏ដោយ កុំប្រាប់ បើថាប្រាប់មិត្តច្បាស់ជាមកកន្លែងហ្នឹងវិញហើយ ។ តែមុននឹងទៅត្រូវមិត្តទៅជួបអង្គការសិន” ។

បេ ក៏បាននិយាយដែរថា គាត់បានឃើញឆ្មាំគុកសម្លាប់ក្មេងៗផ្ទាល់ភ្នែក ដោយសារថាកាលណោះ គាត់នៅក្មេងហើយមានសេរីភាពដើរហើរជាងអ្នកទោសចាស់ៗ ។ បេ បានឃើញឆ្មាំគុកចាប់ជើងកូនក្មេងបោកផ្ទប់នឹងដើមឈើទាលរួចបោះចូលក្នុងរណ្តៅ ក្រោយពេញរណ្តៅហើយទើបកប់សាកសពទាំងនោះ ។

អៀប ឌុច ដែលជាកម្មាភិបាលម្នាក់នៅមន្ទីរសន្តិសុខក្រាំងតាចាន់បាននិយាយថា កាលពីឆ្នាំ១៩៧៨ គាត់បានស្នើទៅថ្នាក់ដឹកនាំមន្ទីរឲ្យដោះលែងគ្រួសាររបស់ ញ៉ ដោយលើកហេតុផលថាគ្រួសាររបស់គាត់គ្មានបង្ហាញពីសកម្មភាពណាមួយដែលក្បត់នឹងបដិវត្តន៍ឡើយ ។

នៅខែមិថុនា ឆ្នាំ១៩៧៨ គ្រួសាររបស់ ញ៉ ត្រូវបានដោះលែង ។ អាន់ បានឲ្យឈ្លបម្នាក់ឈ្មោះ សៀង ជាអ្នកជូនក្រុមគ្រួសារយាយត្រឡប់ទៅផ្ទះវិញ ។ ញ៉ ភ័យណាស់ ព្រោះកន្លងមកអ្នកដែលត្រូវប្រាប់ថាឲ្យត្រឡប់ទៅផ្ទះគឺយកទៅសម្លាប់ហើយ ។ ពេលដើរមកដល់មុំអង្គរកា ញ៉ បានសួរ សៀង ថា “ខ្ញុំរួចទាំងអស់គ្នាហើយ ពូសៀង?” សៀង បានឆ្លើយទាំងគំរាមថា “អើ! យាយ ញ៉ ឯងរួចហើយ តែប្រយ័ត្នមាត់ណា៎ កុំមាត់រអេចរអូចក្រែងឮដល់គេ បើហ៊ានប្រាប់គេ យាយញ៉ឯងហ្នឹងប្រាកដជាមកដល់ទីនេះ មុនព្រឹកទៀតមិនខាន” ។

សៀង បាននាំគ្រួសាររបស់ ញ៉ ទៅរស់នៅភូមិតារាប ចម្ងាយប្រហែល២គីឡូម៉ែត្រពីភូមិស្រែគ្រួ ។ ញ៉ ត្រូវអង្គការចាត់តាំងឲ្យដាក់ចំណីជ្រូកចំនួន៧០ក្បាលជាមួយនារីម្នាក់ដែលជាប្រជាជនថ្មីមកពីភ្នំពេញ ។ រៀងរាល់ថ្ងៃ ញ៉ និងនារីនោះត្រូវទៅកាប់ដើមចេកដើម្បីយកមកហាន់ធ្វើជាចំណីឲ្យជ្រូក ។ ក្រៅពីការងារនេះ ញ៉ ត្រូវយករបបអាហារទៅឲ្យអ្នកជំងឺនៅតាមផ្ទះទៀត ។ ម៉ោងមួយឬពីររសៀលទើប ញ៉ បានហូបបបរ ។ ញ៉ ស្នាក់នៅភូមិតារាបនេះបានរយៈពេលកន្លះឆ្នាំរបបខ្មែរក្រហមក៏ដួលរលំ ។

ទោះបីជារបបខ្មែរក្រហមវិនាសអន្តរាយយូរឆ្នាំមកហើយក៏ដោយ ក៏ ញ៉ នៅតែមិនអាចបំភ្លេចសមាជិកគ្រួសារដែលបាន

ស្លាប់កាលពីសម័យខ្មែរក្រហមដែរ ។ ញ៉ៃ បានឲ្យដឹងថា «ដួនកាលខ្ញុំអង្គុយស្រក់ទឹកភ្នែក ថ្ងៃណាខ្ញុំនឹកឃើញគាត់(ប្តី) ខ្ញុំអត់សម្រាន្តលក់ទេ នឹកឃើញសឹងដល់ក្អឹកក៏មានដែរ ។ ឃើញកូន ឃើញចៅ បានម្ហូបចំណីមក ខ្ញុំនឹកឃើញដល់គាត់ ព្រោះកាលជំនាន់នោះ អត់បានអីហូបទេ» ។ ប៉ុន្តែ ញ៉ៃ ធូរអារម្មណ៍បន្តិចទៅវិញ នៅពេលឃើញអដ្ឋិធាតុជនរងគ្រោះតម្កល់ទុកនៅក្នុងចេតិយមួយដ៏ស្អាត ដែលក្នុងចំណោមធាតុទាំងនោះ រួមមានប្តី កូន កូនប្រសានិងចៅៗ របស់ ញ៉ៃ ដែរ ។

**ញាណ សុជាតិ**

# អតីតអ្នកបើកបរប្រចាំស្ពានទូតគុយបានិងស្ពានទូតឡាវ


ឆាយ មឿន

ឆាយ មឿន គឺជាអ្នកបររថយន្តប្រចាំនៅស្ថានទូតគុយបា និងស្ថានទូតឡាវ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បច្ចុប្បន្ន មឿន រស់នៅឃុំគោគបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ មឿន បានចូលបម្រើបដិវត្តន៍ក្នុងឆ្នាំ១៩៧១ ដោយសារតែមានការថ្នាំងថ្នាក់ជារដ្ឋអំណាចភូមិឃុំ ។

បន្ទាប់ពីថ្ងៃរដ្ឋប្រហារឆ្នាំ១៩៧០ ភូមិកងមាសស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងទ័ពខ្មែរក្រហមដែលសហការជាមួយកងទ័ពវៀតកុង ដើម្បីវាយប្រឆាំងនឹងទាហានលន់នល់ ។ នៅអំឡុងពេលនោះ ខាងខ្មែរក្រហមបានរៀបចំចាត់តាំងរដ្ឋអំណាចភូមិ ហើយឲ្យប្រជាជនដែលរស់នៅក្នុងភូមិនោះធ្វើការផាសប្រវាស់ដៃគ្នា ។ យុវជនយុវនារីទាំងអស់ត្រូវធ្វើការជាសមូហភាពបាចទឹកបញ្ចូលស្រែប្រាំងពីដើមភូមិដល់ចុងភូមិតាមលេខរៀងដែលរដ្ឋអំណាចខ្មែរក្រហមកំណត់ឲ្យ ។ ស្រែរបស់ មឿន ឋិតនៅចុងភូមិ ហេតុដូច្នេះទម្រាំតែដល់ចុងភូមិស្រូវនៅក្នុងស្រែរបស់ មឿន ត្រូវក្រៀមស្វិតអស់ ។ មឿន អាក់អន់ចិត្តនឹងរដ្ឋអំណាចភូមិឃុំដែលបានបែងចែកដូច្នេះ ព្រោះមេភូមិ មេឃុំសុទ្ធតែបានដឹងថាម្តាយរបស់ មឿន ជាស្ត្រីមេម៉ាយដែលមានកូនតូចៗនៅក្នុងបន្ទុក ហើយមានតែ មឿន ម្នាក់ប៉ុណ្ណោះដែលពេញកម្លាំង ។

នៅឆ្នាំ១៩៧១ មឿន និងមិត្តភក្តិ៥នាក់ ឈ្មោះ កៀន, អៀប, ចួយ, អួន និងម្នាក់ទៀត (មិនចាំឈ្មោះ) បានសម្រេចចិត្តចាកចេញពីភូមិទៅបម្រើការនៅកងទ័ពមជ្ឈិមរបស់ខ្មែរក្រហម ដែលមានទីតាំងនៅភូមិថ្មី ឃុំកំពង់ឆ្នាំង ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង ។ ពេលចូលដំបូង មឿន តម្រូវឲ្យហាត់រៀនក្បួនយុទ្ធសាស្ត្រកងទ័ព ដើម្បីត្រៀមខ្លួនឡើងសមរភូមិនៅកំពង់ខស (នៅក្នុងខេត្តកំពង់-ឆ្នាំង) ។ ពីរខែក្រោយមក មេបញ្ជាការអង្គភាពឈ្មោះ សី បានផ្លាស់ មឿន ឲ្យមកខាងនៅអង្គភាពដឹកជញ្ជូនចន្ទរៀល ដែលស្ថិតនៅជិតព្រំដែនខេត្តកំពង់ស្ពឺ ។ មឿន ត្រូវបានឈ្មោះ វុយ ប្រធានអង្គភាពដឹកជញ្ជូនបង្ហាត់បង្រៀនឲ្យចេះបើករថយន្ត ។ បន្ទាប់មក មឿន ត្រូវបានចាត់តាំងឲ្យបើករថយន្តដឹកទំនិញ ដូចជាថ្នាំពេទ្យ, កាំភ្លើងនិងគ្រាប់កាំភ្លើងទៅចែកឲ្យកងទ័ពនៅតាមភូមិភាគ និងតំបន់ផ្សេងៗ ។ ក្រៅពីដឹកជញ្ជូនទំនិញ មឿន ក៏បានចូលរួមប្រយុទ្ធប្រឆាំងនឹងទាហាន លន់ នល់ នៅតាមសមរភូមិផ្សេងដែរ ។

ឆ្នាំ១៩៧៥ មួយសប្តាហ៍បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ អង្គភាពដឹកជញ្ជូនរបស់ មឿន ត្រូវបានផ្លាស់មកនៅក្បែរផ្សារថ្មីទីក្រុងភ្នំពេញ ។ ក្រោយមកប្តូរមកនៅមន្ទីរប៨របស់ក្រសួងការបរទេស ។ មឿន ត្រូវបានចាត់តាំងឲ្យបើករថយន្តប្រមូលសំរាមតាមផ្ទះនិងតាមអគារនានាយកទៅចាក់ចោលនៅម្តុំគល់ស្ពានស្ទឹងមានជ័យ ។ រយៈពេល៤ខែក្រោយ

ក្រសួងការបរទេសខ្មែរក្រហមបានបែងចែកយុវជន យុវនារី និងកម្មាភិបាលឲ្យទៅតាមផ្នែកផ្សេងៗ ខ្លះទៅបម្រើនៅផ្នែកសេដ្ឋកិច្ច ដាំបន្លែ ចិញ្ចឹមសត្វ ដើម្បីផ្គត់ផ្គង់អន្តភាពដែលស្ថិតនៅក្រោមឱវាទក្រសួងការបរទេស ។ ខ្លះទៀតធ្វើនៅផ្នែកចុងភៅដាំបាយឲ្យភ្ញៀវ ។ ចំណែក មឿន មកនៅខាងដឹកជញ្ជូន ។ ផ្នែកនេះបែកជាពីរតូចៗទៀត គឺដឹកភ្ញៀវរបស់ក្រសួងការបរទេស និងដឹកមន្ត្រីទូតនៅតាមស្ថានទូតនានាប្រចាំនៅទីក្រុងភ្នំពេញ ។

មឿន ជាអ្នកបើករថយន្តប្រចាំការនៅស្ថានទូតនៃប្រទេសគុយបា ។ ពេលណាខាងស្ថានទូតគុយបាត្រូវការរថយន្ត ខាងតំណាងស្ថានទូតត្រូវផ្តល់ដំណឹងមកឲ្យក្រសួងការបទេសខ្មែរក្រហម ហើយខាងក្រសួងនឹងបញ្ជូន មឿន ទៅភ្លាម ហើយពេលចប់ភារកិច្ច មឿន ត្រូវត្រឡប់មកកន្លែងវិញ ។ មឿន បានស្គាល់ប្រទេសមួយចំនួនដែលដាក់ស្ថានទូតនៅទីក្រុងភ្នំពេញនៅពេលនោះមានសាធារណរដ្ឋប្រជាមានិតចិន, កូរ៉េខាងជើង វៀតណាម គុយបា ឡាវ និងប្រទេសអេហ្ស៊ីប... ហើយមានតែស្ថានទូតចិននិងកូរ៉េខាងជើងទេ ដែលអនុញ្ញាតឲ្យមានអ្នកបើកបរប្រចាំស្ថានទូត ។ ក្រៅពីនេះខាងក្រសួងការបរទេសខ្មែរក្រហមជាអ្នកចាត់ចែងនិងបញ្ជូនអ្នកបើកបរទៅឲ្យ ប្រសិនបើភ្ញៀវឬមន្ត្រីទូតរបស់ប្រទេសណាចង់ធ្វើដំណើរទៅណាមកណា ។ ការហូបចុកកន្លែងនោះ មឿន មិនមានការខ្វះខាតឡើយ ព្រោះមានចុងភៅចាំរៀបចំបម្រើបាយទឹកគ្រប់ពេលវេលា ចង់ហូបថ្មីណាក៏បាន ។

មឿន តែងតែដឹកអគ្គរដ្ឋទូតគុយបាមកជួបទំនាក់ទំនងការងារជាមួយ អៀង សារី នៅក្រសួងការបរទេស និងជូនទៅកន្លែងផ្សេងៗទៀត ដូចជាជូនទៅព្រលានយន្តហោះពោធិ៍ចិនតុង និងបើកអមដំណើរគណៈប្រតិភូរបស់ប្រទេសគុយបាដែលមកទស្សនកិច្ចនៅកម្ពុជា ឬក៏បើកជូនឯកអគ្គរដ្ឋទូតចូលរួមកម្មពិធីផ្សេងៗដែលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យអញ្ជើញ ។

នៅក្នុងឆ្នាំ១៩៧៥ មឿន បានសុំលិខិតអនុញ្ញាតពីក្រសួងការបរទេស ដើម្បីរៀបការជាមួយ ណយ ដែលម្តាយបានដណ្តឹងឲ្យតាំងពីឆ្នាំ១៩៧០ ។ ណយ ធ្វើការនៅតំបន់៣១ ដែលមានសារុន ជាគណៈតំបន់ ។ ក្រោយពីរៀបការរួច មឿន បានស្នើសុំពីក្រសួងការបរទេសនិងគណៈតំបន់ដើម្បីឲ្យប្រពន្ធបានធ្វើការនៅក្រសួងការបរទេសជាមួយគ្នា ។ ប្រពន្ធរបស់ មឿន ធ្វើការនៅផ្នែកចុងភៅដាំស្លទទួលភ្ញៀវបរទេស ។

នៅឆ្នាំ១៩៧៨ មឿន ត្រូវបានផ្លាស់ឲ្យមកធ្វើជាអ្នកបើកបរនៅស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវរហូតដល់ថ្ងៃទី៧ខែមករា ឆ្នាំ១៩៧៩ ។ ឯកអគ្គរដ្ឋទូតរបស់ប្រទេសឡាវប្រចាំនៅកម្ពុជាមានឈ្មោះ ខាំម៉ាភូគង់ និងជំនួយការម្នាក់ឈ្មោះ សូវេងវង្ស ។ ការងារបើកបរនៅទីនោះក៏មិនខុសពីនៅស្ថានទូតគុយបាដែរ មឿន តែងតែបើកឡានជូនឯកអគ្គរដ្ឋទូតឡាវទៅធ្វើការជាមួយ អៀង សារី ឧបនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីការបរទេសនិងចូលរួមពិធីផ្សេងៗ ដែលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានអញ្ជើញឲ្យចូលរួម ។ មឿន រំឭកថា «ខ្ញុំធ្លាប់បើកឡានជូនលោកឯកអគ្គរដ្ឋទូតឡាវទៅចូលរួមក្នុងពិធីជប់លៀងមួយនៅសាលសន្និសីទចតុមុខ ហើយខ្ញុំបានឃើញវត្តមានរបស់ ប៉ុល ពត, អៀង សារី, ខៀវ សំផន, នួន ជា និង សុន សេន... នៅក្នុងពិធីនោះ» ។

មឿន និយាយទៀតថា នៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ គាត់មិនដែលបានឃើញខ្មែរក្រហមធ្វើទារុណកម្ម ឬសម្លាប់ប្រជាជននិងកម្មាភិបាលគ្នាឯងឡើយ ។ គាត់គ្រាន់តែដឹងថា មានកម្មាភិបាលមួយចំនួនដែលធ្លាប់ធ្វើការជាមួយក៏មានបាត់មុខខ្លះដែរ ប៉ុន្តែមិនដឹងថាអង្គការផ្លាស់ទៅធ្វើការនៅកន្លែងផ្សេងឬយ៉ាងណាឡើយ ។ ករណីដូចឈ្មោះ ប៉ាង, កុយ ធួន (ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម) និង ឌឿន (អតីតកម្មាភិបាលមកពីភូមិភាគឧត្តរ) ។ ប៉ាង តែងតែចូលរួមធ្វើជាគណៈអធិបតីនៅពេលបើកអង្គប្រជុំឬសន្និបាតនៅក្នុងក្រសួងការបរទេស ។ ចុងឆ្នាំ១៩៧៧ ប៉ាង បានបាត់មុខហើយក៏គ្មានដំណឹងអំពីគាត់ដែរ ។ «ខ្ញុំធ្លាប់ឃើញ ប៉ាង ធ្វើការនៅមន្ទីរមួយនៅក្បែរមន្ទីរប៤នេះដែរ គឺធ្វើការជាមួយ ប៉ុល ពត, នួន ជា, ខៀវ សំផន និង អៀង សារី ។ ខ្ញុំស្គាល់ ប៉ាង ច្បាស់ពីព្រោះកាលពីដើមឆ្នាំ១៩៧៥និង៧៦ ប៉ាង តែងតែមកសួរសុខទុក្ខនិងនិយាយលេងសើចជាមួយអតីតកម្មាភិបាលយុវជនដែល

ធ្លាប់ធ្វើការងារជាមួយគាត់កាលពីមុនឆ្នាំ១៩៧៥ ហើយខ្ញុំធ្វើការនៅក្បែរកម្មាភិបាលយុទ្ធជននោះដែរ ។ រឿងមួយទៀតគឺពេលរំដោះទីក្រុងភ្នំពេញភ្លាមៗ គុយ ធួន បានស្នើអ្នកឡាននៅក្រសួងការបរទេស ដើម្បីជូនដំណើរគាត់ទៅទស្សនកិច្ចក្រុងកំពង់សោមចំនួន៣ថ្ងៃ ហើយខ្ញុំត្រូវបានក្រសួងចាត់តាំងឲ្យបើកឡានជូនគាត់ ។ ក្រោយមកខ្ញុំបានឮដំណឹងថាគាត់ ក្បត់អង្គការ ។ ចំណែកឈ្មោះ ខឿន ក៏ខស្សូវាហ៍ឮឈ្មោះនិងឃើញមុខដែរ ប៉ុន្តែក្រោយមកគាត់ក៏បាត់ឈ្មោះតែម្តងមិនដឹងថាទៅណាឡើយ» ។ មឿន បានដឹងថាខ្មែរក្រហមសម្លាប់មនុស្សនៅពេលខ្លួនគាត់ភៀសខ្លួនចេញពីទីក្រុងភ្នំពេញក្នុងខណៈពេលដែលកងទ័ពវៀតណាមវាយចូលកម្ពុជានៅឆ្នាំ១៩៧៩ «ពេលនោះខ្ញុំបានឃើញសាកសពមនុស្សនិងរណ្តៅខ្មោចនៅតាមផ្លូវនៅពេលខ្ញុំត្រឡប់មកដល់ស្រុកកំណើត ។ បងប្អូនញាតិមិត្តនៅក្នុងភូមិបាននិយាយប្រាប់ខ្ញុំអំពីជីវភាពរបស់ប្រជាជននៅតាមជនបទនិងការកាប់សម្លាប់របស់ខ្មែរក្រហម» ។

នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ ពេលមានសភាពការណ៍ជ្រួលច្របល់កងទ័ពវៀតណាមនឹងវាយចូលទីក្រុងភ្នំពេញនោះខាងក្រសួងការបរទេសបានបញ្ជាឲ្យយុវនារីនិងកម្មាភិបាលមួយចំនួនភៀសខ្លួនតាមរទេះភ្លើងឆ្ពោះទៅភាគខាងលិចនៃប្រទេស ។ ប្រពន្ធរបស់ មឿន កំពុងមានផ្ទៃពោះគ្រប់ខែក៏បានចេញដំណើរតាមរទេះភ្លើងនៅក្នុងថ្ងៃនោះដែរ ប៉ុន្តែ មឿន មិនបានរួមដំណើរជាមួយប្រពន្ធទេ ព្រោះរវល់តែយកឡានប្រគល់ឲ្យស្ថានទូត ។ មឿន តាមរកប្រពន្ធរហូតដល់ព្រំដែនកម្ពុជា-ថៃ និងចំណាយពេលអស់២ខែដើម្បីស៊ើបសួររកប្រពន្ធ ប៉ុន្តែគ្មានដំណឹង ហើយថែមទាំងត្រូវទាហានថៃចាប់គាត់និងមិត្តភក្តិ៤នាក់បញ្ជូនមកភ្នំដងរែកវិញ ។ មឿន ក៏ធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញនៅក្នុងឆ្នាំ១៩៨០ ។ ឆ្នាំ១៩៨២ មឿន បានសម្រេចចិត្តរៀបការជាមួយនារីម្នាក់ទៀតដែលរស់នៅក្នុងភូមិជាមួយ ។

បច្ចុប្បន្ន មឿន មានកូនស្រី២នាក់និងប្រុស១ ប្រកបមុខរបរចិញ្ចឹមទានិងធ្វើស្រែប្រាំង ។ មឿន បាននិយាយថា «ទោះបីជានៅក្នុងរបបខ្មែរក្រហម ខ្ញុំបានទទួលរបបហូបចុកគ្រប់គ្រាន់និងមានជីវភាពប្រសើរជាងបច្ចុប្បន្ននេះក៏ដោយ ក៏ប៉ុន្តែបងប្រុសរបស់ខ្ញុំឈ្មោះ សឿន និងប្រពន្ធព្រមទាំងកូន នៅឯស្រុកកំណើតក៏ត្រូវបានសម្លាប់ទាំងអស់នៅក្នុងរបបនោះដែរ ។ ញាតិមិត្តនៅក្នុងភូមិប្រាប់ខ្ញុំថា ប្រពន្ធរបស់ សឿន លួចដាំបាយហូប ដូច្នេះខ្មែរក្រហមក៏ចោទថាក្បត់សមូហភាព ហើយយកទៅសម្លាប់ចោលតែម្តង ។ ចំណែកប្អូនប្រុសខ្ញុំម្នាក់ទៀតឈ្មោះ សឿន ត្រូវខ្មែរក្រហមបង្ខំឲ្យចូលបម្រើកងទ័ពនិងបញ្ជូនទៅវៃជាមួយកងទ័ពវៀតណាមតាមព្រំដែនកម្ពុជា-វៀតណាមនៅក្នុងចន្លោះឆ្នាំ១៩៧៦-៧៧ ហើយបាត់ដំណឹងរហូតមកសព្វថ្ងៃនេះ» ។

មឿន ចង់បានតុលាការមួយដើម្បីឲ្យមានការជំនុំជម្រះទោសពួកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលបានបង្កឲ្យមានការសម្លាប់ប្រជាជននិងការបង្ខិតបង្ខំមិនឲ្យឪពុកម្តាយ កូនចៅ បងប្អូននិងសាច់ញាតិមិនឲ្យមានទំនាក់ទំនងគ្នា ។ សូម្បីតែខ្លួនគាត់ដែលបម្រើការឲ្យអង្គការក៏មិនត្រូវបានអនុញ្ញាតឲ្យមកលេងបងប្អូននិងម្តាយនៅឯស្រុកកំណើតដែរ ។

**ឡុង ដានី**

# សេចក្តីប្រកាសរកប្អូនប្រុសពីរនាក់

នាងខ្ញុំឈ្មោះ អាន គៅ ភេទស្រី អាយុ៥៨ឆ្នាំ រស់នៅភូមិព្រៃម៉ីយ៍ ឃុំផាន់ញើម (អតីតភូមិដើម ឃុំនីរពេជ្រ) ស្រុកប្រាសាទបាល្ល័ង្ក (កំពង់ស្វាយ) ខេត្តកំពង់ធំ ។

សូមសួររកប្អូនប្រុសឈ្មោះ អាន កួយ និង អាន គុយ ដែលបានចេញពីផ្ទះទៅធ្វើកងទ័ពខ្មែរក្រហមនៅឆ្នាំ១៩៧២ ។ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ កួយ បានមកលេងផ្ទះម្តងរយៈពេល៤-៥ថ្ងៃ រួចក្រោយមកក៏បាត់ដំណឹងរហូតដល់សព្វថ្ងៃ ។

បើសាមីខ្លួនបានឮឬបងប្អូនបានស្គាល់ឈ្មោះខាងលើ សូមផ្តល់ព័ត៌មានមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើតាមប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# នៅតែខ្សឹងឆ្ងល់


ជ័យ សឿន

ឆាំ សុគន្ធ ហៅ ជ័យ សឿន គឺជាអតីតអ្នកទោសគុកជីហែនិងគុកព្រៃកពោធិ៍ ខេត្តកំពង់ចាម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សឿន បានទទួលរងនូវទារុណកម្មសព្វបែបយ៉ាងពីសំណាក់សន្តិសុខគុកនិងអ្នកសួរចម្លើយ ដើម្បីឲ្យឆ្លើយតាមសំណួរដែលអ្នកសួរចង់បាន ។ សន្តិសុខគុកបាននាំ សឿន ចេញពីមន្ទីរសុខជីហែទៅដាក់ព្រៃកពោធិ៍ និងក្រោយមកយកទៅដាក់នៅកោះញែកដើម្បីធ្វើការលត់ដំ ។ សឿន រំឭកឡើងវិញថា *«ពេលសួរចម្លើយ អ្នកសួរនោះ អត់មានសួរថាលួចគោ លួចក្របី អីទេគឺសួរថាអាគាត់ឯងខុសអីបានជាគេនាំមក? ។ ខ្ញុំចេះតែឆ្លើយថាអត់ខុសអីទេៗ ខ្ញុំមិនដឹងទេ ។ ខ្ញុំឆ្លើយមិនចំចំណុចដែលពួកវាចង់បាន ពួកវាទាត់ធាក់និងធ្វើទារុណកម្មខ្ញុំយ៉ាងខ្លាំង»* ។

សឿន កើតនៅភូមិតាអេវ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ នៅឆ្នាំ១៩៧២ ភូមិតាអេវជាតំបន់រំដោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ អ្នកភូមិច្រើនប្រកបរបរដួញដូរបារីពីកោះចិន ជីហែ យកទៅលក់នៅព្រៃកឆ្លងជាហូរហែ ។ សឿន ប្រកបមុខរបររត់ម៉ូតូឌុបនៅក្នុងស្រុកភូមិ ។ ក្នុងឆ្នាំដដែល សឿន ត្រូវបានតែងតាំងជាមេឃុំទន្លេបិទ ។ ឆ្នាំ១៩៧៥ សឿន បានលាលែងពីការងារ ដោយសារគាត់មានជំងឺ ។

នៅពេលខ្មែរក្រហមវាយដណ្តើមបានប្រទេសកម្ពុជាទាំងស្រុង សឿន មិនត្រូវបានជម្លៀសចេញពីភូមិឋានទេ គាត់ត្រូវអង្គការចាត់តាំងឲ្យចូលរួមបង្កើតសហករណ៍និងធ្វើស្រែដកស្ទូងជាមួយប្រជាជននៅក្នុងភូមិ ។ ឆ្នាំ១៩៧៧ ថ្ងៃមួយនៅពេលគាត់ឡើងពីភ្ជួរស្រែវិញ ស្រាប់តែប្រធានភូមិឈ្មោះ កេត ជន ជិះកង់មកប្រាប់ថាអង្គការហៅឲ្យទៅប្រជុំនៅផ្ទះគាត់ ។ កេត ជន បានតឿនឲ្យ សឿន ប្រញាប់ប្រញាល់ឡើងព្រោះមានគេចាំនៅឯផ្ទះ ។ ប្រធានភូមិនោះក៏ឲ្យកង់មក សឿន ជិះ ចំណែកគាត់ដើរទៅកាន់វាលស្រែ ។ នៅពេលទៅដល់មុខផ្ទះប្រធានភូមិ សឿន បានឃើញសន្តិសុខស្រុកវ័យក្មេង២នាក់ ដែលម្នាក់ស្ពាយកាំភ្លើង បានភ្ជង់ពីក្រោយខ្នង សឿន ហើយប្រាប់ថា *«អង្គការមិនប្រជុំនៅទីនេះទេ អង្គការឲ្យទៅរៀនសូត្រនៅអនុវិទ្យាល័យជីហែដែលមានចម្ងាយ៥-៦គីឡូម៉ែត្រពីភូមិ* ។ សឿន ត្រូវដឹកតាមកាណូតមកដាក់នៅក្នុងបន្ទប់រៀនមួយ ។ ពេលនោះគាត់ក្រឡេកឃើញបុរសម្នាក់នៅក្នុងបន្ទប់នោះជាស្រេច ។ សន្តិសុខនោះបានបញ្ជាឲ្យ សឿន ដោះសម្លៀកបំពាក់អស់ ដោយទុកតែខោខ្លីមួយប៉ុណ្ណោះ ហើយចាប់គាត់ដាក់ខ្នោះដៃខ្នោះជើងភ្លាម ។ សឿន ងឿងឆ្ងល់និងតក់ស្លុតជាខ្លាំងនៅពេលជួបប្រទះហេតុការណ៍បែបនេះ *«ខ្ញុំមិនដឹងរត់ទៅខាងណាទេ បើកាំភ្លើងគេភ្ជង់ពីក្រោយយើងជាប់ ។ នៅពេលបើកទ្វារបន្ទប់រៀន ស្រាប់តែឃើញមនុស្សប្រុសម្នាក់នៅក្នុងនោះជាស្រេចមិនដឹងជាជាប់នៅក្នុងបន្ទប់នេះតាំងពីពេលណាមក ។ ខ្ញុំភ័យណាស់ នឹកក្នុងចិត្តថាមិនរស់ទេ ។ កងសន្តិសុខក្មេងៗអាយុប្រហែល១៨ឆ្នាំ បានមកដកយកសម្ភារខ្ញុំអស់ ដូចជា បារី ដែកកេះក៏គេមិនឲ្យយើងមានទេ គេដោះខោអាវយើងចេញទុកតែខោខ្លីមួយឲ្យយើងស្លៀកប៉ុណ្ណោះ»* ។

នៅវេលាប្រហែលម៉ោង៧យប់ថ្ងៃដដែល សន្តិសុខគុកបានយកក្រណាត់មករុំភ្នែករបស់ សឿន ហើយបណ្តើរទៅកាន់បន្ទប់សួរចម្លើយ ។ សឿន ស្គាល់មុខអ្នកដែលនាំគាត់ទៅ ប៉ុន្តែមិនស្គាល់មុខអ្នកដែលសួរចម្លើយគាត់ឡើយ ។ សូម្បីតែកន្លែងសួរចម្លើយគាត់ក៏មិនដឹងថាបែរទៅទិសខាងណាដែរ ។ សឿន ត្រូវកងសន្តិសុខជាច្រើននាក់ សួរចម្លើយជាច្រើនដងជាមួយនឹងសំណួរដដែលៗ ព្រមទាំងធ្វើទារុណកម្មវាយទាត់ធាក់និងយកស្នែងគោមកចាក់ចង្កេះគាត់ទៀតផង ។ សឿន សន្លប់ពីរដងនៅពេលសួរ

ចម្លើយនោះ ។ សឿន និយាយថា “សន្តិសុខក្មេងៗដែលមកនាំខ្ញុំទៅសួរចម្លើយបានយកក្រណាត់បិទភ្នែកខ្ញុំ មានម្នាក់ផាក់ស្មាខ្ញុំ ព្រមទាំងទាញចុងក្រណាត់ម្ខាង ហើយម្នាក់ទៀតទាញចុងក្រណាត់ម្ខាងទៀត ធ្វើឲ្យភ្នែកខ្ញុំឡើងដាំហើម ក្តៅក្រហល់ក្រហាយ ។ ពេលសួរចម្លើយម្តងៗយូរណាស់ ផ្លាស់វេនគ្នាសួរម្តងម្នាក់ ហើយអ្នកធ្វើទារុណកម្មចាំតែវាយយើងតាមបញ្ជារបស់អ្នកសួរប៉ុណ្ណោះ ។ ដំបូងគេសួរអំពីប្រវត្តិរូបខ្ញុំ ហើយក្រោយមក សួរតែសំណួរដដែលថាតើ ហ្អែងខុសអីបានជាគេនាំមក ។ អង្គការភ្នែកម្នាស់ បើយើងមិនខុសអង្គការមិននាំមកទេ ដល់ផ្លូវបត់ហើយ ពស់ចឹកឥឡូវហើយ ។ គេបង្ខំឲ្យយើងឆ្លើយ ។ ទារុណកម្មដែលខ្ញុំមិនអាចទ្រាំបានគឺការចាក់ចង្កេះនឹងស្នែងគោ ខ្ញុំឈឺចាប់ខ្លាំងណាស់ ។ ខ្ញុំខំរកនឹកមើលកំហុសរបស់ខ្លួនដែរ តែមិនដឹងថាខុសអី ដល់ធ្វើទារុណកម្មខ្លាំងពេកទៅ ខ្ញុំចង់តែឲ្យពួកវាសម្លាប់ខ្ញុំភ្លាមៗ ។ ខ្ញុំស្បថនៅចំពោះមុខពួកវាថា បើសិនជាខ្ញុំបានប្រព្រឹត្តខុសសូមឲ្យស្លាប់នៅទីនេះចុះ ខ្ញុំស្មោះត្រង់ទេ មិត្តឯងធ្វើបាបខ្ញុំដូច្នេះ បើជាតិក្រោយមានមែន ខ្ញុំនឹងចងពៀរមិត្តឯង៥០០ជាតិ” ។

សឿន និងអ្នកទោសទាំងអស់តែងតែលួចសួរគ្នាអំពីមូលហេតុដែលអង្គការចាប់មកដាក់នៅក្នុងបន្ទប់ឃុំឃាំង ប៉ុន្តែអ្នកទាំងនោះនៅតែរកនឹកមិនឃើញអំពីមូលហេតុសោះ ។ សឿន និយាយថា “ខ្ញុំសួរគេ គេសួរខ្ញុំវិញអំពីមូលហេតុដែលអង្គការចាប់យកមកដាក់នៅក្នុងគុកនេះ យើងសួរគ្នាទៅវិញទៅមក ប៉ុន្តែយើងមិនដឹងដូចគ្នា គ្រាន់តែឡើងពីស្ទូងភ្លាមអង្គការប្រាប់ថាឲ្យមករៀនសូត្រ ។ យើងក៏មកតាមបញ្ជារបស់អង្គការ យើងអត់ដឹងខ្យល់អីសោះ” ។

របបហូបចុកសម្រាប់អ្នកទោសនៅទីនោះមានសភាពយ៉ាប់យ៉ឺនណាស់ ។ សឿន ទទួលបានបបរពោតលាយដំឡូងពីរពេលក្នុងមួយថ្ងៃ ។ សឿន បត់ជើងធំហូរដូចទឹក ដោយសារគាត់មានជំងឺពោះវៀននិងអាហារហូបចុកមិនសមរម្យ ។ “ក្រពះខ្ញុំអន់ណាស់ ។ ពេលខ្លះវាបុកស្ទីកគ្រែឲ្យយើងហូប យើងឃ្លានហូបឡើងអស់គ្មានសល់ទេ” ។ អ្នកទោសទាំងអស់តែងជួយយកអាសាគ្នាទៅវិញទៅមក ជាពិសេសអ្នកទោសដែលចូលមកថ្មី ហើយត្រូវទារុណកម្ម ។ ទឹកនោមនិងស្មៅចិញ្ចៀន គឺជាថ្នាំព្យាបាលជំងឺគ្រាំរបស់អ្នកទោសនៅទីនោះ ។ សឿន រំឭកថា “ខ្ញុំនិយាយឲ្យអស់កេរ្តិ៍ចុះ នៅពេលអ្នកទោសត្រូវគេវាយហើមភ្នែកហើមមុខមាត់ យើងប្រាប់គ្នាឲ្យនោម ហើយយកទឹកនោមមកស្អំចំកន្លែងដែលឈឺនោះព្រោះវាអាចជួយបន្ថយការឈឺចាប់យើងបានខ្លះ ។ ស្មៅចិញ្ចៀនក៏ជាថ្នាំព្យាបាលស័ក្តិសិទ្ធិដែរ ។ ជួនកាលនៅពេលធ្វើការយើងធ្វើជាដួលទៅលើស្មៅ ហើយលួចបោចស្មៅចិញ្ចៀនយកមកទំពាស្អំមុខរបួស ។ សន្តិសុខខ្លះមិនស្តីឲ្យយើងទេ នៅពេលយើងសុំបោចស្មៅនោះ ប៉ុន្តែខ្លះទៀតមិនឲ្យយើងបោចទេ វាជេរប្រទេចយើងថែមទាំងវាយយើងទៀត” ។

រយៈពេលមួយខែក្រោយមក ដោយមិនអាចឈ្លេចយកចម្លើយបាន សន្តិសុខគុកបាននាំគាត់និងអ្នកទោសមួយចំនួនទៀតដោយរុំភ្នែកនឹងក្រណាត់យ៉ាងជិត ដាក់កាណូតនៅវេលាយប់ទៅបញ្ជូនទៅគុកព្រែកពោធិ៍ទៀត ។ សឿន ដឹងរឿងនេះ ដោយសារគាត់ឮសន្តិសុខគុកនិយាយគ្នានៅពេលដឹកជញ្ជូនអ្នកទោសចេញ ។ គ្រាន់តែទៅដល់ទីនោះ សឿន ត្រូវកងសន្តិសុខសួរចម្លើយភ្លាម ។ សឿន ទទួលទារុណកម្មខ្លាំងនៅពេលសួរចម្លើយ ប៉ុន្តែគាត់នៅតែឆ្លើយថា “គាត់មិនដឹងថាគាត់ខុសអីទេ” ។ សន្តិសុខសួរចម្លើយបានធ្វើទារុណកម្ម សឿន កាន់តែខ្លាំង ។ សឿន សន្លប់បាត់ស្មារតីពីរដង ។ “គេច្រកក្បាលខ្ញុំដោយថង់ផ្លាស្ទិក ហើយចងជើងខ្ញុំព្យួរឡើងលើ គេយោលខ្ញុំទៅមកៗ ហើយគេទះផាច់ខាងនេះ ផាច់ខាងនោះ ខ្ញុំសន្លប់អត់ដឹងខ្លួនទេ ។ រួចហើយគេចាក់ទឹកឲ្យខ្ញុំដឹងខ្លួនឡើងវិញ ។ ខ្ញុំឈឺចាប់ខ្លាំងណាស់នៅពេលដឹងខ្លួន” ។

សឿន បញ្ជាក់ថា ការហូបចុកនៅព្រែកពោធិ៍មានកម្រិត សូម្បីតែទឹកក៏មានកម្រិតដែរ មិនដូចនៅមន្ទីរសន្តិសុខដីហែឡើយ ។ “គេឲ្យទឹកយើងផឹកតែមួយកំប៉ុងទឹកដោះគោប៉ុណ្ណោះ កំប៉ុងមួយប្រើជាមួយគ្នាទៅ ប៉ះអ្នកខ្លះចិត្តល្អវាជួសឲ្យយើងពេញមួយកំប៉ុងទៅ អ្នកខ្លះចិត្តអាក្រក់វាដាក់ឲ្យយើងតែកន្លះកំប៉ុង ។ បើនៅដីហែ យើងផឹកទឹកបានតាមចិត្ត” ។

ក្នុងរយៈពេល១០ថ្ងៃ សឿន ត្រូវបានសួរចម្លើយតែមួយយប់ដំបូងប៉ុណ្ណោះ រួចហើយត្រូវសន្តិសុខបញ្ជូនត្រឡប់មកគុកដីហែវិញ ។ សឿន មិនបានដឹងអំពីមូលហេតុនៃការបញ្ជូន

ត្រឡប់មកកន្លែងដើមឡើយ ។ សឿន មកដល់ដីហែបានតែប៉ុន្មានថ្ងៃ ស្រាប់តែលេចចេញសន្តិសុខស្ត្រីក្មេងម្នាក់អាយុប្រហែល ២០ឆ្នាំ [បើតាម ឆេង (សន្តិសុខគុកនៅដីហែ) ប្រាប់ សឿន ថា ស្ត្រីនោះមកពីភូមិភាគនិរតី] នៅចំពោះមុខគាត់ ។ អ្នកនៅទីនោះហាក់ដូចជាកោតខ្លាចនារីនោះខ្លាំងណាស់ ។ នារីនោះបានសួរនាំ សឿន នៅក្នុងបន្ទប់សួរចម្លើយតែពីរនាក់ទេ ។ ស្ត្រីវ័យក្មេងនោះបានស្រាយក្រណាត់ចេញពីភ្នែករបស់ សឿន ហើយក៏សួរក្រែង សឿន ចំណាំមុខគាត់ពីមុន ។ សឿន មិនចាំថានារីនោះជានរណាឡើយ ព្រោះគាត់ស្គាល់មនុស្សច្រើននិងធ្លាប់ជួយយកអាសាមនុស្សក៏ច្រើន ។ «នៅពេលសួរចម្លើយលើកនេះប្លែកណាស់ ព្រោះពេលខ្ញុំចូលក្នុងបន្ទប់ស្រាប់តែឮសំឡេងមនុស្សស្រីសួរឈ្មោះខ្ញុំនិងប្រពន្ធដើមខ្ញុំ ហើយនិយាយថា សំណុំរឿងអ្នកទោសទាំងអស់គាត់ក្តាប់បានថាអ្នកណាខុសអ្វី ប៉ុន្តែចំពោះខ្ញុំគាត់ដូចជាក្តាប់មិនបានសោះ ។ ស្រាប់តែក្រោយមកគាត់ស្រាយក្រណាត់រុំភ្នែកខ្ញុំចេញហើយសួរខ្ញុំត្រង់ៗថា មានធ្លាប់ឱបមនុស្សស្រីម្នាក់ដែលប្រកបរបរដួញដូរបារីនៅឆ្លូងទេ ខ្ញុំឆ្លើយថាធ្លាប់ ។ គាត់សួរថា មានធ្លាប់ធ្វើបាបស្ត្រីនោះទេ ខ្ញុំឆ្លើយថា អត់ធ្លាប់ទេ គាត់សួរទៀតថា តើស្ត្រីនោះស្អាតដូចគាត់ទេ? ខ្ញុំឆ្លើយតាមត្រង់ថាមិនស្អាតអីចឹងទេ ព្រោះស្ត្រីនោះរាងស្គមហើយសាច់មានកន្ទួលច្រើនៗ ។ ស្ត្រីនោះសួរខ្ញុំទៀតថាមានធ្លាប់ធ្វើបាបស្ត្រីនេះទេ? ខ្ញុំឆ្លើយថាមិនធ្លាប់ទេ ។ [ខ្ញុំក៏នឹកដល់ហេតុការណ៍ដែលខ្ញុំឱបស្ត្រីម្នាក់កាលជិតបែករបបលន់នល់ ។ ខណៈពេលនោះស្នូរផ្ទុះគ្រាប់លាន់សន្ធឹកខ្លាំងធ្វើឲ្យម៉ូតូខ្ញុំដួលទៅផ្លូវម្ខាង ខ្ញុំក៏ដួលលើស្ត្រី នោះ ហើយខ្ញុំយកខ្លួនរងខ្លាចក្រែងអំបែងគ្រាប់ត្រូវ] ។ បន្ទាប់មកគាត់ប្រាប់ឲ្យខ្ញុំខិតខំកសាងខ្លួន ក្រែងអង្គការលើកលែងទោស ព្រោះខ្ញុំធ្លាប់មានគុណនឹងអង្គការ ។ ខ្ញុំងឹងងីមិនដឹងថា ខ្លួនឯងមានគុណអីនឹងអង្គការឡើយ» ។

៣ថ្ងៃក្រោយមក សឿន ត្រូវបានបញ្ជូនទៅលត់ដំនៅកោះញែកជាមួយអ្នកទោសប្រហែល២០នាក់ទៀត ភ្នែករបស់ សឿន នៅតែចងក្រណាត់ ហើយដៃជើងនៅតែជាប់ខ្នោះដដែល ។ នៅពេលបញ្ជូនអ្នកទោសទាំងនោះចេញពីដីហែ សមមិត្តនារីដែលសួរចម្លើយខ្ញុំ ក៏នៅឈរមើលដែរ ។

នៅកោះញែក សឿន ត្រូវអង្គការចាត់ឲ្យរែកទឹកស្រោចស្ពៃ ។ នៅទីនោះអ្នកទោសមិនត្រូវបានធ្វើទារុណកម្មទេ ប៉ុន្តែ សឿន រឹតតែមានការតក់ស្លុតព្រោះមនុស្សដែលជាប់នៅទីនោះតែងតែបាត់ខ្លួនជាបន្តបន្ទាប់ ។ ជាងនេះទៅទៀត សឿន ធ្លាប់ត្រូវសមមិត្ត គឹម ជាអ្នកគ្រប់គ្រងនៅកោះញែកទាត់ធាក់មួយទំហឹងនៅពេលគាត់រើសដំឡូងមីមកហូប ។

នៅឆ្នាំ១៩៧៨ ដោយអត់ទ្រាំតទៅទៀតមិនបាន សឿន និងមិត្តភក្តិក៏បបួលគ្នារត់ចេញពីកោះញែកនៅពេលដែលគាត់ស្រោចស្ពៃវេលាយប់ ។ សឿន រត់ទៅដល់វាលម្ទ ហើយបានជួបប្រធានភូមិឈ្មោះ ឡៃ ដែលកាលពីជំនាន់ លន់ នល់ គាត់ធ្លាប់បានជួយយកអាសាឲ្យកន្លែងស្នាក់នៅនិងផ្តល់អាហារហូបចុកទៀតផង ។ ពេលនេះ ឡៃ បានជួយលាក់ប្រវត្តិនិងជួយផ្តល់កន្លែងស្នាក់នៅដល់ សឿន វិញ ។ ដើម្បីគេចពីការចាប់របស់អង្គការ សឿន ក៏ដូរឈ្មោះពី ឆាំ សុគន្ធ មក ជ័យ សឿន វិញ ។ សឿន នៅជួយមើលថែសេះនៅអង្គភាពរបស់ឡៃ ។ ក្រោយមក ឡៃ ត្រូវអង្គការហៅទៅបាត់រហូតដោយមិនដឹងមូលហេតុ ។

នៅពេលកងទ័ពវៀតណាមសម្រុកចូលប្រទេសកម្ពុជា សឿន ត្រូវអង្គការប្រាប់ឲ្យរៀបចំសេះនិងស្បៀងអាហារទៅកាន់ទីក្រុងភ្នំពេញ ។ ពេលធ្វើដំណើរមកដល់ស្គន់ សឿន បានលួចបន្ទូរកង់ រួចកុហកមេបញ្ជាការថា កង់ធូរសុំពេលសប់កង់សិនដើម្បីខ្លួនបានត្រឡប់មកស្រុកកំណើតវិញ ។ ពេលនោះ ដោយសារតែយន្តហោះទម្លាក់គ្រាប់បែកខ្លាំងពេក មេបញ្ជាការនោះក៏នាំក្បួនធ្វើដំណើរទៅទៀត ចំណែក សឿន ជិះកង់បកមកក្រោយវិញជាមួយអ្នករត់ទៅមួយចំនួនទៀត ។ «ដោយមើលសភាពការណ៍មិនស្រួល ខ្ញុំក៏មានគំនិតធ្វើដំណើរត្រឡប់ក្រោយ ដោយលួចបន្ធូរកង់ ហើយសុំអនុញ្ញាតមេបញ្ជាទៅសប់កង់សិន ។ វាស្មានថាកង់ធូរមែន ក៏ប្រាប់ឲ្យខ្ញុំសប់ឲ្យលឿនន្អាលចេញដំណើរទៅតាមក្រោយ ។ ខ្ញុំនិងអ្នកទៅជាមួយ៣-៤នាក់ទៀតធ្វើដំណើរមកស្រុកកំណើតវិញ ។ រឹតតែលំបាកថែមទៀតព្រោះកង់របស់ខ្ញុំត្រូវអ្នកទាំងនោះលួចយកទៅបាត់នៅពេលខ្ញុំឈប់សម្រាកតាម ផ្លូវ

ដូច្នេះខ្ញុំក៏ធ្វើដំណើរដោយថ្មើរជើងត្រឡប់មកផ្ទះ» ។

សឿន បានត្រឡប់មកដល់ស្រុកកំណើតវិញ នៅឆ្នាំ១៩៧៩ ។ ប្រពន្ធដើមរបស់គាត់ឈ្មោះ ណៃ សៀន បានរៀបការប្ដីថ្មី។ សឿន ក៏រៀបការប្រពន្ធមួយទៀតឈ្មោះរស់ សារឿន សព្វថ្ងៃអាយុ៥០ឆ្នាំ បានកូនស្រីម្នាក់ បច្ចុប្បន្ននាងមានអាយុ២២ឆ្នាំ ។

សព្វថ្ងៃ សឿន មានអាយុ៦០ឆ្នាំ ជាជំទប់ទី២ ក្នុងក្រុមប្រឹក្សាឃុំទន្លេបិទ ។ នៅពេលរំឭកដល់របបខ្មែរក្រហម សឿន រលីងរលោងទឹកភ្នែក ហើយក្ដុកក្ដួលក្នុងចិត្ត ។ មរតករបបខ្មែរក្រហមបានធ្វើឲ្យ សឿន មានជំងឺពោះវៀនព្រោះតែសន្តិសុខខ្មែរក្រហមធ្វើទារុណកម្មខ្លាំងពេកក្នុងពេលសួរចម្លើយម្ដងៗ ។ ចំណែកម្ដាយរបស់គាត់បានស្លាប់ដោយសារឈឺបាក់កម្លាំង និងប្អូនប្រុសពីរនាក់ត្រូវអង្គការហៅទៅរៀនសូត្រ ហើយក៏បាត់ដំណឹងរហូត ។ សឿន មិនសង្ឃឹមថាអ្នកទាំងពីរនៅរស់ឡើយ ពីព្រោះអ្នកទាំងពីរបាត់ខ្លួនតាំងពីឆ្នាំ១៩៧៥ម្ល៉េះ ប្រសិនបើនៅរស់ច្បាស់ជាមករកគាត់មិនខាន ។

សឿន និយាយថា «ខ្ញុំមិនយល់សោះហេតុអ្វីអង្គការចាប់ខ្ញុំទៅដាក់គុក និងធ្វើទារុណកម្មខ្ញុំបែបនេះ» ។ សឿន ចង់ដឹងអំពីការគ្រប់គ្រងរបស់របបខ្មែរក្រហមយ៉ាងខ្លាំង ។ គាត់ចាប់អារម្មណ៍នឹងឯកសារទាំងបួនប្រភេទ ដែលក្រុមនិស្សិតស្ម័គ្រចិត្តបានចែកជូនដល់ប្រជាពលរដ្ឋនៅស្រុកត្បូងឃ្មុំ ។ «ខ្ញុំចាប់អារម្មណ៍នឹងឯកសារទាំងនេះណាស់ គ្រាន់តែដឹងភ្លាមខ្ញុំជិះម៉ូតូទៅសុំខ្ចីឯកសារនេះពីមិត្តភក្ដិនៅភូមិដើងខាលមកមើល ព្រោះខ្ញុំចង់ដឹងថា អ្នកណាខ្លះនឹងត្រូវប្រឈមមុខនឹងការកាត់ទោស ហើយតើតុលាការនេះដំណើរការដល់ណាហើយ ។ ជាពិសេស ខ្ញុំចង់ចូលរួមតាមដានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដើម្បីខ្ញុំបាត់ងឿងឆ្ងល់ក្នុងចិត្ត» ។

**សុ ហ្សារីណា**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែររៀបចំកម្មវិធី «វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ»លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្ដីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពត៌មានទាំងឡាយស្ដីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនរបស់លោកអ្នកចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្ដារ ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

◆ រួមចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្ដីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្ដងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្ដីស្វែងរកការពិត ព្រមទាំងផ្ដល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌល ឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងពត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# ការិយាល័យពត៌មានសាធារណៈ

«ការិយាល័យពត៌មានសាធារណៈ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យពត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ពត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យពត៌មានសាធារណៈ» មានផ្តល់ជូននូវសេវា៤យ៉ាងៈ

**១) បណ្ណាល័យ ៖** នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ ៖** មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង ៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ ៖** ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យពត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជ័យ សុភារម្យ ឬ រ័ត្ន ដារា ពិដោរ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។


ក្រុមនិស្សិតធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា


ក្រុមដូនជីប្រជុំនៅបន្ទប់ពត៌មានសាធារណៈ

# ប្រភេទនៃការការពារក្តី

### ១) សេចក្តីផ្តើម

នៅក្នុងបរិបទនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ សិទ្ធិបដិសេធការចោទប្រកាន់ត្រូវបានផ្តល់ឲ្យជនជាប់ចោទ ។ ជាការពិត ការការពារក្តីដែលរឹងមាំនិងស្របច្បាប់គឺជាអ្វីដែលតម្រូវឲ្យមានមុនពេលផ្តន្ទាទោស ដើម្បីឲ្យស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិនៃយុត្តិធម៌ ។ ចុងចោទអាចលើកឡើងនូវការការពារខ្លួនមួយឬច្រើនដែលជាលទ្ធផលអាចទទួលបានការលើកលែងការចោទប្រកាន់ប្រសិនបើតុលាការជឿតាមការអះអាងនោះ ។

នៅចំពោះមុខសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិពិសេសនៅពេលដែលជនជាប់ចោទលើកឡើងនូវការអះអាងការពារខ្លួនណាមួយជនជាប់ចោទមិនចាំបាច់ត្រូវតែបង្ហាញឲ្យអស់មន្ទិលសង្ស័យចំពោះការអះអាងនេះទេ ។ ដោយឡែក វាជាបន្ទុករបស់ព្រះរាជអាជ្ញាក្នុងការជំទាស់ថា ការអះអាងការពារខ្លួននោះឥតមានមន្ទិលសង្ស័យ ប៉ុន្តែ អាស្រ័យទៅលើប្រភេទនៃការការពារខ្លួនដែលបានលើកឡើង ។ ចុងចោទអាចតម្រូវឲ្យបង្ហាញភ័ស្តុតាង ដូចជាត្រូវបង្ហាញថាការអះអាងការពារខ្លួននោះជាការពិត ឬចុងចោទមានបន្ទុកដើម្បីបង្ហាញពីអាទិភាពនៃការការពារនោះនៅលើតុល្យភាពនៃភាពប្រហែល ។

ប្រភេទនៃការការពារខ្លួនមានពីរប្រភេទខុសៗគ្នាគឺ ការការពារក្តីដោយលើកពីកង្វះខាតភ័ស្តុតាង និងការការពារស្របច្បាប់ ឬហៅម្យ៉ាងទៀតថា ការការពារវិជ្ជមាន ។

ការការពារខ្លួនដោយលើកពីកង្វះខាតភ័ស្តុតាងគឺជាការការពារមួយដែលនៅក្នុងសវនាការ ចុងចោទត្រូវបង្ហាញភ័ស្តុតាងឲ្យឃើញថា ព្រះរាជអាជ្ញាបានខកខានក្នុងការបង្ហាញនូវធាតុសំខាន់នៃបទល្មើស ។ ប្រសិនបើចៅក្រមសន្និដ្ឋានថាព្រះរាជអាជ្ញាខកខានមិនបានបំពេញបន្ទុកនៃការបង្ហាញភ័ស្តុតាង ចុងចោទនឹងត្រូវបានលើកលែងការចោទប្រកាន់ ។

គោលបំណងនៃការការពារខ្លួននេះ គឺដើម្បីលើកឡើងនូវភាពមន្ទិលសង្ស័យទាក់ទងនឹងធាតុផ្សំមួយនៅក្នុងសំណុំរឿងរបស់ព្រះរាជអាជ្ញា ។ ចុងចោទធ្វើយ៉ាងនេះបានតាមវិធីពីរយ៉ាង ។ ទីមួយ គាត់អាចអះអាងថា សកម្មភាពដែលបានចោទប្រកាន់ថាជាបទល្មើសព្រហ្មទណ្ឌ តាមពិតមិនមែនជាសកម្មភាពព្រហ្មទណ្ឌទេ ។ នៅក្នុងកាលៈទេសៈនេះ មេធាវីជនជាប់ចោទត្រូវជំទាស់ទៅនឹងអង្គហេតុនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ។ ទីពីរ ចុងចោទមិនជំទាស់ទៅនឹងអង្គហេតុនៃការចោទប្រកាន់ទេ ប៉ុន្តែបានបដិសេធការចូលរួមរបស់ជនចាប់ចោទនៅក្នុងអង្គហេតុនៃការចោទប្រកាន់ទាំងនោះ ដូចជាការលើកឡើងថា ជនជាប់ចោទមិនស្ថិតនៅកន្លែងកើតហេតុទេឬមានការភ័ន្តច្រឡំអត្តសញ្ញាណ ។

ការការពារវិជ្ជមាន ប្រសិនបើអាចបង្ហាញបាន នឹងបណ្តាលឲ្យមានការលើកការចោទប្រកាន់ជនជាប់ចោទ បើទោះបីជាព្រះរាជអាជ្ញាបានបង្ហាញការអស់មន្ទិលសង្ស័យនូវគ្រប់ធាតុផ្សំ



អ្នកទោសមន្ទីរ ស-២១

ទាំងអស់នៅក្នុងនិយមន័យបទល្មើសនោះក៏ដោយ ។ ការការពារក្តីទាំងនេះគឺកង្វះខាតធាតុអត្តនោម័តិ ឬធាតុចិត្តសាស្ត្រចុះថយ ។ ការការពារទាំងនេះរួមទាំងសកម្មភាពដែលប្រព្រឹត្តនៅពេលដែលជនជាប់ចោទមានសតិវិបល្លាស ប្រព្រឹត្តដោយកត្តប្រឡំអង្គហេតុ ប្រព្រឹត្តដោយទទួលការគំរាមកំហែងឬទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ ។ ច្បាប់ព្រហ្មទណ្ឌបានទទួលស្គាល់ប្រភេទសំខាន់ពីរនៃការការពារខ្លួនដែលក្នុងនេះមានការបង្ហាញភ័ស្តុតាងនិងការដោះសាដែលនឹងពន្យល់ឲ្យបានក្បោះក្បាយនៅខាងក្រោមនេះ ÷

សូមកត់សម្គាល់ថា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញខកខានមិនបានបញ្ជាក់ពីទំហំនៃការអះអាងការពារខ្លួនដែលមានសម្រាប់ចុងចោទនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញទេ ។ ប៉ុន្តែក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦របស់កម្ពុជាបានចែងនូវការអះអាងការពារក្តីជាមាត្រដ្ឋាន ដែលអាចលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ ជាងនេះទៅទៀត គ្រប់គ្នាអាចស្វែងរកការណែនាំអំពីការអះអាងការពារក្តីដែលបានលើកឡើងរួចហើយ នៅក្នុងកម្រិតអន្តរជាតិ ។

## ២) ការអះអាងការពារក្តីសំខាន់ៗដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦របស់កម្ពុជា

ការអះអាងការពារក្តីដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ គឺដូចគ្នាទៅនឹងប្រព័ន្ធយុត្តិធម៌របស់ប្រទេសជាច្រើន ។ ការអះអាងការពារក្តីទាំងនេះមាន ÷

### ក) សតិវិបល្លាស

ជនទាំងឡាយណាដែលតុលាការរកឃើញថាមានសតិវិបល្លាសគឺមិនទទួលខុសត្រូវចំពោះសកម្មភាពឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តទេ ប្រសិនបើជននោះមានសតិវិបល្លាសនៅពេលប្រព្រឹត្តបទល្មើស ។ សតិវិបល្លាសត្រូវតែបង្ហាញឲ្យឃើញដោយប្រើប្រាស់មធ្យោបាយដែលពាក់ព័ន្ធ ។ នៅពេលមានមន្ទិលសង្ស័យ ចៅក្រមត្រូវតែធ្វើការស៊ើបអង្កេតដើម្បីកំណត់អំពីស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទ ។

### ខ) ករណីប្រធានស័ក្តិ

ជនល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌចំពោះសកម្មភាពព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្តទេ ដោយសារកម្លាំងដែលមិនអាចទប់ទល់បាន ។ “ប្រធានស័ក្តិ” ត្រូវបានឲ្យនិយមន័យថា ស្ថានភាពសំខាន់បំផុតដែលជនល្មើសត្រូវប្រឈមមុខគ្រោះអាសន្នដែលមិនអាចចៀសវាង និងដែលមិនមែនបង្កឡើងដោយជនល្មើសនោះទេ ហើយដែលជនជាប់ចោទអាចចៀសផុតគ្រោះថ្នាក់នោះទាល់តែខ្លួនប្រព្រឹត្តបទល្មើស ។

### គ) បទបញ្ជាច្បាប់និងអាជ្ញាធរច្បាប់

មិនមានកំហុសកើតឡើងទេ ប្រសិនបើសកម្មភាពនោះទទួលបញ្ជាពីច្បាប់និងពីអាជ្ញាធរច្បាប់ ។ នៅក្នុងករណីនៃបញ្ជាមិនស្របច្បាប់ដែលបញ្ជាដោយអាជ្ញាធរស្របច្បាប់ ចៅក្រមនឹងកំណត់អំពីកម្រិតនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ។

គួរកត់សម្គាល់ថា ការអះអាងការពារក្តីបែបនេះ គឺត្រូវបានហាមប្រាមនៅក្នុងច្បាប់អន្តរជាតិ ។ ដូច្នេះ ករណីនេះអាចត្រូវបានលើកឡើងទាក់ទងទៅនឹងបទល្មើសជាតិ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។

### ឃ) ការការពារធម្មានុរូប

សម្ងាប់ឬបង្ករបួសស្នាមដល់មនុស្សម្នាក់មិនបង្កើតជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមទេ ប្រសិនបើសកម្មភាពនោះត្រូវបានប្រព្រឹត្តឡើងដើម្បីការពារខ្លួនឯង ឬការពារអ្នកដទៃទៀត ។ ការប្រើប្រាស់កម្លាំង អាចធ្វើទៅបានតែក្នុងករណីដែលត្រូវប្រើប្រាស់តទល់ទៅនឹងការវាយប្រហារមិនសមហេតុផលប៉ុណ្ណោះ ។

### ង) អាយុ

ជនល្មើសដែលមានអាយុក្រោម១៨ឆ្នាំ នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត អាចមានកំហុសតែក្នុងករណីដែលអាចរកឃើញថាមានលទ្ធភាពយល់ដឹងអំពីបទល្មើសដែលបានប្រព្រឹត្តនោះ ។

### ច) អាជ្ញាយុកាលច្បាប់

អាជ្ញាយុកាលច្បាប់គឺជារយៈពេលដែលច្បាប់អនុញ្ញាតឲ្យជំនុំជម្រះចំពោះសកម្មភាពព្រហ្មទណ្ឌណាមួយ ។ ប្រសិនបើរយៈពេលដែលអនុញ្ញាតដោយច្បាប់នេះកន្លងផុត បណ្តឹងព្រហ្មទណ្ឌ ឬបទចោទប្រកាន់មិនអនុញ្ញាតឲ្យធ្វើឡើងទេ ។ នៅក្នុងប្រទេសកម្ពុជា បទល្មើសឧក្រិដ្ឋដែលកើតឡើងជាង១០ឆ្នាំទៅហើយ មិន

អាចជំនុំជម្រះបានទៀតទេ ។

មាត្រា៣ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានពន្យារអាជ្ញាយុកាលច្បាប់ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បន្ថែមចំនួន៣០ឆ្នាំទៀតសម្រាប់បទល្មើសនៅក្នុងច្បាប់ជាតិ ។

**៣) ប្រភេទនៃការការពារក្តីដែលជាធម្មតាត្រូវបានលើកឡើងនៅចំពោះមុខសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិ**

ការការពារក្តីខាងក្រោមនេះត្រូវបានលើកឡើងដោយមេធាវីចុងចោទនៅចំពោះមុខសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិពិសេស ជាពិសេសសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិរ៉្វាន់ដា និងយូហ្គោស្លាវី ។ ប៉ុន្តែ ការការពារក្តីប្រភេទខ្លះ ត្រូវបានដកចេញពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។

**ក) ការការពារក្តីដែលត្រូវបានដកចេញនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ**

**បញ្ជាថ្នាក់លើ**

ចាប់តាំងពីសាលាជំនុំជម្រះក្តីនូរ៉ឺមប៊ឺក ការណ៍ដែលថាអ្នកក្រោមបង្គាប់ធ្វើតាមបញ្ជារបស់ថ្នាក់លើ មិនមែនជាការការពារខ្លួននៅចំពោះមុខបទល្មើសអន្តរជាតិទេ ។

ជាការពិត បញ្ជាថ្នាក់លើមិនត្រូវបានចាត់ទុកថា ជាការការពារក្តី នៅក្រោមលក្ខន្តិកៈ នៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវី (មាត្រា៧(៤) និងលក្ខន្តិកៈសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិរ៉្វាន់ដា (មាត្រា៦(៤) និងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ មាត្រា២៩ បានចែងស្រដៀងគ្នានេះដែរថា "ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋទៅតាមបទបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយមិនអាចជួយជនសង្ស័យនេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនោះបានឡើយ" ។

**អភ័យឯកសិទ្ធិរដ្ឋ**

ចំពោះជនសង្ស័យ ឬជនជាប់ចោទពីបទល្មើសឧក្រិដ្ឋកម្មអន្តរជាតិ អភ័យឯកសិទ្ធិដោយផ្នែក អភ័យឯកសិទ្ធិនេះអាចការពាររាល់សកម្មភាពបម្រើជាតិទាំងឡាយរបស់ប្រមុខរដ្ឋពីចំណាត់ការផ្លូវច្បាប់) និងអភ័យឯកសិទ្ធិពេញលេញ (រួចផុតពីចំណាត់ការផ្លូវច្បាប់នូវគ្រប់រាល់សកម្មភាពទាំងអស់របស់ប្រមុខរដ្ឋ បើទោះបីជាសកម្មភាពនោះជាសកម្មភាពសាធារណៈ ឬឯកជនក៏ដោយ) មិនអាចការពារអ្នកទាំងនេះឲ្យរួចផុតពីការជំនុំជម្រះទោសឡើយ ។

មាត្រា២៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចែងថា "តួនាទីឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននោះឡើយ" ។

**ការគោរពច្បាប់ក្នុងស្រុក**

បុគ្គលគ្រប់រូបមិនអាចពួននៅក្រោយខ្នងរដ្ឋរបស់ខ្លួន ហើយអះអាងថា ខ្លួនធ្វើសកម្មភាពស្របតាមឬអនុវត្តកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់ជាតិ ។ សាលាជំនុំជម្រះក្តីនូរ៉ឺមប៊ឺក បានបដិសេធការអះអាងបែបនេះ ។

**សវនាការរូបវន្តបុគ្គលនៅចំពោះមុខសាលាជំនុំជម្រះក្តីយោធានូរ៉ឺមប៊ឺក**




អ្នកទោសមន្ទីរ ស-២១

ចុងចោទបានអះអាងថាពួកគេមិនគួរមានកំហុសដោយសារប្រព្រឹត្តសកម្មភាពនៅក្នុងដែនអំណាចរបស់ខ្លួន ក្រោមបញ្ជារបស់ច្បាប់និងក្រឹត្យរបស់អាល្លឺម៉ង់នោះទេ ។ សាលាជំនុំជម្រះក្តីនូរ៉ឹមប៊ឺកបានអនុវត្តច្បាប់ ដូចដែលបានប្រកាសដោយធម្មនុញ្ញសាលាជំនុំជម្រះក្តីយោធាព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ១០ ដែលតាមរយៈច្បាប់នេះ ច្បាប់អន្តរជាតិគឺខ្ពស់ជាងច្បាប់ទាំងឡាយរបស់អាល្លឺម៉ង់ ។ ច្បាប់បែបនេះមិនលើកលែងដល់បុគ្គលដែលបានអះអាងថា ខ្លួនធ្វើសកម្មភាពស្របតាមច្បាប់ដែលមានជាធរមាននៅពេលបទល្មើសនោះប្រព្រឹត្ត ។ ប៉ុន្តែការចូលរួមនៅក្នុងការអនុវត្ត និងការអនុម័តច្បាប់បែបនេះ បង្កើតជាបទល្មើសឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយសកម្មភាពនេះស្មើនឹងការសមគំនិតក្នុងការប្រព្រឹត្តបទល្មើសដែរ ។

## ការការពារខ្លួន "ទូខ្វូខ្វ"

"ទូខ្វូខ្វ" (ការការពារដែលលើកហេតុផលថា ខ្លួនប្រព្រឹត្តអំពើឃោរឃៅដោយសារតែភាគីម្ខាងទៀតប្រព្រឹត្តអំពើបែបនោះមុន) គឺជាការសារភាពដែលថា ភាគីម្ខាងទៀតប្រព្រឹត្តអំពើបែបនោះមុន ។ សត្រូវបានវាយប្រហារជនស៊ីវិលរបស់យើង ហើយការណ៍នេះបណ្តាលឲ្យយើងធ្វើការវាយប្រហារលើជនស៊ីវិលរបស់សត្រូវវិញ ។

កាលពីអតីតកាល សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវីយល់ឃើញថា "ទូខ្វូខ្វ" គឺ"មិនទាក់ទងទេ" ដោយសារការអះអាងនេះមិនបានបង្ហាញថាមានទោស ឬមិនមានទោសចំពោះបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ។ តុលាការនេះបានយល់ឃើញទៀតថា "ទូខ្វូខ្វ" មិនអាចអនុវត្តបានទេនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិដែលបង្កើតកាតព្វកិច្ចដែលទទួលស្គាល់ជាទូទៅ ។ អំពើរំលោភដោយភាគីសមាជិកនៃច្បាប់សង្គ្រាមមិនអាចដោះសាថា ភាគីសមាជិកមួយទៀតជាអ្នករំលោភមុននោះទេ ទោះក្នុងកាលៈទេសៈណាក៏ដោយ ។ ជាងនេះទៅទៀត ការការពារបែបនេះទាក់ទងទៅនឹងការទទួលខុសត្រូវរបស់រដ្ឋជាជាងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល ។ ការពារខ្លួនប្រភេទនេះត្រូវបានលើកឡើង ហើយត្រូវបានបដិសេធដោយសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវី នៅក្នុងសំណុំរឿងព្រះរាជអាជ្ញាទល់នឹង ខូបប្រេសស្គីក (Prosecutor v. Kupreskic Case) ។

អ្នកទោសមន្ទីរ ស-២១




## អាជ្ញាយុកាលច្បាប់

អនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីការមិនអនុវត្តអាជ្ញាយុកាលច្បាប់ចំពោះបទល្មើសឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានហាមប្រាមរដ្ឋមិនឲ្យកំណត់អាជ្ញាយុកាលចំពោះបទល្មើសឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ។ អ្នកឲ្យយោបល់ខ្លះបានអះអាងថា ភាពមិនអាចអនុវត្តអាជ្ញាយុកាល ច្បាប់ចំពោះបទល្មើសខាងលើនេះ ក៏ដូចជាបទល្មើសប្រល័យពូជសាសន៍គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។

មាត្រា៨និង៩នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចែងថា បទល្មើសប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មសង្គ្រាមមិនមានអាជ្ញាយុកាលច្បាប់ទេ ។

### ១) ការការពារខ្លួនដែលទទួលស្គាល់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

គួរកត់សម្គាល់ថា នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិបច្ចុប្បន្ន ទាំងការការពារខ្លួនដែលចងក្រងរួចហើយ និងមិនបានចងក្រង អាចត្រូវបានលើកឡើងនៅពេលជំនុំជម្រះសេចក្ដី ។

◆ **កង្វះខាតភ័ស្តុតាង**

**ការការពារអាលីប៊ី ៖**

ការការពារអាលីប៊ី (ការអះអាងថាមិនមានវត្តមាននៅកន្លែងកើតហេតុ) ត្រូវបានលើកឡើងនៅពេលដែលមេធាវីចុងចោទអះអាងថា ជនជាប់ចោទមិនបានប្រព្រឹត្តបទល្មើសណាមួយដែលត្រូវបានចោទប្រកាន់ដោយសារជនជាប់ចោទមិនស្ថិតនៅកន្លែងកើតហេតុទេ ។

នៅចំពោះមុខសាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិពិសេសចុងចោទដែលចង់លើកឡើងនូវការការពារខ្លួនបែបនេះ ត្រូវតែបញ្ជាក់ពីទីកន្លែងដែលជនជាប់ចោទបានអះអាងថាខ្លួនមានវត្តមាននៅពេលដែលបទល្មើសកើតឡើង ។ ជនជាប់ចោទត្រូវបញ្ជាក់អំពីឈ្មោះនិងអាសយដ្ឋានរបស់សាក្សីក៏ដូចជាភ័ស្តុតាងផ្សេងៗទៀតដែលជនជាប់ចោទចង់លើកឡើងអំពីការការពារខ្លួនអាលីប៊ីនេះ ។ វាជាបន្ទុករបស់ព្រះរាជអាជ្ញាក្នុងការបង្ហាញថា ភ័ស្តុតាងបញ្ជាក់អំពីអាលីប៊ីនេះពិតជាត្រឹមត្រូវមែនដែរឬអត់ ។ ប្រសិនបើអង្គជំនុំជម្រះពេញចិត្តថា ជនជាប់ចោទស្ថិតនៅកន្លែងមួយផ្សេងពីកន្លែងដែលត្រូវបានចោទប្រកាន់ ព្រះរាជអាជ្ញាបានខកខានមិនបានបង្ហាញឲ្យអស់មន្ទិលសង្ស័យថាជនជាប់ចោទស្ថិតនៅកន្លែងកើតហេតុ ហើយជាលទ្ធផល តុលាការនឹងលើកលែងការចោទប្រកាន់ដល់ជនជាប់ចោទ ។

**ការភ័ន្តច្រឡំអត្តសញ្ញាណ**

មេធាវីចុងចោទអាចលើកឡើងនូវលទ្ធភាពដែលថា សាក្សីបានច្រឡំអត្តសញ្ញាណរបស់ជនជាប់ចោទ ។

នៅក្នុងការវាយតម្លៃភ័ស្តុតាងអត្តសញ្ញាណ សាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិ បានយកមកពិចារណានូវលក្ខខណ្ឌមួយចំនួន ៖ ១) ជាកាលៈទេសៈ ដែលសាក្សីបានឃើញជនជាប់ចោទ ២) ចម្ងាយមើលឃើញជនជាប់ចោទ ៣) ភាពធ្លាប់បានឃើញជនជាប់ចោទមុនពេលចន្អុលជនល្មើស និង ៤) ការរៀបរាប់អត្តសញ្ញាណជនជាប់ចោទដោយសាក្សី ។

នៅក្នុងករណីខ្លះ ជនជាប់ចោទនឹងអះអាងថា សាក្សីភាន់ច្រឡំអត្តសញ្ញាណរបស់ខ្លួន ។ ការការពារខ្លួនបែបនេះអាចមានប្រសិទ្ធភាព នៅពេលដែលជនជាប់ចោទអាចចង្អុលបង្ហាញពីជនម្នាក់ទៀតដែលមានរូបរាងស្រដៀងខ្លួន មានឈ្មោះស្រដៀងខ្លួន មានទឡ្ហានស្រដៀងខ្លួន និងមានវត្តមាននៅក្នុងតំបន់ដែលបទល្មើសបានកើតឡើង ។

◆ **ការការពារវិជ្ជមាន**

**ការការពារខ្លួន**

ការការពារដោះសាជាការការពារដែលត្រូវបានឲ្យនិយមន័យថា ជាសកម្មភាព "ដែលមិនមែនជាបទល្មើស ដែលអាចទទួលយកបាននៅក្នុងសង្គម និងដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬការរិះគន់ទេ" ។

១) ការការពារធម្មានុរូបនិងការការពារទ្រព្យសម្បត្តិ

ការការពារបែបនេះត្រូវបានលើកឡើងនៅចំពោះមុខសាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវីនៅក្នុងសំណុំរឿង ខឌិក និង ស៊ឺខេហ្ស (Kordic and Cerkez case) ។ អង្គជំនុំជម្រះសាលាដំបូងរបស់សាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវី បានធ្វើការកត់សម្គាល់ថា ការអះអាងការពារខ្លួននេះមានចែងនៅក្នុងលក្ខន្តិកៈរបស់វា ប៉ុន្តែថា វាជាផ្នែកមួយនៃគោលការណ៍ទូទៅរបស់ច្បាប់ព្រហ្មទណ្ឌ ដែលសាលាជំនុំជម្រះក្ដីត្រូវតែពិចារណាក្នុងការវិនិច្ឆ័យរឿងក្ដី ។ វាក៏យោងទៅដល់និយមន័យនៃការអះអាងការពារខ្លួននៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៣១(១)(គ) ។ សាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវីបានកំណត់ទៀតថា ការការពារខ្លួនប្រភេទនេះអាចចាត់ទុកថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។

សាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវីបានកំណត់លក្ខខណ្ឌពីរសម្រាប់ការការពារធម្មានុរូប ដើម្បីឲ្យអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនៅក្នុងច្បាប់អន្តរជាតិ ÷

ក) សកម្មភាពនោះត្រូវតែឆ្លើយតបទៅនឹង "ការប្រើប្រាស់កម្លាំងមិនស្របច្បាប់និងបន្ទាន់" មកលើមនុស្សឬទ្រព្យសម្បត្តិ "ដែលទទួលបានការការពារ" ។

ខ) សកម្មភាពនៃការការពារត្រូវតែ "សមាមាត្រទៅនឹង

កម្រិតនៃគ្រោះថ្នាក់» ហើយនៅក្នុងកាលៈទេសៈសង្គ្រាមគោលការណ៍នៃភាពចាំបាច់សំខាន់របស់ទាហានត្រូវតែយកមកពិចារណា ។

២) ភាពចាំបាច់

ភាគច្រើន ការការពារខ្លួនដែលលើកឡើងអំពីករណីនៃភាពចាំបាច់ «អាចទទួលជោគជ័យនៅក្នុងតុលាការនៅពេលដែលជនម្នាក់...ជាលទ្ធផលនៃកម្លាំង ឬលក្ខខណ្ឌ...ដែលតម្រូវឲ្យជ្រើសរើសរវាងការបង្កបទល្មើសតូចតាចមួយ ឬមានគ្រោះថ្នាក់ (ឬបណ្តាលឲ្យអ្នកដទៃទៀតមានគ្រោះថ្នាក់) ចំពោះបុគ្គលម្នាក់ឬទ្រព្យសម្បត្តិ ។

ការការពារក្តីប្រភេទនេះមានចែងនៅក្នុងមាត្រា៣១(១)(ឃ) (ii) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

**ការដោះសា**

ទោះបីជាជនណាម្នាក់បានបង្កគ្រោះថ្នាក់ដល់សង្គមក៏ដោយ ក៏ជននោះមិនគួរត្រូវទទួលនូវការបន្ទោស ឬទណ្ឌកម្មសម្រាប់ការបង្កគ្រោះថ្នាក់នោះដែរ ។ ខុសគ្នាទៅនឹងការរកលេស ការដោះសាគឺពឹងផ្អែកលើបុគ្គលផ្ទាល់ ហើយត្រូវព្យាយាមដើម្បីបង្ហាញថាជននោះមិនមានចេតនាចំពោះការប្រព្រឹត្តកំហុសនោះទេ ។

**ការបង្ខិតបង្ខំ**

ការការពារខ្លួនប្រភេទនេះត្រូវបានប្រើប្រាស់ជាធម្មតានៅពេលដែលជនម្នាក់ត្រូវស្ថិតនៅក្នុងស្ថានភាព «សម្លាប់គេ ឬត្រូវគេសម្លាប់វិញ» ។ សូម្បីតែចំពោះបទបញ្ជាមិនស្របច្បាប់ជាក់ស្តែងក៏ដោយ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់ការការពារខ្លួននេះ ប្រសិនបើជនជាប់ចោទខ្វះខាត «ជម្រើសត្រឹមត្រូវ» ក្នុងការប្រព្រឹត្តសកម្មភាពបែបនោះ ។ និយាយម្យ៉ាងទៀត ការបង្ខិតបង្ខំកើតឡើងនៅក្នុងស្ថានភាពដែលបុគ្គលម្នាក់គ្មានជម្រើសថាតើត្រូវអនុវត្តបញ្ជាមិនស្របច្បាប់ដែលប្រគល់ឲ្យដោយថ្នាក់លើ ។

ការការពារខ្លួននៃការបង្ខិតបង្ខំអាចប្រើប្រាស់បានតែក្នុងករណីចុងចោទអាចបង្ហាញថា ÷

ក) ការគំរាមកំហែងភ្លាមៗចំពោះអាយុជីវិតរបស់ខ្លួន (ឬរូបរាងកាយ ឬប្រហែលជាអាចដល់អាយុជីវិតរបស់អ្នកផ្សេងទៀត) ប្រសិនបើចុងចោទមិនប្រព្រឹត្តបទល្មើស ។

ខ) គ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីបញ្ចៀស ឬគេចពីការប្រព្រឹត្តបែបនោះ ។

គ) បទល្មើសដែលបានប្រព្រឹត្តមិនត្រូវធំជាងគ្រោះថ្នាក់ដែលប្រឈមមុខឡើយ ។

ឃ) ចុងចោទមិនមានចេតនាបង្កស្ថានភាពបែបនោះទេ ។

បញ្ហាចម្រូងចម្រាស់ពិសេសមួយគឺថា តើការបង្ខិតបង្ខំអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទាំងស្រុងឬទេ? ច្បាប់ជាតិនិងការអនុវត្តរបស់រដ្ឋផ្សេងៗ មានការយល់ឃើញខុសៗគ្នាជុំវិញសំណួរនេះ ។ នៅពេលដែលគ្មានច្បាប់ទំនៀមទម្លាប់អន្តរជាតិឬគោលការណ៍ទូទៅនៃច្បាប់ស្តីពីបញ្ហានេះ ការបង្ខិតបង្ខំនៅតែអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយផ្នែកខ្លះ ឬអាចប្រើប្រាស់ដើម្បីបន្ធូរបន្ថយទណ្ឌកម្ម ។

**ការបកស្រាយអំពីការបង្ខិតបង្ខំដោយសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវី**

សេចក្តីសម្រេចរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវីនៅក្នុងរឿងក្តីរបស់អ៊ើដេម៉ូវិក (Erdemovic) ជាករណីមួយនៅក្នុងចំណុចនេះ ។ ជនស៊ែបដើមកំណើតប៊ូស្នៀម្នាក់ដែលបានសារភាពថា បានចូលរួមនៅក្នុងការសម្លាប់បុរសនិងក្មេងមូស្លីមនៅទីក្រុងស្រ៊ីប្រេនិកានៅក្នុងឆ្នាំ១៩៩៥ ប៉ុន្តែបានលើកឡើងថា ប្រសិនបើខ្លួនហ៊ានប្រកែក មិត្តភក្តិជនជាតិស៊ែបរបស់ខ្លួននឹងសម្លាប់គាត់ជាមួយជនស៊ីវិលមូស្លីមទាំងនោះ ។ សេចក្តីសម្រេចដោយសំឡេងបីទល់នឹងពីររបស់សាលាជំនុំជម្រះក្តីនេះបានរកឃើញថា ចំពោះបទល្មើសធ្ងន់ធ្ងរ ដូចជាការសម្លាប់ជនស៊ីវិល ឬឈ្លើយសឹក ការបង្ខិតបង្ខំ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទាំងស្រុងទេ ប៉ុន្តែអាចធ្វើជាមូលដ្ឋានសម្រាប់ការបន្ធូរបន្ថយទោស ។

គួរកត់សម្គាល់ថា មាត្រា៣១(១)(ឃ) នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់ថា ការបង្ខិតបង្ខំជាការការពារខ្លួននៅក្នុងច្បាប់អន្តរជាតិ ។ មាត្រានេះបានចែងថាៈ

«(ឃ) ការប្រព្រឹត្តដែលត្រូវបានចាត់ទុកថាជាបទល្មើសនៅក្រោមយុត្តាធិការរបស់តុលាការ[តុលាការព្រហ្មទណ្ឌអន្តរជាតិ] ដែលបណ្តាលមកពីការបង្ខំដោយការគំរាមកំហែងដល់

អាយុជីវិតភ្លាមៗ ឬការបង្កបួសស្នាមធ្ងន់ធ្ងរភ្លាមៗ ឬជាបន្តបន្ទាប់ប្រឆាំងនឹងជននោះផ្ទាល់ឬអ្នកដទៃទៀត ហើយជនដែលប្រព្រឹត្តសកម្មភាពនោះបានធ្វើសកម្មភាពសមហេតុផលដើម្បីការពារខ្លួនពីការគំរាមកំហែងនោះ ។
ការគំរាមកំហែងបែបនោះអាច ៖

(i) ត្រូវបានបង្កឡើងដោយអ្នកផ្សេង ឬ

(ii) បង្កឡើងនៅក្នុងកាលៈទេសៈដែលជននោះមិនអាចគ្រប់គ្រងបាន»

◆ កំហុសអង្គហេតុ

ការព្រងើយកន្តើយចំពោះអង្គហេតុ ឬកំហុសអង្គហេតុអាចជាការដោះសាស្របច្បាប់ចំពោះអ្វីដែលអាចជាបទល្មើស ។ ឧទាហរណ៍ ជនជាប់ចោទម្នាក់អាចអះអាងថា គាត់ច្រឡំថា របស់ដែលគាត់បានបាញ់នោះគឺជាដើមឈើងាប់មិនមែនជាមនុស្សមានជីវិតទេ ។

មាត្រា៣២(១) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់ការអះអាងការពារក្តីបែបនេះដូចតទៅៈ «កំហុសអង្គហេតុអាចធ្វើជាមូលដ្ឋានសម្រាប់ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌតែក្នុងករណីដែលវាមិនមានធាតុអត្តនោម័តិដែលតម្រូវឲ្យមានដោយបទល្មើសនោះ» ។

**◆ កំហុសអង្គច្បាប់**

ជនជាប់ចោទអាចលើកឡើងនូវការការពារបែបនេះនៅពេលដែលជនជាប់ចោទមានមូលហេតុត្រឹមត្រូវដែលមិនអាចដឹងថាការប្រព្រឹត្តរបស់ខ្លួនត្រូវបានហាមឃាត់ ។ ជាទូទៅ កំហុសអង្គច្បាប់មិនត្រូវបានចាត់ទុកជាមូលដ្ឋានសម្រាប់ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ប៉ុន្តែមាត្រា៣២(២) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិបានចែងអំពីការការពារបែបនេះដូចតទៅៈ «កំហុសអង្គច្បាប់អំពីថាតើសកម្មភាពមួយជាបទល្មើសនៅក្នុងយុត្តាធិការរបស់តុលាការ មិនអាចជាមូលដ្ឋានសម្រាប់ដកចេញនូវការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។ ប៉ុន្តែ កំហុសអង្គច្បាប់អាចជាមូលដ្ឋានសម្រាប់ដកចេញនូវការទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើមិនមានធាតុអត្តនោម័តិដែលតម្រូវឲ្យមានដោយបទល្មើសនោះ ឬដូចមានចែងនៅក្នុងមាត្រា៣៣ (មាត្រានេះទាក់ទងនឹងបញ្ជាថ្នាក់លើ) ។

**ការអះអាងការការពារផ្សេងទៀត**

◆ *ជំងឺផ្លូវចិត្ត ឬខូចសតិ (សូមមើលមាត្រា៣១(១)(ក) របស់លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ)*

◆ *ការប្រើប្រាស់គ្រឿងស្រវឹង (សូមមើលមាត្រា៣១(១)(ខ) របស់លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ)*

◆ *ការយល់ព្រម ៖ ប្រសិនបើបុគ្គលម្នាក់យល់ព្រមទៅនឹងសកម្មភាពរបស់អ្នកដទៃទៀតដែលអាចបង្កជាបទល្មើស ការអះអាងការពារខ្លួនបែបនេះមិនមានប្រសិទ្ធភាពទេនៅក្នុងកាលៈទេសៈនេះ ។ ការយល់ព្រមនេះមិនមែនជាការការពារខ្លួនចំពោះបទល្មើសរំលោភ និងការបំពារបំពានផ្លូវភេទទេ ប្រសិនបើជនរងគ្រោះភ័យខ្លាចចំពោះអំពើហិង្សា ការបង្ខាំងខ្លួន ឬការគាបសង្កត់ផ្លូវចិត្ត ។*

ជាងនេះទៅទៀត គួរកត់សម្គាល់ថា មេធាវីចុងចោទអាចធ្វើឲ្យមានស្ថានសម្រាលទោសដែលមានចែងនៅក្នុងមាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដើម្បីទទួលបានការបន្ថយទោស ប្រសិនបើកូនក្តីរបស់ខ្លួនត្រូវបានរកឃើញថាមានកំហុស ។

**ឯកសារហ្វឹកហ្វឺនផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា**


# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@online.com.kh
Home page: www.dccam.org

# ការរាប់ចំនួនមនុស្សស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

*(តចប់)*

## ៩. ការប៉ាន់ស្មានចម្រុះ

តើវាអាចឬទេក្នុងការសម្រួលការប៉ាន់ស្មានដែលបានមកពីវិធីសាស្ត្រផ្សេងៗ? តើមានកត្តាផ្សេងទៀតដែលមិនបានលើកមកពិចារណានៅក្នុងការប៉ាន់ស្មានទាំងនេះឬទេ? តើយើងគួរតែវាយតម្លៃម្ដងទៀតនូវរាល់ការសន្និដ្ឋានដែលដូចគ្នាដែរឬទេ? យើងប្រហែលជាអាចត្រូវវាយតម្លៃម្ដងទៀត ។ ប្រសិនបើយើងពិចារណាអំពីភាពខ្លាំងនិងភាពខ្សោយនៃតួលេខប៉ាន់ស្មានដែលមាននិងពិចារណាអំពីភាពសាំញ៉ាំរបស់ទិន្នន័យបន្ថែមខ្លះ យើងប្រហែលជាអាចរកឃើញតួលេខមួយដែលសមរម្យបំផុតនៅក្នុងវង្វង់ទំនងមួយនៃទិន្នន័យនីមួយៗ ។

ជាបឋម សូមពិចារណាអំពីសំណួរទាក់ទងនឹងចំនួនប្រជាជននៅពេលចាប់ផ្ដើម ។ តើការសន្និដ្ឋានអំពីអត្រាកំណើនសមរម្យដែរឬទេ? ការសន្និដ្ឋាននៅឆ្នាំ១៩៧០របស់ វីកខឺរី បានបង្ហាញឲ្យឃើញនូវអត្រាកំណើននៅក្រោម២,៧ភាគរយប៉ុណ្ណោះ ។ ការប៉ាន់ស្មានដែលខ្ពស់ជាងនេះ ហើយដែល ឃៀរនិន ពេញចិត្តបានប្រើប្រាស់នូវអត្រាកំណើនប្រមាណ៣ភាគរយ ដែលប្រហែលជាស្មើគ្នានឹងអត្រាកំណើននៅក្នុងប្រទេសថៃនៅក្នុងរយៈកាលដូចគ្នានេះ ។ ទន្ទឹមនោះដែរ ប្រទេសឡាវ មានអត្រាកំណើនប្រហែល២,៨ភាគរយប៉ុណ្ណោះ ។ ការសន្និដ្ឋានខាងលើនេះ ហាក់បីដូចជាទំនងបើធៀបទៅនឹងអត្រានៅក្នុងប្រទេសផ្សេងៗក្នុងតំបន់ ។ ប៉ុន្តែដូចដែលបានលើកឡើងរួចហើយ ការប៉ាន់ស្មានទាបដែលលើកឡើងដោយ វីកខឺរី គឺមិនត្រូវគ្នានឹងទិន្នន័យផ្សេងៗទេ ។

ការគណនារបស់ ឃៀរនិន គឺផ្អែកទៅលើចំនួនប្រជាជនសរុបនៅពេលចាប់ផ្ដើមត្រឹម ៧,៨៩៨លាននាក់ ។ អ៊ូវែលលីន ជឿជាក់ថា ចំនួនប្រជាជននៅពេលចាប់ផ្ដើមគឺប្រមាណ៧,៩៥២លាននាក់ ប៉ុន្តែ បានលើកឡើងថា វាប្រហែលជាមានប្រយោជន៍ជាងនៅក្នុងការពិចារណាអំពីវង្វង់ដែលទំនង បើពិនិត្យមើលអំពីភាពមិនពិតប្រាកដរបស់ទិន្នន័យ ។

តើតួលេខមួយណាដែលត្រឹមត្រូវជាង? ខ្ញុំអះអាងថា តួលេខរបស់ អ៊ូវែលលីន ប្រហែលជាត្រឹមត្រូវជាងគេ ។ មីកហ្គោហ្វី ដែល ឃៀរនិន បានបរិយាយថាជា "អ្នកប្រជាសាស្ត្រដែលនាំមុខគេរបស់កម្ពុជា" កាលពីឆ្នាំ១៩៧២ បានព្យាករណ៍ចំនួនប្រជាជនកម្ពុជានៅឆ្នាំ១៩៧៥ថា មាន៨,៥លាននាក់ ។ ដោយសារការសន្និដ្ឋាននេះធ្វើឡើងនៅក្នុងឆ្នាំ១៩៧២ វាហាក់បីដូចជាទំនងថា មីកហ្គោហ្វី បានគិតដល់បញ្ហាសង្គ្រាមស៊ីវិល ។ ដាប់ប៊ែលយូដេ សេមសិន ដែលជាសេដ្ឋវិទូនិងស្ថិតិវិទូ ធ្វើការនៅទីក្រុងភ្នំពេញរហូតដល់ខែមីនា ឆ្នាំ១៩៧៥ ក៏បានជឿជាក់ដែរថា ចំនួនប្រជាជននៅពាក់កណ្ដាលឆ្នាំ១៩៧៤ គឺប្រហែលជា៧,៨៩លាននាក់ ។ ទន្ទឹមនោះដែរ អ្នកប្រជាសាស្ត្រ បានីស៊័រ និង ចនសាន់ ក៏បានលើកឡើងថា ចំនួនកុមារដែលមានអាយុចាប់ពី៦ឆ្នាំដល់១៥ឆ្នាំ នៅក្នុងការរាប់ចំនួនឆ្នាំ១៩៨០របស់សាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្ហាញថា សង្គ្រាមមិនមានឥទ្ធិពលលើអត្រាកំណើតច្រើនដូចដែលត្រូវបានជឿជាក់ជាទូទៅនោះទេ ។

ក្រៅអំពីសំណួរទាក់ទងនឹងអត្រាកំណើនប្រជាជន ការប៉ាន់ស្មានចំនួនប្រជាជននៅឆ្នាំ១៩៧៥ តម្រូវឲ្យធ្វើការសន្និដ្ឋានផងដែរ អំពីចំនួនមនុស្សស្លាប់នៅអំឡុងពេលសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០-១៩៧៥ ។ អ៊ូវែលលីន និង ឃៀរនិន បានពឹងផ្អែកលើការសន្និដ្ឋានមួយថា ចំនួនមនុស្សស្លាប់នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិលគឺប្រមាណ៣សែននាក់ ។ គួរបញ្ជាក់ថា តួលេខនេះទាបជាងការប៉ាន់ស្មានចំនួនមនុស្សស្លាប់ ដែលតែងតែត្រូវបានប្រើប្រាស់ជាញឹកញាប់ពី៥សែនទៅ៦សែននាក់ ។ តើតួលេខទាំងនេះទំនងដែរឬទេ?

មានភ័ស្តុតាងសំខាន់ខ្លះៗដែលអះអាងថា ចំនួនមនុស្សស្លាប់ដោយសារសង្គ្រាមគឺទាបជាងអ្វីដែលត្រូវបានជឿជាក់

ជាទូទៅ ។ នៅក្នុងប្រវត្តិជីវិតដែលសរសេរដោយជនរងគ្រោះកម្ពុជាជាច្រើន បន្ទាប់ពីរបបប៉ុលពត វាមានការលំបាកក្នុងការស្វែងរករឿងរ៉ាវនៃការស្លាប់នៅក្នុងសម័យសង្គ្រាមពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ។ នៅក្នុងសៀវភៅ «នៅពេលអំបែងអណ្តែត» របស់ ហ៊ឹម ចាន់បុទ្ធី, ហ៊ឹម បានរៀបរាប់ពីការភៀសខ្លួនរបស់ក្រុមគ្រួសារចេញពីផ្ទះនៅក្នុងខេត្តតាកែវ និងអំពីផ្ទះដែលខូចខ្ទីនៅពេលត្រឡប់មកវិញ ។ បើទោះបីជាមានរឿងយ៉ាងនេះក៏ដោយ ក៏មិនមានសមាជិកគ្រួសារណាម្នាក់បាត់បង់ជីវិតទេ ។ គាត់បានរៀបរាប់អំពីការបាត់បង់ជីវិតសមាជិក២នាក់នៅក្នុងក្រុមគ្រួសារថា «ក្មេង១មិនមែនត្រូវគ្រាប់បែកនោះទេ ហើយប្រហែលជាអាចនៅរស់ប្រសិនបើមានមន្ទីរពេទ្យជួយសង្គ្រោះត្រឹមត្រូវ» ។ ប៉ុន្តែនៅក្រោមរបបខ្មែរក្រហម ហ៊ឹម បានបាត់បង់សមាជិកគ្រួសារអស់ចំនួន២៨នាក់ ។ ហាំង ង៉ោ ក៏ដូច្នោះដែរ បានរៀបរាប់អំពីការបំផ្លិចបំផ្លាញផ្ទះរបស់ឪពុកគាត់ ប៉ុន្តែមិនបានរៀបរាប់ពីការបាត់បង់ជីវិតនៅក្នុងគ្រួសារទេ ។ នៅក្នុងសៀវភៅ «ចាកចេញពីផ្ទះខ្មោច» សំ និង យូ សុខារី បានរៀបរាប់អំពីការទម្លាក់គ្រាប់បែកនៅក្នុងភូមិរបស់ក្រុមគ្រួសារខ្លួននៅក្នុងខេត្តកំពង់ស្ពឺ ។ អ្នកភូមិភាគច្រើនបានភៀសខ្លួនភ្លាមៗបន្ទាប់ពីការទម្លាក់គ្រាប់បែក ប៉ុន្តែក្រុមគ្រួសាររបស់ សុខារី នៅតែស្នាក់នៅក្នុងភូមិនោះអស់រយៈពេល៦ខែ រហូតដល់មានការទម្លាក់គ្រាប់បែកបំផ្លិចបំផ្លាញផ្ទះរបស់ពួកគេ ។ ប៉ុន្តែ សៀវភៅនេះក៏មិនបានលើកឡើងពីការបាត់បង់ជីវិតដែរ ។ ម៉ៃ សុមេត និង ម៉ម ធីតា បានរៀបរាប់ថាខ្លួនបានឃើញគ្រាប់រ៉ុក្កែត និងការវាយប្រហារភេរវកម្មនៅក្នុងទីក្រុងភ្នំពេញ ប៉ុន្តែមិនបានរៀបរាប់អំពីការស្លាប់សមាជិកណាមួយនៅក្នុងចំណោមគ្រួសាររបស់ខ្លួននោះទេ ។ វ៉ាន់ ណាត បានរៀបរាប់អំពីការស្លាប់របស់មិត្តភក្តិម្នាក់ដែលត្រូវបានសម្លាប់ដោយការវាយប្រហាររបស់ខ្មែរក្រហម ប៉ុន្តែមិនបានរៀបរាប់អំពីការស្លាប់សមាជិកណាមួយនៅក្នុងក្រុមគ្រួសាររបស់ខ្លួននោះទេ ។ ប្រវត្តិជីវិតដោយ លឿង អ៊ឹង, ឡុង សុផល, ប៉ូល ថៃ និង ម៉ូលីដា ហ្ស៊ីមូស្សាក់ ក៏មិនបានរៀបរាប់អំពីការស្លាប់នៅក្នុងក្រុមគ្រួសាររបស់ខ្លួននៅអំឡុងពេលសង្គ្រាមដូចគ្នាដែរ ។

ជាការពិត វាមានសារសំខាន់ក្នុងការចងចាំថា អ្នកនិពន្ធទាំងនេះមិនមែនជាអ្នកតំណាងសង្គមកម្ពុជាដែលត្រូវបានយកមកចងក្រងជាស្ថិតិនោះទេ ។ អ្នកបោះពុម្ពស្វែងរករឿងរ៉ាវដែលទទួលបានចំណាប់អារម្មណ៍ខ្លាំង ហើយបទពិសោធន៍ដ៏ជូរចត់របស់ «ប្រជាជនថ្មី» ពិតជាទទួលបានការចាប់អារម្មណ៍មែន ។ ជាងនេះទៅទៀត អ្នកទីក្រុងដែលមានការអប់រំខ្ពស់គឺទំនងជាអ្នកដែលសរសេររឿងរ៉ាវរបស់ខ្លួន ។ មានកត្តាជាច្រើនដែលទំនងជាអាចបណ្តាលឲ្យអ្នកដែលឈឺចាប់បំផុតនៅសម័យសង្គ្រាម បង្ហើបប្រវត្តិរបស់ខ្លួនត្រូវបានទទួលស្គាល់ជាទូទៅថា ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកបានបណ្តាលឲ្យកសិករជាច្រើនចូលខ្មែរក្រហម ។ ដូច្នេះវាហាក់បីដូចជាសមហេតុផលក្នុងការសន្និដ្ឋានថា អ្នកដែលប្រឈមមុខនឹងការលំបាកបំផុតគឺទំនងជាអ្នកដែលចូលបម្រើខ្មែរក្រហម ។ ប៉ុន្តែ បើគិតអំពីសោកនាដកម្មដែលប្រព្រឹត្តដោយខ្មែរក្រហមនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ អ្នកទាំងនេះ [អ្នកដែលចូលបម្រើខ្មែរក្រហម] ប្រហែលជាមិនសរសេរប្រវត្តិជីវិតរបស់ខ្លួននោះទេ ។ អ្នកជិះជាន់មិនមែនជាតួអង្គល្អនោះទេ ។

ភ័ស្តុតាងផ្សេងទៀតក៏បានបង្ហាញដែរថា ចំនួនអ្នកស្លាប់នៅក្នុងអំឡុងពេលសង្គ្រាមគួរតែត្រូវបានវាយតម្លៃសាជាថ្មី ។ នរវិទូ មៃយ៍ អេប៊ីហារ៉ា ដែលបានធ្វើការសិក្សានៅភូមិមួយក្នុងខេត្តកណ្តាលពីឆ្នាំ១៩៥៩-១៩៦០ បានត្រឡប់ទៅកាន់ភូមិនោះវិញកាលពីឆ្នាំ១៩៩០ ។ នៅក្នុងចំណោមមនុស្សដែលគាត់បានស្គាល់នៅឆ្នាំ១៩៦០ ចំនួន១៥៩នាក់ គិតត្រឹមឆ្នាំ១៩៧៥ ត្រូវបានរកឃើញថា មាន១៦នាក់ស្លាប់ដោយចាស់ជរា ឬដោយសារជំងឺ និង៤នាក់បានស្លាប់នៅអំឡុងពេលសង្គ្រាម ។ មនុស្សចំនួនពាក់កណ្តាល (៦៩នាក់) នៅក្នុងចំណោមមនុស្ស ១៣៩នាក់ដែលនៅរស់ បានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ នៅក្នុងការពិភាក្សាអំពីការស្រាវជ្រាវរបស់ អេប៊ីហារ៉ា, ឃៀរនិន បានធ្វើការកត់សម្គាល់ថា «ក្រុមគ្រួសារថ្មីចំនួន១៨គ្រួសារ បានកើនឡើងនៅក្នុងភូមិនេះបន្ទាប់ពីឆ្នាំ១៩៦០ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្តីឬប្រពន្ធ២៦នាក់ក្នុងចំណោម៣៦នាក់ និងកូន២៩នាក់ទៀតបានស្លាប់» ។

ទិន្នន័យរបស់ អេប៊ីហាក៊ា បានបង្ហាញអំពីភាពខុសគ្នានៃអត្រាស្លាប់រវាងអំឡុងពេលនៃសង្គ្រាមស៊ីវិលនិងរបបប៉ុលពត ។ ចំនួនអ្នកស្លាប់នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ច្រើនជាងចំនួនស្លាប់នៅក្នុងពេលសង្គ្រាមប្រមាណ១៧ដង ។

ដើម្បីបង្ហាញពីទំនាក់ទំនងនៃអត្រាស្លាប់ទាំងនេះ សូមត្រឡប់ទៅកាន់តម្លៃនៃការប៉ាន់ស្មានដើមរបស់ វីកឃើរី ៖ ៥សែននាក់ស្លាប់នៅអំឡុងពេលសង្គ្រាមនិង៧សែន៤ម៉ឺននាក់ស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ប្រសិនបើតួលេខនេះត្រឹមត្រូវ គ្រប់ៗគ្នានឹងរំពឹងទុកថា ការសម្ភាសន៍ជាមួយអ្នករួចរស់ជីវិតនឹងឃើញចំនួនមនុស្សស្លាប់សរុបដ៏ច្រើននៅក្នុងអំឡុងពេលទាំងពីរនេះ ៖ គួរតែមាន២នាក់ស្លាប់ក្នុងអំឡុងពេលសង្គ្រាម និង៣នាក់ស្លាប់នៅក្នុងរបបខ្មែរក្រហម [នៅក្នុងចំណោមអ្នកស្លាប់៥នាក់] ។ ប្រសិនបើយើងទទួលយកការប៉ាន់ស្មានរបស់ ឃៀរនិន យើងប្រាកដជារំពឹងគិតថា ប្រសិនបើមានម្នាក់ស្លាប់នៅអំឡុងពេលសង្គ្រាម នោះ៥ឬ៦នាក់ស្លាប់នៅក្នុងរបបខ្មែរក្រហម ។

ទោះបីជាយ៉ាងណាក៏ដោយ សូម្បីតែអត្រានេះក៏នៅតែខ្ពស់ដែរ ។ ស៊ីវ ហេដឌ័រ បានធ្វើការសន្និដ្ឋានពីការសម្ភាសរបស់គាត់ថា ចំនួនមនុស្សស្លាប់សរុបនៅក្នុងចំណោមកសិករ គឺប្រមាណជា៧ដង ខ្ពស់ជាងចំនួនអ្នកស្លាប់ដោយសារសង្គ្រាម ។ យើងគួរតែចាំថា ស៊ីវ ហេដឌ័រ និយាយសំដៅទៅរកកសិករដែលជាទូទៅស្លាប់ដោយសារសង្គ្រាមខ្លាំងជាងអ្នកទីក្រុង ប៉ុន្តែមិនសូវស្លាប់នៅក្នុងរបបខ្មែរក្រហមទៅវិញ ។

អត្រាស្លាប់៥០ភាគរយនៅក្នុងភូមិរបស់ អេប៊ីហាក៊ា គឺខ្ពស់ជាងកម្រិតធម្មតានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែប្រសិនបើយើងយកអត្រាស្លាប់នៅជុំវិញ២៥ភាគរយវិញ យើងនៅតែបានអត្រាពី១ទៅ៨,៥ដងដែល [ការស្លាប់នៅអំឡុងពេលសង្គ្រាមទល់នឹងការស្លាប់នៅក្នុងរបបខ្មែរក្រហម] ។

បើទោះបីជាអត្រាស្លាប់ចេញពីភូមិនេះមានកម្រិតខ្ពស់ក៏ដោយ ក៏អត្រាស្លាប់ទាំងនេះ មិនមែនខុសពីគេប៉ុន្មានដែរ ។ ការសន្ទនាផ្ទាល់របស់ខ្ញុំជាមួយជនភៀសខ្លួនក៏បានបង្ហាញពីអត្រាស្លាប់ដែរ ។ នៅពេលដែលនិយាយដល់របបប៉ុលពត ប្រជាជនកម្ពុជាភាគច្រើននឹងចាប់ផ្តើមរៀបរាប់ឈ្មោះ ÷ "ចំនួនអ្នកស្លាប់" ដូចដែលធ្លាប់លើកឡើងដោយអ្នកនិពន្ធ មីនហ៊ុង ហូ ។ ក៏ប៉ុន្តែនៅពេលដែលនិយាយអំពីការស្លាប់នៅពេលសង្គ្រាមវិញ ការរៀបរាប់ឈ្មោះអ្នកស្លាប់នេះគឺមានចំនួនតិចៈ ប្រហែលជាប្អូនជីដូនមួយដែលជាទាហាន, ពូដែលមិនទាន់ច្បាស់ថាស្លាប់ ឬរស់ ។ល ។

វាមានសារសំខាន់ក្នុងការបញ្ជាក់ថា មនុស្សដែលខ្ញុំបានសម្ភាស មិនមែនតំណាងឲ្យចំនួនប្រជាជនទាំងអស់ ឬតំណាងឲ្យជនភៀសខ្លួនទាំងអស់នោះទេ ។ ជាទូទៅ គ្រប់គ្នារំពឹងថាជនភៀសខ្លួនតំណាងឲ្យអ្នកដែលវេទនាខ្លាំងនៅក្រោមរបបមួយ បានភៀសខ្លួនចេញ លុះត្រាតែប្រឈមមុខនឹងការលំបាកខ្លាំងណាស់ទើបមនុស្សម្នាក់ដាច់ចិត្តចាកចោលប្រទេសរបស់ខ្លួន ។ ជាងនេះទៅទៀតជនភៀសខ្លួនដែលខ្ញុំបានសម្ភាស ភាគច្រើនមកពីខេត្តបាត់ដំបងនិងទីក្រុងភ្នំពេញ ។ តំបន់ទាំងពីរនេះមិនសូវប៉ះពាល់ដោយសង្គ្រាមដូចតំបន់ផ្សេងៗទៀតទេ ។

ការពិចារណាសំខាន់មួយទៀតគឺភាពទំនងដែលថា អ្នកដែលឆ្លើយតបទៅនឹងការស្ទបស្ទង់នោះ ភ្លាមៗមិនបានដឹងថាការស្លាប់ខ្លះគឺដោយសារមូលហេតុសង្គ្រាមទេ ។ ការបង្កើតហេតុនិងផលគឺមិនមែនជារឿងងាយស្រួលនោះទេ ។ ក្រេក អេចឆេសាន់ បានធ្វើការកត់សម្គាល់ថា "នៅពេលដែលគោរបស់អ្នកស្លាប់ អ្នកមិនអាចភ្ជួរស្រែ អ្នកមិនអាចធ្វើស្រែបាន កូនរបស់អ្នកនឹងខ្វះខាតអាហារបរិភោគ កូនរបស់អ្នកនឹងឈឺ ហើយនៅចុងក្រោយបំផុត ស្លាប់ដោយសារខ្សោយអស់កម្លាំង" ។

ការប្រមូលចំនួនមនុស្សស្លាប់នៅអំឡុងពេលសង្គ្រាមស៊ីវិល អាចជាការពន្យល់ដល់ការលំបាកក្នុងការស្វែងរកអ្នករួចរស់ជីវិតដែលសមាជិកក្រុមគ្រួសាររបស់ពួកគាត់បានស្លាប់នៅចន្លោះឆ្នាំ១៩៧០និងឆ្នាំ១៩៧៥ ដោយសារថាគ្រាប់បែកដែលធ្លាក់ចំផ្ទះមួយអាចសម្លាប់ក្រុមគ្រួសារនោះទាំងមូល ហើយក៏អាចមិនប៉ះពាល់ដល់ផ្ទះផ្សេងទៀតទាល់តែសោះ ។ ដូចគ្នាដែរ ការធ្វើបាបជនជាតិវៀតណាមនៅក្នុងរបបលន់នល់ ក៏អាចមានបញ្ហាដូចគ្នាចំពោះក្រុមគ្រួសារវៀតណាមទាំងឡាយដែលស្លាប់ផុតពូជ ។

ការពិចារណាសំខាន់មួយទៀតនោះគឺថា អ្នកដែលប្រហែលជាត្រូវស្លាប់នៅក្នុងអំឡុងសង្គ្រាម គឺអ្នកដែលរស់នៅក្បែរតំបន់ព្រំដែនកម្ពុជា-វៀតណាម ក៏ជាអ្នកដែលប្រហែលជាត្រូវស្លាប់

នៅក្នុងរបបខ្មែរក្រហមដែរ ។ ការបោសសម្អាតរបស់របបខ្មែរក្រហមសំដៅទៅរកកសិករនៅក្នុងភូមិភាគបូព៌ ។ អត្រាស្លាប់ខ្ពស់នៅក្នុងចំណោមក្រុមគ្រួសារទាំងនេះនៅអំឡុងពេលសង្គ្រាមអាចប៉ះពាល់ដល់ការបកស្រាយរបស់យើងអំពីអត្រានៃការស្លាប់នៅក្នុងដំណាក់កាលនីមួយៗ ។

ការពិចារណាចុងក្រោយគឺជាលទ្ធភាពដែលថា ការសង្កត់ធ្ងន់ផ្នែកវប្បធម៌ដែលមិនធ្វើឲ្យប៉ះពាល់ដល់អ្នកដទៃ គឺមានភាពទាក់ទងនៅទីនេះ ÷

តើប្រជាជនកម្ពុជាមានការខ្វាចរអារឬទេក្នុងការពិភាក្សាអំពីការស្លាប់ដែលបង្កឡើងដោយសហរដ្ឋអាមេរិកនៅចំពោះមុខអ្នកសម្ភាសជាជនជាតិអាមេរិកាំង?

ទោះជាយ៉ាងណាក៏ដោយ នៅពេលគ្រប់គ្នាអាចបង្កើតទ្រឹស្តីអំពីអ្វីដែលភ័ស្តុតាងផ្សេងទៀតអាចកើតឡើង វាមិនច្បាស់លាស់ថា កត្តាទាំងនេះនឹងពន្យល់អំពីភាពខុសប្លែកគ្នាយើងអាចមើលឃើញនៅពេលដែលយើងប្រៀបធៀបអត្រានៃការស្លាប់នៅក្នុងសង្គ្រាមទៅនឹងការស្លាប់នៅក្រោមរបបខ្មែរក្រហម ។ ការស្លាប់គ្រួសារទាំងមូលនៅក្នុងរបបខ្មែរក្រហមប្រហែលជាអាចកើតឡើងច្រើនជាងនៅក្នុងពេលសង្គ្រាមទៀតដង ។ ការធ្វើបាបនិងការសម្លាប់ជនជាតិភាគតិចគឺកាន់តែធ្ងន់ធ្ងរជាងនេះថែមទៀត ។ កំហឹងក្រេវក្រោធរបស់លន់នល់គឺផ្តោតជាពិសេសទៅលើជនជាតិវៀតណាម ។ ទោះជាយ៉ាងណាក៏ដោយ នៅក្រោមរបបខ្មែរក្រហម ជនជាតិចិន ជនជាតិចាម និងជនជាតិវៀតណាមទាំងអស់ស្លាប់នៅក្នុងចំនួនច្រើនជាងប្រជាជនទូទៅ ។ ជាងនេះទៅទៀត ភាពជ្រុលនិយមរបស់ខ្មែរក្រហមមានន័យថា ក្រុមគ្រួសារទាំងមូលត្រូវបានសម្លាប់ដើម្បីផ្តាច់ពូជ«ខ្មាំង» ។ នៅក្នុងករណីជាច្រើន ការសម្លាប់មិនមែនកើតឡើងតែនៅក្នុងគ្រួសារដែលជាសាច់ញាតិបង្កើតប៉ុណ្ណោះទេ ថែមទាំងខ្សែស្រឡាយដែលជាប់ពាក់ព័ន្ធទៀតផង ។

នៅតែមានការសង្ស័យនៅឡើយចំពោះចំនួនមនុស្សស្លាប់សរុបនៅក្នុងអំឡុងពេលសង្គ្រាម ។ តើយើងអាចទាញអ្វីបានចេញពីការអះអាងរបស់ អេចឆេសាន់ ដែលថាមានតែរណ្តៅសាកសពពីរប៉ុណ្ណោះដែលមានគ្រោងឆ្អឹងរបស់អ្នកស្លាប់ដោយការទម្លាក់គ្រាប់បែក? នៅក្នុងចំណោមអ្នកដែលស្លាប់ដោយការទម្លាក់គ្រាប់បែក តើមានប៉ុន្មាននាក់ដែលជាវៀតណាមខាងជើង និងតើប៉ុន្មាននាក់ដែលមិនមែនជាជនជាតិកម្ពុជា? បើយើងពិចារណាអំពីការអះអាងរបស់ ណូអាម ឆោមស្គី និង អេដវឺត ហឺមែន ដែលលើកឡើងថា អត្ថបទសារពត៌មាននៅពេលនោះខកខានមិនបានដកស្រង់សម្តីរបស់ជនរងគ្រោះដោយសារសង្គ្រាម ៈ តើនេះមកពីសារពត៌មានចង្អៀតចង្អល់ ឬមកពីមិនមានជនរងគ្រោះច្រើនដូចដែលត្រូវបានជឿជាក់ជាទូទៅ? បើប្រៀបធៀបទៅនឹងប្រទេសវៀតណាម ដែលខ្ទង់មកុម្មុយនិស្តអាចវាយប្រហារគ្រប់ទីកន្លែងនិងគ្រប់ពេលវេលា ហើយអាមេរិកនិងវៀតណាមខាងត្បូងអាចផ្អែកលើការផ្លាស់ប្តូរទីតាំងរហ័សដើម្បីវាយប្រហារភ្លាមៗ វាទំនងជាថា ខ្សែត្រៀមជួរមុខរបស់កម្ពុជាគឺងាយស្រួលប៉ាន់ស្មានជាង ហើយការណ៍នេះធ្វើឲ្យមានភាពងាយស្រួលក្នុងការជម្លៀសប្រជាជនមុនពេលឆាកប្រយុទ្ធចាប់ផ្តើម ។

តើតួលេខ៣សែននាក់ សមហេតុសមផលជាងការប៉ាន់ស្មាន ៥ទៅ៦សែននាក់ឬ? ដោយប្រើប្រាស់អត្រាស្លាប់របស់វៀតណាមជាផ្លូវការ សូមពិចារណា ថាតើការស្លាប់៣សែននាក់កើតឡើងយ៉ាងដូចម្តេច? នៅក្នុងប្រទេសវៀតណាម ការស្លាប់របស់ទាហានប្រមាណជា១លាន៣សែន៨ម៉ឺននាក់ និងជនស៊ីវិលប្រមាណ២លាននាក់ ហើយចំនួននេះបានបង្ហាញនូវអត្រាស្លាប់ជនស៊ីវិល ១,៤៥នាក់ក្នុងចំណោមការស្លាប់ទាហានមួយនាក់ ។ ប្រសិនបើយើងសន្មតថា នៅក្នុងប្រទេសកម្ពុជាមានអត្រាស្លាប់ដូចគ្នាដែរនោះ យើងនឹងបានចំនួនទាហានដែលស្លាប់ចំនួន ១២២.៤៨៨នាក់ ហើយជនស៊ីវិលដែលស្លាប់គឺ១៧៧.៥១២ ។ វាមានការលំបាកខ្លាំងក្នុងការគណនាចំនួនជនស៊ីវិលស្លាប់សរុប (ដូចដែលបានបង្ហាញកាលពីដំបូង) ហើយជាញឹកញាប់ មានការលំបាកក្នុងការកំណត់ឲ្យច្បាស់ថាតើការស្លាប់មួយណាដែលទាក់ទងទៅនឹងសង្គ្រាម ។ ប៉ុន្តែ សូមពិចារណាអំពីចំនួនទាហានស្លាប់ ។ បើយើងប្រើប្រាស់ស្ថិតិពីវៀតណាមជាផ្លូវការ សូមពិចារណាអំពីចំនួនអ្នកស្លាប់សរុបដែលយើងបានប្រមាណ១សែន២ម៉ឺន២ពាន់៥រយនាក់ ។ បើប្រៀបធៀបអត្រាស្លាប់និងអ្នករបួសរបស់កងកម្លាំងយោធាអាមេរិក នៅក្នុងប្រទេសវៀតណាមគឺប្រមាណ១ទល់

នឹង៣ ។ ប៉ុន្តែសម្រាប់ប្រទេសកុម្មុយនិស្តវៀតណាម សេវាសុខភាពមិនគ្រប់គ្រាន់ មានន័យថា អ្នករបួសភាគច្រើនអាចស្លាប់ៈ អត្រាស្លាប់និងរបួសគឺប្រហែលជា២ទល់នឹង១ ។ ស្ថិតិរបស់កម្ពុជាដែលមានគឺតិចតួចបំផុត ប៉ុន្តែកាលពីចុងឆ្នាំ១៩៧០ រដ្ឋាភិបាលបានរាយការណ៍អំពីការខូចខាតថា ៣.៨៤៨នាក់ស្លាប់ និង ៧.៨៩៥នាក់រងរបួស ។ អត្រា១ទល់នឹង២នេះទំនងជាកើនឡើងខ្លាំងនៅពេលក្រោយមកទៀត ដោយសារស្ថានភាពនៅក្នុងសមរភូមិកាន់តែអាក្រក់ឡើង និងដោយសារធនធានសុខាភិបាលដែលកំពុងតែខ្វះខាតស្រាប់ផង ត្រូវខូចខាតទាំងស្រុង ។ នៅពេលនោះ កងកម្លាំងខ្មែរក្រហមប្រហែលជាមានអត្រាស្លាប់ដូចកុម្មុយនិស្តវៀតណាមដែរ ។ ប្រសិនបើអត្រានូទៅគឺប្រហែលជា១ស្មើនឹង១ នោះ ចំនួនទាហានដែលរងរបួសប្រហែលជាអាចនៅចន្លោះ១សែនទៅ១សែន២ម៉ឺន៥ពាន់នាក់ ហើយអត្រាស្លាប់សរុបរបស់ទាហានគឺប្រហែលជា២សែន៤ម៉ឺននាក់ ។ ចំនួននេះហាក់បីដូចជាឡើងខ្ពស់បើយើងមើលពីចំនួនទាហានទាំងសងខាងដែលចូលប្រយុទ្ធ ។ គិតចាប់ពីឆ្នាំ១៩៧៣ កងកម្លាំងរបស់ខ្មែរក្រហមត្រូវបានប៉ាន់ស្មានថា មានប្រហែលជា២សែននាក់ ។ កងកម្លាំងរបស់លន់នល់ រួមទាំងក្រុមទាហានប៉ារ៉ាផង ប្រហែលជាខ្ពស់បំផុតត្រឹម២សែន៩ម៉ឺន ។ ប្រសិនបើយើងសន្មតថា នៅពេលកំពុងមានសង្គ្រាម អ្នកស្លាប់និងអ្នករបួសទាំងអស់ត្រូវបានជំនួសដោយអ្នកដែលទើបតែជ្រើសរើសបានថ្មីៗ យើងប្រហែលជាមានចំនួនអ្នកប្រយុទ្ធសរុប ៧សែន៣ម៉ឺននាក់ ។ តួលេខនេះមានន័យថា ក្នុងចំណោមទាហានបីនាក់មានស្ទើរតែមួយនាក់ដែលស្លាប់ឬរងរបួស ហើយតួលេខនេះគឺខ្ពស់ខ្លាំង បើធៀបទៅនឹងជម្លោះផ្សេងៗទៀត ។

ការណ៍ដែលថា អត្រានេះខ្ពស់មិនមែនមានន័យថាមិនអាចត្រឹមត្រូវនោះទេ ហើយអត្រានៃការស្លាប់នៅក្នុងរបបខ្មែរក្រហមក៏ខ្ពស់ខ្លាំងដែរ បើធៀបទៅនឹងរបបផ្សេងៗទៀត ។ នៅក្នុងប្រវត្តិសាស្ត្រដ៏សោកសៅរបស់ជម្លោះមនុស្ស មានសង្គ្រាមមួយដែលខុសប្លែកពីគេដោយសារមានការបង្ហូរឈាមនិងការបំផ្លិចបំផ្លាញខ្លាំង ។ ប៉ុន្តែ មិនមានភ័ស្តុតាងរឹងមាំណាមួយដែលបង្ហាញថា សង្គ្រាមស៊ីវិលរបស់កម្ពុជា មានការបំផ្លិចបំផ្លាញខ្លាំងជាងជម្លោះដទៃៗទៀតទេ ។

បានីស្ទ័រ និង អេចឆេសាន់ បានប៉ាន់ស្មានការស្លាប់សរុបដោយសារសង្គ្រាមថា មានប្រហែលជា២សែន៧ម៉ឺន៥ពាន់នាក់ ។ សេមសិន ក៏ជឿជាក់ដែរថា ចំនួនមនុស្សស្លាប់ដោយសារសង្គ្រាមត្រូវបានប៉ាន់ស្មានលើសកំណត់ ។ គាត់បានលើកឡើងថា ការស្លាប់របស់ជនស៊ីវិល "អាចមានតួលេខនៅក្នុងរង្វង់រាប់ម៉ឺននាក់ ប៉ុន្តែមិនអាចលើសនេះទេ" ហើយគាត់បានកត់សម្គាល់ថា អនុព័ន្ធយោធាបានប៉ាន់ស្មានអំពីទំហំនៃកងទ័ពនីមួយៗថានៅចន្លោះពី១សែននិង១សែន៥ម៉ឺននាក់ ។ ប្រសិនបើត្រឹមត្រូវ តួលេខទាំងនេះមានន័យថា សូម្បីតែតួលេខស្លាប់៣សែនក៏ខ្ពស់ណាស់ដែរ ។

យើងគួរតែចងចាំថា ចំនួនអ្នកស្លាប់ក៏មានបន្ថុប់ចំនួនអ្នកដែលរងរបួសដែរ ។ ប្រសិនបើយើងទទួលយកតួលេខស្លាប់៥សែននាក់ យើងនឹងបានអ្នករបួសប្រមាណជាកន្លះលាននាក់ដែរ ។ នេះមានន័យថា មនុស្សម្នាក់ក្នុងចំណោម១៦នាក់នៃប្រជាជននៅឆ្នាំ១៩៧៥ជាអ្នករបួសនៅក្នុងអំឡុងពេលសង្គ្រាម ។ បទសម្ភាសន៍ជាមួយអ្នករួចរស់ជីវិតបានបង្ហាញថា តួលេខនេះមិនត្រឹមត្រូវទេ ។ ខ្ញុំគិតថា តួលេខណាមួយនៅចន្លោះ១សែន៥ម៉ឺននិង៣សែន ហើយគិតថាតួលេខ២សែន៥ម៉ឺននាក់ជាតួលេខខ្ពស់ជាងគេបំផុត ។

## ៦) ការស្វែងរកចំណុចប្រសព្វគ្នា

តើតួលេខនេះប៉ះពាល់ដល់ការប៉ាន់ស្មាននៃការស្លាប់នៅក្នុងរបបខ្មែរក្រហមដូចម្តេច? ដោយសារការប៉ាន់ស្មានរបស់ អ៊ូវែលលីន អំពីចំនួនប្រជាជននៅក្នុងឆ្នាំ១៩៧៥ (៧,៩៥២ លាននាក់) ផ្អែកលើការសន្និដ្ឋានថា ៣សែនស្លាប់ដោយសង្គ្រាម ខ្ញុំនឹងអះអាងនូវតួលេខ៨,០០២លាននាក់ ហើយតួលេខដែលទំនងជាងគេនៃចំនួនប្រជាជននៅឆ្នាំ១៩៧៥ ប្រហែលជា៨,១០២ លាននាក់ ។

ឃៀរនិន បានអះអាងថា ចំនួនប្រជាជននៅពេលចាប់ផ្តើម [របបខ្មែរក្រហម] គឺ៧,៨៩៤លាននាក់ ហើយនេះជាតួលេខដែលសមបំផុត ។ ប៉ុន្តែ ចំណុចចម្រូងចម្រាស់មួយនោះ គឺទាក់ទងទៅនឹងចំនួនជនជាតិវៀតណាមដែលធ្វើមាតុភូមិនិវត្តន៍នៅក្នុងឆ្នាំ ១៩៧៥ ។ ឃៀរនិន បានលើកឡើងនូវតួលេខ១សែន៥ម៉ឺន




គំនរអដ្ឋិធាតុនិងសម្លៀកបំពាក់របស់ជនរងគ្រោះនៅមន្ទីរតាម៉ន ក្នុងស្រុកទូកមាស ខេត្តកំពត

នាក់ វីកឃើរី បានប៉ាន់ស្មានថា២សែននាក់ ។ ដោយផ្អែកលើការសន្និដ្ឋានដែលថា វីកឃើរី អាចត្រឹមត្រូវ យើងអាចចាត់ទុកតួលេខ ៧,៨៤៤លាននាក់ ថាជាតួលេខនៃចំនួនប្រជាជនចាប់ផ្តើម [ចំនួនប្រជាជននៅឆ្នាំ១៩៧៥] ដែលទាបបំផុតហើយទំនងបំផុត ។

វាកាន់តែមានការលំបាកជាងនេះទៅទៀតក្នុងការប៉ាន់ស្មានចំនួនប្រជាជនសរុបនៅឆ្នាំ១៩៧៩ឲ្យបានត្រឹមត្រូវ ដោយសារការកំណត់ចំនួនប្រជាជននៅក្នុងឆ្នាំ១៩៧៥មានការលំបាកណាស់ទៅហើយ ។ បានីស្ទ័រ និង អេចឆេសាន់ បានប្រើប្រាស់នូវការស្រង់ស្ថិតិដែលប្រើប្រាស់ដោយសាធារណរដ្ឋប្រជាមានិតកម្ពុជានៅក្នុងឆ្នាំ១៩៨០ ដើម្បីប៉ាន់ស្មានចំនួនប្រជាជនសរុបនៅក្នុងឆ្នាំ១៩៧៩ ហើយបានសន្និដ្ឋានថា មានចំនួន៦.៥៨៩.៩៥៤នាក់ ។ ប៉ុន្តែអ្នកទាំងពីរនេះបានលើកឡើងនូវការអះអាងរបស់អៀ ម៉េងទ្រី ដែលថា "មន្ត្រីខេត្តនិងមន្ត្រីមូលដ្ឋានបានបំផ្លើសចំនួនប្រជាជនដែលរស់នៅក្រោមការគ្រប់គ្រងរបស់ខ្លួនដោយសារមូលហេតុហិរញ្ញវត្ថុ" ។ឃៀរនិន បានអះអាងថា ចំនួនប្រជាជននៅក្នុងខែមករា ឆ្នាំ១៩៧៩ គឺនៅចន្លោះពី៦ទៅ៦,៧លាននាក់ ហើយការគណនាអំពីអត្រាស្លាប់របស់គាត់បានលើកឡើងនូវតួលេខ៦,២១៩លាននាក់ដែលជាចំនួនប្រជាជននៅឆ្នាំ១៩៧៩ ។ ទោះជាយ៉ាងណាក៏ដោយ ប្រភពផ្សេងៗទៀតបានអះអាងថាចំនួនអ្នករួចរស់ជីវិត [ពីរបបកម្ពុជាប្រជាធិបតេយ្យឬចំនួនប្រជាជននៅក្នុងឆ្នាំ១៩៧៩] អាចទាបជាងនេះ ។ សៀវភៅរបស់អង្គការយូនីសេហ្វមួយកាលពីឆ្នាំ១៩៩០ដែលបានធ្វើតារាងចំនួន



ប្រជាជននៅក្នុងប្រទេសកម្ពុជា បានប្រើប្រាស់ស្ថិតិពីក្រសួងសុខាភិបាលនិងកសិកម្មរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបង្ហាញពីចំនួនប្រជាជន សរុបនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៨១ ថាមានចំនួន៦លាន៦សែន៨ម៉ឺន៤ពាន់នាក់ ។ ការវិភាគរបស់យូនីសេហ្វក៏បានប្រើប្រាស់ការប៉ាន់ស្មានចំនួនប្រជាជនសម្រាប់ឆ្នាំ១៩៨០ថា៦លាន៧សែននាក់ ។ ដោយសារតួលេខនេះខ្ពស់ជាងតួលេខនៃចំនួនប្រជាជនសរុបនៅឆ្នាំ១៩៨១ វាហាក់បីដូចជាទំនងថា តួលេខនេះបានបញ្ចូលនូវចំនួនប្រជាជនភៀសខ្លួនប្រមាណ៣សែននាក់នៅតាមព្រំដែនថៃផងដែរ ។ តួលេខទាំងនេះប្រហែលជាបានមកពីការស្ទាបស្ទង់ដែលប្រើប្រាស់ដោយ បានីស្ទ័រ, អេចឆេសាន់ និង វីកឃឺរី ។

ការប៉ាន់ស្មាន «ចំនួនប្រជាជនឆ្នាំ១៩៧៩» (ពោលគឺចំនួនប្រជាជនសរុបប្រសិនបើគ្មានការសម្លាប់) តម្រូវឲ្យមានការប៉ាន់ស្មានអំពីអត្រាកំណើនចំនួនមនុស្សនិងឥទ្ធិពលនៃអន្តោ-ប្រវេសន៍ ។

ឃៀរនិន បានលើកឡើងថា អត្រាកំណើននៅក្នុងអំឡុងរបបខ្មែរក្រហមគឺប្រមាណជា១ភាគរយក្នុងមួយឆ្នាំ ប៉ុន្តែគាត់មិនបានលើកឡើងនូវភស្តុតាងបញ្ជាក់ទេ ។ ភស្តុតាងនៃរឿងខ្លីៗរបស់អ្នកដែលរួចរស់ជីវិតបានបង្ហាញថា ភាពមានកំណើតបានធ្លាក់ចុះ ។ តើការធ្លាក់ចុះនោះមានកម្រិតខ្លាំងប៉ុនណា? វាហាក់បីដូចជាថា ការប៉ាន់ស្មានរបស់ ឃៀរនិន គឺទាញចេញដោយប្រយោលពីលទ្ធផលនៃការស្រង់ស្ថិតិ ។ បើពិនិត្យមើលត្រឡប់មកក្រោយវិញពីចំនួនមនុស្សស្លាប់ដែលបានសន្មត មាន១លាន៧សែននាក់ គ្រប់ៗគ្នាត្រូវតែទទួលស្គាល់នូវអត្រាកំណើតទាបដើម្បីសម្រុះសម្រួលជាមួយតួលេខនៃការប៉ាន់ស្មានចំនួនប្រជាជននៅក្នុងឆ្នាំ១៩៧៥ និង១៩៧៩ ។

មានមធ្យោបាយដែលល្អជាងនេះឆ្ងាយដើម្បីកំណត់ពីភាពមានកំណើតៈ ទិន្នន័យជាក្រុមៗ ។ ជាក់ស្តែងមិនមានស្ថិតិស្តីអំពីអត្រាកំណើតនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហមនោះទេ ប៉ុន្តែវាប្រហែលជាអាចនៅក្នុងការគណនាចំនួនកំណើតដែលបែងចែកជាប្រភេទអាយុផ្សេងៗ ដូចដែលមានបង្ហាញនៅក្នុងទិន្នន័យសម្រង់ប្រជាជន ។ ដោយផ្អែកលើរចនាសម្ព័ន្ធនៃអាយុរបស់ប្រជាជននៅក្នុងការរាប់ចំនួនរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជានៅក្នុងឆ្នាំ១៩៨០ បានីស្ទ័រ និង អេចឆេសាន់ បានសន្និដ្ឋានថា ភាពមានកំណើតបានធ្លាក់ចុះប្រមាណ៣៨ភាគរយ ។ ស្រដៀងនេះដែរ អ៊ូវែលលីន និង ប៉ុណ្ណាក់ ប៉ូច បានវិភាគទិន្នន័យពីមន្ទីរពិសោធន៍ចំនួនប្រជាជនមេគង្គ ហើយបានសន្និដ្ឋានថា អត្រាកំណើតនៅអំឡុងពេលនៃរបបខ្មែរក្រហមបានធ្លាក់ចុះប្រហែលជា១ភាគ៣ ។ ដោយខ្វះខាតទិន្នន័យអំពីការស្លាប់របស់ទារកនៅក្នុងអំឡុងពេលមានវិបត្តិ ការប៉ាន់ស្មានមិនអាចត្រឹមត្រូវឥតខ្ចោះនោះទេ ។ ការកើនឡើងយ៉ាងខ្លាំងនៃអត្រាទារកស្លាប់មានន័យថា ទិន្នន័យជាក្រុមៗនឹងបណ្តាលឲ្យយើងប៉ាន់ស្មានទាបជាងចំនួនពិតប្រាកដ ។ បើទោះបីជាយ៉ាងនេះក៏ដោយ ទិន្នន័យប្រជាសាស្ត្របានបង្ហាញអំពីអត្រាកំណើតដែលខ្ពស់ជាងការប៉ាន់

ស្ថាននៃអត្រាកំណើនប្រជាជន១ភាគរយរបស់ ឃៀរនិន ។

វាមានសារសំខាន់ក្នុងការចងចាំថា ឃៀរនិន និង អ៊ូវែលលីន មិនបានពឹងផ្អែកលើតួលេខចំនួនប្រជាជន ដើម្បីឲ្យបានការប៉ាន់ស្មានផ្ទាល់ខ្លួននោះទេ ។ បើពិនិត្យមើលអំពីការប៉ាន់ស្មានរបស់អ្នកទាំងពីរអំពីចំនួនប្រជាជននៅពេលចាប់ផ្តើមនិងនៅពេលបញ្ចប់ធ្វើឲ្យយើងប្រៀបធៀបការប៉ាន់ស្មានបានងាយស្រួលជាង ។

ទីមួយ បើទោះបីជាអ្នកទាំងពីរ [ឃៀរនិន និង អ៊ូវែលលីន] បានលើកឡើងនូវតួលេខប្រហាក់ប្រហែលគ្នាអំពីចំនួនប្រជាជននៅក្នុងឆ្នាំ១៩៧៥ ការវិភាគរបស់ អ៊ូវែលលីន ទិន្នន័យសម្រង់ប្រជាជនដើម ហាក់បីដូចជាបានបង្ហាញនូវអត្រាកំណើនខ្ពស់ ដែលការណ៍នេះបានធ្វើឲ្យប៉ះពាល់ដល់ការបកស្រាយអំពីអត្រាស្លាប់«ធម្មតា»របស់យើង ។

ទីពីរ អ៊ូវែលលីន ជឿជាក់ថា ការប៉ាន់ស្មានអំពីចំនួនប្រជាជននៅក្នុងឆ្នាំ១៩៧៩ត្រូវបានពន្លើស ដើម្បីទទួលបាននូវជំនួយម្ហូបអាហារបន្ថែម ។ គាត់បានលើកឡើងថា តួលេខនៅក្រោម៦លាននាក់ ប្រហែលជាតួលេខដែលត្រឹមត្រូវជាង ។ អ្នកវិភាគផ្សេងទៀត ដែលរួមមាន រ៉ូបឺត មូស្កាត និង ចូណាថាន់ ស្រួមសេត ក៏បានលើកឡើងដែរថា ការរាប់ចំនួនមនុស្សនៅក្រោយរបបខ្មែរក្រហមត្រូវបានរាប់ពន្លើស ។

បើទោះបីជាមានការខុសប្លែកគ្នាផ្សេងទៀតនៅក្នុងការសន្និដ្ឋានរបស់ ឃៀរនិន និង អ៊ូវែលលីន វាប្រហែលជាត្រឹមត្រូវក្នុងការនិយាយថា កត្តាទាំងពីរនេះគឺមានសារសំខាន់ ។

តើការប៉ាន់ស្មានអំពីចំនួនប្រជាជនដែលខុសៗគ្នានេះសមស្របជាមួយនឹងភ័ស្តុតាងកោសល្យវិច័យដែរឬទេ? សូមពិចារណាម្តងទៀតលើទិន្នន័យរបស់គម្រោងផែនទីរណ្តៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយប្រើប្រាស់ការប៉ាន់ស្មានថ្មីទាក់ទងនឹងរណ្តៅសាកសព ៖ ១.៣៨៦.៧៣៤នាក់ ។ ប្រសិនបើជនរងគ្រោះទាំងនេះសុទ្ធតែស្លាប់ដោយការសម្លាប់ ហើយប្រសិនបើការសម្លាប់មានចំនួនប្រមាណពាក់កណ្តាលនៃការស្លាប់សរុបនៅក្នុងរបបនោះ (តួលេខដែលលើកឡើងដោយ អ៊ូវែលលីន) នោះយើងបានចំនួនមនុស្សស្លាប់សរុប២.៧៧៣.៤៦៨នាក់ ។ ប្រសិនបើដកចំនួនអ្នកស្លាប់ដោយធម្មជាតិចេញប្រមាណ៥សែននាក់ យើងនឹងបានចំនួនអ្នកស្លាប់ដោយសារមូលហេតុផ្សេងៗ(មិនមែនតាមធម្មជាតិ) ចំនួន២លាន២សែន៧ម៉ឺននាក់ ។ ប្រសិនបើចំនួនមនុស្សដែលត្រូវបានសម្លាប់៤០ភាគរយវិញ (តួលេខដែលលើកឡើងដោយ ស៊្លីវិនស្គី) យើងនឹងបានចំនួនអ្នកស្លាប់ដោយមូលហេតុផ្សេងៗប្រមាណ២.៩៦៦.៨៣៥នាក់ ។

ប្រសិនបើការប៉ាន់ស្មានរបស់ ឃៀរនិន ១លាន៦សែន៧ម៉ឺននាក់ត្រឹមត្រូវ យើងនឹងទាញបានការសន្និដ្ឋានជាច្រើនខុសៗគ្នា...ប៉ុន្តែមិនមានការសន្និដ្ឋានណាមួយដែលប្រសើរនោះទេ ។ យើងអាចសន្មតថា ក្រុមការងាររបស់គម្រោងផែនទីរណ្តៅសាកសពបានប៉ាន់ស្មានចំនួនសាកសពលើស ប៉ុន្តែគ្មានភ័ស្តុតាងបញ្ជាក់ថា ការប៉ាន់ស្មានលើសនេះជាការពិតទេ ។ យើងអាចសន្មតថា ភាគច្រើននៃរណ្តៅសាកសព គឺបណ្តាលមកពីសង្គ្រាមស៊ីវិល ឬមកពីការលុកលុយរបស់វៀតណាម ប៉ុន្តែដូចដែល អេចឆេសាន់ បានធ្វើការកត់សម្គាល់ថា មានភ័ស្តុតាងសំខាន់ៗដែលបង្ហាញថា រណ្តៅសាកសពទាំងនេះមិនមែន [បណ្តាលមកពីសង្គ្រាមស៊ីវិលឬមកពីការលុកលុយរបស់វៀតណាម]នោះទេ ។ ម្យ៉ាងទៀត យើងអាចសន្មតថា ភាគច្រើនបំផុតនៃអ្នកដែលស្លាប់នៅក្នុងរបបខ្មែរក្រហមត្រូវបានកប់នៅក្នុងរណ្តៅសាកសពដោយមិនគិតអំពីមូលហេតុផ្សេងៗនៃការស្លាប់ ។ ប៉ុន្តែការណ៍នេះមិនទំនងទេ ចម្លើយរបស់ជនភៀសខ្លួនជាច្រើនបង្ហាញថាភាគច្រើននៃអ្នកដែលស្លាប់ដោយជំងឺមិនត្រូវបានកប់នៅក្នុងរណ្តៅសាកសពរួមទេ ហើយក្រៅពីនេះមានមនុស្សជាច្រើនដូចជាអ្នកដែលស្លាប់ដោយការព្យាយាមរត់គេចខ្លួន ក៏មិនត្រូវបានកប់នៅក្នុងរណ្តៅសាកសពរួម...ហើយប្រសិនបើអ្នកទាំងនោះត្រូវបានកប់ ក៏មិនមែននៅក្នុងរណ្តៅសាកសពរួមដែរ ។

យើងក៏អាចពិនិត្យមើលអំពីភ័ស្តុតាងបន្តិចបន្តួចផ្សេងទៀតដែលបានពិភាក្សាយ៉ាងសង្ខេបនៅក្នុងរបាយការណ៍របស់គម្រោងផែនទីរណ្តៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងការស្រង់ស្ថិតិតាមផ្ទះរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ អេចឆេសាន់ បានកត់សម្គាល់ថា តួលេខស្លាប់៣លាន៣សែននាក់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជាគឺបានមកពីការបូកបញ្ចូលគ្នារវាងចំនួនគ្រោងឆ្អឹងនៅក្នុងរណ្តៅសាកសពនិងចំនួនអ្នក

ស្លាប់ដែលទទួលបានពីការរាយការណ៍ ។ គាត់បានចង្អុលបង្ហាញថា តួលេខរួមបញ្ចូលគ្នាទាំងនេះនឹងបណ្តាលឲ្យមានការរាប់ពីរដងនូវជនរងគ្រោះជាច្រើន និងថាការស្រង់ស្ថិតិ ក៏មិនត្រឹមត្រូវដែរ ដោយសារកំហុសឆ្គងទ្រឹស្តី ដូចជាការខកខានពិចារណាអំពីករណីដែលការស្លាប់មួយ ត្រូវបានរាយការណ៍ពីរដងដោយគ្រួសារពីរផ្សេងគ្នា ។

ការសម្រេចចិត្តបូកបញ្ចូលគ្នានូវចំនួនគ្រោងឆ្អឹងដែលគាស់ និងចំនួនដែលបានមកពីការស្រង់ស្ថិតិ គឺពិតជាមិនត្រឹមត្រូវទេ ប៉ុន្តែ ចុះត្រឹមតែចំនួនដែលបានមកពីការស្រង់ស្ថិតិ? សេចក្តីសង្ខេបនៃរបាយការណ៍របស់សាធារណរដ្ឋប្រជាមានិតកម្ពុជាបានបែកចំនួនសរុបជាពីរផ្នែក ៖ ២.៧៤៦.១០៥នាក់បានពីការស្រង់ស្ថិតិ និង៥៦៨.៦៦៣នាក់ពីរណ្តៅសាកសព ។ ប្រសិនបើគ្មានមូលហេតុដើម្បីបញ្ចូលតួលេខទាំងនេះ ការកែតម្រូវកំហុសនោះគឺគ្រប់គ្រាន់ ៖ យើងអាចមិនពិចារណាអំពីតួលេខគ្រោងឆ្អឹងពីរណ្តៅសាកសព ពោលគឺផ្តោតការចាប់អារម្មណ៍តែទៅលើតួលេខពីការស្ទាបស្ទង់ ។

ដោយសារមិនមានឯកសារច្បាស់លាស់និយាយអំពីវិធីសាស្ត្រនៃការស្រង់ស្ថិតិ យើងអាចត្រឹមតែពិនិត្យមើលអំពីកំហុសផ្នែកស្ថិតិប៉ុណ្ណោះ ។ ប៉ុន្តែ យើងអាចទស្សទាយយ៉ាងទូលំទូលាយអំពីកំហុសឆ្គង ដែលប្រហែលជាកើតឡើង ហើយពីចំណុចនេះយើងអាចទាញបាននូវចំនួនមនុស្សស្លាប់អប្បបរមា ។

ចំណុចខុសឆ្គងដែលកើតឡើងញឹកញាប់បំផុតនៅពេលដែលជនរងគ្រោះម្នាក់ត្រូវបានរាប់បញ្ចូលទៅក្នុងរចនាសម្ព័ន្ធរបស់ក្រុមគ្រួសារទាំងពីរៈ ជាក់ស្តែង ទាំងជីដូនជីតាខាងឪពុកនិងខាងម្តាយ អាចរាយការណ៍អំពីការស្លាប់របស់ចៅតែមួយ ។ ករណីប្រភេទនេះអាចកើតឡើងច្រើន នៅពេលដែលក្រុមគ្រួសារទាំងពីររស់នៅក្នុងភូមិផ្សេងគ្នា ។ ក្រៅពីនេះក៏មានករណីផ្សេងទៀតដែរ ការស្លាប់របស់ក្រុមគ្រួសារដែលបែកគ្នាអាចត្រូវបានកត់ត្រាខុស ។ ជាក់ស្តែង ការស្លាប់របស់ឪពុកម្នាក់ដែលមានកូនបួននាក់រស់នៅក្នុងខេត្តបួនផ្សេងគ្នា ។ ការស្លាប់នេះត្រូវបានកត់ត្រា៤ដង ។ យើងប្រហែលជាអាចពិនិត្យមើលផងដែរ អំពីលទ្ធភាពដែលថា អ្នកដែលរស់នៅក្នុងប្រទេសកម្ពុជាអាចដឹងមិនច្បាស់អំពីជោគវាសនារបស់ក្រុមគ្រួសារខ្លួនដែលរត់ទៅប្រទេសថៃ ឬអាចនិយាយម្យ៉ាងទៀតថា បុគ្គលម្នាក់ស្លាប់ ឬរស់នៅក្នុងជំរំជនភៀសខ្លួន ឬតាំងលំនៅថ្មីនៅក្នុងប្រទេសផ្សេងៗអាចត្រូវក្រុមគ្រួសារដែលរស់នៅក្នុងប្រទេសចាត់ទុកថាស្លាប់ ។

ដោយសារកំហុសដែលអាចកើតឡើងញឹកញាប់គឺការរាប់ពីរដង ចំណុចនេះគួរតែជាការផ្តោតអារម្មណ៍ចម្បងរបស់យើងនៅពេលដែលយើងព្យាយាមប៉ាន់ស្មានអំពីទំហំនៃកំហុស ។ តើការរាប់ចំនួនមិនត្រឹមត្រូវនេះកើតឡើងញឹកញាប់ប៉ុនណា?

ជាទូទៅ ដើម្បីកុំឲ្យការស្លាប់មួយត្រូវបានរាប់ពីរដង សមាជិកក្រុមគ្រួសារទាំងសងខាងនៅក្នុងរចនាសម្ព័ន្ធគ្រួសារត្រូវតែនៅមានជីវិត ។ ដោយសារអត្រាស្លាប់ចំពោះក្រុមខ្លះអាចមានជិតដល់៣០ភាគរយ ករណីប្រភេទនេះអាចមិនកើតឡើងញឹកញាប់ទេ ។ វាមិនមែនជារឿងភ្ញាក់ផ្អើលទេក្នុងការរកឃើញថាមានការរាប់ពីរដងចំពោះក្រុមគ្រួសារដែលរស់នៅបែកខ្ញែកគ្នា វាទំនងណាស់ថាក្រុមគ្រួសារកម្ពុជាភាគច្រើននៅតែរស់នៅក្បែរៗសាច់ញាតិរបស់ខ្លួន ។ ជាងនេះទៅទៀត មិនមានហេតុផលក្នុងការសន្មតថា អ្នកស្រាវជ្រាវរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាខ្វះចន្លោះពេកនោះទេ ។ ឧបមាថា គ្រួសារ“ក” បាននិយាយថាចៅរបស់គាត់ឈ្មោះ សុផល, ហាំង និង ជា បានស្លាប់នៅក្នុងឆ្នាំ១៩៧៧ ហើយគ្រួសារ “ខ” ដែលផ្ទះរបស់ខ្លួននៅឆ្ងាយពីគ្នាបាននិយាយថា ចៅរបស់គាត់ឈ្មោះ សុផល, ហាំង និង ជា បានស្លាប់នៅក្នុងឆ្នាំ១៩៧៧ ។ វាលំបាកនឹងជឿថា អ្នកស្រាវជ្រាវទាំងនោះខកខានមិនចំណាំថា ជនរងគ្រោះទាំងបីនេះជាមនុស្សដដែល ។ ប៉ុន្តែនៅក្នុងសហគមន៍ធំៗ ការផ្សារក្នុងការកំណត់ឈ្មោះជាន់គ្នាជាការលំបាកយ៉ាងខ្លាំង ។ (ពិចារណាអំពីទំហំនៃការផ្សារ ៖ ប្រៀបធៀបការលំបាកក្នុងការស្វែងរករបស់១០០ដែលជាន់គ្នានៅក្នុងបញ្ជីមួយដែលមានរបស់៥ពាន់មុខទៅនឹងការលំបាកក្នុងការស្វែងរករបស់១០មុខដែលជាន់គ្នា នៅក្នុងបញ្ជីមួយដែលមានរបស់៥០០មុខ) ។ ដើម្បីកែសម្រួលការរាប់ជាន់គ្នានេះ យើងត្រូវរកអំណះអំណាងជាទូទៅមួយ ៖ សន្មតថាការរាប់ពីរដងមិនកើតឡើងនៅក្នុងចំណោមប្រជាជនជនបទទេ ប៉ុន្តែសន្មតថារាល់ការស្លាប់ទាំងឡាយដែលរាយការណ៍ដោយអ្នកទីក្រុងត្រូវ

បានរាប់ពីរដង ។ បានីស៊័រ និង អេចឆេសាន់ បានលើកឡើងថា ប្រជាជនប្រមាណ១២,៦ភាគរយរស់នៅក្នុងទីក្រុងសំខាន់ៗនៅក្នុងឆ្នាំ១៩៨០ ហើយការស្រង់ចំនួនប្រជាជននៅឆ្នាំ១៩៩៨ បានបង្ហាញថា មានអ្នកទីក្រុង១៧,៧ភាគរយ ។ ដោយផ្អែកលើការសន្មត ដែលថាអ្នកទីក្រុងស្លាប់ច្រើនជាងអ្នកជនបទ យើងគួរតែកែសម្រួលចំនួននេះទៅមុខ ។ (សន្មតថាការស្លាប់ចំនួន២០ភាគរយដែលបានរាយការណ៍ ត្រូវបានរាប់ពីរដង) ។ នៅក្នុងករណីនេះ យើងអាចដកពាក់កណ្តាលនៃចំនួននេះចេញពីចំនួនស្លាប់សរុប ហើយយើងបានចំនួន២.៤៧១.៨៩៥នាក់ ។

បន្ទាប់មក យើងអាចកែសម្រួលបុគ្គលដែលត្រូវបានរាប់ថាស្លាប់ ដែលតាមការពិតនៅរស់នៅក្នុងជំរំជនភៀសខ្លួន ឬនៅក្នុងប្រទេសផ្សេងទៀត ។ នៅក្នុងករណីភាគច្រើន ក្រុមគ្រួសារដែលមានសមាជិករស់នៅជុំគ្នាច្រើន អាចដឹងអំពីការគេចខ្លួន ឬដឹងនៅពេលក្រោយមកថា អ្នកផ្សេងទៀតបានភៀសខ្លួន ឬបើមិនដូច្នោះទេ អ្នកដែលរស់នៅក្នុងជំរំអាចមានមធ្យោបាយទាក់ទងសមាជិកគ្រួសារនៅក្នុងប្រទេសកម្ពុជា ។ យើងសន្មតថា ១ភាគ៣នៃអ្នកដែលរស់នៅក្នុងជំរំត្រូវបានច្រឡំរាប់ថាស្លាប់ នោះយើងនឹងត្រូវដក១សែននាក់ចេញទៀត ហើយយើងចំនួនសរុប២.៣៧១.៨៩៥នាក់ ។

ការកែសម្រួលចុងក្រោយរបស់យើងគឺត្រូវដកចេញពីតួលេខនេះនូវចំនួនស្លាប់ដែលយើងចាត់ទុកថាដោយសារមូលហេតុធម្មតា ។ តួលេខដែលទទួលយកជាទូទៅចំពោះអត្រាស្លាប់នៅមុនពេលសង្គ្រាម គឺប្រមាណជា៥សែននាក់ ។ ការណ៍នេះបានផ្តល់ឲ្យយើងនូវការស្លាប់ដោយមិនមែនមូលហេតុធម្មជាតិប្រមាណ ១,៨៧លាននាក់ ។

តួលេខនេះស្ទើរតែដូចគ្នានឹងចំនួនខ្ពស់បំផុតដែលលើកឡើងដោយ ហៀវនិន ។ ប៉ុន្តែនៅក្នុងការគណនាពិសេសរបស់យើង តួលេខ១,៨៧លាននាក់ ប្រហែលជាចំនួនស្លាប់សរុបអប្បបរមា ដោយសារថាយើងបានកែសម្រួលតែកត្តាទាំងឡាយណាដែលនាំទៅដល់ការរាប់ចំនួនមនុស្សលើសប៉ុណ្ណោះ ។ នៅមានកត្តាផ្សេងទៀតដែលអាចនាំទៅដល់ការរាប់ចំនួនជនរងគ្រោះមិនគ្រប់តាមការពិតខ្លះ ។ យ៉ាងហោចណាស់ក៏មាន៣ក្រុមដែរ ដែលមិនត្រូវបានតំណាងនៅក្នុងការស្ទាបស្ទង់នោះ ក្រុមគ្រួសារដែលស្លាប់ផុតពូជ ក្រុមគ្រួសារដែលអ្នកនៅរស់ទាំងអស់ហើយបានភៀសខ្លួនទៅបរទេស ក្រុមគ្រួសារដែលសមាជិកគ្រួសារនៅសល់ជីវិតរស់នៅក្នុងតំបន់ដាច់ស្រយាល ដែលធ្វើឲ្យអ្នកស្រង់ស្ថិតិមិនអាចធ្វើដំណើរទៅដល់ ។ ការសន្និដ្ឋានរបស់យើងនៅទីនេះបានព្យាករណ៍ទៅលើការប៉ាន់ស្មានប្រជាជនប្រមាណ៣សែននាក់ដែលរស់នៅក្នុងជំរំភៀសខ្លួន ហើយយើងដឹងយ៉ាងច្បាស់ថា ចំនួនក្រុមគ្រួសារដែលស្លាប់ផុតពូជគឺមានចំនួនច្រើន ។ ដោយពិនិត្យមើលអំពីកត្តាទាំងនេះ ការស្ទាបស្ទង់នេះបានផ្តល់យ៉ាងរឹងមាំនូវចំនួនមនុស្សស្លាប់ដោយមូលហេតុមិនមែនធម្មជាតិ២លាននាក់ ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏គ្មានទិន្នន័យល្អស្តីពីវិធីសាស្ត្រនៃការស្រង់ស្ថិតិដែរ យើងគួរពិចារណាអំពីលទ្ធភាពផ្សេងទៀត ។ ឧទាហរណ៍ តើអ្នកស្រាវជ្រាវបានព្យាយាមកែសម្រួលលទ្ធផលដើម្បីឲ្យត្រឹមត្រូវចំពោះក្រុមដែលមានតំណាងមិនគ្រប់គ្រាន់ដែរឬទេ? ឬម្យ៉ាងទៀត តើអាចឬទេ ដែលថាលទ្ធផល [នៃការស្ទាបស្ទង់] ត្រូវបានបំភ្លៃដើម្បីធ្វើឲ្យរបបខ្មែរក្រហមមើលទៅអាក្រក់ខ្លាំង?

ជាការពិត ប្រសិនបើលទ្ធផលនៃការស្ទាបស្ទង់បានឆ្លុះបញ្ចាំងនូវភាពលម្អៀងមនោគមវិជ្ជា ឬអសមត្ថភាពយ៉ាងធ្ងន់ធ្ងរ ដូច្នេះ យើងគួរតែចាត់ទុកថាស្ថិតិផ្សេងទៀតដែលបានមកពីសាធារណរដ្ឋប្រជាមានិតកម្ពុជា ដូចជាការប៉ាន់ស្មានចំនួនប្រជាជននៅក្នុងឆ្នាំ ១៩៨០ ក៏មានការសង្ស័យដូចគ្នាដែរ ។

ជំនឿផ្ទាល់ខ្លួនរបស់ខ្ញុំគឺថា ការស្ទាបស្ទង់ត្រូវបានធ្វើឡើងអស់ពីលទ្ធភាពរបស់អ្នកស្រាវជ្រាវទៅហើយ គ្រប់ក្រុមគ្រួសារកម្ពុជាទាំងអស់មានដាប់ស្លាកស្នាមនៅក្នុងរបបប៉ុលពត ។ នៅពេលរបបនោះបានកន្លងផុតទៅ ប្រជាជនកម្ពុជាទាំងអស់ចង់ដឹងថាមានរឿងអ្វីកើតឡើង ។

### ៧) ការសន្និដ្ឋានសាកល្បង

តើទាំងអស់នេះបានប្រាប់យើងអ្វីខ្លះ? នៅតែមិនទាន់មានចម្លើយច្បាស់លាស់នៅឡើយ ។ ការជឿជាក់ផ្ទាល់ខ្លួនរបស់ខ្ញុំគឺថា ភ័ស្តុតាងដែលបានបង្ហាញយ៉ាងរឹងមាំថា ចំនួនមនុស្សស្លាប់សរុបមិនមែនដោយលក្ខខណ្ឌធម្មជាតិគឺ២លាននាក់ ។ ខ្ញុំអាច

អះអាងនូវតួលេខដែល“ទំនងបំផុត”គឺប្រមាណជា២,១៨លាននាក់ ។ ភ័ស្តុតាងបច្ចុប្បន្នបង្ហាញថា តួលេខនៃការប៉ាន់ស្មានខ្ពស់បំផុតរបស់ ឃៀរនិន ១,៨៧លាននាក់ គឺប្រហែលជាតួលេខទំនង “អប្បបរមា” ។ ការប៉ាន់ស្មានទំនងអតិបរមាគឺប្រហែលជា២,៤៩៥លាននាក់ ។

តួលេខទាំងនេះត្រូវបានគណនាដោយផ្អែកលើមូលដ្ឋាននៃការប៉ាន់ស្មានអំពីចំនួនប្រជាជននិងអំពីកំណើន ប៉ុន្តែរាល់ការគណនាបែបនោះត្រូវស្ថិតនៅក្រោមការកម្រិតមួយចំនួន ។ ខ្ញុំនឹងអះអាងថា រាល់ការប៉ាន់ស្មានទាំងឡាយយ៉ាងហោចណាស់ត្រូវតែបំពេញលក្ខខណ្ឌចំនួន៥ ៖

◆ ដោយផ្អែកលើទិន្នន័យពីការស្រង់ស្ថិតិដោយជ្រើសរើសមនុស្សមួយចំនួនមកធ្វើជាតំណាងមនុស្សទាំងអស់ (អត្រាស្លាប់សរុបត្រូវតែយ៉ាងហោចណាស់២១ភាគរយនៃចំនួនប្រជាជននៅពេលចាប់ផ្តើម១៩៧៥) ។

◆ ដោយផ្អែកលើទិន្នន័យពីគម្រោងផែនទីរណ្តៅសាកសព ចំនួនមនុស្សស្លាប់សរុបត្រូវតែលើសចំនួនជនរងគ្រោះនៅក្នុងរណ្តៅសាកសព ។

◆ ដោយផ្អែកលើទិន្នន័យពីការស្រង់ស្ថិតិតាមផ្ទះរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ចំនួនមនុស្សស្លាប់មិនមែនដោយលក្ខខណ្ឌធម្មជាតិសរុបត្រូវតែលើសពី១,៨៧លាននាក់ ។

◆ ដោយផ្អែកលើអត្រានៃការស្លាប់នៅក្នុងពេលសង្គ្រាម និងការស្លាប់នៅអំឡុងរបបប៉ុលពត ចំនួនមនុស្សស្លាប់សរុបត្រូវតែខ្ពស់ជាងចំនួនមនុស្សស្លាប់នៅក្នុងពេលសង្គ្រាមយ៉ាងហោចណាស់៧ដង ។

◆ ចំនួនមនុស្សស្លាប់សរុបនេះត្រូវតែបង្ហាញថា ចំនួនប្រជាជនដែលរួចរស់ជីវិតយ៉ាងហោចណាស់៦លាននាក់ ។

ចំនួនប្រជាជនសរុបនៅឆ្នាំ១៩៧៥ដែលប្រហែលជា៨លាននាក់ វាហាក់បីដូចជាត្រឹមត្រូវជាង ។ ដូចដែលបានកត់សម្គាល់ប្រជាសាស្ត្រវិទូភាគច្រើនជឿជាក់ថា ការស្រង់ចំនួនប្រជាជនជាទូទៅរាប់ទាបជាងចំនួនពិតប្រាកដ ជាពិសេសនៅក្នុងប្រទេសក្រីក្រ ។ បានីស៊័រ និង អេចឆេសាន់ បានធ្វើការកត់សម្គាល់ថា “ការស្មាបស្ទង់នៅក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៦៤ បានបង្ហាញថា ការស្រង់ចំនួនប្រជាជននៅក្នុងឆ្នាំ១៩៦២ អាចរំលង [មិនបានស្រង់] ប្រជាជនប្រមាណ៤ភាគរយនៃចំនួនប្រជាជនសរុប” ។ មីហ្គោហ្ស៊ី ក៏ជឿជាក់ដែរថា ការស្រង់ចំនួនប្រជាជននោះគឺរាប់មិនគ្រប់តាមចំនួនពិតប្រាកដទេ ហើយដូចដែលបានកត់សម្គាល់រួចហើយ ស៊ីយ៉ាមប៉ូស និង អ៊ូវែលលីន ជឿជាក់ថាអត្រាកំណើតក៏មានរាប់ខ្វះដែរ ។ ទន្ទឹមនោះដែរ ការប៉ាន់ស្មានដែលមានស្រាប់អំពីចំនួនមនុស្សស្លាប់ដោយសង្គ្រាមប្រហែលជាត្រូវបានរាប់លើស ។ បានីស៊័រ និង អេចឆេសាន់ បានរៀបរាប់ការប៉ាន់ស្មានរបស់ខ្លួន ២សែន៧ម៉ឺន៥ពាន់នាក់ ដែលស្លាប់មិនមែនដោយមូលហេតុធម្មជាតិ ថាជា “ចំនួនស្លាប់ខ្ពស់បំផុត ដែលយើងអាចមើលឃើញថាត្រឹមត្រូវ” ។

ភ័ស្តុតាងខាងប្រជាសាស្ត្របានបង្ហាញថា អត្រាកំណើតនៅក្នុងរបបប៉ុលពតមិនបានធ្លាក់ចុះខ្លាំងដូចដែលបានជឿជាក់ពីមុននោះទេ ។ ដោយសន្មតអំពីអត្រាកំណើន៣ភាគរយអត្រាស្លាប់ធម្មតា១៩នាក់ក្នុងចំណោម១ពាន់នាក់ ហើយអត្រាកំណើតធម្មតា អាចប្រហែលជា៤៩ក្នុង១ពាន់នាក់ ។ អ៊ូវែលលីន និង ប៉ូច បានប៉ាន់ស្មានថា ភាពមានកូនបានថយចុះប្រមាណ៣៤ភាគរយ ។ ការធ្លាក់ចុះភាពមានកូននៅក្នុងរយៈពេលខ្លីបែបនោះប្រហែលជាស្របនឹងការធ្លាក់ចុះអត្រាកំណើតស្មើគ្នាដែរ ។ មានន័យថា អត្រាកំណើតគឺប្រមាណជា៣២នាក់ក្នុងចំណោមមនុស្ស១ពាន់នាក់ ដែលអាចមានន័យថា អត្រាកំណើនប្រចាំឆ្នាំ (ចំនួនកំណើតក្នុង១ពាន់នាក់ដកចំនួនស្លាប់ក្នុងចំណោម១ពាន់នាក់) គឺប្រហែលជា១,៣ភាគរយ ។ ចំនួនប្រជាជននៅពេលចាប់ផ្តើម ៨,០០២លាននាក់ គុណនឹងអត្រាកំណើនប្រចាំឆ្នាំ១,៣ភាគរយ យើងនឹងបានចំនួនប្រជាជនប្រហែលជា៨,៣៩លាននាក់នៅក្នុងឆ្នាំ១៩៧៩ ។ ខ្ញុំចាត់ទុកថាតួលេខនេះ ជាចំនួនប្រជាជននៅក្នុងឆ្នាំ១៩៧៩ដែលទំនងបំផុត ។ បើពិនិត្យមើលអំពីភាពមិនច្បាស់លាស់នៃទិន្នន័យប្រហែលជាសមហេតុផលជាងការកំណត់តួលេខនៅក្នុងវង្វង់ចំនួនទំនងវិញជាជាងកំណត់យកតែតួលេខនៃការស្លាប់តែមួយ ។ ដោយសន្មតថា មានអត្រាកំណើនដូចគ្នានេះ ប៉ុន្តែបើចំនួនប្រជាជននៅពេលចាប់ផ្តើម៨,១០២លាននាក់វិញ នោះចំនួនប្រជាជនសរុបនៅក្នុងឆ្នាំ១៩៧៩ គឺ៨,៤៩៥លាន

នាក់ ។ ទន្ទឹមនឹងនេះដែរ ចំនួនអប្បបរមានៅក្នុងវង្វង់ដែលទំនងនេះ គឺកាន់តែខិតទៅជិតការប៉ាន់ស្មានចំនួនប្រជាជននៅឆ្នាំ១៩៧៩ របស់ ឃៀរនិន ៨,២១៥លាននាក់ ។ ដោយផ្អែកលើការសន្មត ដែលថា ការប៉ាន់ស្មានដែលខ្ពស់ជាងនេះរបស់ វីកឃីរ អំពីចំនួន អ្នកនិរទេសខ្លួនទៅប្រទេសវៀតណាម អាចត្រឹមត្រូវ ហើយយើង អាចបន្ថយតួលេខនេះប្រមាណ៥ម៉ឺននាក់ នោះយើងនឹងបានចំនួន ប្រជាជន៨,១៦៥លាននាក់សម្រាប់ឆ្នាំ១៩៧៩ ។

តើមានអ្នកនៅសល់ជីវិតប៉ុន្មាននាក់? បានីស៊័រ និង ចនសាន់ បានអះអាងថានៅចុងឆ្នាំ១៩៧៨ មានប្រជាជនកម្ពុជាប្រហែល ៦,៣៦លាននាក់នៅក្នុងប្រទេស ។ អ្នកទាំងពីរបានអះអាងផង ដែរអំពីចំនួនប្រជាជន២សែន១ម៉ឺន៨ពាន់នាក់ដោយសារការ ភៀសខ្លួន ។ ប៉ុន្តែ ភាគច្រើននៃអ្នកទាំងនេះមានជនជាតិវៀតណាម ប្រមាណ១សែន៩ម៉ឺននាក់ ដែលត្រូវបានដកចេញរួចជាស្រេច ពីចំនួនប្រជាជននៅពេលចាប់ផ្តើម ។ នៅមុនឆ្នាំ១៩៧៩ ប្រជា ជនដែលនៅសល់៩ម៉ឺន៨ពាន់នាក់បានភៀសខ្លួនទៅកាន់ប្រទេស ថៃ ឡាវ និងប្រទេសវៀតណាម ។ ដូច្នេះ ចំនួនអ្នកដែលរួចរស់ ជីវិតគឺ៦,៤១៨លាននាក់ ។

ប៉ុន្តែ តើការរាប់ចំនួននៅក្នុងឆ្នាំ១៩៨០ត្រឹមត្រូវដែរ ឬទេ? អ៊ូវែលលីន បានជឿជាក់ថា ចំនួនប្រជាជនដែលនៅរស់ ប្រាកដជានៅក្រោម៦លាននាក់ ។ បានីស៊័រ និង ចនសាន់ បាន ទទួលស្គាល់ថា បុគ្គលិករដ្ឋបាលដែលទទួលខុសត្រូវរាប់ចំនួន មនុស្សនៅក្នុងឆ្នាំ១៩៨០ មានការលើកទឹកចិត្តឲ្យប៉ាន់ស្មានចំនួន មនុស្សនៅក្រោមការគ្រប់គ្រងរបស់ខ្លួនលើស ប៉ុន្តែក៏បានកត់ សម្គាល់ផងដែរថា ជាទូទៅ ការស្រង់ចំនួនប្រជាជនគឺតែងតែខ្វះ ចន្លោះជានិច្ច ។ នេះប្រហែលដោយសារអ្នកទាំងពីរមើលឃើញ ពីកត្តាទាំងពីរថាអាចទូទាត់គ្នា បានជាពមិនកែតម្រូវតួលេខនេះ ។ ប៉ុន្តែ ខ្ញុំនឹងអះអាងថា ប្រសិនបើដូច បានីស៊័រ និង ចនសាន់ បាន លើកឡើងមែន យើងគួរតែចាត់ទុកតួលេខឆ្នាំ១៩៨០ថា ជាការ ស្រង់ចំនួនប្រជាជនមិនគ្រប់ ។ យើងក៏គួរកែសម្រួលដែរ ចំពោះ ប្រជាជន នៅពេលចាប់ផ្តើមការងាររបស់យើង ដើម្បីប៉ះប៉ូវ ចំពោះការរាប់ខ្វះនោះ...ហើយដូចដែលកត់សម្គាល់ពីដំបូង ការកែ សម្រួលបែបនេះនឹងទទួលបាននូវការប៉ាន់ស្មានមួយដែលកាន់តែ ខ្ពស់ជាងមុននូវចំនួនអ្នកស្លាប់មិនមែនដោយមូលហេតុធម្មជាតិ ។ ខ្ញុំក៏ជឿដែរថា ភាគច្រើននៃអ្នកដែលបានភៀសខ្លួនទៅប្រទេស វៀតណាមនៅអំឡុងពេលសង្គ្រាមប្រហែលជាអាចត្រឡប់ទៅ កាន់ប្រទេសវិញកាលពីមុនឆ្នាំ១៩៨០ ។

ខ្ញុំមិនបានដឹងអំពីភស្តុតាងទាំងឡាយដែលបង្ហាញថា តួលេខ របស់ បានីស៊័រ និង អេចឆេសាន់ មិនមែនជាការរាប់ចំនួនមនុស្ស ខ្វះនោះទេ ដូច្នេះយើងអាចដាក់តួលេខ៦,៤១៨លាននាក់នៅ ខាងចុងខ្ពស់បំផុតនៃវង្វង់ចំនួនប្រជាជនដែលទំនង ។ ចំណុចទាប បំផុតនៃវង្វង់ចំនួនមនុស្សនេះគឺប្រហែលជា៦លាននាក់ ។ ដោយសារអវត្តមាននៃទិន្នន័យច្បាស់លាស់ ខ្ញុំនឹងចាត់ទុកថាតួ លេខកណ្តាល៦,២០៩លាននាក់ ជាតួលេខទំនងបំផុត ។

ការដកតួលេខនេះពីចំនួនប្រជាជនដែលទំនងបំផុត៨,៣៩ លាននាក់ នឹងបានតួលេខមនុស្សស្លាប់មិនមែនដោយមូលហេតុ ធម្មជាតិប្រហែល២,១៨លាននាក់ ។ វង្វង់នៃចំនួនមនុស្សស្លាប់ សរុបដោយផ្អែកលើតួលេខខាងលើគឺនៅចន្លោះពី១,៧៤៧លាន នាក់ ទៅដល់២,៤៩៥លាននាក់ ។ បើទោះបីជាតួលេខដែលទាប បំផុតនេះហាក់បីដូចជាមិនទំនងបើធៀបទៅនឹងការស្ទាបស្ទង់របស់ សាធារណរដ្ឋប្រជាមានិតកម្ពុជា២លាន១សែន២ម៉ឺននាក់ដែល ជាចំណុចកណ្តាលនៃវង្វង់ចំនួននេះគឺក្បែរទៅនឹងតួលេខដែលទំនង បំផុត ។

## ៨) បញ្ហាសម្រាប់ការសិក្សាបន្ត

ជាការពិត តួលេខទាំងអស់នេះនៅតែមិនទាន់ច្បាស់លាស់ ទេ ។ វាស្ទើរតែមិនអាចទៅរួចទេ ដែលថាចំនួនសរុបនឹងអាចត្រូវ បានគណនាច្បាស់លាស់ ការស្រាវជ្រាវបន្ថែមអាចអនុញ្ញាតឲ្យ យើងធ្វើឲ្យប្រសើរឡើងចំពោះការប៉ាន់ស្មានរបស់យើង ។

ខ្ញុំមិនមែនចាត់ទុកការវិភាគដែលបង្ហាញនៅទីនេះថាច្បាស់ លាស់នោះទេ ។ ល្អបំផុត ខ្ញុំសង្ឃឹមថា វាអាចជួយសម្រួល ៈ ពោល គឺការអះអាងខ្វះនៅទីនេះអាចផ្តល់នូវគំនិតដែលអាចធ្វើឲ្យអ្នក ស្រាវជ្រាវផ្សេងទៀតអាចធ្វើការគណនាច្បាស់លាស់ជាងមុន ។

នៅក្នុងការចងក្រង ការគណនាទាំងនេះ ខ្ញុំបានធ្វើការសន្មត មួយចំនួនដោយមិនមានភស្តុតាង ។ នេះជាចំណុចសំខាន់ ហើយ ដែលតម្រូវឲ្យមានការបកស្រាយ ៈ ខ្ញុំមិនមែនអះអាងថាភស្តុតាង

ផ្សេងទៀតមិនមាននោះទេ ។ ខ្ញុំគ្រាន់តែកត់សម្គាល់ថា ខ្ញុំមិនបានឃើញភស្តុតាងបែបនោះ ។ អ្នកឯកទេសស្រាវជ្រាវដែលមានលទ្ធភាពចូលទៅកាន់ធនធានផ្សេងៗទៀត សង្ឃឹមថានឹងអាចពិនិត្យឲ្យបានល្អិតល្អន់ទៅលើចំណុចដែលបានពិភាក្សានៅទីនេះ ហើយនិងសង្ឃឹមថានឹងអាចផ្តល់នូវការវិភាគដែលត្រឹមត្រូវជាងនេះ ។

ការស្រាវជ្រាវបន្ថែមអាចបកស្រាយបញ្ហាមួយចំនួន ។ នៅក្នុងចំណោមនេះ ÷

◆ ចំនួនជនជាតិវៀតណាមបន្ទាប់ពីឆ្នាំ១៩៧៩ ។ បើពិនិត្យមើលថា មិនមានជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យទាំងមូល ការវាយតម្លៃជនជាតិវៀតណាមនៅក្នុងរយៈពេលក្រោយកម្ពុជាប្រជាធិបតេយ្យនឹងអាចអនុញ្ញាតឲ្យយើងប៉ាន់ស្មានចំនួនជនអន្តោប្រវេសន៍ដែលមកតាំងលំនៅក្នុងប្រទេសកម្ពុជា ។ ចំនួននេះគឺមានសារសំខាន់ប្រសិនបើយើងចង់គណនាចំនួនស្លាប់សរុបតាមរយៈការប្រៀបធៀបចំនួនប្រជាជនសរុបនៅឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ ។

◆ ទម្លាប់នៃការកប់សាកសពនៅក្នុងរបបប៉ុលពត ។ តើជនរងគ្រោះដោយសារការអត់ឃ្លាននិងជំងឺប៉ុន្មាននាក់ដែលត្រូវបានកប់ដាច់ដោយឡែក តើមានប៉ុន្មាននាក់ដែលត្រូវកប់នៅក្នុងរណ្តៅសាកសពរួម? តើវាអាចឬទេ ក្នុងការកំណត់ទំនាក់ទំនងរវាងចំនួនទាំងនេះចំពោះទីកន្លែងខុសគ្នាផ្សេងៗ និងអំឡុងពេលខុសៗគ្នា ។

◆ ចំនួនមនុស្សស្លាប់ដោយសារសង្គ្រាមនិងមូលហេតុបន្ទាប់បន្សំ ។ តើយើងអាចគណនាចំនួនស្លាប់ដោយសារសង្គ្រាមបានត្រឹមត្រូវជាងតាមរយៈការប្រៀបធៀបជាមួយនឹងជម្លោះផ្សេងទៀតឬទេ ដោយបញ្ចូលធាតុផ្សំផ្សេងៗដូចជា ដង់ស៊ីតេប្រជាជនចំនួនសព្វាវុធ រយៈពេលនៃជម្លោះ និងទំហំនៃកងកម្លាំងដែលបានចូលរួម?

◆ ទំនាក់ទំនងរវាងចំនួនជនភៀសសឹកនិងចំនួនអ្នកស្លាប់ ។ តើការសិក្សាអំពីអត្រាស្លាប់និងការធ្វើអន្តោប្រវេសន៍ដែលបង្ខិតបង្ខំ អាចបង្កើតជាគំរូទូទៅដែលអាចផ្តល់ឲ្យនូវការប៉ាន់ស្មានមួយដែលផ្អែកលើការប៉ាន់ស្មានមួយទៀតឬទេ?

ការពិនិត្យលើការស្រង់ស្ថិតិរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ការពិនិត្យមើលលើលទ្ធផលដើមនៃការស្រង់ស្ថិតិនឹងអាចផ្តល់ឲ្យយើងនូវការវិភាគល្អិតល្អន់អំពីគុណវិបត្តិរបស់វា ហើយការបញ្ចូលទៅក្នុងកុំព្យូទ័រនូវបញ្ជីឈ្មោះជនរងគ្រោះនឹងអាចផ្តល់ឲ្យយើងនូវឈ្មោះដែលជាន់គ្នាដើម្បីឲ្យយើងលុបចេញបាន ។ ដោយគ្មានការសង្ស័យ ការណ៍នេះជាជំហានតែមួយដែលសំខាន់បំផុតឆ្ពោះទៅរកការគណនាយ៉ាងល្អិតល្អន់នូវចំនួនមនុស្សស្លាប់នៅក្រោមរបបខ្មែរក្រហម ។

ការប្រឈមមុខចំពោះភស្តុតាងដែលមិនពេញលេញ និងការមិនអាចធ្វើការសន្និដ្ឋានបានមានន័យថា យើងនឹងមិនអាចមើលឃើញរូបភាពពេញលេញនូវអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាទេ ។ មានន័យថា ៣០ឆ្នាំបានកន្លងផុតទៅហើយ វាជាពេលដើម្បីឆ្ពោះដំណើរទៅខាងមុខ ។

ប្រវត្តិវិទូសាំទៅនឹងគំនិតនៃអំពើប្រល័យពូជសាសន៍ ។ ជាការងាយស្រួលក្នុងការទទួលយកថា កម្ពុជាមិនមែនជាកន្លែងទីមួយដែលកើតអំពើប្រល័យពូជសាសន៍នោះទេ ប៉ុន្តែវាពិបាកក្នុងការទទួលយកថា កម្ពុជាមិនមែនជាកន្លែងចុងក្រោយដែលកើតអំពើនេះដែរ ។ ក្រៅពីនេះ មានឧក្រិដ្ឋកម្មថ្មីៗទៀត តើយើងនៅតែព្រួយបារម្ភអំពីរឿងចាស់ឬ? ហេតុអ្វីបានជាយើងចាំបាច់ខ្វល់នឹងរឿងចំនួន? មួយលានកន្លះ ពីរលានកន្លះ...តើវាសំខាន់ឬទេ? វាសំខាន់ដោយសារអ្នកស្លាប់ទាំងនោះសុទ្ធតែមានឈ្មោះ ។

មនុស្សមួយចំនួនបានចំណាយគំនិតនិងពេលវេលាដ៏មានតម្លៃនៅក្នុងការជួយរៀបចំអត្ថបទនេះ ។ អ្នកទាំងនេះមិនមានការទទួលខុសត្រូវចំពោះការធ្វើសេចក្តីសន្និដ្ឋាន ការភ័ន្តច្រឡំនិងកំហុសនៅក្នុងអត្ថបទនេះទេ ប៉ុន្តែវាជារបស់ខ្ញុំតែម្នាក់គត់ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកទាំងឡាយដែលមានឈ្មោះដូចតទៅនេះ ៖ គ្រេក អេចឆេសាន់, ផេទ្រិក អ៊ូវែលលីន, ស៊ីវ ហេដឌ័រ, ដូឌី លេឌ័រវូដ, ជេមាន ជី វ៉ាល់ក៍, ប៊ែន ឃៀរនិន, អែដ ម៉ូអ៊ីស, ខាល ហូប, ដូណាល ឃីក, ចន ម៉េយ៍, ស៊ូហ្សាន រូប៊ីអូ, ជិមហូសឺរ, ម៉ូរីន ស្សាប, ស្រី ស្សាប និង វ៉ា ថាច ។

**ប្រ៊ីស ស្សាប**

# មិនចង់រំឭករឿងរ៉ាវពីរបបខ្មែរក្រហម

រយៈពេលជិតមួយឆ្នាំហើយដែលខ្ញុំបានមកធ្វើការជាបុគ្គលិកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្ញុំបានអានឯកសារជាច្រើនដូចជាចម្លើយសារភាពរបស់អ្នកទោសនិងឯកសាររបស់ខ្មែរក្រហមជាច្រើនទៀត ។ លើសពីនេះទៅទៀត ខ្ញុំធ្លាប់បានចុះទៅចូលរួមសម្ភាសមនុស្សមួយចំនួនទាំងជនរងគ្រោះនិងជនដៃដល់ដែលបានឆ្លងកាត់និងរួចជីវិតពីរបបនេះ ។ ជាលទ្ធផលខ្ញុំបានដឹងរឿងរ៉ាវច្រើនអំពីប្រវត្តិជូរចត់របស់ពួកគាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រុមគ្រួសារឪពុកម្តាយខ្ញុំក៏មិនខុសពីគាត់ទាំងអស់នោះដែរ ប៉ុន្តែដោយសារខ្ញុំជាក្មេងជំនាន់ក្រោយ ដូច្នេះខ្ញុំមិនអាចដឹងពីទំហំនៃការឈឺចាប់ក្នុងរបបនោះប៉ុនណាទេ ។ ឪពុកខ្ញុំបានរៀបរាប់រឿងរ៉ាវរបស់គាត់ឲ្យខ្ញុំនិងប្អូនៗស្តាប់ថា គាត់និងប្អូនស្រីជាមនុស្សតែពីរនាក់គត់ដែលបានរួចជីវិតពីរបបនោះនៅក្នុងគ្រួសារមួយដែលមានសមាជិក១៣នាក់ មានបងប្អូន៩នាក់ (ក្មួយប្រុសពីរនាក់និងឪពុកម្តាយរបស់គាត់) ។


ណារឿន និងក្រុមគ្រួសារ

មុនឆ្នាំ១៩៧៥ ឪពុកខ្ញុំមានបងប្អូន៩នាក់ ប្រុស៤នាក់និងស្រី៥នាក់ ។ គាត់ជាកូនទីប្អូននៅក្នុងគ្រួសារមួយដែលមានជាប់ខ្សែចិននៅភូមិព្រែកគ្រែង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ប្រកបរបបលក់ដូរ ។ នៅឆ្នាំ១៩៧៣ គ្រួសាររបស់ឪពុកខ្ញុំបានផ្លាស់មករស់នៅទីក្រុងភ្នំពេញដើម្បីគេចពីការវាយប្រហាររវាងកងទ័ពខ្មែរក្រហមនិងទាហានលន់នល់ ។ ពេលផ្លាស់មកភ្នំពេញ បងប្រុសពីរនាក់របស់ពុកឈ្មោះ ដេង ជ៉ោ និងម្នាក់ទៀតឈ្មោះ ដេង ប៉ៅសេង នៅចាំផ្ទះ ព្រោះថាផ្ទះត្រូវទាហានលន់នល់សុំធ្វើជាកន្លែងស្នាក់នៅនិងដាក់អាវុធ ។ ថ្ងៃមួយខ្មែរក្រហមបានវាយប្រហារចូលមកដល់ភូមិ ហើយបានកៀរប្រជាជនទៅដល់ស្រុកស្អាងកោះធំ ។ បងប្រុសពីរនាក់របស់គាត់ក៏ត្រូវខ្មែរក្រហមកៀរទៅដែរ ។ មកដល់ពាក់កណ្តាលឆ្នាំ១៩៧៥ ទើបឮដំណឹងថា គាត់ទាំងពីរត្រូវខ្មែរក្រហមចាប់ដាក់គុកនៅស្រុកស្អាងកោះធំ ដោយចោទថាជាគិញ ។ គាត់ទាំងពីរបានបាត់បង់ជីវិតនៅទីនោះ ។

ឆ្នាំ១៩៧៥ ពេលខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញគ្រួសាររបស់ពុកបានវិលត្រឡប់មកស្រុកកំណើតវិញ ។ ប៉ុន្តែបងស្រីរបស់ពុកឈ្មោះ ដេង ណាំអេង និងកូនប្រុសពីរនាក់ទៅរស់នៅខេត្តស្វាយរៀងជាមួយស្វាមីគាត់ ។

ឆ្នាំ១៩៧៦ អ៊ីស្រី ណាំអេង និងកូនប្រុសពីរនាក់បានត្រឡប់មករស់នៅជាមួយគ្រួសារវិញនៅកៀនស្វាយ ដោយសារតែប្តីរបស់គាត់ឈ្មោះ អ៊ុច សារឿន ត្រូវខ្មែរក្រហមហៅយកទៅកសាង ។ ឪពុកខ្ញុំប្រាប់បងស្រីគាត់ថាប្រាកដជាត្រូវខ្មែរក្រហមសម្លាប់ហើយ ពីព្រោះ អ៊ី សារឿន ជាទាហានពាក់ស័ក្តិមួយនៅរបបសាធារណរដ្ឋខ្មែរ ។ អ៊ីស្រី ណាំអេង ត្រូវអង្គការចាត់តាំងឲ្យគាត់ចូលខាងកសិករនារីជាមួយឪពុកម្តាយគាត់ ។ ក្នុងឆ្នាំដដែល ឪពុកខ្ញុំនិងមីង សុខេង ត្រូវបំបែកឲ្យទៅនៅកងយុវជននិងកងនារី នៅឃុំស្រែអម្ពិលស្រុកកំពង់ស្វាយ ខេត្តកណ្តាល ។ កាលនោះ ពុកមានអាយុ១៦ឆ្នាំ គាត់ព្យាយាមកុហកខ្មែរក្រហមថាគាត់ទើបតែមានអាយុ១៤ឆ្នាំប៉ុណ្ណោះ ដើម្បីឲ្យបានរស់នៅជិតឪពុកម្តាយ ប៉ុន្តែខ្មែរក្រហមមិនជឿ ហើយបានបញ្ជូនពុកនិងមីង ទៅកងយុវជននិងយុវនារី ។ ឪពុកខ្ញុំនិយាយថាប្រសិនបើគាត់ទាំងពីរនៅជាមួយឪពុកម្តាយប្រហែលជាស្លាប់បាត់ទៅហើយ ។ នៅស្រែអម្ពិល ខ្មែរក្រហមឲ្យគាត់លើកទំនប់

ជីកប្រឡាយ ធ្វើការពីព្រលឹមទល់ព្រលប់គ្មានសម្រាកទេ ពេលហូបបាយថ្ងៃត្រង់ហើយត្រូវចុះទៅធ្វើការវិញភ្លាម បើនៅរដូវស្រូវទុំ គាត់ត្រូវធ្វើការពេលថ្ងៃ ពេលយប់ត្រូវទៅដេញកណ្តុរកុំឲ្យស៊ីស្រូវ ។

ឆ្នាំ១៩៧៧ ឪពុកម្តាយនិងបងប្អូនរបស់ពុកដែលរស់នៅក្នុងភូមិត្រូវខ្មែរក្រហមបញ្ជូនឡើងឡានទាំងអស់ ហើយក៏បាត់ដំណឹងរហូតដល់សព្វថ្ងៃ ។ ពុកបានដំណឹងនេះពីយុវជនម្នាក់ឈ្មោះ ផល ដែលបានមកចូលរួមក្នុងអង្គមិទ្ទីងមួយនៅស្រែអម្ពិលមកខ្សឹបប្រាប់គាត់ ។ ពុកសន្និដ្ឋានថាពួកគាត់ទាំងអស់គ្នាប្រហែលជាបាត់បង់ជីវិតអស់ហើយ ព្រោះអ្នកដែលខ្មែរក្រហមបញ្ជូនឡើងឡាននៅពេលនោះគ្មាននរណាម្នាក់បានត្រឡប់មកភូមិវិញទេ ។ ក្រោយពេលដឹងថា ក្រុមគ្រួសាររបស់គាត់ត្រូវខ្មែរក្រហមបញ្ជូនឡើងឡាន ពុកនិងមីងព្យាយាមធ្វើធម្មតាដើម្បីកុំឲ្យអង្គការដឹង ។

ឪពុកខ្ញុំនិយាយថា សំណាងដែរ ដែលខ្មែរក្រហមមិនបានស៊ើបរកគាត់និងមីង ។ ប្រសិនខ្មែរក្រហមស្រាវជ្រាវរកប្រវត្តិរូបឃើញ ពួកវាច្បាស់ជាបញ្ជូនទៅដាក់គុកនៅវត្តចំពុះក្អែករហូតដល់ស្លាប់ ។ ពុកខ្ញុំប្រាប់ថា គុកចំពុះក្អែកនេះជាកន្លែងសម្រាប់ដាក់អ្នកទោសដែលខ្មែរក្រហមស្រាវជ្រាវប្រវត្តិរូបឃើញ និងអ្នកដែលលួចរត់ទៅផ្ទះបីដង ។ ពុកត្រូវខ្មែរក្រហមហៅសួរប្រវត្តិរូបចំនួនបួនដង ប៉ុន្តែគាត់នៅតែឆ្លើយថា គាត់ជាកសិករកាលពីសង្គមចាស់ ។ ពុកខ្ញុំថាគាត់អាចលាក់ប្រវត្តិរូបគាត់បានយូរយ៉ាងនេះ ដោយសារតែពេលនោះគ្មាននរណាអាចលួចចេញមកភូមិកំណើតបាន ។

ឪពុកខ្ញុំធ្វើការនៅស្រែអម្ពិលរហូតដល់ចុងឆ្នាំ១៩៧៨ ទើបខ្មែរក្រហមឲ្យទៅលើកដីនៅស្រុកកណ្តាលស្ទឹង ព្រោះថាស្រែអម្ពិល ពេលនោះត្រូវទឹកលិចអស់ ។ ការរស់នៅកណ្តាលស្ទឹងលំបាកខ្លាំងជាងនៅស្រែអម្ពិលទៅទៀត នៅទីនោះគ្មានអ្វីហូបទេ មានតែត្នោតទុំនិងក្រសាំង សូម្បីតែទីជម្រកក៏គ្មានដែរ ពេលយប់ត្រូវដេកផ្ទាល់នឹងដី ។ នៅពេលភ្លៀងម្តងៗវេទនាណាស់ គាត់ត្រូវយកដើមត្រែង មកប្រក់ធ្វើជាកូនរោងដើម្បីជ្រក ។ មិនយូរប៉ុន្មានខ្មែរក្រហមចាប់ផ្តើមតាមដានប្រវត្តិរូបក្រុមគ្រួសារពុកទាំងយប់ទាំងថ្ងៃ ។ ឪពុកខ្ញុំថា គាត់ចាប់ផ្តើមដឹងរឿងនោះដោយសារខ្មែរក្រហមឈប់ចែកខោអាវនិងក្រមាឲ្យគាត់ដូចមុន ។ ពុកប្រាប់ទៀតថា ប្រសិនបើខ្មែរក្រហមមកហៅទៅ គាត់ប្រាកដជាស្លាប់មិនខាន ។

មកដល់ឆ្នាំ១៩៧៩ ពុកខ្ញុំត្រឡប់មកស្រែអម្ពិលវិញ ដូនពេលនោះ កងទ័ពវៀតណាមក៏ចូលមកដល់ ។ នៅពេលនោះហើយដែលគេដឹងថាគ្រួសាររបស់គាត់ត្រូវខ្មែរក្រហមយកឡើងឡាន ។ ខ្មែរក្រហមបានកៀរ ពុកខ្ញុំទៅភ្នំពេញ តែគាត់ព្យាយាមគេចមកដើរក្រោយគេ ហើយក៏រត់ចេញពីជួរត្រឡប់មកភូមិវិញ ។ ពុកខ្ញុំបានសង់ផ្ទះមួយនៅលើគ្រឹះចាស់ដែលត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាម ។ ពុកខ្ញុំប្រាប់ថាសំណល់អតីតកាល ដែលនៅសល់ពីរបបខ្មែរក្រហមចំពោះគាត់គ្មានអ្វីក្រៅពីភាពកំព្រាឪពុកម្តាយ បងប្អូន និងសាច់ញាតិនោះទេ ។ មកទល់ពេលនេះ សូម្បីតែឆ្អឹងឪពុកម្តាយ បងប្អូនរបស់គាត់ក៏គាត់មិនដឹងជានៅទីណាផង ដូច្នេះហើយបានជាពុកមិនចង់រំឭករឿងរ៉ាវខ្មែរក្រហមឲ្យកូនៗស្តាប់ ។ **ឆាយ ណារឿន**

## សេចក្តីប្រកាសរកកូនប្រុសឈ្មោះ មាស សុខុម

១) នាងខ្ញុំ អ៊ឹម យាវ អាយុ៧០ឆ្នាំ រស់នៅភូមិស្វាយទាប ឃុំអម្ពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។ សូមប្រកាសសួររកកូនប្រុសឈ្មោះ មាស សុខុម ដែលបានបាត់ខ្លួននៅក្នុងអំឡុងឆ្នាំ១៩៧៨ ។ ពេលដែល សុខុម ត្រូវខ្មែរក្រហមបញ្ជូនទៅប្រយុទ្ធជាមួយវៀតណាមនៅទល់ដែនខេត្តកំពង់ចាម ។ សុខុម គឺជានិរសារឃុំអម្ពិលក្រៅតាំងពីឆ្នាំ១៩៧៤ ក្រោយមកផ្លាស់ទៅធ្វើជានិរសារស្រុកស៊ីធរកណ្តាល ។ មុនពេលអង្គការខ្មែរក្រហមបញ្ជូនទៅសមរភូមិ សុខុម បានមកលេងផ្ទះម្តង ព្រមទាំងបានផ្តាំផ្ញើគាត់និងប្តីគាត់ថាឲ្យប្រយ័ត្នខ្លួន ព្រោះនឹងមានមនុស្សយកទៅសម្លាប់មិនខាន ។ តាំងពីនោះមកក៏បាត់ដំណឹងកូនរហូត ។

ប្រសិនបើកូនឈ្មោះ មាស សុខុម បានឃើញសេចក្តីប្រកាសនេះ ឬក៏ញាតិមិត្តណាបានស្គាល់ ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ពត៌មានមកនាងខ្ញុំតាមរយៈមជ្ឈ-មណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញឬទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# គ្រួសារខ្ញុំនៅឯណា?

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញត្រូវបានរំដោះពីរបបលន់នល់មកជារបបកម្ពុជាប្រជាធិបតេយ្យ ។ កាលនោះខ្ញុំមានអាយុ១២ឆ្នាំ រស់នៅជាមួយឪពុកម្តាយនិងបងប្អូនរបស់ខ្ញុំនៅភូមិភ្នំត្រែល ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។ ថ្ងៃមួយពេលដែលខ្ញុំកំពុងលេងល្បែងកូនក្មេងជាមួយក្មេងៗដទៃទៀតនៅជិតខាងគ្នា ស្រាប់តែឃើញមនុស្សម្នាជាច្រើនធ្វើដំណើរនៅតាមផ្លូវខាងមុខផ្ទះខ្ញុំ ខ្លះរុញឡានតូចៗ ខ្លះរុញស៊ីក្លូ ខ្លះអូសរទេះ ម៉ូតូ កង់ និងដើរព្រោងព្រាត ដោយមានបង្អែចអីវ៉ាន់ទៅជាមួយនិងសម្លៀកបំពាក់ថ្មីៗចម្រុះពណ៌គួរឲ្យគយគន់ ។ អ្នកខ្លះចូលសួររកផ្ទះបងប្អូន ឬអ្នកធ្លាប់ស្គាល់គ្នា ឯអ្នកខ្លះទៀតចេះតែបន្តដំណើរទៅមុខ ហាក់បីដូចជាគ្មានគោលដៅច្បាស់លាស់ ។ ដោយឡែក អ្នកដំណើរ១១នាក់នេះវិញបានសុំផ្ទះឪពុករបស់ខ្ញុំឈប់សម្រាកដើម្បីដាំបាយហូប ។ ខ្ញុំសប្បាយចិត្តណាស់ដោយបានស្គាល់អ្នកទាំងនោះ ហើយក្មេងៗដែលជាកូនរបស់គាត់ស្រលាញ់និងចូលចិត្តខ្ញុំ ។ ខ្ញុំបានយកសាច់គោងៀតរបស់ម្តាយខ្ញុំនិងរបស់របរហូបចុកជាច្រើនទៀតឲ្យពួកគាត់ហូប ។ ដោយមានទំនាក់ទំនងដ៏ស្និទ្ធស្នាលរវាងគ្នានិងគ្នា ជាពិសេសក្មេងៗ ឪពុកខ្ញុំបានឃាត់ក្រុមគ្រួសារនោះឲ្យសម្រាកនៅផ្ទះរបស់ខ្ញុំមួយរយៈ ។ អ្នកទាំងនោះក៏យល់ព្រមស្នាក់នៅ ។

មិនបានប៉ុន្មានថ្ងៃផង កងឈ្លបប្រចាំតំបន់បានមកត្រួតពិនិត្យនៅផ្ទះរបស់ខ្ញុំ ហើយចោទឪពុកម្តាយខ្ញុំថា បានលាក់ប្រជាជន១៧មេសា ។ អ្នកដំណើរទាំងនោះបានចាកចេញពីផ្ទះរបស់ខ្ញុំទៅ ។ ចំណែកក្រុមគ្រួសារខ្ញុំត្រូវអង្គការជម្លៀសឲ្យទៅភូមិពេជ្រចង្វារដែលមានចម្ងាយ២គីឡូម៉ែត្រពីភូមិកំណើតរបស់ខ្ញុំ ។

ឪពុកខ្ញុំឈ្មោះ សាយ ខៃ អាយុ៤៥ឆ្នាំ ត្រូវអង្គការចាត់តាំងឲ្យធ្វើជាងសំណង់ ដើម្បីសាងសង់មន្ទីរពេទ្យមួយស្ថិតនៅខាងកើតភ្នំត្នោត ភូមិពេជ្រចង្វារ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។ ចំណែកម្តាយរបស់ខ្ញុំដែលមានផ្ទៃពោះជិតគ្រប់ខែបានសុំអនុញ្ញាតឈ្លបដើម្បីសម្រាលកូន ។ បងស្រីៗរបស់ខ្ញុំចំនួន ៥នាក់ត្រូវបានជម្លៀសទៅភូមិបន្ទាយ ឃុំជីទ្រារ ស្រុកទ្រាំង ខេត្តតាកែវ ។

ឪពុកខ្ញុំនិងក្រុមជាងធ្វើការងារពីព្រលឹមទល់ព្រលប់ ។ ខ្ញុំនៅចាំថា មានពេលខ្លះគាត់ធ្វើការរហូតដល់ហួសពេលបាយ ហើយម្តាយខ្ញុំបានប្រើឲ្យខ្ញុំទៅហៅគាត់ក៏មាន ។ ពេលត្រឡប់មកពីធ្វើការ គាត់តែងតែដោះអាវ ស្លៀកខោចែវខ្លីកញ្ចាស់មួយ ទោះបីជាម្តាយខ្ញុំសុំឲ្យគាត់ផ្លាស់ចេញក៏ដោយ ក៏គាត់មិនធ្វើតាមដែរ ព្រោះគាត់ខ្លាចអង្គការកត់សម្គាល់ថា គាត់ជាអ្នកមូលធននិយម ។ ពេលគាត់ត្រឡប់មកពីធ្វើការ ឪពុកខ្ញុំតែងតែសញ្ជឹងគិតនិងនិយាយប្រាប់ម្តាយខ្ញុំថា កងឈ្លបទាំងនោះកំពុងតាមដានប្រវត្តិរូបរបស់គាត់ ហើយគាត់ប្រហែលមិនបានជួយថែរក្សាប្រពន្ធកូនបានយូរឡើយ ជាពិសេស កូនដែលនៅក្នុងផ្ទៃរបស់ម្តាយខ្ញុំ ។ គាត់គិតថា ប្រសិនបើគាត់រត់គឺអាចរស់តែម្នាក់ឯង រីឯប្រពន្ធនិងកូនប្រហែលជានឹងត្រូវអង្គការសម្លាប់ចោល ដូច្នេះគាត់សុខចិត្តស្លាប់ឲ្យតែប្រពន្ធនិងកូននៅរស់ ។

បីថ្ងៃក្រោយមក នៅពេលគាត់កំពុងតែដំបន្ទាលូសធ្វើជាដែកគោល ស្រាប់តែមានឈ្លបពីរនាក់ស្លៀកពាក់ខោអាវខ្មៅស្ពាយអាវុធM១៦ពីរដើមមានចងក្រណាត់ក្រហមនៅចុងកាំភ្លើងផង បានមករកឪពុកខ្ញុំថា “អង្គការដឹងថា ពូឯងធ្លាប់ធ្វើជាវិស្វករសំណង់ ហេតុនេះហើយ អង្គការសូមអញ្ជើញពូទៅធ្វើជាគ្រូបង្រៀន ពីព្រោះអង្គការត្រូវការអ្នកមានជំនាញច្បាស់លាស់ដើម្បីជួយកសាងប្រទេស” ។ គ្រាន់តែឮសម្តីនេះភ្លាម ឪពុកខ្ញុំទម្លាក់ទឹកមុខជ្រប់សម្លឹងទៅក្រុមជាង ព្រមទាំងនិយាយថា ÷ “អ្នកទាំងអស់គ្នាខ្ញុំលាសិនហើយ” ។ ឃើញដូចនេះ ក្រុមជាងទាំងអស់សម្តែងនូវទឹកមុខក្រៀមក្រំ អាឡោះអាល័យជាទីបំផុត ប៉ុន្តែមិនហ៊ាននិយាយស្តីអ្វីឡើយ គ្រាន់តែដឹងក្នុងចិត្តថា កាលណាអង្គការតម្រូវហើយ មិនអាចវិលវិញបានទេ ។ ឈ្លបទាំងពីរមិនបង្អង់យូរ ក៏បណ្តើរគាត់ចេញទៅបានចម្ងាយប្រហែលមួយរយម៉ែត្រពីការដ្ឋានសំណង់ ក្បែរផ្លូវរទេះមានព្រៃល្បាស់ ឈ្លបទាំងនោះក៏

ចាប់ចងដៃរបស់គាត់ទៅក្រោយយ៉ាងតឹង ។ ខ្ញុំនិងបងជីដូនមួយ ឈ្មោះ សាយ សុខ (កាលនោះមានអាយុ១៦ឆ្នាំ) បានតាមលបមើលឪពុកខ្ញុំនៅខាងត្បូងផ្លូវរទេះ ដែលមានព្រៃបាំងជិត ។ នៅពេលឈ្លបកំពុងចងឪពុកខ្ញុំ ខ្ញុំចង់ស្ទុះទៅជួយនិងឱបគាត់ឲ្យជាប់ តែត្រូវបងជីដូនមួយខ្ញុំចាប់ខ្ញុំជាប់ ហើយបោចស្មៅញាត់មាត់ខ្ញុំមិនឲ្យស្រែកខ្លាចក្រែងឮដល់ឈ្លបទាំងនោះ ។ ឪពុកខ្ញុំត្រូវបានបណ្តើរបន្តទៅទៀតរហូតដល់ផ្ទះមួយដែលត្រូវជាបងប្អូនជីដូនមួយរបស់គាត់គាត់ក៏សុំឈ្លបចូលផឹកទឹក ដោយសន្យាថាមិននិយាយអ្វីជាមួយម្ចាស់ផ្ទះជាដាច់ខាត ប៉ុន្តែការពិតគាត់មានបំណងផ្តាំផ្ញើប្អូនរបស់គាត់អំពីស្ថានភាពរបស់គាត់នាពេលនោះ ។

កងឈ្លបបណ្តើរឪពុកខ្ញុំមកដល់ផ្លូវជាតិ ហើយចងគាត់ភ្ជាប់ទៅនឹងដើមស្តៅធំមួយនៅក្បែរនោះដើម្បីទៅហៅបុរសម្នាក់ឈ្មោះ ពូ ឈិន ដែលមានវ័យស្របាលឪពុកខ្ញុំ និងធ្លាប់រស់នៅភូមិឃុំជាមួយគ្នាឲ្យចេញមក ។ កងឈ្លបបណ្តើរគាត់ទាំងពីរចេញទៅទិសខាងកើតបានប្រមាណ៧រយម៉ែត្រ ក៏ចូលទៅយកមនុស្សម្នាក់ទៀតឈ្មោះ ឈាង ឈួន អាយុ៤៥ឆ្នាំ រស់នៅភូមិឃុំជាមួយគ្នាថែមទៀត ។ គាត់ជាអតីតគយសម័យសង្គមរាស្ត្រនិយម (បច្ចុប្បន្នជាឪពុកក្មេករបស់ខ្ញុំបាទ) ។ បន្ទាប់មកទៀត កងឈ្លបបានចងអ្នកទាំងបីបណ្តើរឆ្ពោះទៅទិសខាងលិចបាត់ ចំណែកខ្ញុំពីរនាក់ជីដូនមួយបានតាមលបមើលដល់ត្រឹមសាលាស្រុកអង្គរជ័យតែប៉ុណ្ណោះ ។

ម្តាយខ្ញុំពុំទាន់បានដឹងពីរឿងរ៉ាវទាំងនេះឡើយ គាត់ខំលួចដាំបាយនិងស្ងោរព្រាបដែលគាត់ចិញ្ចឹមដើម្បីត្រៀមហូបបាយជុំគ្នា ។ ប៉ុន្តែជាអកុសល បំណងរបស់គាត់ត្រូវរលាយតែមួយប៉ប្រិចភ្នែក ក្រោយពីដឹងថា ឪពុកខ្ញុំត្រូវឈ្លបយកទៅ គាត់ក៏សន្លប់បាត់ស្មារតី ។ បន្ទាប់ពីឪពុកខ្ញុំត្រូវអង្គការយកទៅបាន២០ ថ្ងៃម្តាយខ្ញុំបានសម្រាលកូន ។ ខ្ញុំនៅចាំបានថា នៅឆ្នាំ១៩៧៥ ក្រោយពីម្តាយខ្ញុំសម្រាលកូនបានប្រាំពីរថ្ងៃ អង្គការបានជម្លៀសគ្រួសារខ្ញុំទៅភូមិបន្ទាយ ឃុំជីខ្មារ ស្រុកទ្រាំង ខេត្តតាកែវ ។ ម្តាយខ្ញុំសង្ឃឹមថានឹងបានជួបបងៗខ្ញុំនៅទីនោះ តែផ្ទុយទៅវិញបងៗរបស់ខ្ញុំត្រូវអង្គការបញ្ចូលក្នុងកងនារី ហើយយើងក៏មិនបានជួបគ្នាដែរ ។

នៅភូមិបន្ទាយបានប្រហែលបីខែ ទើបម្តាយខ្ញុំទទួលដំណឹងថា បងស្រីរបស់ខ្ញុំឈ្មោះ សាយ សន ត្រូវដំបូករលំសង្កត់បាក់ជើងទាំងពីរក្នុងពេលកាប់ដីដំបូកយកទៅដាក់ដីស្រែ ។ ពេលនោះបងស្រីខ្ញុំត្រូវបានបញ្ជូនមកព្យាបាលនៅផ្ទះ ។ ស្របពេលជាមួយ

ប្រជាជនកំពុងជីកប្រឡាយធ្វើទំនប់



គ្នានេះ ខ្ញុំក៏ត្រូវអង្គការបំបែកទៅតាមការដ្ឋានរៀងៗខ្លួន។ ខ្ញុំត្រូវអង្គការចាត់ឲ្យទៅធ្វើការនៅកំពង់អម្ពិលនិងអន្លង់ទៀន ខេត្តតាកែវជាប់ព្រំដែនវៀតណាម ។

នៅឆ្នាំ១៩៧៩ ពេលកងទ័ពរណសិរ្សរំដោះជាតិកម្ពុជាវាយរំលំរបបប៉ុលពត គ្រួសារខ្ញុំបានរត់បែកគ្នាអស់ ។ ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ ខ្ញុំបានឮចាស់ៗដែលធ្លាប់ស្គាល់ម្តាយខ្ញុំប្រាប់ថា គាត់និងបងៗខ្ញុំនៅរស់ ហើយខ្ញុំក៏បានវិលត្រឡប់មកស្រុកកំណើតជួបជុំគ្នាឡើងវិញ ។ បន្ទាប់មកខ្ញុំក៏បានចូលរៀននៅសាលាវត្តពេជ្រចង្វាជាមួយសិស្សានុសិស្សជាច្រើនទៀត ។

ម្តាយខ្ញុំប្រឈមមុខនឹងការលំបាកខាងជីវភាពខ្លាំងណាស់ ព្រោះគាត់ជាស្ត្រីមេម៉ាយ ហើយត្រូវទទួលបន្ទុកចិញ្ចឹមកូនដល់ទៅ៨នាក់ មានពេលខ្លះគាត់មិនហូបអាហារទេ គាត់អង្គុយមើលកូនៗហូប ។ ទោះយ៉ាងណាក្តី គាត់មិនដែលមានទុទិដ្ឋិនិយមក្នុងគ្រួសារឡើយ ។

លុះដល់ឆ្នាំ១៩៨៥ ខ្ញុំជាសិស្សម្នាក់រៀននៅសាលាមធ្យមសិក្សាកម្រិត២ អង្គរជ័យ នាយកសាលាបានអនុញ្ញាតឲ្យខ្ញុំធ្វើទស្សនកិច្ចនៅមន្ទីរតាមន្ត ស្ថិតនៅក្នុងភូមិប្រភ្នំ ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ដែលជាកន្លែងពិឃាតមនុស្សស្លូតត្រង់រាប់ម៉ឺននាក់មិនចាញ់នៅកន្លែងផ្សេងៗទៀតក្នុងប្រទេសកម្ពុជាឡើយ ។ ខ្ញុំបានជួបជុំសិស្សានុសិស្សទាំងអស់ដោយមានវេចបាយកញ្ចប់ទៅជាមួយផង ដើម្បីដាក់បាតលោកខ្លះនិងទុកហូបខ្លួនឯងខ្លះ ព្រោះយល់ថាប្រហែលឪពុកខ្ញុំស្លាប់នៅទីនោះដងក៏មិនដឹង ។

ខ្ញុំឃើញគណៈកម្មការប្រមូលអដ្ឋិធាតុលលាដ៍ក្បាលនិងឆ្អឹងដៃជើងគរជាពំនូកដូចភ្នំនិងតម្រៀបគ្នាយ៉ាងមានរបៀបបំផុត ។ ដំបូងគណៈកម្មការ នាយកសាលា សិស្សានុសិស្សទាំងអស់បានធ្វើពិធីគោរពវិញ្ញាណក្ខន្ធដល់ជីដូនជីតា ឪពុកម្តាយ និងបងប្អូនសាច់ញាតិ និងប្រជាពលរដ្ឋស្លូតត្រង់ដែលបានស្លាប់ដោយការធ្វើទារុណកម្មសព្វបែបយ៉ាងនៅក្នុងរបបខ្មែរក្រហម ដូចជា ដកក្រចក ឆក់ខ្សែភ្លើង វាយក្បាលនឹងត្បូងចប គល់ឫស្សី ចាក់នឹងចំពុះទុង និងវះយកថ្លើមជាដើម បន្ទាប់ពីលោកនាយកឡើងថ្លែងសុន្ទរកថារួចមក ខ្ញុំដែលតំណាងឲ្យសិស្សានុសិស្សទាំងអស់បានឡើងធ្វើការចាប់អារម្មណ៍ចំពោះសោកនាដកម្មក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហមដែលបានសម្លាប់យ៉ាងរង្គាលនូវជនស្លូតត្រង់ អ្នកស្នេហាជាតិ មន្ត្រីរាជការ និស្សិត បញ្ញវន្តវិស្វករ សិស្ស គ្រូបង្រៀន ព្រះសង្ឃ ដោយគ្មានរើសមុខ។ ក្រោយមកគណៈកម្មការចាប់ផ្តើមរាប់បាត្រនិងនិមន្តព្រះសង្ឃ៧អង្គសូត្រមន្តបង្សុកូលឧទ្ទិសដល់វិញ្ញាណក្ខន្ធអ្នកដែលបានចែកឋានទៅកាន់លោកខាងមុខ ។ ពិធីនេះបានបញ្ចប់ទៅនៅម៉ោងប្រហែល១១ថ្ងៃត្រង់ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សបានត្រឡប់មកគេហដ្ឋានរៀងៗខ្លួនវិញ ។

ជាការពិតណាស់ កាលពីមុន ខ្ញុំគ្រាន់តែឮរឿងរ៉ាវប្រល័យពូជសាសន៍នៅកម្ពុជាតាមវិទ្យុនិងការនិយាយប្រាប់របស់ម្តាយខ្ញុំប៉ុណ្ណោះ ខ្ញុំស្ទើរតែពុំជឿ លុះមកដល់បច្ចុប្បន្នមានភស្តុតាងបញ្ជាក់អំពីសោកនាដកម្មនោះគ្រប់គ្រាន់ដោយមិនអាចប្រកែកបានឡើយ ។

នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដឹកនាំដោយ ប៉ុលពត, ខៀវ សំផន ខ្ញុំបានបាត់បង់សាច់ញាតិ៥នាក់ដែលក្នុងនោះមាន ឪពុកបង្កើតរបស់ខ្ញុំ ឪពុកក្មេក ជីដូនខាងម្តាយ ជីតាខាងឪពុក និងឪពុកមាម្នាក់ ។

**សាយ សួរគា**

## សេចក្តីប្រកាសរកកូនប្រុសឈ្មោះ ម៉ាន ម៉ុន

យស ផេង អាយុ៧២ឆ្នាំ ត្រូវជាម្តាយ ព្រមទាំងកូនស្រី ម៉ាន ម៉ន អាយុ៤៥ឆ្នាំ សូមប្រកាសសួរកូនប្រុសឈ្មោះ ម៉ាន ម៉ុន ដែលបានចេញពីផ្ទះតាំងពីឆ្នាំ១៩៧៦ បាត់ដំណឹងរហូតដល់សព្វថ្ងៃ។ ដើមឆ្នាំ១៩៧៦ ម៉ាន ម៉ុន ត្រូវខ្មែរក្រហមបង្ខំឲ្យសឹក បន្ទាប់មកត្រូវបានបញ្ជូនទៅធ្វើការក្នុងកងដាំដំឡូងនៅម្តុំភ្នំពាមជាំង ស្រុកព្រះស្តេច ។ តាំងពីពេលនោះមក ម៉ាន់ ម៉ុន មិនបានត្រឡប់មកផ្ទះវិញទេ ។

ប្រសិនបើកូនបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តបានស្គាល់ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ព័ត៌មានមកនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬទូរស័ព្ទលេខ ៨៥៥ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកឪពុកម្តាយនិងប្អូន៦នាក់




ខ្ញុំបាទឈ្មោះ ស៊ុន ស៊ីវ៉ា អាយុ៥៣ឆ្នាំ សព្វថ្ងៃរស់នៅផ្ទះលេខ៦៣ ផ្លូវលេខ៣៥០ ក្រុម៣៥ ភូមិ៦ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន ក្រុងភ្នំពេញ ក្បែរសារមន្ទីរទួលស្លែង ។ សូមសួររកក្រុមគ្រួសារឈ្មោះ ស៊ុន ថូ ជាគ្រូបង្រៀននៅសាលាវត្តថ្មស ខេត្តកំពង់ឆ្នាំង ត្រូវជាឪពុកឈ្មោះ ឃឹម ថុន ត្រូវជាម្តាយនិងប្អូនៗចំនួន៦នាក់ទៀត ។ អ្នកទាំងអស់នេះមានឈ្មោះដូចតទៅ÷

១) ប្អូនប្រុស ស៊ុន សារឿន ២) ប្អូនស្រី ស៊ុន សុផានី ៣)ប្អូនស្រី ស៊ុន សុផាណា ៤) ប្អូនស្រី ស៊ុន សុផល្លា ៥) ប្អូនស្រី ស៊ុន សុមាលី និង៦) ស៊ុន សាវ៉ាន់ នៅកុមារ មានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង មុំខាងមុខវត្តអារញ្ញ ដែលបានបែកគ្នាក្នុងឆ្នាំ១៩៧៥ ដោយរូបខ្ញុំបាទ ស៊ុន ស៊ីវ៉ា មកបន្តការសិក្សាមុខវិជ្ជាពេទ្យនៅក្រុងភ្នំពេញ ។ ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ រូបខ្ញុំបាទបានទៅរកក្រុមគ្រួសារនៅខេត្តកំពង់ឆ្នាំង ហើយទទួលដំណឹងពីអ្នកជិតខាងថា គ្រួសារខ្ញុំបាទត្រូវពួកខ្មែរក្រហមសម្លាប់ចោលទាំងអស់នៅក្រោយថ្ងៃរំដោះខែមេសា ឆ្នាំ១៩៧៥ ។ ក្រោយមកទៀត នៅពេលខ្ញុំទៅធ្វើបុណ្យភ្ជុំបិណ្ឌបង្សុកូលដើម្បីឧទ្ទិសកុសលជូនពួកគាត់នៅខេត្តកំពង់ឆ្នាំង ពេលនោះ អ្នកភូមិប្រាប់ថាមានបងប្អូននិងអ្នកផ្សេងទៀតមករកគ្រួសារខ្ញុំបាទដល់ទីនោះ ។

ប្រសិនបើប្អូន និងលោក លោកស្រីបានទទួលពត៌មានដែលទាក់ទងដល់គ្រួសារខ្ញុំបាទ សូមមេត្តាផ្តល់ដំណឹងមករូបខ្ញុំបាទតាមរយៈអាសយដ្ឋានខាងលើ ឬតាមទូរស័ព្ទលេខ ០១១ ៩៥៧ ២៨៥ ដោយអនុគ្រោះ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកប្អូនប្រុស ជួន គី

នាងខ្ញុំឈ្មោះ ជួន សុង ភេទស្រីអាយុ៥២ឆ្នាំ សព្វថ្ងៃរស់នៅភូមិប៉ាតឡាង ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ឪពុកឈ្មោះ ចាប គុន (ស្លាប់ដោយជំងឺនៅឆ្នាំ១៩៧៦) ។ ម្តាយឈ្មោះ ស៊ីវ ស៊ឹម (ស្លាប់ដោយជំងឺនៅឆ្នាំ១៩៧៥) ។

នាងខ្ញុំមានបងប្អូន១០នាក់ សព្វថ្ងៃរស់នៅ២នាក់ ស្លាប់ ៨នាក់ ដែលមានឈ្មោះដូចខាងក្រោម

១) ជួន សុស ភេទស្រី (ស្លាប់ដោយសារជំងឺឆ្នាំ១៩៧៤) ២) ជួន សុង ភេទស្រី អាយុ៥២ឆ្នាំ នៅរស់ ៣) ជួន គីម ភេទប្រុស (ស្លាប់នៅឆ្នាំ១៩៧៥) ៤) ជួន សៅ ភេទស្រី (ស្លាប់ដោយសារជំងឺនៅឆ្នាំ១៩៩២) ៥)ជួន គី ភេទប្រុស (បាត់ពីតាំងពីអាយុ១៧ឆ្នាំ) ៦) ជួន ពុត ភេទស្រី (នៅរស់) ៧) ជួន គីន ភេទប្រុស (ស្លាប់ដោយសារជំងឺនៅឆ្នាំ២០០១) ៨) ចួន ពឹន ភេទប្រុស (ស្លាប់ដោយសារជំងឺនៅឆ្នាំ១៩៧៥) ៩) ជួន គិន ភេទប្រុស (ស្លាប់ដោយសារជំងឺនៅឆ្នាំ១៩៧៣) ១០) ជួន ធី ភេទស្រី (ស្លាប់ដោយសារជំងឺនៅឆ្នាំ១៩៧៩)

ប្រសិនបើ ប្អូន ជួន គី នៅរស់ហើយបានឮដំណឹងនេះ សូមទាក់ទងមកបងឈ្មោះ ជួន សុង ដែលរស់នៅភូមិឃុំខាងលើ ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬលេខទូរស័ព្ទ ០២៣ ២១១ ៨៧៥ និងលេខទូរសារ ០២៣ ២១០ ៣៥៨ ។ សូមអរគុណ ។

ចម្រៀងខ្មែរក្រហមៈ

# ចូរកូនថែរក្សាប្រពៃណី

ប្រមូលនិងចងក្រងដោយៈ សើ សាយ្យាណា

ន. កូនពន្លកកូនមកជិតម្តាយ ពុកម៉ែបរិយាយប្រាប់ដល់កូនមាសថ្លៃ សូមកូនចងចាំៗមួយជីវិត
រក្សាប្រពៃណីបដិវត្តន៍យើង ។

វ. កូនអើយទម្រាំបានដូចសព្វថ្ងៃ សង្គមជាតិថ្មីយុត្តិធម៌រុងរឿង ប្រជាជនយុទ្ធជនកម្មាភិបាលយើង
ពលីក្នុងភ្លើងច្រើនគណនា ។

ន. មិត្តយើងឆ្លងក្នុងឧបសគ្គច្រើនក្តាត់ រស់ក្នុងសម្ងាត់តឹងតែងវេទនា អាខ្មាំងតាមដានគ្មានលោះពេលណា
ព្រាត់ប្រាសគ្រួសារពុំដែលជួបមុខ ។

វ. ពេលថ្ងៃពួនលើស្អាកខ្ទមកសិករ ពេលយប់ចុះមកដឹកនាំសព្វមុខ ហូបពុំដែលឆ្អែត ដេកពុំដែលលក់
រាប់ឆ្នាំញីញាក់សុខភាពខ្ទាំខ្ទេច ។

ន. នៅពេលដើរៗជើងទទេ ឡើងភ្នំរាប់ខែ កាត់ថ្មព្រៃព្រឹក្ស ដេកផ្ទាល់នឹងដីកៅស៊ូរហែក
ភ្លៀងសាចភ្លៀងលិចអង្គុយញ័រញាក់ ។

វ. ក្រោយមកទើបបានដេកក្នុងអង្រឹង មកព្រៃស្ងាត់ឈឹងធ្វើផ្ទះសំណាក់ ពន្លឺថ្ងៃចូលមិនដល់ងងឹត
មុខចាក់គ្រុនចាញ់រងារតែដាច់ខាតតស៊ូ ។

ន. ខោអាវផាឌីបតែមួយចង្កេះ ពុកផុយរលេះរលួយរយ៉ៃ ពេលបោកម្តងៗអង្គុយចាំញ័រ
ស្ងួតហើយស្លៀកតចូលភូមិធ្វើការ ។

វ. ពេលខ្មាំងឡោមព័ទ្ធនិរសារត្រូវដាច់ ហូបក្តួចគាស់ចេកជំនួសបបរ ហត់ហេវគ្រុនចាញ់ ហូបឫសឈើវល្លិ៍
ស្គាំងស្គមស្លាំងស តែចិត្តក្រហមឆ្អៅ ។

ន. កូនអើយហ្នឹងហើយជីវភាពបងៗ រាប់សិបឆ្នាំកន្លងបានត្រួសត្រាយផ្លូវ ជីវភាពបដិវត្តន៍រុងរឿងក្រហមឆ្អៅ
ដែលនាំមកនូវសព្វថ្ងៃមនោរម្យ ។

វ. ហេតុនេះសព្វថ្ងៃកូនរស់នៅស្រួលដូចចិត្ត កូនត្រូវប្រយ័ត្នៗចំហទ្រូង កូនត្រូវរក្សាប្រពៃណីឲ្យក្រហម
កម្មសិទ្ធសមរម្យ គឺស្លាបព្រាមួយតូច ។

ន. កូនចាំឲ្យច្បាស់ណាកូនមាសម្តាយ ពេលកូនហូបបាយកូននឹកដល់ក្តួច ពេលកូនស្លៀកល្អ នឹកដល់ឈាមស្រោច
ពេលណាកូនសើចនឹកដល់មិត្តកំព្រា ។

រួម. សូមកូនសំលៀងជំហរបដិវត្តន៍ ឲ្យរហូតប្រហមមុតថ្លា សីលធម៌រស់នៅទៅតាមមាគ៌ា
នោះទើបធានាបដិវត្តន៍អវសាន ។

រួម. កូនមាសស្ងួនកូនសម្លាញ់អើយ កូនកុំធ្វើអ្វីដែលនាំឲ្យរំខាន ដុសខាត់ប្រពៃណីជាអ្នកបន្តវេន
ទុកកេរ្តិ៍ថ្កើងថ្កានអមតៈណាកូន ។

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល